បណ្ឌិត ឈឹម ទូច បណ្ឌិត សុខ ស៊ីវ

# ប្រស្នា

# គិហិប្រតិបត្តិពិស្តារ

ចម្លងតាមច្បាប់ដើម

ព.ស ២៥៥៧ - គ.ស ២០១៣

# ប្រស្នា

# គិហិប្រតិបត្តិពិស្តារ

រៀបរៀងដោយ

## លោក បណ្ឌិត ឈឹម ទូច ( ឥន្ទប្បញ្ញោ )

និង

## លោក សិទ្ធត្ថបណ្ឌិត សុខ ស៊ីវ

**ព.ស. ២៥១៦ គ.ស. ១៩៧២**

* ចម្លងតាមច្បាប់ដើមដោយខ្ញុំព្រះករុណា ខ្ញុំបាទ **ទ៉ាត តិរក្ស**


ផ្សព្វផ្សាយដោយ គេហដ្ឋាន

**អតិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ**

ក្រុងម៉ុងរេអាល - កេបិក - កាណាដា

**ព.ស. ២៥៥៧ - គ.ស. ២០១៣**

**សម្រាប់ចែកជាធម្មទាន**

# សៀវភៅចាស់ដែលបានចម្លងជាថ្មី ៖

១. ស្នាព្រះហស្តក្រោយបង្អស់នៃសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត**
២. ធម៌នមស្ការព្រះរតនត្រ័យ ពិស្តារ - សង្ខេប ( ខ្នាតធំ, ខ្នាតមធ្យម, ខ្នាតតូច )
៣. ប្រជុំនានាធម៌សង្វេគ ( ជ័យ ម៉ៃ )
៤. អានាបានស្សតិកម្មដ្ឋាន វិបស្សនាបញ្ហាធម្មបរិយាយ ( គង់ ឌឹប )
៥. ធម្មនិយាម ៣០ និងកំណាព្យផ្សេង ៗ ( ប៊ុត សាវង្ស, ភិក្ខុ សាន សុជា )
៦. ជីវិតកថា ( មុិញ សាវ៉ាន ) ថ្មី
៧. ធម្មប្រទីប ( ប្រជុំកងធម៌ យិន វន់ )
៨. រឿង ព្រះភិក្ខុពនេចរ ( ឱម ណាគ្រី )
៩. រឿង នគរកាយ ( ចាប ពិន )
១០. ច្បាប់គោរពមាតាបិតា ( អ៊ូ ចុង )
១១. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម អ៊ុម ស៊ុម )
១២. ត្រៃកូដធម៌ ( សុង ស៊ីវ )
១៣. ឱវាទបាតិមោក្ខ ( ចាប ពិន )
១៤. កម្រងកំណាព្យ ( ហុិម ឆាន់ ) ថ្មី
១៥. ឧបនីយតិសូត្រ ( ព្រះមហាវីរិយបណ្ឌិតោ ប៉ាង ខាត់ )
១៦. ធម្មទេស ៤ យ៉ាង ( មុិញ សាវ៉ាន ) ថ្មី
១៧. ធម៌នមស្ការសង្ខេបសម្រាប់យុវវ័យ Khmer-Français ( វ៉ាត ភិរក្ស ) ថ្មី
១៨. ធម៌នមស្ការសង្ខេបសម្រាប់យុវវ័យ Khmer-Anglais ( វ៉ាត ភិរក្ស ) ថ្មី
១៩. លោកនីតិបករណ៍ ( ព្រះ អ៊ុក ជា វជិរញ្ញាណាភយវង្ស )
២០. មង្គលសូត្រ ៣៨ ប្រការ ( ព្រះវិន័យធរអនុគណ ឯក ញឹម ធម្មិស្សរោ )



**ចិរំ តិដ្ឋតុ សទ្ធម្មោ**

**សូមព្រះសទ្ធម្មឋិតនៅអស់កាលយូរអង្វែង**

# មាតិកាធម៌

សៀវភៅនេះចែកតាមគោលមាតិកាមាន ៧ វគ្គ គឺ ៖


១. អារម្ភកថា និងឧទ្ទិសកថា ........................................ ទំព័រ
២. គិហិប្រតិបត្តិវចនប្បញ្ហា ................................................ ១១
៣. ត្រៃប្រណាមប្បញ្ហា ..................................................... ១៤
៤. សរណាគមនវចនប្បញ្ហា ............................................. ៣៩
៥. ឧបាសកវចនប្បញ្ហា ................................................. ៥៧
៦. វិន័យឧបាសកប្បញ្ហា ................................................ ១០៤
៧. ភាវេតព្វកិច្ចប្បញ្ហា ..................................................... ១៤៥
៨. បកិណ្ណកធម៌ .............................................................. ១៧១

* ក្នុងបកិណ្ណកធម៌នេះមានធម៌ ឥមិនា, សុខោ, ឥចេវមច្ចន្ទ:, វន្ទាមិ - ចេតិយំ, យោកប្បកោដីហិបិ, អាកាសដ្ឋា, យំកិញ្ចិ, យាទេវតា, បសន្នា - ហោន្តុ, វិបត្តិបដិពាហាយ, សគ្គេ, ព្រហ្មា និងវិធីវេរគ្រប់បែប . . .

៩. ពាក្យកាព្យឧទ្ទិស ....................................................... ២២០
១០. ព្រះត្រៃលក្ខណ៍ ........................................................ ២២១
១១. ព្រះត្រៃលក្ខណ៍សង្ខេប ............................................... ២២៣
១២. ធម្មសង្វេគ .............................................................. ២២៤
១៣. បរាភវសូត្រ .............................................................. ២២៦
១៤. សមាសភាពចូលរួម .................................................... ២៣៩
១៥. ពុទ្ធបរិស័ទដែលបានចូលរួមបោះពុម្ពសៀវភៅ .................. ២៤០
១៦. ផ្សេងៗពីគេហដ្ឋាន អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ ...... ២៤៤

# អារម្ភកថា

**សៀវភៅ** «**ប្រស្នា គិហិប្រតិបត្តិពិស្តារ**» គឺជាស្នាដៃរបស់លោក បណ្ឌិត **ឈឹម ទូច** ( **ឥន្ទប្បញ្ញោ** ) និងលោក សិទ្ធត្ថបណ្ឌិត **សុខ ស៊ីវ** ជាអ្នករៀបចំសម្រួលឡើង ។

សៀវភៅនេះ ត្រូវបានបោះពុម្ពជាលើកចុងក្រោយបង្អស់នៅព.ស. ២៥១៦ ត្រូវនឹង គ.ស.១៩៧២ ជាលើកទី ៩ ។ ដោយស្នាមគំនូសនៃអត្ថបទនេះ ត្រូវបានគេបោះពុម្ពជាច្រើនលើកច្រើនសា កន្លងមកអស់រយៈពេលយូរ, មានបាត់បង់ទំព័រខ្លះផង, មានការលំបាកដល់ការអានសិក្សាផង ហើយខ្ញុំព្រះករុណា ខ្ញុំបាទយល់ថាសៀវភៅនេះ គឺជាគ្រឹះ ជាមូលដ្ឋានសំរាប់ពុទ្ធសាសនិកជនទាំងអស់ប្រតិបត្តិ ហើយជាពិសេសគឺចង់ថែរក្សានូវស្នាដៃនេះឲ្យគង់វង្ស ទុកនៅជាកេរដំណែលវែងឆ្ងាយទៅក្នុងពេលអនាគតផង ខ្ញុំព្រះករុណា ខ្ញុំបាទ ក៏ព្យាយាមសរសេរចម្លងឡើងវិញនូវសៀវភៅ «**ប្រស្នាគិហិប្រតិបត្តិពិស្តារ**» នេះ ។

ក្នុងនាម «ខ្ញុំបាទ» ជាកូនចៅជំនាន់ក្រោយ សូមលើកហត្ថទាំងទ្វេលំអោនកាយ វាចា ចិត្ត គោរពដល់លោកព្រឹទ្ធាចារ្យទាំងពីរដែលលោកជាអ្នកប្រាជ្ញ, ជាបណ្ឌិត និងជាម្ចាស់សៀវភៅ «**ប្រស្នា គិហិប្រតិបត្តិពិស្តារ**» នេះ សូមលោកអនុញ្ញាតដល់ខ្ញុំ ដើម្បីសរសេរចម្លង និងរៀបរៀងនូវសៀវភៅ «**ប្រស្នា គិហិប្រតិបត្តិពិស្តារ**» របស់លោកសាជាថ្មីឡើងវិញ ។

**ហេតុបច្ច័យ** . . . ជួយបំពេញឲ្យខ្ញុំព្រះករុណា ខ្ញុំបាទសរសេរចម្លងសៀវភៅនេះចប់សព្វគ្រប់ពេញបរិបូណ៌ខ្ញុំព្រះករុណា ខ្ញុំបាទសូម

ថ្លែងអំណរអរព្រះគុណ និងសូមអរគុណដល់លោក ដែលមានឧបការៈចំពោះសៀវភៅនេះគឺ ៖

❖ ព្រះតេជព្រះគុណ **ធឹង ធីម ( ចន្ទត្ថេរ)** ព្រះចៅអធិការវត្ត **ធម្មិការាម** (ក្រុងម៉ុងឫស្សី) ដែលព្រះអង្គបានជួយផ្ដល់ឯកសាដែលបាត់បង់, មានព្រះទ័យទុកដាក់ផ្ទៀងផ្ទាត់នូវអក្ខរាវិរុទ្ធ ជាពិសេសគឺកម្លាំងកាយចិត្ត ដល់ខ្ញុំព្រះករុណា ក្នុងការសរសេរចម្លងជាសៀវភៅថ្មីនេះឡើងវិញ ។

❖ ព្រះគ្រូ **សុំ ម៉ុនធឿម (សុវណ្ណត្ថេរោ)** វត្ត **ពុទ្ធសុទ្ធារាម** ដែលព្រះអង្គបានចំណាយពេលវេលាក្នុងការជួយពិនិត្យ និងកែសម្រួលឡើងវិញនូវអក្ខរាវិរុទ្ធជាពិសេសវាក្យស័ព្ទភាសាបាលី ដើម្បីការពារនូវសេចក្ដីភ្លាំងភ្លាត់គ្រប់បែបយ៉ាង ។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់ ៖

ឧបាសក **ម៉ិញ សាវ៉ាន** និងឧបាសក **ហ៊ិម ឆាន់** លោកជាព្រឹទ្ធាចារ្យរបស់ខ្ញុំ ដែលតែងតែផ្ដល់នូវគតិយោបល់ល្អៗ ចំណាយពេលវេលាដ៏មានតម្លៃ ពិគ្រោះទាំងខាងផ្លូវលោកនិងផ្លូវធម៌ ថាតើអ្វីដែលធ្វើទៅសមរម្យ និងអ្វីដែលធ្វើទៅមិនសមរម្យ ហើយជួយត្រួតពិនិត្យផ្ទៀងផ្ទាត់កែសំរួលពាក្យពេចន៍អក្ខរាវិរុទ្ធដើម្បីធ្វើឲ្យសៀវភៅនេះបានល្អ និងត្រឹមត្រូវមិនឲ្យឃ្លៀងឃ្លាតពីច្បាប់ដើម ។

ខ្ញុំព្រះករុណា ខ្ញុំបាទសូមថ្លែងអំណរអរព្រះគុណ និងអរគុណដល់ព្រះគុណម្ចាស់គ្រប់ព្រះអង្គ និងអស់លោក-អ្នកសប្បុរសទាំងឡាយដែលជាសទ្ធាសម្បន្ន និងសទ្ធាសម្បន្នា ចិត្តបុណ្យ បានបរិច្ចាគបច្ច័យតាមកម្លាំងសទ្ធា, ក្នុងការបោះពុម្ពសៀវភៅនេះចែកជាធម្មទាន ។

សូមព្រះគុណម្ចាស់ និងអស់លោក-អ្នកសប្បុរសបានសម្រេចនូវសម្មាទិដ្ឋិគ្រប់ៗជាតិ និងបាននូវឧបនិស្ស័យរួចផុតចាកទុក្ខទាំងពួងកុំបី

ឃ្លៀងឃ្លាតឡើយ ។

ទន្ទឹមនេះដែរ ខ្ញុំព្រះករុណា, ខ្ញុំបាទសូមទាន មេត្តាខន្តីអភ័យ - ទោសរាល់កំហុសឆ្គងនូវពាក្យសព្ទបាលី សម្រាយ ដែលកើតឡើង ឬភ្លាំងភ្លាត់ដោយប្រការណា សូមទានព្រះករុណាម្ចាស់ព្រមទាំងលោក-អ្នកអានទាំងឡាយមេត្តាអនុគ្រោះ ហើយជួយជួសជុល កែ បំពេញចែកជូនដល់ខ្ញុំព្រះករុណា ខ្ញុំបាទ ផងដើម្បីជាកិច្ចអនុគ្រោះចំពោះព្រះពុទ្ធសាសនាតរៀងទៅ ។

ក្នុងការចម្លងឡើងវិញនេះ ខ្ញុំព្រះករុណា ខ្ញុំបាទបានរៀបរៀងទំព័រជាថ្មី ព្រមទាំងបានកែអក្ខរាវិរុទ្ធខ្លះផងដោយយោង ទៅតាមវចនានុ - ក្រមខ្មែរ ( ២០០៨ ) ដែលជាស្នាព្រះហស្ដរបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត ជោតញ្ញាណោ** ប៉ុន្តែខ្លឹមសារនិងសំនួនវោហាររបស់អ្នកនិពន្ធនៅរក្សាទុកដូចដើម ។

**សូម**ឧទ្ទិសស្នាដៃថ្មីនៃសៀវភៅ «**ប្រស្នាគិហិប្រតិបត្តិពិស្តារ**» នេះ ថ្វាយ ប្រគេន និងជូនដល់ ៖

- **សម្ដេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ**
  **ប.អ.ស - អ.ម.រ** (១)
- **លោក** បណ្ឌិត **ឃីម ទូច ( ឥន្ទប្បញ្ញោ )**
- **លោក** សិទ្ធត្ថបណ្ឌិត **សុខ ស៊ីវ**

ដែលលោកបានបន្សល់ទុកនៅមរតកអក្សរសាស្ត្រសម្រាប់កូនចៅខ្មែរជំនាន់ក្រោយ ។ សូមព្រះអង្គ លោកបណ្ឌិតទាំងពីរ ទទួលជ្រាបគោលបំណងល្អរបស់ខ្ញុំព្រះករុណា ខ្ញុំបាទ ហើយអនុមោទនា និងបានសោយសុខតាមសមគួរដល់គតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

សូមអំណាចផលានិសង្សនៃអាមិសទាន និង ធម្មទាននេះ ជួយឧបត្ថម្ភដល់ពួកសត្វទាំងឡាយ ក្នុងចតុឱឃាដលោក ទាំងអស់បានទទួលឥដ្ឋមនុញ្ញផលគ្រប់ៗគ្នា ព្រមទាំងមានប្រាជ្ញាថ្លាគំនិត បដិបត្តិព្រះធម៌ បានសម្រេចមគ្គផលដល់ទីបំផុតទុក្ខកុំបីខានឡើយ ។

**សូមអនុមោទនា** !!!

ក្រុងម៉ុងរេអាល, ថ្ងៃ ៥ ᧯ ៧ ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៥(២)
ត្រូវនឹងថ្ងៃ ព្រហស្បតិ៍ ទី ១៦ ខែ ឧសភា គ.ស. ២០១១

**អ្នកសរសេរចម្លង**

**ង៉ាត ភិរក្ស**



(១) អានថា បណ្ឌិតអក្សរសាស្ត្រ - អភិធជមហារដ្ឋគុរុ (អៈភិធៈជៈ មៈហារ័ត-ឋៈគុរុ)
(២) អានថា ថ្ងៃព្រហស្បតិ៍ ១៥ កើត ខែជេស្ឋ ឆ្នាំថោះត្រីស័ក ព. ស. ២៥១១

# ប្រស្នា គិហិប្រតិបត្តិពិស្តារ

## (នមាមិ សុគតំ នាថំ)

## ប្រស្នាសួរ, ឆ្លើយអំពីពាក្យថា គិហិប្រតិបត្តិ



**សំណួរ**. គិហិប្រតិបត្តិ ប្រែថាដូចម្ដេច ?

**ចម្លើយ**. ប្រែថាការប្រតិបត្តិរបស់គ្រហស្ថ, ការប្រព្រឹត្តរបស់គ្រហស្ថ ឬការអនុវត្តន៍របស់គ្រហស្ថ ដើម្បីសុខសន្តិភាពក្នុងត្រៃលោក ។

**ស**. ពាក្យថា គិហិប្រតិបត្តិ និងគិហិប្បដិបត្តិ ដូចគ្នាឬផ្សេងគ្នា ? ព្រោះអ្វី ?

**ច**. ដូចគ្នាគ្រាន់តែប្លែកតួអក្សរ និងស្វរស័ព្ទប៉ុណ្ណោះ, ព្រោះប្រតិបត្តិ ជាសំស្រ្កឹត, បដិបត្តិ ជាបាលី ។

**ស**. គិហិដែលប្រែថាគ្រហស្ថនោះ បានដល់បុគ្គលប្រភេទណា ? ទេវតា, ព្រហ្មជាដើមហៅថា គ្រហស្ថបានដែរឬទេ ?

**ច**. បានដល់បុគ្គលដែលមិនមែនជាបព្វជិត រាប់តាំងពីកុមារា, កុមារី, មាណវៈ, មាណវិកា រហូតដល់តាយាយជាទី

បំផុត, ឯទេវតា ព្រហ្មជាដើម ក៏សង្គ្រោះចូលក្នុងពាក្យថា គ្រហស្ថនេះដែរ ព្រោះមិនមែនជាបព្វជិត ។

**ស** . ចុះមានពាក្យថា ៖ ឃរាវាស, ទាយក, ទាយិកា, ឧបាសក, ឧបាសិកា ពាក្យទាំង ៥ នេះដូចគ្នានឹងគ្រហស្ថដែរឬទេ ? ចូរអធិប្បាយ !

**ច** . ពាក្យទាំង ៥ នេះ នៅក្នុងវង្សគ្រហស្ថទាំងអស់គ្រាន់តែផ្សេងគ្នា តាមថ្នាក់តាមជាន់ប៉ុណ្ណោះគឺ ៖

ឃរាវាស សំដៅយកគ្រហស្ថ ដែលមានគូស្រករហើយ, ទាយក ទាយិកា សំដៅយកគ្រហស្ថដែលមានសទ្ធាត្រឹមតែធ្វើទានមានបច្ច័យ ៤ ជាដើមដល់បដិគ្គាហកៈ(ស្មូម) ។ ឧបាសកឧបាសិកា សំដៅយកគ្រហស្ថដែលចូលទៅជិតព្រះរតនត្រ័យ ឬស្ថិតនៅជិតព្រះរតនត្រ័យ, ដូចមានបទវិគ្រោះថា **រតនត្តយំ ឧបាសតីតិ ឧបាសកោ** ប្រែថា ជនអ្នកចូលទៅជិតព្រះរតនត្រ័យ ។ ពាក្យថាចូលទៅជិតនេះ សំដៅយកនាមកាយ ទោះបីបុគ្គលនោះស្ថិតនៅក្នុងទីឆ្ងាយដាច់ស្រយាលយ៉ាងណាក៏ដោយ ឲ្យតែមានចិត្តប្រព្រឹត្តជាប់លាប់ក្នុងគុណព្រះរតនត្រ័យ យកព្រះរតនត្រ័យជាទីពឹងទីរឭកហើយ, បុគ្គលនោះឈ្មោះថាចូលទៅជិតស្ថិតនៅជិតព្រះរតនត្រ័យបាននាមថា ឧបាសក ឧបាសិកា ។

**ស** . បើរួមបុគ្គលទាំង ៥ គឺ ឃរាវាស១, ទាយក១, ទាយិកា១, ឧបាសក១, ឧបាសិកា១ ឲ្យឈ្មោះយ៉ាងខ្លីតែមួយម៉ាត់ បានឬទេ ?

**ច** . បាន, ឲ្យឈ្មោះថាគ្រហស្ថតែមួយម៉ាត់ ដែលប្រែចេញ

ពីពាក្យថា «**គិហិ**» នោះឯង ។

**ស** . បើដូច្នោះ ពាក្យថា «**គិហិប្រតិបត្តិ**» មិនមែនសំរាប់ប្រតិបត្តិតែឧបាសក, ឧបាសិកាទេឬ ?

**ច** . មិនមែនសំរាប់តែឧបាសក ឧបាសិកាទេ បុគ្គលជាគ្រហស្ថទាំងឡាយអាចប្រតិបត្តិបានទាំងអស់ ។

**ស** . ដូចម្តេចហៅថា ប្រតិបត្តិ ?

**ច**. ដែលហៅថា «**ប្រតិបត្តិ**» គឺប្រព្រឹត្តតាម ធ្វើតាមពុទ្ធឱវាទ និងតាមច្បាប់ដែលអ្នកប្រាជ្ញទាំងឡាយរៀបរៀងជាន់ក្រោយ ដើម្បីឲ្យមានរបៀបតាមលំនាំពុទ្ធឱវាទ, ដូចជារបៀបនមស្ការរំលឹកគុណព្រះរតនត្រ័យដែលធ្លាប់ និយាយថាសូត្រធម៌ថ្វាយបង្គំព្រះ, បើយើងមិនប្រព្រឹត្តតាមច្បាប់ ចេះតែនាំគ្នាសូត្រតាមចំណូលចិត្តក៏មិនអាចមានរបៀប មានសណ្តាប់ធ្នាប់បាន, គ្នាតែពីរនាក់ក៏សូត្រជាមួយគ្នាមិនកើត,បើយើងញ៉ាំងខ្លួនប្រតិបត្តិតាមច្បាប់ទោះបីគ្នាប៉ុន្មាននាក់ក៏ដោយ នៅស្រុកខេត្តណាក៏ដោយ អាចសូត្រចូលគ្នាបានដោយស្រួល, នេះហៅថាការប្រតិបត្តិក្នុងត្រៃប្រណាម ។ ឯការប្រតិបត្តិចំពោះក្រឹត្យវិន័យវិញ ក៏មានលំនាំដូចគ្នាដែរ ។ រួមសេចក្តីឲ្យខ្លីថា ការញ៉ាំងខ្លួនធ្វើតាមច្បាប់ហៅថា «**ប្រតិបត្តិ** » ។

# វគ្គទី ២ ត្រៃប្រណាមបញ្ញា



**សំណួរ** . របៀបសូត្រធម៌នមស្ការព្រះរតនត្រ័យនៅប្រទេសកម្ពុជាយើង អ្នកប្រាជ្ញលោករៀបរៀងដូចម្ដេចខ្លះ ? សូត្រអ្វីមុន សូមឆ្លើយឲ្យហូរហែតាមច្បាប់របស់លោកឲ្យសព្វគ្រប់ ដើម្បីពុទ្ធបរិស័ទទាំងឡាយប្រតិបត្តិឲ្យបានត្រឹមត្រូវតាមបែបតែមួយ ដែលធ្លាប់ប្រតិបត្តិមក ?

**ចម្លើយ** . របៀបសូត្រធម៌នមស្ការព្រះរតនត្រ័យនៅប្រទេសកម្ពុជា លោកអ្នកប្រាជ្ញលោករៀបរៀង **មានពិស្តារ, មានសង្ខេប** ដូចបែបតទៅនេះ ៖

## រតនត្តយបូជាពិស្តារ

ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រ័យ

**ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ឥមេហិ ទីបធូបាទិសក្ការេហិ ធម្មំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ឥមេហិ ទីបធូបាទិសក្ការេហិ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ** (១) ។

***ប្រែថា*** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀន និងធូបជាដើមនេះដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់អ្នកដ៏មានគុណទាំងឡាយមានមាតាបិតាជាដើម ផងដល់ខ្ញុំព្រះករុណាផងអស់កាលជាអង្វែងទៅហោង ។

# ពុទ្ធរតនប្បណាម

## ថ្វាយបង្គំព្រះពុទ្ធរតនៈ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**
**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**
**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

***ប្រែថា*** វីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមាន

---

(១). សូត្រយ៉ាងខ្លីរួមទាំង ៣ មេជាមួយគ្នាថា **ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ** ដូច្នេះក៏បាន ។

ដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

( សូត្របាលី ៣ ចប់ ប្រែតែមួយចប់ក៏បាន )

**យោ សន្និសិន្នោ វរពោធិមូលេ**
**មារំ សសេនំ មហតឹ វិជេយ្យោ**[១]
**សម្ពោធិមាគច្ឆិ អនន្តញាណោ**
**លោកុត្តមោ តំ បនមាមិ ពុទ្ធំ ។**

***ប្រែថា*** ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចំរើននូវព្រះអានាបាណស្សតិកម្មដ្ឋាន លើរតនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរបានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

នមស្ការព្រះសម្មាសម្ពុទ្ធដូចសេចក្តីខាងលើនេះ គឺនមស្ការដោយ «**សង្ខេប**» មិនបានញែកកាលចេញជា ៣ ឡើយ, បើនមស្ការ

(១) ដែលធ្លាប់សូត្ររៀងមកថា **វិជ្ជយោ** តែបានពិនិត្យផ្ទៀងផ្ទាត់ទៅឃើញថា **វិជេយ្យោ** ទើបត្រឹមត្រូវប្រែដូច វិជិត្វា ឬ វិជេត្វា ។

ដោយ «**ពិស្តារ**» វិញទើបញែកកាលចេញជា ៣ ដូចសេចក្តីខាងក្រោមនេះ ៖

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**
**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ។**

*ប្រែថា* ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំង-ឡាយអង្គឯណាដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រកល្បនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយ បង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

រួចហើយគប្បីតាំងចិត្តរំឭកដល់ពុទ្ធគុណទាំង ១០ ព្រះនាមដោយបង្អោនកាយវាចាថា ៖

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។**

*ប្រែថា* **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោល គឺកិលេសព្រមទាំងវាសនាគឺកាយបយោគនិងវចីបយោគ

**សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥ **សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះ ព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរដ្ឋាន គឺអមតមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន **សត្ថាទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ទាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

រំឭកដល់ពុទ្ធគុណរួចហើយ គប្បីប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា ៖

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

*ប្រែថា* **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭក នៃខ្ញុំព្រះករុណាមិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណាដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ប្តេជ្ញាខ្លួនដូច្នេះហើយ គប្បីសូត្រសូមខមាទោសនឹងព្រះពុទ្ធជាម្ចាស់ថា ៖

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ**
**យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ។**

*ប្រែថា* **ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ដោយអវយវៈដ៏ឧត្តមគឺត្បូង **ពុទ្ធេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់ **ពុទ្ធោ ខមតុ តំ មមំ** សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង )

# ធម្មរតនប្បណាម

ថ្វាយបង្គំព្រះធម្មរតនៈ

**អដ្ឋង្គិការិយបថោ[១] ជនានំ**
**មោក្ខប្បវេសាយ ឧជូ ច មគ្គោ[២]**
**ធម្មោ អយំ សន្តិករោ បណីតោ**
**និយ្យានិកោ តំ បនមាមិ ធម្មំ ។**

*ប្រែថា* ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឲ្យត្រជាក់រំងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេស ជាធម៌ដ៏ឧត្តមជាគុណញ៉ាំងសត្វឲ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

នមស្ការដល់ព្រះសទ្ធម្ម ដូចខាងលើនេះ គឺនមស្ការដោយសង្ខេបមិនបានញែកកាលចេញជា ៣ ឡើយ, បើនមស្ការដោយ

---

(១) ដែលធ្លាប់សូត្រមកថា **អដ្ឋង្គិកោ អរិយបថោ** តែបានពិនិត្យផ្ទៀងផ្ទាត់ទៅ ឃើញថា **អដ្ឋង្គិការិយបថោ** ទើបត្រូវតាមឆន្ទរបស់គាថា គង់នៅតែកាត់បទប្រែជា **អដ្ឋង្គិកោ អរិយបថោ** ដូចដែល ។

(២) ក្នុងសៀវភៅបោះពុម្ពភាសាសីហឡ ( អក្សរលង្កាទ្វីប ) ថា **មោក្ខប្បវេសាយុជុកោ ច មគ្គោ** គង់មានសេចក្តីត្រូវគ្នានឹងបាលីក្នុងទីនេះដែរ ។

ពិស្ដារវិញទើបញែកកាលចេញជា ៣ ដូចសេចក្ដីខាងក្រោមនេះ ៖

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**
**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។**

*ប្រែថា* ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធដែលនិព្វានកន្លងទៅហើយក្ដី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្ដី ព្រះធម៌ទាំងឡាយឯណាដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្ដី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

រួចហើយគប្បីតាំងចិត្តរំឭកដល់ធម្មគុណ ដោយបង្អោនកាយវាចាថា ៖

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។**

*ប្រែថា* **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដកជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ **ធម្មោ** ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១ **សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិតដោយបច្ចវេក្ខណញាណ គឺថានឹងបានដឹងដោយស្ដាប់ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះ

អរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនបានយឺតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន **ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

រំឭកដល់ធម្មគុណដូចនេះរួចហើយ គប្បីប្រកាសប្ដេជ្ញាខ្លួនដោយពាក្យសច្ចៈថា ៖

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

*ប្រែថា* **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្ដីជយមង្គលចូរមានដល់ខ្ញុំព្រះករុណាដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ប្ដេជ្ញាខ្លួនដូចនេះហើយ គប្បីសូត្រសូមខមាទោសនឹងព្រះធម៌ជាម្ចាស់ថា ៖

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ[១] ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ។**

*ប្រែថា* **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ដោយអវយវៈដ៏ឧត្តមគឺត្បូង **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់ **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង )



(១) ក្នុងសៀវភៅបោះពុម្ពអក្សរសីហឡ (អក្សរអ្នកលង្កាទ្វីប) ថា **តិវិធ** សំដៅ សេចក្តីចំពោះព្រះធម៌ ៣ យ៉ាង គឺ ព្រះបរិយត្តិធម៌, បដិបត្តិធម៌ និងបដិវេធធម៌ ។

# សង្ឃរតនប្បណាម

ថ្វាយបង្គំព្រះសង្ឃរតនៈ

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**
**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**
**គុណេហិនេកេហិ សមិទ្ធិបត្តោ**
**អនាសវោ តំ បនមាមិ សង្ឃំ ។**

*ប្រែថា* ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរំងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេច ដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

នមស្ការដល់ព្រះអរិយសង្ឃដូចសេចក្តីខាងលើនេះគឺនមស្ការដោយសង្ខេបមិនបានញែកកាលជា ៣ ឡើយ បើនមស្ការដោយពិស្តារវិញ ទើបញែកកាលចេញជា ៣ ដូចសេចក្តីខាងក្រោមនេះ ៖

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**
**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។**

***ប្រែថា*** ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនិងផលកន្លងទៅហើយក្ដី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គ និងផលក្នុងកាលខាងមុខក្ដី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនិងផលក្នុងកាលជាបច្ចុប្បន្ននេះក្ដី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះគ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្ដង )

រួចហើយគប្បីតាំងចិត្តរំឭកដល់សង្ឃគុណដោយបង្អោនកាយវាចាថា ៖

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។**

***ប្រែថា*** **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃគឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោក

ប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា **ញាយបដិ-បន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានជាស្ពានក្សេមផុតចាកទុក្ខទាំងពួង **សាមីចិបដិបន្នោ ភគវតោ សាវក-សង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់ សីល សមាធិ បញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកិទាគាមិមគ្គ និងសកិទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១ **អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវសោតា-បត្តិមគ្គ ១ សោតាបត្តិផល ១ សកិទាគាមិមគ្គ ១ សកិទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនុ៎ះជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវ ចតុ-ប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីលហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទានគឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្រ ដែលមកអំពីទិសផ្សេងៗហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្ម ហើយ

បូជា **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។

រំឭកដល់សង្ឃគុណដូច្នេះរួចហើយ គប្បីប្រកាសប្ដេជ្ញាខ្លួនដោយពាក្យសច្ចៈថា ៖

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

*ប្រែថា* **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ **សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្ដីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ប្ដេជ្ញាខ្លួនដូចនេះរួចហើយ គប្បីសូត្រសូមខមាទោសនឹងព្រះសង្ឃជាម្ចាស់ថា ៖

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេ**
**យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ ។**

*ប្រែថា* **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការ គឺ សម្មតិសង្ឃ និងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង **សង្ឃេ - យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើ ឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់ **សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង )

វិធីនមស្ការថ្វាយបង្គំនូវព្រះរតនត្រ័យមិនចំពោះកាល និង ថ្វាយបង្គំនូវព្រះរតនត្រ័យក្នុងកាលទាំង ៣ និងសេចក្តីរំឭកគុណ ព្រះរតនត្រ័យ និងពាក្យប្តេជ្ញាខ្លួនចំពោះព្រះរតនត្រ័យ និងថ្វាយ បង្គំសូមខមាទោសចំពោះព្រះរតនត្រ័យទាំង ៥ ន័យ ដែលបាន ពោលមកហើយក្នុងខាងដើមនេះ ក៏ចប់ប៉ុណ្ណោះដោយពិស្តារ ។

អ្នកដែលមានសទ្ធា ប្រាថ្នានឹងនមស្ការដល់ព្រះរតនត្រ័យ នោះបើមានពេលឱកាសល្មមនឹងសូត្រនមស្ការទាំង ៣ បទ ឲ្យបាន ចប់សព្វគ្រប់ដោយសេចក្តីពិស្តារដូចបែបយ៉ាងខាងដើមនោះ ក៏ជា ការឧត្តមប្រពៃក្រៃពេក តែបើពេលខ្លីមិនអាចនឹងសូត្រឲ្យចប់សព្វ គ្រប់បាន ក៏គ្រាន់តែសូត្រសេចក្តីរឭក ពុទ្ធគុណ ធម្មគុណ សង្ឃគុណ និងសូត្រថ្វាយបង្គំហើយនិងសូត្រថ្វាយសក្ការបូជា ដោយសេចក្តីសង្ខេបខ្លី ៗ ដូចន័យខាងក្រោមនេះក៏បាន ។

# រតនប្បណាម បែបសង្ខេប

ព្រមទាំងបូជាគ្រឿងសក្ការៈ

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ តំ អរហាទិគុណសំ យុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

*ប្រែថា* **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសិកសត្រូវពោល គឺកិលេសព្រមទាំងវាសនាគឺកាយបយោគនិងវចីបយោគ **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥ **សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរដ្ឋាន គឺ អមតមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជា

អ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន **សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ **តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយដោយគុណមានគុណថា អរហំ ជាដើមនោះដោយសិរសាគឺត្បូង **តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំង - ឡាយមានប្រមាណប៉ុណ្ណេះ ។

( ក្រាបថ្វាយបង្គំម្តង )

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

*ប្រែថា* **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែង

ហើយដោយល្អ **ធម្មោ** ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១ **សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិតដោយបច្ចវេក្ខណញាណ គឺថានឹងបានដឹងដោយស្តាប់ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនបានឃើតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថាកាលបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន **ឱប - នយិកោ** ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើមគប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន **តំ ស្វាក្ខាតាទិគុណសំ យុត្តំ ធម្មំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណមានគុណថា ស្វាក្ខាតោជាដើមនោះដោយសិរសាគឺត្បូង **តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

( ក្រាបថ្វាយបង្គំម្តង )

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ តំ សុបដិបន្នាទិគុណសំ យុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

*ប្រែថា* **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃគឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគលោកប្រតិបត្តិដោយត្រង់គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគលោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្បៀមផុតចាកទុក្ខទាំងពួង **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់ សីល សមាធិ បញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវ សោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកិទាគាមិមគ្គ និងសកិទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ

និងអរហត្តផលជាគូ ១ **អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកិទាគាមិមគ្គ ១ សកិទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនុ៎ះជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីលហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្រដែលមកអំពីទិសផ្សេងៗហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្តគឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន **តំ សុបដិបន្នាទិគុណសំ យុត្តំ សង្ឃំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា សុបដិបន្នោជាដើមនោះដោយសិរសាគឺត្បូង **តម្ពា សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណោះ ។

( ក្រាបថ្វាយបង្គំម្តង )

# នមស្ការយ៉ាងសង្ខេប

**នមោ តស្សារហន្តស្ស ភគវន្តស្ស តាទិនោ**
**សម្មា សាមំ វ ពុទ្ធស្ស ធម្មេ វិភជ្ជវាទិនោ ។**

*ប្រែថា* **នមោ តស្សារហន្តស្ស ភគវន្តស្ស តាទិនោ** កិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគជាម្ចាស់នោះ ព្រះអង្គជាព្រះអរហន្តដ៏វិសេសជាបុគ្គលមិនញាប់ញ័រដោយលោកធម៌ទាំង ៨ ឡើយ **សម្មា សាមំ វ ពុទ្ធស្ស ធម្មេ វិភជ្ជវាទិនោ** ព្រះអង្គត្រាស់ដឹងនូវធម៌ គឺបុគ្គលគប្បីដឹងដោយប្រពៃ ចំពោះព្រះអង្គពិតហើយទ្រង់សំដែងញែកចែកនូវធម៌ទាំងឡាយនោះ ដល់សត្វទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

**នមោ តស្សេវ ធម្មស្ស និយ្យានិកស្ស វដ្ដតោ**
**បភេទានវវិធស្ស ស្វាក្ខាតស្សេវ សច្ចតោ ។**

*ប្រែថា* **នមោ តស្សេវ ធម្មស្ស និយ្យានិកស្ស វដ្ដតោ** កិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះធម៌ជាម្ចាស់នោះជាធម៌មានគុណជាទីស្រោចស្រង់នូវសត្វ ឲ្យចេញចាកវដ្តសង្សារ **បភេទានវវិធស្ស ស្វាក្ខាតស្សេវ សច្ចតោ** ជាធម៌មានប្រភេទ ៨ ប្រការមាន សោតាបត្តិមគ្គជាដើម មានព្រះ

និព្វានជាទីបំផុត ដែលព្រះសម្មាសម្ពុទ្ធសំដែងទុកមកហើយដោយប្រពៃមែនពិត ។

( ក្រាបថ្វាយបង្គំម្តង )

**នមោ អរិយសង្ឃស្ស សញ្ជាតិភូតស្ស សត្ថុនោ**
**កិលេសានុសយេ សព្វេ បហានប្បដិបត្តិយា ។**

*ប្រែថា* **នមោ អរិយសង្ឃស្ស សញ្ជាតិភូតស្ស សត្ថុនោ** កិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះអរិយសង្ឃជាម្ចាស់នោះ ជាព្រះសង្ឃកើតហើយក្នុងពួកសាវកនៃព្រះសាស្តា **កិលេសានុសយេ សព្វេ បហានប្បដិបត្តិយា** ជាព្រះសង្ឃប្រត្តិបត្តិ ដើម្បីលះបង់នូវលាមកធម៌ទាំងឡាយទាំងពួងដែលជាធម៌រមែងតែងផ្តេកផ្តួលទៅតាមកិលេស ជាគ្រឿងញុំាងសន្តានចិត្តនៃសត្វទាំងពួងឲ្យសៅហ្មង ។

( ក្រាបថ្វាយបង្គំម្តង )

# នមស្ការយ៉ាងសង្ខេប

**វិសុទ្ធករុណាញាណ ពុទ្ធំ សម្ពុទ្ធបូជិតំ**
**ធម្មំ សទ្ធម្មសម្ភូតំ វន្ទេ សង្ឃំ និរង្គណំ ។**

*ប្រែថា* ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជា

ម្ចាស់ ព្រះអង្គមានព្រះហឫទ័យករុណាដល់សត្វដទៃ គឺថាទ្រង់បៀតបៀននូវកងទុក្ខដែលមានក្នុងសន្ដាននៃសត្វដទៃ ដោយព្រះញាណ ពោលគឺព្រះអរហត្តមគ្គដ៏ហ្មត់ចត់ស្អាតចាកមន្ទិល គឺរាគាទិក្កិលេស សូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ គឺព្រះសម្ពុទ្ធបូជាហើយ គឺថាព្រះអង្គសំដែងហើយសូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ដែលកើតដោយអរិយជាតិព្រោះព្រះសទ្ធម្មជាអ្នកមិនមានដំណើរទៅកាន់ភាវៈទាប គឺកិលេសឡើយ ។

( ក្រាបថ្វាយបង្គំម្ដង )

# នមស្ការយ៉ាងសង្ខេប

**នមោ ពុទ្ធំ តិលោកគ្គំ ញេយ្យសាគរបារគុំ**
**គវាគវករំ ធម្មំ គណញ្ច គុណសាគរ ។**

***ប្រែថា*** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់ព្រះអង្គ ជាបុគ្គលប្រសើរលើសសត្វក្នុងត្រៃលោក ព្រះអង្គមានញាណគឺគុណសំរាប់ដឹងនូវញេយ្យធម៌ទាំងពួងដ៏ជ្រាលជ្រៅ បីដូចជាសាគរធំ ព្រះអង្គមានដំណើរទៅដល់ហើយនៅត្រើយសាគរគឺញាណនៃព្រះអង្គផង ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ គឺគុណសំរាប់ទ្រទ្រង់នូវសត្វទាំងឡាយដែលជាអ្នកប្រត្តិបត្តិដ៏សមគួរតាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាជាម្ចាស់ មិនឲ្យ

ធ្លាក់ចុះទៅក្នុងអបាយភូមិទាំងឡាយផង ភវាភវករំ ជាគុណតែង ធ្វើនូវកម្មភព គឺកុសលាកុសលចេតនា ២៩ មានកុសលចេតនា ជាដើម និងឧបបត្តិភព គឺភពទាំង ៩ មាន កាមភពជាដើម ដែល កើតអំពីបច្ច័យគឺកម្មភព ឲ្យវិនាសសាបសូន្យទៅផង ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះអរិយសង្ឃ លោកមានគុណដ៏ជ្រាលជ្រៅបី ដូចជាសាគរផង ។

( ក្រាបថ្វាយបង្គំម្តង )

# សុភមង្គលកថា

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា**
**សព្វពុទ្ធានុភាវេន សោត្ថិ ហោតុ និរន្តរំ ។**

*ប្រែថា* **ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្តីចំរើន ដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួង ទាំងឡាយចូររក្សានូវខ្ញុំ **សព្វពុទ្ធានុភាវេន** ដោយអានុភាពនៃ ព្រះពុទ្ធគ្រប់ព្រះអង្គ **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្តី ចូរមានដល់ខ្ញុំឲ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា**
**សព្វធម្មានុភាវេន សោត្ថិ ហោតុ និរន្តរំ ។**

*ប្រែថា* **ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្ដីចំរើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ **សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្ដីចូរមានដល់ខ្ញុំឲ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា**
**សព្វសង្ឃានុភាវេន សោត្ថិ ហោតុ និរន្តរំ ។**

*ប្រែថា* **ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្ដីចំរើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ **សព្វសង្ឃានុភាវេន** ដោយអានុភាពនៃព្រះសង្ឃទាំងពួង **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្ដីចូរមានដល់ខ្ញុំឲ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

( **ចប់ត្រៃប្រណាម** )



# វគ្គទី ៣ សរណគមន[1]វចនប្បញ្ហា



**សំណួរ** . សរណគមន៍ មានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ចម្លើយ** . សរណគមន៍មាន ២ គឺ លោកុត្តរសរណគមន៍ ១ លោកិយសរណគមន៍ ១ ។

**ស**. លោកុត្តរសរណគមន៍នោះ តើសរណគមន៍ដូចម្ដេច ? បានដល់សរណគមន៍របស់បុគ្គលពួកណា ?

**ច**. លោកុត្តរសរណគមន៍នោះ ជារបស់អ្នកដែលបានឃើញនូវសច្ចៈ ៤ ដោយច្បាស់លាស់ ក្នុងខណៈដែលមគ្គបង្កើតឡើងជាដំបូងយកព្រះនិព្វានជាអារម្មណ៍ឈ្មោះថាលោកុត្តរសរណគមន៍ បានដល់ សរណគមន៍របស់ព្រះអរិយបុគ្គល មានសោតាបន្នបុគ្គលជាដើម ។

**ស**. លោកិយសរណគមន៍នោះដូចម្ដេច ? បានដល់បុគ្គលពួកណា ?

---

(១) សរណគមន៍ : ការពោលពាក្យប្ដេជ្ញាយក ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ ជាទីរឭក ឬជាទីពឹង ។

**ឆ**. លោកិយសរណគមន៍នោះ បានដល់ពួកបុថុជ្ជន[២] យកពុទ្ធគុណ, ធម្មគុណ, សង្ឃគុណ ជាអារម្មណ៍ដល់ចិត្ត សម្រេចបានត្រឹមគ្របសង្កត់នូវឧបកិលេសដោយវិក្ខម្ភនប្បហាន ឈ្មោះថា លោកិយសរណគមន៍ ។

**ស**. ហេតុដែលកើតសរណគមន៍ មានប៉ុន្មានយ៉ាង ?

**ឆ**. ហេតុដែលកើតសរណគមន៍មាន ៣ យ៉ាងគឺ ៖

១. **ពុទ្ធាទីសុ វត្ថូសុ សទ្ធាបដិលាភោ ច** បានចំពោះនូវសេចក្តីជឿក្នុងវត្ថុទាំងឡាយមានព្រះពុទ្ធជាដើម ;

២. **សទ្ធាមូលិកា សម្មាទិដ្ឋិ ច** យល់ឃើញល្អត្រឹមត្រូវមានសទ្ធាជាឫសគល់ ;

៣. **ទិដ្ឋុជុកម្មំ ច** ការធ្វើទិដ្ឋិឲ្យត្រង់ ។

**ស**. ប្រភេទសរណគមន៍មានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ឆ** . ប្រភេទសរណគមន៍មាន ៤ យ៉ាងគឺ ៖

១ . **អត្តសន្និយ្យាតនៈ** ប្រគល់ខ្លួនថ្វាយដល់ព្រះរតនត្រ័យ ;

២ . **តប្បរាយនតា** ភាពជាអ្នកមានព្រះរតនត្រ័យជាទីពឹងតរៀងទៅខាងមុខ ;

៣ . **សិស្សភាវូបគមនៈ** ដល់នូវភាពជាអ្នកធ្វើខ្លួនឲ្យជាសិស្សព្រះរតនត្រ័យ ;

---

(២) បុថុជ្ជន ប៉ុថុច-ជន់ បា.; សំ. ( ន. ) ជនមានកិលេសក្រាស់, ជនអ្នកមានសេចក្តីសៅហ្មង ។ * ប្រថុជ្ជន ប្រថុច-ជន់ ( គុ. ) ដែលប្រកុន, ប្រញឹកខ្លាំង, មមាញឹកពេក, ប្រញឹកប្រញាប់ហួសពេក, បន្ទាន់ណាស់ ។

**៤. បាណិបាតន:** ទំលាក់ដាក់ដៃចុះ ក្រាបថ្វាយបង្គំព្រះរតនត្រ័យ ។

**ស**. វិធីដល់សរណគមន៍ ៤ យ៉ាងនោះដូចម្ដេចខ្លះ ?

**ឆ**. វិធីដល់សរណគមន៍ទាំង ៤ យ៉ាងដូចនេះ ដូចមានបាលីថា ៖

**អជ្ជ អាទឹ កត្វា អហំ អត្តានំ ពុទ្ធស្ស និយ្យាទេមិ** ;
**អជ្ជ អាទឹ កត្វា អហំ អត្តានំ ធម្មស្ស និយ្យាទេមិ** ;
**អជ្ជ អាទឹ កត្វា អហំ អត្តានំ សង្ឃស្ស និយ្យាទេមិ** ;

ខ្ញុំព្រះករុណា សូមប្រគល់កាយថ្វាយខ្លួនរបស់ខ្ញុំដល់ព្រះពុទ្ធជាម្ចាស់ ផ្ដើមធ្វើក្នុងថ្ងៃនេះជាដើម , ខ្ញុំព្រះករុណាសូមប្រគល់កាយថ្វាយខ្លួនរបស់ខ្ញុំ ដល់ព្រះធម៌ជាម្ចាស់ ផ្ដើមធ្វើក្នុងថ្ងៃនេះជាដើម, ខ្ញុំព្រះករុណា សូមប្រគល់កាយថ្វាយខ្លួនរបស់ខ្ញុំដល់ព្រះសង្ឃជាម្ចាស់ ផ្ដើមធ្វើក្នុងថ្ងៃនេះជាដើម, ដូច្នេះឈ្មោះថា **អត្តសន្និយ្យាតន:** ។

**អជ្ជ អាទឹ កត្វា អហំ ពុទ្ធប្បរាយនោ** ,
**អជ្ជ អាទឹ កត្វា អហំ ធម្មប្បរាយនោ** ,
**អជ្ជ អាទឹ កត្វា អហំ សង្ឃប្បរាយនោតិ មំ ធារេថ:** ,

ខ្ញុំព្រះករុណា សូមយកព្រះពុទ្ធជាម្ចាស់ ជាទីពឹងតរៀងទៅខាងមុខផ្ដើមធ្វើក្នុងថ្ងៃនេះជាដើម, ខ្ញុំព្រះករុណា សូមយកព្រះធម៌ជាម្ចាស់ ជាទីពឹងតរៀងទៅខាងមុខ ផ្ដើមធ្វើក្នុងថ្ងៃនេះជាដើម, ខ្ញុំ

ព្រះករុណា សូមយកព្រះសង្ឃជាម្ចាស់ ជាទីពឹងតរៀងទៅខាងមុខ ផ្ដើមធ្វើក្នុងថ្ងៃនេះជាដើម សូមលោក ទាំងឡាយចាំទុកនូវខ្ញុំព្រះករុណាថាយ៉ាងនេះចុះ ។ យ៉ាងនេះឈ្មោះថា **តប្បរាយនៈ** ។

**អជ្ជ អាទឹ កត្វា អហំ ពុទ្ធស្ស អន្តេវាសិកោ** ,
**អជ្ជ អាទឹ កត្វា អហំ ធម្មស្ស អន្តេវាសិកោ** ,
**អជ្ជ អាទឹ កត្វា អហំ សង្ឃស្ស អន្តេវាសិកោតិ**
**មំ ធារេថ** ,

ខ្ញុំព្រះករុណា ជាសិស្សព្រះពុទ្ធជាម្ចាស់ ផ្ដើមធ្វើក្នុងថ្ងៃនេះជាដើម, ខ្ញុំព្រះករុណា ជាសិស្សព្រះធម៌ជាម្ចាស់ ផ្ដើមធ្វើក្នុងថ្ងៃនេះជាដើម, ខ្ញុំព្រះករុណា ជាសិស្សព្រះសង្ឃជាម្ចាស់ ផ្ដើមធ្វើក្នុងថ្ងៃនេះជាដើម សូមលោកទាំងឡាយចាំទុកនូវខ្ញុំព្រះករុណាយ៉ាងនេះចុះ ។ ដូច្នេះឈ្មោះថា **សិស្សភាវូបគមន** ។

**អជ្ជ អាទឹ កត្វា អហំ អភិវាទនបច្ចុប្បដ្ឋាន-**
**អញ្ជលិកម្មសាមីចិកម្មំ ពុទ្ធាទីនំយេវ តិណ្ណំ**
**វត្ថូនំ ករោតីតិ មំ ធារេថ** ,

ខ្ញុំព្រះករុណា សូមធ្វើនូវអភិវាទនកម្ម ( កិរិយាថ្វាយបង្គំ ) ធ្វើនូវបច្ចុប្បដ្ឋានកម្ម ( កិរិយាក្រោកឡើងទទួល ) ធ្វើនូវអញ្ជលីកម្ម ( កិរិយាលើកដៃប្រណម្យ ) ធ្វើនូវសាមីចិកម្ម ( កិរិយាប្រព្រឹត្តគួរសម ) ដល់វត្ថុទាំងឡាយមានព្រះពុទ្ធជាដើមពិតប្រាកដ សូមលោកទាំងឡាយចាំទុកនូវខ្ញុំព្រះករុណាថាយ៉ាងនេះចុះ ។ ដូច្នេះ

ឈ្មោះថា **បាណិបាតនៈ** ។

**បាណិបាតនៈចែកចេញជា ៤ ទៀតគឺ ៖**

**១. ញាតិ** ថ្វាយបង្គំដោយគិតថា ព្រះពុទ្ធជាញាតិរបស់ខ្លួន ;

**២. ភយៈ** ថ្វាយបង្គំដោយគិតខ្លាច ;

**៣. អាចរិយៈ** ថ្វាយបង្គំដោយគិតថា ព្រះពុទ្ធជាអាចារ្យរបស់ខ្លួន ;

**៤. ទក្ខិណេយ្យ** ថ្វាយបង្គំដោយគិតថា ព្រះពុទ្ធជាទក្ខិ-ណេយ្យបុគ្គលដ៏ប្រសើរ ។

សរណគមន៍កើតឡើងដោយថ្វាយបង្គំ ថាជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ, ឯថ្វាយបង្គំដោយគិតថាជាញាតិក្តី ដោយគិតខ្លាចក្តី ដោយគិតថាព្រះពុទ្ធជាអាចារ្យរបស់ខ្លួនក្តី មិនកើតជាសរណគមន៍ឡើយ, ព្រោះហេតុនោះបុគ្គលណាមួយគិតថា ព្រះពុទ្ធលោកកើតក្នុងវង្សស្តេចសក្យៈក្តី ស្តេចកោលិយៈក្តី លោកជាញាតិរបស់អញក្តី ដូច្នេះហើយទើបថ្វាយបង្គំនោះ ឈ្មោះថាមិនមែនជាអ្នកកាន់សរណគមន៍ទេ ។

ម្យ៉ាងទៀត បុគ្គលណាគិតថា ព្រះសមណគោតមលោកមានអានុភាពខ្លាំង សូម្បីតែស្តេចផែនដីក៏គោរពកោតខ្លាចដែរ កាលបើអញមិនថ្វាយបង្គំ លោកមុខជានឹងធ្វើនូវសេចក្តីវិនាសអន្តរាយដល់អញជាមិនខាន ដូច្នោះហើយទើបថ្វាយបង្គំ បុគ្គល

នោះឈ្មោះថាមិនមែនជាអ្នកកាន់សរណគមន៍ទេ ។ បុគ្គលណាមួយនឹកឃើញចំណោះវិជ្ជាណា ដែលខ្លួនបានរៀនអំពីសំណាក់ព្រះអង្គកាលដែលព្រះអង្គនៅជាព្រះពោធិសត្វក្តី បានរៀនយកពាក្យប្រដៅទូន្មានក្នុងកាលដែលព្រះអង្គបានត្រាស់ហើយយ៉ាងនេះថា ៖

**ចតុធា វិភជេ ភោគេ បណ្ឌិតោ ឃរមាវសី**
**ឯកេន ភោគំ ភុញ្ជេយ្យ ទ្វីហ កម្មំ បយោជយេ**
**ចតុត្ថញ្ច និធាបេយ្យ អាបទាសុ ភវិស្សតិ ។**

បណ្ឌិតអ្នកមានប្រាជ្ញាអាស្រ័យនៅការគ្រប់គ្រងរក្សាផ្ទះ គប្បីចែករំលែកភោគជា ៤ ចំណែក បរិភោគប្រើប្រាស់មួយចំណែក, ប្រកបធ្វើការងារពីរចំណែក, គប្បីកប់ទុកចំណែកទី ៤ ទុកការពារសេចក្តីអន្តរាយដូច្នេះក្តី ហើយគិតថា ព្រះពុទ្ធលោកជាអាចារ្យរបស់អញ ហើយទើបថ្វាយបង្គំ បុគ្គលនោះឈ្មោះថា មិនមែនជាអ្នកកាន់សរណគមន៍ទេ ។ លុះតែបុគ្គលណាមួយគិតថាព្រះពុទ្ធនេះ លោកជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរបំផុតក្នុងលោក បើអ្នកណាដល់ហើយយកជាទីពឹង អ្នកនោះនឹងរួចចាកទុក្ខដូច្នេះ ហើយទើបថ្វាយបង្គំ បុគ្គលនោះទើបឈ្មោះថាជាអ្នកកាន់សរណ-គមន៍ពិតប្រាកដមែន ។

ឧបាសកក្តី ឧបាសិកាក្តី ដែលបានកាន់សរណគមន៍យ៉ាងនេះហើយជួបប្រទះញាតិរបស់ខ្លួន ដែលបួសក្នុងពួកតិរ្ថិយដទៃ ហើយគិតថាតិរ្ថិយនោះ ត្រូវជាញាតិរបស់អញ ក៏ថ្វាយបង្គំទៅ សរណគមន៍មិនធ្លាយឡើយ ។

អ្នកថ្វាយបង្គំញាតិដែលបួសក្នុងពួកតិរ្ថិយដទៃ សរណគមន៍មិនដាច់ មិនចាំបាច់និយាយថ្វីដល់អ្នកថ្វាយបង្គំស្តេចផែនដីខ្លាចក្រែងដាច់សរណគមន៍នោះ គឺមិនដាច់ដូចគ្នាដែរ ព្រោះស្តេចផែនដីមនុស្សអ្នកនៅក្នុងដែនដីតែងគោរពបូជា កាលបើយើងមិនថ្វាយបង្គំមុខជានឹងដល់នូវសេចក្តីវិនាសអន្តរាយដល់យើងមិនខានត្រូវតែថ្វាយបង្គំទើបគួរ ។

ម៉្យាងទៀត ឧបាសក ឧបាសិកា ជួបប្រទះនឹងតិរ្ថិយដែលធ្លាប់បង្រៀនចំណេះវិជ្ជាណាមួយដល់ខ្លួន គិតថាតិរ្ថិយនេះជាអាចារ្យរបស់អញហើយក៏ថ្វាយបង្គំទៅ សរណគមន៍ក៏មិនបែកធ្លាយដែរ ។ ប្រភេទផ្សេងៗនៃសរណគមន៍ បណ្ឌិតគប្បីដឹងយ៉ាងនេះចុះ ។

**ស**. ផលរបស់សរណគមន៍ដូចម្តេចខ្លះ ?

**ច**. ផលរបស់សរណគមន៍ដូច្នេះគឺ **សរណគមនផលំ** សាមញ្ញផល ៤ ជាផលសំរេចនៃលោកុត្តរសរណគមន៍ សេចក្តីអស់ទៅនៃទុក្ខទាំងពួងជាផលហូរចូលមកនៃលោកុត្តរសរណគមន៍ សមដូចពុទ្ធដីកាក្នុងគម្ពីរធម្មបទដ្ឋកថាខុទ្ទកនិកាយថា ៖

**យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ ចត្តារិ អរិយសច្ចានិ ធម្មប្បញ្ញាយ បស្សតិ ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។**

» បុគ្គលណាបានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក ឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃ នូវអរិយសច្ចទាំង ៤ គឺទុក្ខ ១, តណ្ហាជាហេតុនាំឱ្យកើតទុក្ខ ១,ព្រះនិព្វានកន្លងបង់នូវទុក្ខ ១, អរិយមគ្គមានអង្គ ៨ ជាហេតុនាំឱ្យដល់នូវព្រះនិព្វានជាគ្រឿងស្ងប់រំងាប់ទុក្ខ ១, នេះជាទីពឹងដ៏ក្សេមក្សាន្តជាទីពឹង ដ៏ឧត្តមរបស់បុគ្គលនោះៗ តែងរួចចាកទុក្ខទាំងពួង ព្រោះអាស្រ័យទីពឹងនេះឯង ។

**ស**. សរណគមន៍ជាលោកុត្តរៈ មានដាច់មានសៅហ្មងឬទេ ?

**ច**. សរណគមន៍ជាលោកុត្តរៈ មិនមានដាច់មិនមានសៅហ្មងទេ ព្រោះលោកុត្តរៈសរណគមន៍យកព្រះនិព្វានជាអារម្មណ៍ ។

**ស**. យកព្រះនិព្វានជាអារម្មណ៍នោះដូចម្តេច ? ដឹងព្រះនិព្វាននោះតើដឹងដោយសារអ្វី ?

**ច**. ដឹងព្រះនិព្វាននោះដឹងដោយមគ្គញ្ញាណ ៤ លុះតែបុគ្គលណាមួយធ្វើមគ្គញ្ញាណទាំង ៤ នោះឲ្យកើតឡើងបានទើបដឹងព្រះនិព្វានបាន ។

**ស**. មគ្គញ្ញាណទាំង ៤ នោះកើតដូចម្តេចខ្លះចូររៀបរាប់ និងអធិប្បាយ ?

**ច**. មគ្គញ្ញាណទាំង ៤ នោះត្រូវដឹងដោយញាណទស្សនវិសុទ្ធិដូចអធិប្បាយតទៅនេះ ៖

ញាណទស្សនវិសុទ្ធិនោះគឺ ញាណដែលដឹងក្នុងមគ្គទាំង ៤ គឺ៖ សោតាបត្តិមគ្គ ១, សកិទាគាមិមគ្គ ១, អនាគាមិមគ្គ ១, អរហត្តមគ្គ ១, ហៅថា **ញាណទស្សនវិសុទ្ធិ** ។

សេចក្ដីថា មគ្គញ្ញាណជាបឋមនោះព្រះយោគាវចរ[១] គប្បីប្រាថ្នាឲ្យសំរេច មិនគប្បីធ្វើនូវកិច្ចដទៃទៀតឡើយ ត្រូវតែធ្វើវិបស្សនាជាទីបំផុតនៃអនុលោមតែម៉្យាងឲ្យសំរេច, កិលេសដែលបិទបាំងនូវសច្ចធម៌ ព្រះយោគាវចរកំចាត់បង់ដោយអនុលោម ៣ ចិត្តដែលមិនជាប់នៅក្នុងសង្ខារ មិនស្ទុះទៅកាន់អារម្មណ៍ ដូចទឹកដែលមិនដក់នៅលើស្លឹកឈូក មាននិមិត្ត[២] ជាអារម្មណ៍នឹងមានការប្រព្រឹត្តទៅជាអារម្មណ៍ទាំងនេះ ក៏កើតឡើងដល់ព្រះយោគីដែលមានសេចក្ដីខ្វល់ខ្វាយ លំដាប់នោះព្រះយោគីក៏ចំរើននូវអនុលោមញ្ញាណធ្វើនូវព្រះនិព្វាន ដែលមិនមាននិមិត្តប្រាសចាកសង្ខារឲ្យមានជាអារម្មណ៍ ហើយក៏កន្លងនូវបុថុជ្ជនគោត្រនិងបុថុជ្ជនភូមិ ហើយឡើងកាន់អរិយគោត្រនិងអរិយភូមិ គោត្រភូញាណក៏កើតឡើងប្រាកដ គោត្រភូញាណគ្របសង្កត់នូវកិរិយាកើតឡើង និងកិរិយាប្រព្រឹត្តទៅហើយស្ទុះទៅកាន់ព្រះនិព្វានជាអារម្មណ៍ដូច្នេះឈ្មោះថា គោត្រភូ ។ កិរិយាដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងៗដោយជវ័ន[៣]តែមួយ ឧបមាដូចបុរសលោតកន្លង

---

(១) យោគាវចរ ...វៈច : អ្នកតាំងចិត្តឲ្យចុះស៊ប់ក្នុងការភាវនា, អ្នកចម្រើនកម្មដ្ឋាន ។

(២) និមិត្ត ...មិត : ដើមហេតុ, លក្ខណៈ, គោល, ចារឹក, ខ្នាសរបស់បុរសស្ត្រី ។

(៣) ជវនៈ ជៈ វៈ នៈ ឬ ជៈ វាន់ (ន.) (ជវន) សន្ទុះ, កម្លាំងដែលស្ទុះ, ទំហឹង, ល្បឿន,

នូវប្រទ្បាយទឹក មានប្រាថ្នានឹងឆ្លងទៅត្រើយម្ខាង លុះដល់ហើយ ក៏នៅស្ងៀម យ៉ាងណាមិញ, ចំណែកព្រះយោគាវចរដែលប្រាថ្នា នឹងឋិតនៅត្រើយម្ខាង គឺព្រះនិព្វាន ដែលលោតអំពីកំណើតនឹង ឋិតនិងទីលំនៅ ទៅដោយរហ័សមាន ឧទយព្វយានុបស្សនា ជាដើម ចងនូវមែកឈើគឺ អត្តភាព ក្បួនគឺរូប អនុលោមជវន ដែលពិចារណាឃើញ អនិច្ចំ ទុក្ខំ អនត្តា ដូច្នេះ ក៏មិនព្រមលែង នូវរូបនោះ ហើយលោតឡើងដោយអនុលោមចិត្តជាបឋមមានចិត្ត ទោរទន់ទៅកាន់ព្រះនិព្វាន ដូចជាកាយដែលទោរទន់ទៅកាន់ ត្រើយម្ខាង ជិតព្រះនិព្វានដោយតតិយជវន ដូចជាដល់ត្រើយ ខាងនាយលែងពិចារណានូវសង្ខារដល់ត្រើយគឺ ព្រះនិព្វានដោយ គោត្រភូចិត្ត កិរិយាដែលញាប់ញ័រ ដោយមិនបានសេពគប់នូវ អារម្មណ៍តែមួយ ដូចជាបុរសដែលមិនបានឈរនៅដោយស្រួល ក៏យ៉ាងនោះដែរ ។ អនុលោមញ្ញាណកំចាត់បង់នូវងងឹត គឺកិលេស ដែលបិទបាំងនូវសច្ច ៤ តែមិនអាចធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ បាន ឯគោត្រភូធ្វើព្រះនិព្វានឲ្យជាអារម្មណ៍បាន តែមិនអាចកំចាត់ បង់នូវងងឹតគឺកិលេសបាន ឧបមាដូចបុរសម្នាក់មានភ្នែកភ្លឺដើរ ចេញទៅក្នុងវេលារាត្រីស្ងាត់ គិតថាអញនឹងមើលនូវនក្ខត្តឫក្ស ហើយក្រឡេកមើលទៅខាងលើឃើញព្រះចន្ទ្រ តែមិនប្រាកដព្រោះ មានពពកបាំង លំដាប់នោះមានខ្យល់បក់ផាត់ពពកដ៏ក្រាស់ ខ្យល់ ខ្លះបក់ផាត់ពពកយ៉ាងកណ្ដាល ខ្យល់ខ្លះទៀតបក់ផាត់ពពកយ៉ាង ល្អិត បុរសនោះក៏ឃើញនូវព្រះចន្ទ្រពេញវង់ច្បាស់ ងងឹតគឺកិលេស

ដ៏ក្រាស់ និងកិលេសយ៉ាងល្អិត ដូចជាពពកបីជាន់ដែលបិទបាំងនូវព្រះចន្ទ្រ អនុលោមចិត្តដូចខ្យល់កំចាត់បង់នូវពពក គោត្រភូដូចជាបុរសមានភ្នែកភ្លឺ, ព្រះនិព្វានដូចជាព្រះចន្ទ្រកំចាត់បង់នូវងងឹតដែលបិទបាំងនូវសច្ចៈដោយអនុលោមចិត្តមួយ ។ ដូចជាកំចាត់បង់ពពកដោយលំដាប់នៃខ្យល់ ឃើញនូវព្រះនិព្វានដោយគោត្រភូញាណ កំចាត់បង់នូវងងឹតដូចបុរសឃើញនូវព្រះចន្ទ្រពេញវង់ស្អាត ។ ខ្យល់កំចាត់បង់នូវពពក តែមិនអាចឃើញនូវព្រះចន្ទ្រខ្លួនឯងបាន យ៉ាងណា, ចំណែកអនុលោមញាណកំចាត់បង់នូវកិលេស តែមិនអាចឃើញនូវព្រះនិព្វានដោយខ្លួនឯងបាន គោត្រ-ភូញាណ ឃើញនូវព្រះនិព្វានតែមិនអាចកំចាត់បង់នូវកិលេសបានក៏យ៉ាងនោះដែរ ។ មគ្គមិនលែងនូវសញ្ញាដែលគោត្រភូញាណឲ្យសញ្ញានោះ ត្រាស់ដឹងដោយតៗ គ្នាមិនដាច់ ហើយទំលាយគំនរគឺ លោភៈ ទោសៈ មោហៈ ។ ឧបមាដូចបុរសបាញ់ធ្នូហើយតម្រូតក្តារមួយរយជាន់ប្រមាណប៉ុនគោឧសភ ហើយយកសំពត់រុំមុខកាន់ព្រួញឈរនៅទីបំផុត ហើយគេឲ្យបុរសដទៃទៀតទៅបង្វិលក្តារយន្តនោះ ឲ្យមានមុខទៅត្រង់ក្តារ ដែលបុរសនោះឈរនៅហើយទើបឲ្យសញ្ញាដោយចុងដំបង បុរសដែលបាញ់នោះក៏មិនលែងនូវសញ្ញាដោយចុងដំបងនោះឡើយ ហើយបាញ់ព្រួញទៅក៏មុតក្តារទាំងមួយរយជាន់នោះគោត្រភូញាណដូចជាសេចក្តីសំគាល់ដោយចុងដំបង មគ្គញាណដែលទំលាយនូវ លោភៈ ទោសៈ មោហៈ ដូចជាបុរសដែលមិនលែងនូវសញ្ញាដោយចុងដំបងហើយ

បាញ់ទៅមុតក្តារមួយរយជាន់ មគ្គដែលដឹងដូច្នេះហៅថាសោតា - បត្តិមគ្គញាណ ។ ព្រះអរិយបុគ្គលជាគំរប់ពីរឈ្មោះថា សោតាបន្ន បុគ្គល ដែលអន្ទោលទៅក្នុងទេវតានិងមនុស្សអស់ ៧ ជាតិទើបធ្វើ នូវទីបំផុតនៃទុក្ខបាន ចិត្តរបស់លោកក៏យាងចុះទៅកាន់ភវង្គជាទី បំផុតនៃផល លំដាប់នោះមនោទ្វារាវជ្ជនៈផ្តាច់បង់ នូវភវង្គ ដែល កើតឡើងដោយពិចារណានូវមគ្គ មនោទ្វារាវជ្ជនៈ នោះរលត់ទៅ ជវ័នពិចារណានូវមគ្គទាំង ៧ ដោយលំដាប់ចិត្តដែលយាងចុះកាន់ ភវង្គម្តងទៀត ហើយពិចារណានូវផល ។

**បច្ចវេក្ខណកិច្ច** កិច្ចដែលសោតាបន្នបុគ្គលត្រូវពិចារណា មាន ៥ យ៉ាងគឺ ៖

**១. មគ្គំ បច្ចវេក្ខតិ** ពិចារណានូវមគ្គ ដោយន័យដូច្នេះ ថាអាត្មាអញមកតាមផ្លូវណា ;

**២. ផលំ បច្ចវេក្ខតិ** ពិចារណានូវផលជាអានិសង្សដែល អាត្មាអញត្រូវបាន ;

**៣. បហីនក្កិលេសំ បច្ចវេក្ខតិ** ពិចារណានូវកិលេសដែល ខ្លួនលះបង់ហើយ ថាកិលេសទាំងឡាយនេះអាត្មាអញលះបង់ បានហើយ ;

**៤. អវសេដ្ឋកិលេសំ បច្ចវេក្ខតិ** ពិចារណានូវកិលេស ដែលសល់នៅ ថាកិលេសទាំងអស់ដែលសល់នៅនេះត្រូវលះ ដោយមគ្គខាងលើ ;

**៥. និព្វានំ បច្ចវេក្ខតិ** ពិចារណានូវព្រះនិព្វានថា ធម៌

នេះហើយដែលជាអារម្មណ៍ត្រូវត្រាស់ដឹង ។

សោតាបន្នបុគ្គលមាន ៥, សកិទាគាមិបុគ្គលមាន ៥, អានាគាមិបុគ្គលមាន ៥ ដូចគ្នា ឯព្រះអរហន្តមានតែ ៤ កិលេសដែលនៅសល់នោះ ព្រះអរហន្តលោកមិនមានទេ អរិយសាវកជាសោតាបន្នបុគ្គលនោះលោកលះបង់នូវ កាមរាគៈ ព្យាបាទៈដ៏ស្តើង, លោកប្រជុំឥន្ទ្រិយ, លោកញ៉ាំញីនូវ រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ថាជា ទុក្ខំ អនិច្ចំ អនត្តា ចិត្តលោកក៏យោងទៅកាន់ថ្នល់គឺ វិបស្សនានុលោមញ្ញាណ និងគោត្រភូញាណក៏កើតឡើងដោយជវនចិត្តតែមួយក្នុងទីបំផុតនៃសង្ខារុបេក្ខា សកិទាគាមិមគ្គកើតឡើងក្នុងលំដាប់នៃគោត្រភូញាណ ដែលដឹងនូវសកិទាគាមិមគ្គ ដូច្នេះហៅថា សកិទាគាមិមគ្គញ្ញាណជាគំរប់ ២ ។

អរិយបុគ្គលជាគំរប់ ៤ ហៅថា សកិទាគាមិបុគ្គល លោកមកកាន់លោកនេះអស់វារៈម្តងទៀត ហើយពិចារណានូវ បច្ចវេក្ខណៈ ៥ រួចលោកលះបង់នូវ កាមរាគៈ ព្យាបាទៈ ដែលសេសសល់ លោកប្រជុំនូវឥន្ទ្រិយហើយញ៉ាំញីនូវបញ្ចក្ខន្ធ លុះប្រព្រឹត្តដូច្នោះហើយអនុលោមគោត្រភូក៏កើតឡើង ទាំងអនាគាមិមគ្គក៏កើតឡើង ដូច្នេះហៅថា អនាគាមិមគ្គញ្ញាណជាគំរប់ ៣ ។

អរិយបុគ្គលជាគំរប់ ៦ ឈ្មោះថា អនាគាមិបុគ្គល លោកបរិនិព្វានទៅក្នុងជាន់សុទ្ធាវាស លែងត្រឡប់មកកាន់កាមលោកនេះទៀតហើយ លោកពិចារណានូវមគ្គទាំង ៤ ខំលះបង់នូវរូប

រាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជាដែលសេសសល់នៅ លោកប្រជុំនូវឥន្ទ្រិយ ពលៈពោជ្ឈង្គ ហើយញ៉ាំញីនូវបញ្ចក្ខន្ធថាជា ទុក្ខំ អនិច្ចំ អនត្តា អនុលោមគោត្រភូញាណដែលដឹងក្នុងអរហត្តមគ្គ ដូច្នោះ ហៅថា អរហត្តមគ្គញ្ញាណជាគំរប់ ៨ ។

អរិយបុគ្គលជាគំរប់ ៨ ហៅថា អរហត្តបុគ្គល លោកជាព្រះខីណាស្រព លះបង់នូវសំយោជនៈទាំងអស់គ្មានសេសសល់ឡើយ ញាណទាំង ៤ នេះញាណដឹងចំពោះមគ្គ តួបុគ្គលតាំងនៅក្នុងផលបានជាផ្លាស់គ្នាជាលំដាប់ៗ ញាណដែលដឹងនូវមគ្គទាំង ៤ ដូច្នេះហៅថា ញាណទស្សនវិសុទ្ធិ ។

បុគ្គលដែលដឹងនូវព្រះនិព្វានបាន លុះតែធ្វើនូវមគ្គញាណ[១] ឲ្យកើតឡើងទើបយកព្រះនិព្វានជាអារម្មណ៍បាន ។ លោកុត្តរ - សណគមន៍នោះ ព្រះអរិយបុគ្គលទាំង ៤ ពួកនេះដែលលោកដល់, ចំណែកបុថុជ្ជនមិនត្រូវបានសរណគមន៍នេះទេ ។

## ផលលោកិយសរណគមន៍មាន ២ យ៉ាងគឺ ៖

**១. ភវសម្បទាបិ** បរិបូណ៌ដោយភពកន្លែងកើត ;

**២. ភោគសម្បទាបិ** បរិបូណ៌ដោយភោគសម្ប័ទ ;

**ស**. សម្បទាទាំងពីរយ៉ាងនេះ មានសេចក្ដីអធិប្បាយយ៉ាងណាខ្លះ ? ចូរអធិប្បាយមកមើល៍ ?

---

(១) មគ្គញាណទាំង ៤ នេះដូចកញ្ចក់សំរាប់ឆ្លុះបញ្ចាំងមើលនូវព្រះនិព្វាន ។

**ច**. សម្បទាទាំងពីរយ៉ាងនេះ មានសេចក្តីអធិប្បាយយ៉ាងនេះគឺ ៖

- **ភវសម្បទាបិ** បរិបូណ៌ដោយភពកន្លែងកើតនោះ គឺបុគ្គលដែលយកព្រះរតនត្រ័យ ជាទីពឹង ទីរឭក ដល់ទំលាយបញ្ចក្ខន្ធស្លាប់ពីមនុស្សលោកនេះទៅ នឹងទៅកើតសុគតិភូមិទេវ-លោកទៀងប្រាកដ ដូចបទថា ៖

**យេ កេចិ ពុទ្ធំ សរណំ គតាសេ ន តេ គមិស្សន្តិ អបាយំ បហាយ មានុសំ ទេហំ ទេវកាយំ បរិបូរេស្សន្តិ ។**

» ជនទាំងឡាយណាមួយ ដល់ហើយនូវព្រះពុទ្ធជាទីពឹងទីរឭក ជនទាំងនោះនឹងមិនទៅកាន់អបាយភូមិ លុះលះរាងកាយជារបស់មនុស្សបោលហើយ នឹងទៅបំពេញកាយជាទេវតាក្នុងសុគតិទេវលោក ។

- **ភោគសម្បទាបិ** បរិបូណ៌ដោយភោគសម្ប័ទនោះ បុគ្គលដែលយកព្រះរតនត្រ័យជាទីពឹងទីរឭក ដល់ទំលាយបញ្ចក្ខន្ធពីមនុស្សលោកនេះហើយ តែងទៅកើតសុគតិភព ប្រសើរលើសលែងជាងទេវតាដទៃ បរិបូណ៌ដោយទិព្វសម្បត្តិ ១០ យ៉ាងគឺ ៖

- **ទិព្វេន អាយុនា** អាយុទិព្វ ១ ;
- **ទិព្វេន វណ្ណេន** ពណ៌ សម្បុរទិព្វ ១ ;
- **ទិព្វេន សុខេន** សេចក្តីសុខទិព្វ ១ ;

- **ទិព្វេន យសេន** យសទិព្វ ១ ;
- **ទិព្វេន អធិបតេយ្យេន** អធិបតីទិព្វ ១ ;
- **ទិព្វេហិ រូបេហិ** រូបារម្មណ៍ទាំងឡាយទិព្វ ១ ;
- **ទិព្វេហិ សទ្ទេហិ** សទ្ទារម្មណ៍ ទាំងឡាយទិព្វ ១ ;
- **ទិព្វេហិ គន្ធេហិ** គន្ធារម្មណ៍ទាំងឡាយទិព្វ ១ ;
- **ទិព្វេហិ រសេហិ** រសារម្មណ៍ទាំងឡាយទិព្វ ១ ;
- **ទិព្វេហិ ផោដ្ឋព្វេហិ** ផោដ្ឋព្វារម្មណ៍ទាំងឡាយទិព្វ ១។

ព្រះធម៌ក្តី ព្រះសង្ឃក្តី ផលចែកចេញជាពីរដូចៗ គ្នា មានកំលាំងស្មើគ្នាដូចព្រះពុទ្ធដែរ, ផលនៃសរណគមន៍បណ្ឌិតគប្បីដឹងយ៉ាងនេះដែរ ។

**ស. សង្កិលេសោ** សៅហ្មងសរណគមន៍មានប៉ុន្មានយ៉ាង ? ចូររាប់ហើយអធិប្បាយផង ?

**ច.** សៅហ្មងសរណគមន៍មាន ៣ យ៉ាងគឺ ៖ **អញ្ញាណ** សេចក្តីមិនដឹង ១, **សំសយៈ** សេចក្តីសង្ស័យ ១, **មិច្ឆាញាណ** សេចក្តីដឹងខុសចូលចិត្តខុស ១ ។

## អធិប្បាយថា ៖

- **អញ្ញាណ** មិនដឹងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាអ្វី ។ ព្រះពុទ្ធមានគុណសម្បទាយ៉ាងណា, ព្រះធម៌មានគុណានុភាពយ៉ាងណា, ព្រះសង្ឃមានគុណវុឌ្ឍយ៉ាងណា, មិនដឹងយ៉ាងនេះឈ្មោះថា អញ្ញាណ ។

- **សំសយៈ** សេចក្តីសង្ស័យថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ អ្នកនិយាយចេះតែថាតាមគ្នា រកអ្វីជាប្រាកដគ្មាន ប្រហែលជារូបដែលគេគូរដាក់នឹងកញ្ចក់ ឬរូបដែលគេសាងដោយប្រាក់មាសជាដើមនេះហើយថាព្រះពុទ្ធទេដឹង ? គេសូត្រសព្វថ្ងៃហ្នឹងហើយយ៉ាងជាព្រះធម៌ ? ព្រះសង្ឃដែលដើរទៅបិណ្ឌបាតផ្ទះយើងហ្នឹងហើយយ៉ាងជាព្រះសង្ឃ ? សង្ស័យយ៉ាងនេះហៅថា សំសយៈ ។
- **មិច្ឆាញាណ** សេចក្តីដឹងខុស ចូលចិត្តខុស ដូចអ្នកខ្លះយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក, ចូលចិត្តថាអ្នកដែលរាប់អានខ្មោចគេមានអាសន្នម្តងៗពេលណាឡើង គេតែងបន់ខ្មោចឲ្យជួយ, យើងគោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បើយើងមានអាសន្នភយន្តរាយអ្វីមួយកើតឡើង យើងបន់លោកឲ្យជួយរំដោះភយន្តរាយទាំងនោះឲ្យបានសុខដល់យើង, ដឹងខុសចូលចិត្តខុសយ៉ាងនេះ ឈ្មោះថា មិច្ឆាញាណ ។

ទោសប៉ុណ្ណោះជាដើមនាំឲ្យសៅហ្មងដល់សរណគមន៍ ។

**ស. ភេទោ** ហេតុដែលនាំឲ្យបែកធ្លាយសរណគមន៍មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ឆ.** ហេតុដែលនាំឲ្យបែកធ្លាយសរណគមន៍មាន ២ យ៉ាងគឺ ៖

**១. សាវជ្ជោ ច** បែកធ្លាយដោយទោស ;

**២. អនវជ្ជោ ច** បែកធ្លាយមិនប្រកបដោយទោស ;

**ស.** បែកធ្លាយសរណគមន៍ ប្រកបដោយទោសយ៉ាងណា, មិនប្រកបដោយទោសយ៉ាងណា ? ចូរអធិប្បាយ !

**ច**. បែកធ្លាយសរណគមន៍ប្រកបដោយទោស និងមិនប្រកបដោយទោសយ៉ាងនេះ ៖

- **សាវជ្ជោ ច** បែកធ្លាយសរណគមន៍ប្រកបដោយទោសនោះព្រោះប្រគល់ខ្លួនដល់គ្រូដទៃ ក្រៅអំពីព្រះរតនត្រ័យ ឬចូលសាសនាដទៃក្រៅអំពីព្រះពុទ្ធសាសនា យ៉ាងនេះមានឈ្មោះថា សាវជ្ជោ នឹងធ្លាក់ទៅរងទុក្ខវេទនាក្នុងអបាយភូមិ ព្រោះខ្លួនបានជីកឫសគល់របស់ខ្លួនអស់ហើយ ។
- **អនវជ្ជោ ច** បែកធ្លាយសរណគមន៍មិនប្រកបដោយទោស គឺបែកធ្លាយដោយបុគ្គលអ្នកគោរពសរណគមន៍ ធ្វើកាលកិរិយាស្លាប់ទៅ ចិត្តរលត់លែងគិតព្រះរតនត្រ័យ ទើបបែកធ្លាយសរណគមន៍យ៉ាងនេះឈ្មោះថា អនវជ្ជោ ហើយត្រឡប់បានជាផលពីរយ៉ាងគឺ ៖ ភវសម្បទា ១, ភោគសម្បទា ១ ដូចបានអធិប្បាយរួចមកហើយ ។

**ស**. អង្គរបស់សរណគមន៍មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ច**. អង្គរបស់សរណគមន៍មាន ៣ យ៉ាងគឺ ៖

**១. សទ្ធា** សេចក្ដីជឿជាក់ក្នុងគុណព្រះរតនត្រ័យ ;

**២. បញ្ញា** ការដឹងច្បាស់ក្នុងគុណព្រះរតនត្រ័យ ;

**៣. ជីវិតបរិច្ចាគ** ស៊ូលះបង់ជីវិតមិនលះបង់ធម៌ ។

( **ចប់ត្រៃសរណគមន៍** )

# វគ្គទី ៤ ឧបាសកវចនបញ្ហា



**សំណួរ**. ដូចម្តេចដែលហៅថា ឧបាសក, ឧបាសិកា ?

**ចម្លើយ**. គ្រហស្ថដែលចូលទៅជិតដល់នូវព្រះរតនត្រ័យ ហើយយកជាទីពឹង ទីរឭក ស្មើដោយជីវិត ហៅថាឧបាសក ឧបាសិកា ដូចព្រះពុទ្ធដីកាថា ៖

**យតោ ខោ មហានាម ឧបាសកោ ពុទ្ធំ សរណំ គតោ ហោតិ ធម្មំ សរណំ គតោ ហោតិ សង្ឃំ សរណំ គតោ ហោតិ ឯត្តាវតា ខោ មហានាម ឧបាសកោ ហោតិ ។**

» បពិត្រមហានាមបុគ្គលជាឧបាសកដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរឭកដោយហេតុណា បពិត្រមហានាមដោយហេតុនោះបុគ្គលនោះឈ្មោះថា ឧបាសក ឧបាសិកា ។

**ស**. មុននឹងដល់ព្រះរតនត្រ័យ ដើម្បីទទួលបាន:ជាឧបាសក ជាឧបាសិកានោះ មានវិធីប្រតិបត្តិដូចម្តេចខ្លះ ?

**ច**. បុរសឬស្ត្រីដែលមានសទ្ធាជ្រះថ្លាក្នុងគុណព្រះរតនត្រ័យ

គឺគុណព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ ហើយមានប្រាថ្នាប្ដេជ្ញាខ្លួន ជាឧបាសកឬជាឧបាសិកាជាបុព្វភាគប្បដិបត្តិ គឺសេចក្ដីប្រតិបត្តិ ជាចំណែកខាងដើមឲ្យបានពេញស័ប់ជាអ្នកកាន់ព្រះពុទ្ធសាសនា ឬជាអ្នកតម្កល់នៅក្នុងព្រះពុទ្ធសាសនានោះ ដំបូងបង្អស់ត្រូវ បញ្ចេញវចីភេទសូមខមាទោស នឹងព្រះរតនត្រ័យក្នុងទីចំពោះ ព្រះភ័ក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះនឹងព្រះសថូបឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធក៏បាន ចំពោះមុខ បុគ្គលគឺភិក្ខុទាំងឡាយតាំងពី ៤ រូបឡើងទៅក៏បាន ។

ឯវិធីខមាទោស និងថ្វាយខ្លួនមានដូចតទៅនេះ ៖

- **បុរស ( ស្ត្រី ) ម្នាក់ឯងសូមខមាទោស**

**អច្ចយោ មំ ភន្តេ អច្ចគ្គមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ ( យោហំ / យាហំ )* ភន្តេ កាយេន វា វាចាយ វា មនសា វា ( ភគវតោ / ពុទ្ធស្ស ) វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ( តស្ស /តស្សា )* មេ ភន្តេ ( ភគវា / អយ្យោ / អយ្យា / សង្ឃោ) អច្ចយំ អច្ចយតោ បដិគ្គណ្ហា ( តុ / តុ / ន្តុ / តុ ) អាយតឹ សំវរាយ ។**

( * ) បុរស ថា **យោហំ , អកាសឹតស្ស** ។

( * ) ស្ត្រី ថា **យាហំ , អកាសឹតស្សា** ។

***ប្រែថា*** បពិត្រព្រះ ( ដ៏មានព្រះភាគ / ករុណា / ករុណា ទាំងឡាយ / សង្ឃ ) ដ៏ចំរើន ទោសកំហុសដែលប្រព្រឹត្តកន្លង

គ្របសង្កត់ហើយនូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណាជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះ ( ដ៏មានព្រះភាគ / ករុណា / ករុណាទាំងឡាយ / សង្ឃ ) ដ៏ចំរើន ! ក្រែងខ្ញុំព្រះករុណាបានធ្វើហើយនូវសេចក្តីល្មើសមិនគោរពដល់ព្រះ ( ដ៏មានព្រះភាគក្តី / ព្រះពុទ្ធជាម្ចាស់) ក្តី, ព្រះធម៌ក្តី, ដល់ព្រះសង្ឃក្តី, ដោយកាយក្តី, ដោយវាចាក្តី, ដោយចិត្តក្តី បពិត្រព្រះ ( ដ៏មានព្រះភាគ / ករុណា / ករុណាទាំងឡាយ / សង្ឃ ) ដ៏ចំរើនសូមព្រះ ( ដ៏មានព្រះភាគ / ករុណា / ករុណាទាំងឡាយ / សង្ឃ ) អត់នូវទោសកំហុសនោះដល់ខ្ញុំព្រះករុណា ព្រោះអំពើនៃទោសនោះជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងបានប្រព្រឹត្តឲ្យល្អតទៅក្នុងខាងមុខនោះហោង ។

បើសុទ្ធតែបុរសឬស្ត្រីច្រើននាក់ ឬបុរសនិងស្ត្រីច្រើននាក់លាយគ្នាតាំងពី ២ នាក់ឡើងទៅ ហើយសូត្រខមាទោសព្រមគ្នា នោះត្រូវសូត្រថា ៖

- **បុរស ឬ ( ស្ត្រី )* ច្រើននាក់សូមខមាទោស**

**អច្ចយោ នោ ភន្តេ អច្ចគ្គមា យថាពា ( លេ / លា )* យថាមុ ( ឡ្ហេ / ឡ្ហា )* យថាអកុស ( លេ / លា )* មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ( ភគវតោ / ពុទ្ធស្ស ) វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា ( តេសំ / តាសំ )* នោ ភន្តេ ( ភគវា / អយ្យោ / អយ្យា / សង្ឃោ ) អច្ចយំ អច្ចយតោ បដិគ្គណ្ហា ( តុ / តុ / ន្តុ / តុ )**

## អោយតី សំវរាយ ។

(*) បុរសច្រើននាក់ត្រូវសូត្រថា **យថាពាលេ**, **យថាមុឡ្ហេ**, **យថាអកុសលេ**,**អករិម្ហាតេសំ**
(*) ស្ត្រីច្រើននាក់ត្រូវសូត្រថា **យថាពាលា**, **យថាមុឡ្ហា**, **យថាអកុសលា**, **អករិម្ហាតាសំ**

***ប្រែថា*** បពិត្រព្រះ( ដ៏មានព្រះភាគ / ករុណា / ករុណាទាំងឡាយ / សង្ឃ ) ដ៏ចំរើន ទោសកំហុសដែលប្រព្រឹត្តកន្លងគ្របសង្កត់ហើយនូវខ្ញុំព្រះករុណាទាំងឡាយ តាមដោយខ្ញុំព្រះករុណាទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះ ( ដ៏មានព្រះភាគ / ករុណា / ករុណាទាំងឡាយ / សង្ឃ ) ដ៏ចំរើន ! ក្រែងខ្ញុំព្រះករុណាទាំងឡាយបានធ្វើហើយនូវសេចក្តីល្មើសមិនគោរពដល់ព្រះ ( ដ៏មានព្រះភាគក្តី / ព្រះពុទ្ធជាម្ចាស់ ) ក្តី , ព្រះធម៌ក្តី, ដល់ព្រះសង្ឃក្តី, ដោយកាយក្តី, ដោយវាចាក្តី, ដោយចិត្តក្តី បពិត្រព្រះ ( ដ៏មានព្រះភាគ / ករុណា / ករុណាទាំងឡាយ / សង្ឃ ) ដ៏ចំរើនសូមព្រះ ( ដ៏មានព្រះភាគ / ករុណា / ករុណាទាំងឡាយ / សង្ឃ ) អត់នូវទោសកំហុសនោះដល់ខ្ញុំព្រះករុណាទាំងឡាយព្រោះ អំពើនៃទោសនោះជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងបានប្រព្រឹត្តឲ្យល្អតទៅក្នុងខាងមុខនោះហោង ។

រួចបុគ្គល ឬគណៈ ឬសង្ឃ ត្រូវទទួលថា ៖ **សាធុ**, **សាធុ**, **សាធុ** ។ ***ប្រែថា*** ប្រពៃហើយ, ប្រពៃហើយ, ប្រពៃហើយ ។

**( ពាក្យពន្យល់អំពីការសូត្របាលីសូមខមាទោសត្រូវមើលគិហិប្រតិបត្តិ )**

**ស**. ចុះវិធីថ្វាយខ្លួនជាឧបាសកឬឧបាសិកានោះតើដូចម្តេច ?

**ច**. វិធីប្តេជ្ញាថ្វាយខ្លួននោះ គប្បីបញ្ចេញវចីភេទពោលប្តេជ្ញាខ្លួនថា ជាអ្នកបានដល់ព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក ដើម្បីឲ្យបានឡើងជា នាមបញ្ញត្តិ ឧបាសក ឬជាឧបាសិកាក្នុងព្រះពុទ្ធសាសនាតទៅ ។

ឯការប្តេជ្ញាខ្លួននោះ នឹងប្តេជ្ញាក្នុងទីចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះមុខបុគ្គល ឬគណៈ ឬសង្ឃក៏បាន ។ បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ហើយសូត្រប្តេជ្ញាខ្លួនចំពោះមុខបុគ្គល ឬគណៈ ឬសង្ឃនោះ ត្រូវប្តេជ្ញាដោយពាក្យថា ៖

- **បុរស ( ស្ត្រី )* ម្នាក់ឯងសូមប្តេជ្ញាខ្លួន**

**ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ( ឧបាសកំ / ឧបាសិកំ )* ( មំអយ្យោ / មំអយ្យា / មំសង្ឃោ )( ធារេតុ / ធារេន្តុ / ធារេតុ ) អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។**

( * ) បុរសត្រូវសូត្រថា **ឧបាសកំ**, ជាឧបាសក ។

( * ) ស្ត្រីត្រូវសូត្រថា **ឧបាសិកំ**, ជាឧបាសិកា ។

***ប្រែថា*** បពិត្រព្រះ ( ករុណា / ករុណាទាំងឡាយ / សង្ឃ ) ដ៏ចំរើន ! ខ្ញុំព្រះករុណាសូមដល់នូវព្រះមានព្រះភាគដែលទ្រង់បរិនិព្វានទៅអស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះ ( ករុណា / ករុណា

ទាំងឡាយ / សង្ឃ ) ជ្រាបនូវខ្ញុំព្រះករុណាថា ជា ( ឧបាសក / ឧបាសិកា )* បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹងទីរឭកស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។

រូបបុគ្គល ឬគណៈ ឬសង្ឃ ត្រូវទទួលថា ៖ **សាធុ**, **សាធុ**, **សាធុ** ***ប្រែថា*** ប្រពៃហើយ, ប្រពៃហើយ, ប្រពៃហើយ ។

បើគ្នាច្រើន ពី ២ នាក់ឡើងទៅ ទោះសុទ្ធតែបុរសក្តី សុទ្ធតែស្ត្រីក្តី ឬបុរសនិងស្ត្រីលាយគ្នាក្តី ឧបមាដូចជាភូមិមួយមានគ្នាច្រើនបុរសផង ស្ត្រីផងមានសេចក្តីជ្រះថ្លា នាំគ្នាទៅថ្វាយខ្លួនក្នុងទីមួយជាមួយគ្នា ដូចជាក្នុងសាលា ឬក្នុងវិហារត្រូវសូត្រតាមភេទរៀងៗ ខ្លួនថា ៖

- **បុរស ( ស្ត្រី )* ច្រើននាក់សូមប្តេជ្ញាខ្លួន**

**ឯតេ ( ឯតា )* មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ( ឧបាសកេ / ឧបាសិកាយោ )* នោ ( អយ្យោ / អយ្យា / សង្ឃោ ) ធារេ ( តុ / ន្តុ / តុ ) អជ្ជតគ្គេ បាណុបេ ( តេ / តា ) សរណំ ( គតេ / គតា ) ។**

(*) បុរសច្រើនគ្នាត្រូវថា ៖ **ឯតេ**, **ឧបាសកេនោ**, **គតេ** ។

(*) ស្ត្រីច្រើនគ្នាត្រូវថា ៖ **ឯតា**, **ឧបាសិកាយោនោ**, **គតា** ។

***ប្រែថា*** បពិត្រព្រះ ( ករុណា / ករុណាទាំងឡាយ / សង្ឃ )

ដ៏ចំរើន ! ខ្ញុំព្រះករុណាទាំងឡាយសូមដល់នូវព្រះមានព្រះភាគ ដែលទ្រង់បរិនិព្វានទៅអស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះ ( ករុណា / ករុណាទាំងឡាយ / សង្ឃ ) ជ្រាបនូវខ្ញុំព្រះករុណាទាំងឡាយថា ជាឧបាសក ( ឧបាសិកា )* បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹងទីរឭកស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។

បើបុរសតែម្នាក់ឬស្ត្រីតែម្នាក់ ហើយសូត្រប្តេជ្ញាខ្លួនចំពោះព្រះពុទ្ធរូប ព្រះសថូប ព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះដ៏មានបុណ្យនោះត្រូវពោលប្តេជ្ញាដោយពាក្យថា ៖

**ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ( ឧបាសកំ / ឧបាសិកំ )* មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។**

( * ) បុរសត្រូវសូត្រថា **ឧបាសកំ**, ជាឧបាសក ។
( * ) ស្ត្រីត្រូវសូត្រថា **ឧបាសិកំ**, ជាឧបាសិកា ។

***ប្រែថា*** បពិត្រព្រះមានព្រះភាគដ៏ចំរើន ! ខ្ញុំព្រះករុណាសូមដល់នូវព្រះមានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះមានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថា ជា ( ឧបាសក / ឧបាសិកា )* បានដល់ហើយនូវព្រះរតនត្រ័យជា ទីពឹងទីរឭកស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។

វិធីសូមខមាទោសក្តី វិធីប្តេជ្ញាខ្លួនជាឧបាសក ឧបាសិកាក្តីបើអ្នកដែលមិនចេះសូត្រជាបាលី នឹងសូត្រជាសេចក្តីសម្រាយតាមភាសាខ្លួនក៏បាន បើចេះសូត្រទាំងបាលីទាំងសេចក្តីសម្រាយផង ដូចបានពោលមកហើយនោះជាការប្រពៃពិត តែកុំសូត្រតែបាលីទទេដោយមិនដឹងសេចក្តីថាជាអ្វីនោះឡើយ ព្រោះកិច្ចដែលសូត្រខមាទោសនិងប្តេជ្ញាខ្លួននេះ ចំពោះយកសទ្ធាគឺសេចក្តីជឿជាក់ និងបញ្ញាជាសម្មាទិដ្ឋិដែលដឹងពិត យល់ត្រូវពិតជាប្រមាណ ។

## ( ចប់វិធីថ្វាយខ្លួនតែប៉ុណ្ណោះ )

**ស**. បើមិនបានខមាទោស និងថ្វាយខ្លួនទេចូលទៅសូមសីលតែម្តង តើឡើងជាឧបាសក ឬឧបាសិកាឬទេ ?

**ឆ**. បើមិនបានខមាទោស និងថ្វាយខ្លួនទេនោះ នឹងថាឡើងជាឧបាសក ឬឧបាសិកាមិនបានទេ ព្រោះមិនបានប្តេជ្ញាខ្លួននិងជម្រះទោសឲ្យស្អាតជាមុន គ្មានអ្វីជាសំគាល់ ព្រះសង្ឃនឹងមិនហ៊ានទូន្មានប្រៀនប្រដៅច្បាប់ធម៌វិន័យព្រោះគេមិនបានថ្វាយខ្លួន, ឧបមាដូចភិក្ខុ - សាមណេរ ដែលបានប្រឡងជាប់មានឋានៈជាកូនសិស្សពេញទី រមែងមានសេចក្តីកោតខ្លាចយកចិត្តទុកដាក់ក្នុងការរៀនសូត្រជាងសិស្សដែលគ្រាន់តែសុំស្តាប់ក្នុងថ្នាក់ជាមួយព្រោះយល់ឃើញថា ខ្លួនមិនមែនជាសិស្សទៅស្តាប់ក៏បានមិនទៅ

ក៏បាន ។ អំពើដែលដាក់ខ្លួនឲ្យថយចុះ ហើយបន្ទូរបន្ថយសេចក្ដីព្យាយាមដូច្នេះ ជាហេតុឲ្យថយចំណេះវិជ្ជាមិនចេះចាំច្បាស់លាស់ឡើយ យ៉ាងណា ឧបាសក ឧបាសិកា ដែលសមាទានសីល មិនបានខមាទោសថ្វាយខ្លួនក៏យ៉ាងនោះដែរ ។

**ស**. ចុះដូចរឿងពីដើមមកជាច្រើន តួយ៉ាងអរិយបុរសដែលស្ទួចត្រីជួបនឹងព្រះអង្គ បានស្តាប់ធម៌ក៏បានសម្រេចសោតាបត្តិ-ផល ក្នុងពេលនោះទៅ មានឮថាថ្វាយខ្លួនពីណា ?

**ច**. រឿងនោះមិនដូច្នោះទេ ព្រោះបុគ្គលចែកចេញជាពីរពួក គឺ ៖ **ឧគ្ឃដិតញ្ញូបុគ្គល** បុគ្គលស្តាប់ធម៌ឆាប់បានសម្រេច, ដ្បិតមាននិស្ស័យចាស់ក្លាមិនបាច់ថ្វាយខ្លួនជាឧបាសក ឧបាសិកាក៏សម្រេចមគ្គផលបាន ។ ចំណែកយើងសព្វថ្ងៃនេះជា **នេយ្យបុគ្គល** ជាបុគ្គលដែលត្រូវអ្នកប្រាជ្ញទូន្មានទើបប្រព្រឹត្តល្អបាន ហេតុដូច្នេះ ត្រូវថ្វាយខ្លួនទើបគួរ ។

**ស**. **អាជីវៈ** ការចិញ្ចឹមជីវិតរបស់ឧបាសក ឧបាសិកានោះ តើដូចម្ដេចខ្លះ ?

**ច**. **អាជីវៈ** ការចិញ្ចឹមជីវិតរបស់ឧបាសក ឧបាសិកានោះ ត្រូវវៀរនូវ « **មិច្ឆាជីវៈ** » គឺជំនួញខុស ៥ ប្រការ ។

**ស**. ជំនួញខុស ៥ ប្រការនោះគឺជំនួញអ្វីខ្លះ ? ចូររាប់ និងអធិប្បាយ ?

**ច**. ជំនួញខុស ៥ ប្រការនោះគឺ ៖ សត្ថវណិជ្ជា ១, សត្តវណិជ្ជា ១, មំសវណិជ្ជា ១, មជ្ជវណិជ្ជា ១, វិសវណិជ្ជា ១ ។

• **សត្ថវណិជ្ជា** ជួញគ្រឿងសស្ត្រាវុធ[១]បានជាមិនឲ្យជួញ ព្រោះជាហេតុនាំឲ្យសម្លាប់សត្វ ;

• **សត្តវណិជ្ជា** ជួញសត្តគឺមនុស្ស គឺចាប់មនុស្សលក់ បានជាមិនឲ្យជួញព្រោះមនុស្សមានជាតិស្មើគ្នា មិនគួរឲ្យគ្នាថោកទាប ;

• **មំសវណិជ្ជា** ជួញសាច់គឺ ចិញ្ចឹមជ្រូកមាន់ទាជាដើម យកសាច់លក់ ឬលក់ទាំងរស់ ឬមួយយកគោទៅលក់ឲ្យអ្នកសម្លាប់ក៏ឈ្មោះថា មំសវណិជ្ជា ទាំងអស់ ;

• **មជ្ជវណិជ្ជា** ជួញទឹកស្រវឹង គឺសុរា និងមេរ័យបានជាមិនឲ្យជួញ ជាហេតុឲ្យមនុស្សផឹកខូចសតិស្មារតី ;

• **វិសវណិជ្ជា** ជួញថ្នាំពិស គឺថ្នាំសម្រាប់បំពុលឲ្យគេស្លាប់ ។

**ជំនួញ ៥** ប្រការនេះឧបាសក ឧបាសិកាមិនគួរជួញឡើយ ។

**ស.** វិបត្តិរបស់ ឧបាសក ឧបាសិកាមានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ឆ.** វិបត្តិរបស់ ឧបាសក ឧបាសិកាមាន ៥ យ៉ាងគឺ ៖

**១. អស្សទ្ធោ ហោតិ** ឧបាសក ឧបាសិកាមិនមានសទ្ធា មិនជឿគុណព្រះរតនត្រ័យ ;

**២. ទុស្សីលោ ហោតិ** ឧបាសក ឧបាសិកាទ្រុស្តសីល ;

**៣. កោតុហល មង្គលិកោ ហោតិ** ឧបាសក ឧបាសិកា

---

(១) សស្ត្រាបានដល់គ្រឿងផ្ទាល់ដៃមានដាវជាដើម, អាវុធ គឺគ្រឿងប្រយោលមានកាំភ្លើងជាដើម ។

ជាអ្នកប្រកាន់នូវមង្គលភ្ញាក់ផ្អើលជ្រួលជ្រើម ;

**៤. មង្គលំ បច្ចេតិ នោ កម្មំ** ឧបាសក ឧបាសិកាជឿសិរីសួស្ដីមិនជឿផលកម្ម ;

**៥. ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ** ឧបាសក ឧបាសិកាស្វែងរកទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈអ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនា ;

**ស.** អស្សទ្ធោ ឧបាសក ឧបាសិកាមិនមានសទ្ធា, ហេតុអ្វីក៏កើតជាឧបាសក ឧបាសិកាដែរ ? ព្រោះឧបាសក ឧបាសិកាមានសទ្ធាជាឫសគល់ ?

**ឆ.** កាលពីដើមមានសទ្ធាមែន ប៉ុន្តែមកខាងក្រោយត្រឡប់ទៅជាមិនមានសទ្ធាវិញ បានចាត់ថាជាមានវិបត្តិ ។

**ស.** តើទុស្សីលនោះមានន័យដូចម្ដេច ?

**ឆ.** ទុស្សីល គឺសំដៅយកមនុស្សដែលមិនមានសីលពីដើមមកក្ដី មានសីលហើយដាច់ទៅវិញក្ដី ហៅថា ទុស្សីលទាំងអស់ ។ ទុស្សីល ចេញទៅជា «**និស្សីលោ**»ឬ«**អសីលោ**» ប្រែថា «**មនុស្សមិនមានសីល**» ។

**ស.** តើជឿនូវមង្គលភ្ញាក់ផ្អើលនោះ មានន័យដូចម្ដេច ?

**ឆ.** ជឿនូវមង្គលភ្ញាក់ផ្អើលនោះ គឺមានឮដំណឹងថាព្រះផុស ឬហេតុអ្វីផ្សេងៗដែលមិនពិត មានទិដ្ឋិមង្គលជាដើម ។

**ស.** ជឿមង្គលសិរីសួស្ដីមិនជឿផលកម្មនោះ តើមានន័យដូចម្ដេច ?

**ច**. ជឿមង្គលសិរីសួស្តីមិនជឿផលកម្មនោះគឺដូច្នេះ គឺប្រកាន់ចន្ទគ្គាហៈ ប្រកាន់ថាខែនេះល្អ ខែនេះអាក្រក់ជាដើម, សុរិយគ្គាហៈ ប្រកាន់ថ្ងៃលិចថ្ងៃអណ្តែតជាដើម ឬជឿភូមិករឲ្យសុខទុក្ខជាដើម មិនជឿកម្មផលរបស់កម្មទេ ។

**ស**. ដូចម្តេចស្វែងរកទក្ខិណេយ្យបុគ្គល ក្រៅពីព្រះពុទ្ធសាសនា ? ចូរតបឲ្យយ៉ាងខ្លីមកមើល !

**ច**. ស្វែងរកទក្ខិណេយ្យបុគ្គលក្រៅពីព្រះពុទ្ធសាសនានោះ គឺស្វែងរកនិគ្រន្ថអន្យតិរ្ថិយ ដែលតាំងខ្លួនជាទក្ខិណេយ្យបុគ្គលផ្ទឹមនឹងព្រះពុទ្ធសាសនា បើអ្នកណាឲ្យវត្ថុអ្វីៗ លុះត្រាតែប្រគល់ដល់ហត្ថបាសត្រឹមត្រូវទើបទទួល ហេតុដូច្នេះ ហើយបានជាមានក្នុងអចេលក៏សិក្ខាបទ ហាមមិនឲ្យភិក្ខុឲ្យវត្ថុដល់ពួកអចេលក៏ បើភិក្ខុណាឲ្យ ភិក្ខុនោះនឹងត្រូវអាបត្តិបាចិត្តិយ ហេតុដូច្នេះបានជាឧបាសក ឧបាសិកាស្វែងរក ចាត់ជាវិបត្តិព្រោះមិនមែនជាអ្នកបួសក្នុងព្រះពុទ្ធសាសនា ។

បើឧបាសក ឧបាសិកាណាប្រកបដោយវិបត្តិទាំង ៥ យ៉ាងនេះណាមួយឈ្មោះថា **ចណ្ឌាលឧបាសក** ( **ឧបាសកខូចកាច** ), **មលឧបាសក** ( **ឧបាសកមានធម៌ជាមន្ទិល** ), **បដិកិដ្ឋឧបាសក** ( **ឧបាសកដែលព្រះពុទ្ធទ្រង់តិះដៀល** ) ។

**ស**. សម្បត្តិឧបាសកនោះដូចម្តេច ? មានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ច**. សម្បត្តិឧបាសកនោះ បានដល់ការដល់ព្រមដោយសីល និងអាជីវៈមាន ៥ យ៉ាងគឺ ៖

**១. សទ្ធោ ហោតិ** ឧបាសកមានសទ្ធា, មានសេចក្តីជឿគុណព្រះរតនត្រ័យ ;

**២. សីលវា ហោតិ** ឧបាសកមានសីល ;

**៣. ន កោតុហលមង្គលិកោ ហោតិ** ឧបាសកមិនប្រកាន់មង្គលភ្ញាក់ផ្អើល ;

**៤. កម្មំ បច្ចេតិ នោ មង្គលំ** ឧបាសកជឿតែផលកម្មមិនជឿមង្គលសិរីសួស្តី ;

**៥. ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ** ឧបាសក មិនស្វែងរកទក្ខិណេយ្យបុគ្គលក្រៅពីព្រះពុទ្ធសាសនា ធ្វើសេចក្តីគោរពតែក្នុងព្រះពុទ្ធសាសនា ។

បើឧបាសក ឧបាសិកាណាប្រកបដោយសម្បត្តិ ៥ យ៉ាងនេះឈ្មោះថា **រតនឧបាសក** ( ឧបាសកកែវ ) **បទុមឧបាសក** ( ឧបាសកដូចផ្កាឈូក ) **បុណ្ឌរិកឧបាសក** ( ឧបាសកដូចជាផ្កាឈូកស ) ឈ្មោះទាំង ៣ នេះកើតឡើងដោយអំណាចគុណធម៌ដូចបានពណ៌នាមកហើយខាងដើមនេះ ។

**ស.** អ្វីជាតួសីល ?

**ឆ.** ចេតនាជាតួសីល ពុទ្ធភាសិតថា ៖

**ចេតនាហំ ភិក្ខវេសីលំ វទាមិ**

» ម្នាលភិក្ខុទាំងឡាយ ! តថាគតពោលថា ចេតនាជាតួសីល

**ស.** ចេតនា មានប៉ុន្មានយ៉ាង ?

**ឆ.** ចេតនាមាន ៣ យ៉ាង ។

**ស**. មាន ៣ យ៉ាងនោះគឺអ្វីខ្លះ ? ចូររាប់និងអធិប្បាយ !

**ច**. មាន ៣ យ៉ាងនោះគឺ ៖ សម្បត្តិវិរតិចេតនា ១, សមាទានវិរតិចេតនា ១, សមុច្ឆេទវិរតិចេតនា១ ។

អធិប្បាយថា :

• **សម្បត្តិវិរតិចេតនា** វៀរចំពោះវត្ថុដល់ព្រមគឺសត្វគួរនឹងសម្លាប់ ក៏មិនហ៊ានសម្លាប់ ទ្រព្យគេគួរនឹងលួចយកបាន ក៏មិនហ៊ានលួចយកដូច្នេះជាដើម គឺមិនហ៊ានប្រព្រឹត្តកន្លងខ្លាចមានពៀរវេរាទៅខាងមុខដូច្នេះឈ្មោះថា សម្បត្តិវិរតិចេតនា ។

• **សមាទានវិរតិចេតនា** នោះគឺវៀរដោយសមាទានអំពីសំណាក់ ភិក្ខុសាមណេរ ឬគ្រហស្ថដែលគេបានសមាទានពីមុនមកហើយសមាទានតពីគេមកទៀត ហើយប្រព្រឹត្តតាមសិក្ខាបទដែលខ្លួនសមាទាននោះឈ្មោះថា សមាទានវិរតិចេតនា ។

• **សមុច្ឆេទវិរតិចេតនា** នោះគឺវៀរដោយការផ្តាច់បង់នូវកិលេសជាមួយនឹងអរិយមគ្គដែលកើតឡើង សីលក៏កើតព្រមក្នុងពេលនោះកិលេសក៏អស់ទៅដូច្នេះឈ្មោះថាសមុច្ឆេទវិរតិចេតនា ។

**ស**. វិធីសមាទាននោះមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ច**. សមាទាននោះមានពីរយ៉ាងគឺ សមាទាននិច្ចសីល ១, សមាទានឧបោសថសីល ១ ។

**ស**. សមាទាននិច្ចសីលដូចម្តេច ?

**ច**. សមាទាននិច្ចសីលនោះដូច្នេះ ៖

# វិធីសមាទាននិច្ចសីល

( សំរាប់សមាទានគ្នាច្រើន * )

**ឧកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ បញ្ច សីលានិ យាចាម ។**
**ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ បញ្ច សីលានិ យាចាម ។**
**តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ បញ្ច សីលានិ យាចាម ។**

*ប្រែថា* សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ។

បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា, ជាគំរប់ ២ ដងផង, ជាគំរប់ ៣ ដងផង។

# វិធីសមាទាននិច្ចសីល

( សំរាប់សមាទានម្នាក់ឯង )

**ឧកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ បញ្ច សីលានិ យាចាមិ ។**

**ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាមិ ។**
**តតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាមិ ។**

*ប្រែថា* សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ។

បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, ជាគំរប់ ២ ដងផង, ជាគំរប់ ៣ ដងផង ។

ឬសូមថា ៖

# វិធីសមាទាននិច្ចសីល

## ( សំរាប់សមាទានម្នាក់ឯង )

**ឧកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។**
**ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ**

**យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។**
**តតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ**
**យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។**

*ប្រែថា* សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណា សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ។

បពិត្រព្រះករុណាដ៏ចម្រើន ! សូមព្រះករុណា ធ្វើនូវសេចក្ដីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះករុណា បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណាសូមនូវនិច្ចសីលប្រកបដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា, ជាគំរប់ ២ ដងផង, ជាគំរប់ ៣ ដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ! សូមព្រះករុណា ធ្វើនូវសេចក្ដីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះករុណា ។

# វិធីសមាទាននិច្ចសីល

**( សំរាប់សមាទានគ្នាច្រើន )**

**ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ**
**យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។**
**ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**

**តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ**
**យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។**
**តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ**
**យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។**

***ប្រែថា*** សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណាទាំងឡាយ សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ។

បពិត្រព្រះករុណាដ៏ចម្រើន ! សូមព្រះករុណា ធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណាទាំងឡាយ សូមនូវនិច្ចសីលប្រកបដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា, ជាគំរប់ ២ ដងផង, ជាគំរប់ ៣ ដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ! សូមព្រះករុណា ធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

សូមដូច្នេះក៏បានតាមសេចក្តីពេញចិត្តរបស់អ្នកសូម ។

បើអ្នកសមាទានតែម្នាក់ត្រូវថា **អហំ**, **យាចាមិ** ហើយត្រង់ប្រែត្រូវថាខ្ញុំព្រះករុណាសូម, ថា **មេ** ត្រូវប្រែថា ដល់ខ្ញុំព្រះករុណា

បើគ្នាច្រើនតាំងពីពីរនាក់ឡើងទៅ ត្រូវសូត្រថា **មយំ**, **យាចាម** ត្រង់ប្រែត្រូវថា ខ្ញុំព្រះករុណាទាំងឡាយ, ថា **នោ** ត្រង់ប្រែថា ដល់យើងខ្ញុំព្រះករុណាទាំងឡាយ ។ បើគ្នាច្រើនសូត្រព្រមទាំងអស់គ្នា លុះសូមដូច្នេះរួចហើយលោកអ្នកឲ្យសីល លោកសូត្រ **នមោ** ៣ចប់ហើយ លោកឲ្យព្រះត្រៃសរណគមន៍និងនិច្ចសីល ។

**អ្នកសមាទានសីលត្រូវទទួលថាតាមលោកដោយបញ្ចេញវចីភេទឲ្យឮច្បាស់លាស់កុំទទួលខ្សឹបៗ ដែលលោកប្រទានដូចតទៅ៖**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**
**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**
**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

*ប្រែថា* រីកិរិយានមស្ការថ្វាយបង្គំ នៃខ្ញុំព្រះករុណាចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭកជាគំរប់ ២ ដងផង ។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭកជាគំរប់ ២ ដងផង ។

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭកជាគំរប់ ២ ដងផង ។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭកជាគំរប់ ៣ ដងផង ។

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭកជាគំរប់ ៣ ដងផង ។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭកជាគំរប់ ៣ ដងផង ។

- ហើយព្រះសង្ឃអ្នកប្រទានសីលពោលថា ៖

**តិសរណគ្គហណំ បរិបុណ្ណំ** *ប្រែថា* កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍បរិបូណ៌តែប៉ុណ្ណេះ ។

អ្នកសមាទានសីលត្រូវទទួលថា ៖ **អាម ភន្តេ** *ប្រែថា* ខ្ញុំព្រះករុណាលោកម្ចាស់ ។

- ហើយព្រះសង្ឃឲ្យនិច្ចសីល ជាបច្ចេកសមាទានថា ៖

**១. បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ

វៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**២. អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ។

**៣.កាមេសុ មិច្ឆាចារា វេរមណីសិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**៤. មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

**៥. សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តី ប្រមាទគឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

- រួចហើយបព្វជិតលោកអ្នកឲ្យសីល លោកពោលដាស់តឿនក្រើនរំឭកថា ៖

**ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា**
**អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។**

***ប្រែថា*** អ្នក, (អ្នកទាំងឡាយ)* គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះឲ្យប្រពៃ ត្រូវរក្សាឲ្យល្អអស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

* បើអ្នកសមាទានតែម្នាក់ឯង ត្រូវថា «**អ្នក**» បើគ្នាច្រើនត្រូវថា «**អ្នកទាំងឡាយ**» ។

អ្នកសមាទានត្រូវទទួលថា ៖ **អាម ភន្តេ** ***ប្រែថា*** ខ្ញុំព្រះករុណាលោកម្ចាស់ ។

- ព្រះសង្ឃ លោកសំដែងអានិសង្សសីលឲ្យស្តាប់តទៅទៀតថា ៖

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**
**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

***ប្រែថា*** សត្វទាំងឡាយបានទៅកាន់ស្ថានសួគ៌ក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈក៏ព្រោះសីល សត្វទាំង - ឡាយបានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វានក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរសគប្បីជម្រះនូវសីលឲ្យបរិសុទ្ធកុំឲ្យសៅហ្មង ។

អ្នកសមាទានត្រូវទទួលថា ៖ **សាធុ, សាធុ, សាធុ** ។
***ប្រែថា*** ប្រពៃហើយ, ប្រពៃហើយ, ប្រពៃហើយ ។

( **វិធីសមាទាននិច្ចសីលជាបច្ចេកសមាទានចប់តែប៉ុណ្ណោះ** )

**ស**. ឧបាសក ឧបាសិកា បើជិតដល់ថ្ងៃរក្សាឧបោសថសីលហើយមានកិច្ចធ្វើដូចម្ដេចខ្លះ ?

**ឆ**. ឧបាសក ឧបាសិកា កាលបើជិតដល់ថ្ងៃរក្សាឧបោសថសីលហើយត្រូវរៀបចំចាត់ចែងនូវវត្ថុផ្សេងៗ ដែលមិនប្រកបដោយទោស លុះដល់ថ្ងៃឧបោសថត្រូវអធិដ្ឋានមុន ក្រែងជ្រុលពេល ។ ដើម្បីតាំងចិត្តជាមុនថាអញនឹងសមាទានឧបោសថក្នុងថ្ងៃនេះដូចពាក្យថា ៖

- **សំរាប់ឧបាសក**

**អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច**
**ទិវសំ ឧបោសថិកោ ភវិស្សាមិ ។**

*ប្រែថា* ថ្ងៃនេះជាថ្ងៃរក្សានូវឧបោសថសីល ខ្លួនអញនឹងជាអ្នករក្សានូវឧបោសថ អស់ថ្ងៃនេះនិងយប់នេះ ។

- **សំរាប់ឧបាសិកា**

**អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច**
**ទិវសំ ឧបោសថិកា ភវិស្សាមិ ។**

*ប្រែថា* ថ្ងៃនេះជាថ្ងៃរក្សានូវឧបោសថសីល ខ្លួនអញនឹងជាអ្នករក្សានូវឧបោសថ អស់ថ្ងៃនេះនិងយប់នេះ ។

បើមិនចេះបាលី នឹងអធិដ្ឋានតាមភាសារបស់ខ្លួន ។ ក៏គួរដោយពិត លុះអធិដ្ឋានកំណត់ដូច្នេះរួចហើយត្រូវតាំងវិរតិចេតនា

( ចេតនាដែលវៀរ, ដែលតមដាច់ខាត ) វៀរចាកសីលភេទគឺហេតុដែលជាទីទំលាយនៃសីលនោះៗ ឲ្យគ្រប់សិក្ខាបទទាំង ៨ កាលបើបានអធិដ្ឋានដូចនេះរួចហើយ តពីពេលនោះមកក៏គប្បីសមាទាននូវឧបោសថសីលអំពីបុគ្គលដទៃ មានភិក្ខុជាដើមតាមកាលដ៏គួរចុះ បើទុកជាដល់ពេលព្រះអាទិត្យរះឡើងប្រមាណពេញពន្លឺធំទើបបាន សមាទានក្តីក៏ឈ្មោះថាបានសមាទានដោយប្រពៃ ឈ្មោះថាបានរក្សានូវឧបោសថសីលពេញកាលកំណត់ ១ ថ្ងៃ ១ យប់ដោយបរិបូណ៌, ព្រោះអ្នកសមាទានបានធ្វើនូវឧបោសថកាលមិនឲ្យខ្វះខាត ទាំងវិរតិចេតនាសោត ក៏កើតបរិបូណ៌ក្នុងសន្តាននឹងបានផលានិសង្សច្រើន ។

**ស**. ដូចម្តេចហៅថា សីលភេទ ?

**ឆ**. ដែលហៅថា សីលភេទគឺដូច្នេះ ឧបាសក ឧបាសិកាមុនពេលដែលនឹងសមាទានឧបោសថឲ្យដាច់សីលត្រង់ណាមួយក្នុងថ្ងៃឧបោសថនោះ ដូចជាដេកលើគ្រែឬពូកជ្រុលដល់អរុណរះឡើងវិញទើបភ្ញាក់ ឬសិក្ខាបទដទៃៗ លើកលែងតែ «**វិកាល**» មួយចេញព្រោះវិកាលកំណត់ពីថ្ងៃជ្រេពីត្រង់ទៅដូច្នេះឈ្មោះថា **សីលភេទ** ។

សិក្ខាបទទាំង ៧ រាប់តាំងពីព្រលឹមទៅ ចំណែក «**វិកាល**» រាប់ពីថ្ងៃជ្រេទៅ ធ្លាយសិក្ខាបទណាហើយសមាទានមិនឡើងជាឧបោសថទេ ។

**ស**. ឧបាសក ឧបាសិកា បើសមាទានឧបោសថហើយត្រឡប់មកសមាទាននិច្ចសីលវិញជាមួយនឹងគេវិញតើគួរឬមិនគួរ ?

**ច**. មិនគួរទេ, ព្រោះខ្លួនបានសមាទានឧបោសថសីលជាសីលជាន់ខ្ពស់រួចហើយ ត្រឡប់ទៅសមាទាននិច្ចសីលៗនោះសមាទានថ្ងៃណាក៏បាន ឥតមានកំណត់ទេ បើគ្រាន់តែទទួលសរណគមន៍គួរ ។

**ស**. ឧបោសថ នឹងឡើងប្រកបដោយអង្គប៉ុន្មាន ?

**ច**. ឧបោសថ នឹងឡើងប្រកបដោយអង្គ ៣ ។

**ស**. អង្គ ៣ គឺអ្វីខ្លះ ? ចូររៀបរាប់ និងអធិប្បាយ !

**ច**. អង្គ ៣ នោះគឺ កាល ១ , វចីភេទ ១ , ចេតនា ១ ។

អធិប្បាយថា ៖

- **កាល** នោះដែលព្រះអង្គទ្រង់កំណត់ គឺថ្ងៃខាងខ្នើត ៣, អដ្ឋមី ១, ចាតុទ្ទសី ១, បណ្ណរសី ១, រនោចដូចគ្នា, អដ្ឋកថា ថែមថ្ងៃបញ្ចមីទាំងពីរមកទៀត ឈ្មោះថា ថ្ងៃបកតិឧបោសថ ។
- **វចីភេទ** នោះ ត្រូវបញ្ចេញវាចាសូត្រឲ្យឮខ្លាំងមិនត្រូវសូត្រខ្សឹបៗទេ ។
- **ចេតនា** គឺចេតនាវៀរគ្រប់សិក្ខាបទនោះៗ បើប្រកបដោយអង្គទាំង ៣ នេះទើបឡើងជាឧបោសថ ។ កាលបើឧបាសក ឧបាសិកានឹងសមាទាននូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ ជាបច្ចេកសមាទានអំពីបុគ្គលដទៃគឺភិក្ខុ ឬសមណេរនោះគប្បីសូត្រ នមស្ការថ្វាយបង្គំរំឭកដល់គុណព្រះរតនត្រ័យដោយសង្ខេបជាមុន រួចហើយត្រូវសូត្រសូមឧបាសថសីលព្រមទាំងព្រះត្រៃសរណគមន៍ចំពោះនឹងភិក្ខុ ឬសមណេរថា ៖

# វិធីសមាទានឧបោសថសីល

**( សំរាប់សមាទានគ្នាច្រើន )**

**ឧកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ អដ្ឋ សីលានិ យាចាម ។**
**ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ អដ្ឋ សីលានិ យាចាម ។**
**តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ អដ្ឋ សីលានិ យាចាម ។**

*ប្រែថា* សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ។

បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណាទាំងឡាយសូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគំរប់ ២ ដងផង, ជាគំរប់ ៣ ដងផង ។

# វិធីសមាទានឧបោសថសីល

**( សំរាប់សមាទានម្នាក់ឯង )**

**ឧកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ អដ្ឋ សីលានិ យាចាមិ ។**
**ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**

**តិសរណេន សហ អដ្ឋ សីលានិ យាចាមិ ។**
**តតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ អដ្ឋ សីលានិ យាចាមិ ។**

*ប្រែថា* សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ។

បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគំរប់ ២ ដងផង, ជាគំរប់ ៣ ដងផង ។

ឬសូមថា ៖

# វិធីសមាទានឧបោសថសីល

**( សំរាប់សមាទានគ្នាច្រើន )**

**ឧកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ**
**យាចាម អនុគ្គហំ កត្វា សីលំ ទេថនោ ភន្តេ ។**
**ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**
**តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ**
**យាចាម អនុគ្គហំ កត្វា សីលំ ទេថនោ ភន្តេ ។**

**តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម អនុគ្គហំ កត្វា សីលំ ទេថនោ ភន្តេ ។**

*ប្រែថា* សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីលប្រកបព្រម ដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគំរប់ ២ ដងផង, ជាគំរប់ ៣ ដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីល ដល់ខ្ញុំព្រះករុណាទាំងឡាយ ។

# វិធីសមាទានឧបោសថសីល

**( សំរាប់សមាទានម្នាក់ឯង )**

**ឧកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថមេ ភន្តេ ។**

**ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថមេ ភន្តេ ។ តតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថមេ ភន្តេ ។**

*ប្រែថា* សូមគោរព, ព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណា សូមនូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្ដីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះករុណា ។

បពិត្រព្រះករុណាដ៏ចម្រើន ! ខ្ញុំព្រះករុណា សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគំរប់ ២ ដងផង, ជាគំរប់ ៣ ដងផង បពិត្រព្រះករុណាដ៏ចម្រើន ! សូមព្រះករុណាមេត្តាធ្វើនូវសេចក្ដីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះករុណា ។

ដូច្នេះក៏បាន តាមសេចក្ដីពេញចិត្តរបស់អ្នកសូម សេចក្ដីអធិប្បាយអំពីអ្នកសូមតែម្នាក់និងច្រើននាក់នោះ ដូចគ្នានឹងវិធីសូមនិច្ចសីលខាងដើមដែរ ។

រួចហើយ លោកអ្នកឲ្យសីល លោកសូត្រ នមោ ៣ ចប់

ហើយ លោកឲ្យព្រះត្រៃសរណគមន៍ រួចហើយលោកឲ្យនូវឧបោសថសីល ៖

**អ្នកសមាទានសីលត្រូវទទួលថាតាមព្រះសង្ឃ ដូចវិធីសមាទាននិច្ចសីលខាងដើម ដោយបញ្ចេញវចីភេទឲ្យឮច្បាស់លាស់កុំទទួលខ្សឹបៗ ដែលលោកប្រទានដូចតទៅ ៖**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**
**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**
**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

*ប្រែថា* វីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគំរប់ ២ ដងផង ។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគំរប់ ២ ដងផង ។

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគំរប់ ២ ដងផង ។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគំរប់ ៣ ដងផង ។

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគំរប់ ៣ ដងផង ។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគំរប់ ៣ ដងផង ។

➢ ហើយព្រះសង្ឃអ្នកប្រទានសីលពោលថា ៖

**តិសរណគ្គហណំ បរិបុណ្ណំ** *ប្រែថា* កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍បរិបូណ៌តែប៉ុណ្ណោះ ។

អ្នកសមាទានសីលត្រូវទទួលថា ៖ **អាម ភន្តេ** *ប្រែថា* ខ្ញុំព្រះករុណាលោកម្ចាស់ ។

➢ ហើយព្រះសង្ឃឲ្យនូវឧបោសថសីលជាបច្ចេកសមាទានថា ៖

**១. បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**២. អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេ មិនបានឲ្យដោយកាយឬដោយវាចា ។

**៣. អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្ត នូវធម៌មិនប្រសើរគឺសេពនូវមេថុនធម្ម ។

**៤. មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

**៥. សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

**៦. វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។

**៧. នច្ចគីត វាទិត វិសូកទស្សន មាលាគន្ធ វិលេបន ធារណ មណ្ឌន វិភូសនដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគុំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់ និងតាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

**៨. ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

រួចហើយអ្នកសមាទាន សូត្រកំណត់ឧបោសថកាលថា ៖

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។**

*ប្រែថា* ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីលដ៏ប្រកបដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឲ្យបរិបូណ៌ ប្រពៃអស់កាលកំណត់ថ្ងៃនេះនិងយប់នេះ សូមកុសលចូរជាឧបនិស្ស័យធ្វើឲ្យច្បាស់នូវព្រះនិព្វាន ពួដ៏អនាគតកាលទៅឯមុខនោះហោង ។

➢ រួចហើយបព្វជិត លោកអ្នកឲ្យសីល លោកពោលដាស់តឿនក្រើនរំលឹកថា ៖

**ឥមានិ អដ្ឋសិក្ខាបទានិ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។**

*ប្រែថា* អ្នក, ( អ្នកទាំងឡាយ ) គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឲ្យប្រពៃ ត្រូវរក្សាឲ្យល្អដោយអំណាចនៃឧបោសថសីលអស់ កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា ៖ **អាម ភន្តេ**
*ប្រែថា* ខ្ញុំព្រះករុណាលោកម្ចាស់ ។

➢ ហើយព្រះសង្ឃ លោកសំដែងអានិសង្សសីលឲ្យស្តាប់តទៅទៀតថា ៖

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

*ប្រែថា* សត្វទាំងឡាយបានទៅកាន់ស្ថានសួគ៌ក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈក៏ព្រោះសីល, សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខគឺព្រះនិព្វានក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរសគប្បីជម្រះនូវសីលឲ្យបរិសុទ្ធ កុំឲ្យ

សៅហ្មង ។

អ្នកសមាទានត្រូវទទួលថា ៖ **សាធុ**, **សាធុ**, **សាធុ** ។

***ប្រែថា*** ប្រពៃហើយ, ប្រពៃហើយ, ប្រពៃហើយ ។

**(វិធីសមាទានឧបោសថសីលជាបច្ចេកសមាទានចប់តែប៉ុណ្ណោះ)**

**ស**. អានិសង្សសីលឲ្យមានភោគសម្ប័ទ, ចុះថាទានមានភោគសម្ប័ទដែរ, តើមានសម្ប័ទផ្សេងគ្នាដូចម្ដេច ?

**ឆ**. អានិសង្សសីល និងអានិសង្សទានផ្សេងគ្នាដូចនេះ អានិសង្សសីលឲ្យមានភោគសម្ប័ទក្នុងជាតិនេះ ព្រោះប្រាសចាកអបាយមុខ ទ្រព្យដែលបានមកចេះតែគង់ មិនវិនាសទៅដោយហេតុណាមួយ បើរក្សាតែសីលបរិសុទ្ធ ប្រកបដោយមច្ឆរិយៈកំណាញ់មិនបរិច្ចាគទាន ដល់ទៅជាតិមុខមិនមានភោគសម្ប័ទទេ, បានតែរូបសម្ប័ទតែម្យ៉ាង, អានិសង្សទានក្នុងបច្ចុប្បន្ននេះទៅជា «**បិយោ**» ប្រកបដោយគេស្រឡាញ់ច្រើនទៅជាតិមុខទើបមានភោគសម្ប័ទ សេចក្ដីផ្សេងគ្នាដូចវិសជ្ជនាមកនេះ ។

**ស**. អានិសង្សសីល ត្រង់ភោគសម្បទា ចំណែកបព្វជិតថាមានភោគសម្ប័ទដែរ ចុះភោគសម្ប័ទដូចម្ដេច ?

**ឆ**. ភោគសម្បទា ចំណែកអ្នកបួសបើមានសីលបរិសុទ្ធហើយមានភោគសម្ប័ទ គឺអរិយទ្រព្យ ៧ និងឈានសមាបត្តិជាដើមនេះ ជាភោគសម្ប័ទរបស់អ្នកបួស ។

**ស**. អានិសង្សសីល ត្រង់ **និព្វុតឹ យន្តិ** អ្នករក្សាសីលបាន

ដល់ព្រះនិព្វាន, រក្សាសីលតែប៉ុណ្ណឹងទេឬ ? ឬមានធម៌ឯទៀតដែរ ?

**ច.** មិនមែនតែសីលប៉ុណ្ណឹងទេ មានច្រើនតទៅទៀត ប៉ុន្តែមានសីលជាមូលហេតុ បើមិនបានរក្សាសីលមុនទេ ទៅចម្រើនធម៌ឯទៀតក៏មិនបានសម្រេចដែរ ។

**ស.** គុណឧបាសក ឧបាសិកា មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ច.** គុណឧបាសក ឧបាសិកា មាន ១០ យ៉ាងគឺ ៖

**១. សង្ឃេន សទ្ធឹ សមានសុខទុក្ខោ ហោតិ** ឧបាសក ឧបាសិការួមសេចក្តីសុខទុក្ខមួយអន្លើដោយភិក្ខុសង្ឃ គឺថាបើភិក្ខុសង្ឃមានសេចក្តីសុខក៏ត្រេកអរ, បើភិក្ខុសង្ឃមានសេចក្តីទុក្ខ ក៏ទុក្ខជាមួយផង ;

**២. កាយិកវាចសិកញ្ច សុរក្ខិតំ ហោតិ** ឧបាសក ឧបាសិកាមានកាយកម្ម និងវចីកម្មរក្សាហើយដោយប្រពៃ ;

**៣. ធម្មោ អធិប្បតេយ្យោ ហោតិ** ឧបាសក ឧបាសិកាមានធម៌ជាធិបតី គឺថាកាលបើប្រព្រឹត្តធ្វើអ្វីៗ រមែងកាន់យកធម៌ជាធំជាទីតាំង ជាទីអាងមាំមួនមិនឲ្យឃ្លៀងឃ្លាតអំពីធម៌ឡើយ ;

**៤. យថាថាមេន សំវិភាគរតោច ហោតិ** ឧបាសក ឧបាសិកាជាអ្នកត្រេកអរក្នុងការបរិច្ចាគទានតាមសមគួរដល់កម្លាំងនៃខ្លួន ធ្វើទានតាមសមគួរដល់ទ្រព្យតិចនិងច្រើន បើមានតិចក៏ធ្វើតិច បើមានច្រើនក៏ធ្វើច្រើន មិនមានមច្ឆរិយធម៌គ្របសង្កត់សន្តានចិត្តឡើយ ;

**៥. ជិនសាសនំ ជានិតុញ្ច វាយមតិ** ឧបាសក ឧបាសិកា

ឧស្សាហ៍ព្យាយាម ដើម្បីនឹងឲ្យដឹងច្បាស់នូវសាសនៈ គឺពាក្យប្រៀនប្រដៅ ពាក្យបណ្តាំនៃព្រះជិនស្រី ;

**៦. សម្មាទិដ្ឋិកោ ច ហោតិ** ឧបាសក ឧបាសិកាជាសម្មាទិដ្ឋិ គឺមានប្រាជ្ញាឃើញត្រូវតាមសេចក្តីពិត ;

**៧. អបគតោ កោតុហលមង្គលិកោ ច ហោតិ** ឧបាសក ឧបាសិកាប្រាសចាកមង្គលភ្ញាក់ផ្អើល ហើយជាអ្នកមិនប្រកាន់ជឿថាមង្គលមានឫក្សពារវេលាជាដើមឲ្យផលឡើយ ប្រកាន់ជឿតែកម្មជាកុសល និងអកុសលថាឲ្យផល ;

**៨. ជីវិតហេតុបិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ** ឧបាសក ឧបាសិកាបើទុកជាមានហេតុគួរដល់នូវសេចក្តីវិនាសជីវិតក្តី ក៏មិនលះបង់ព្រះរតនត្រ័យ ហើយត្រឡប់ទៅកាន់យកមនុស្សដទៃជាគ្រូអាចារ្យជាទីពឹងរបស់ខ្លួនថា ប្រសើរជាងព្រះរតនត្រ័យនោះឡើយ ;

**៩. សមគ្គារាមោច ហោតិ** ឧបាសក ឧបាសិកា មានសេចក្តីត្រេកអរក្នុងសាមគ្គីធម៌ គឺសេចក្តីព្រមព្រៀងគ្នា ;

**១០. សាសនេ ចរតិ** ឧបាសក ឧបាសិកាប្រព្រឹត្តល្អក្នុងព្រះពុទ្ធសាសនា ប្រព្រឹត្តតាមតែធម៌វិន័យជាពុទ្ធសាសនា ។

ឧបាសកគុណ ទាំង ១០ យ៉ាងនេះ ឧបាសក ឧបាសិកាគប្បីប្រតិបត្តិតាមកុំឲ្យឃ្លៀងឃ្លាតឡើយ ព្រោះជាធម៌អាចនឹងធ្វើចិត្តឧបាសក ឧបាសិកា អ្នកប្រតិបត្តិឲ្យស្ុចរិតផូរផង់ក្នុងព្រះពុទ្ធសាសនា ហើយឲ្យបានជាបច្ច័យនៃព្រះនិព្វាន ។

**ស**. ដាច់សីលដោយហេតុប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? ចូររាប់និងអធិប្បាយ !

**ច**. ដាច់សីលដោយហេតុ ២ យ៉ាង គឺ ៖ សាវជ្ជោ ១ , អនាវជ្ជោ ១ ។ អធិប្បាយថា ៖

- **សាវជ្ជោ** ដាច់សីលមានទោស គឺប្រព្រឹត្តកន្លងសិក្ខាបទដែលជាលោកវជ្ជៈ ,
- **អនាវជ្ជោ** ដាច់សីលមិនមានទោស គឺស្លាប់ ។

**ស**. ចុះបុគ្គលអ្នករក្សាសីល មានធម៌អ្វីសម្រាប់គ្រប់គ្រងមិនឲ្យដាច់ទៅបាន ?

**ច**. មាន **លោកបាលធម៌** ថែរក្សាបុគ្គលនោះកុំឲ្យដាច់សីលទៅបាន ។

**ស**. លោកបាលធម៌ មានប៉ុន្មានយ៉ាង? អ្វីខ្លះ ? ចូរអធិប្បាយ!

**ច**. លោកបាលធម៌ មាន ២ យ៉ាងគឺ ហិរិ ១ ឱត្តប្បៈ ១ ។

- **ហិរិ** ខ្មាសឬអៀននឹងអំពើទុច្ចរិត,
- **ឱត្តប្បៈ** តក់ស្លុតខ្លាច អំពើទុច្ចរិត ។

សេចក្តីប្រៀបថា ៖ ដូចដែកពីរដុំ ដែកមួយដុំប្រលាក់លាមក គេមិនហ៊ានកាន់ព្រោះខ្ពើម, ដែកមួយដុំទៀតគេដុតភ្លើងឲ្យក្តៅគេមិនហ៊ានកាន់ព្រោះខ្លាចក្តៅ ។ **ហិរិ** ដូចជាខ្ពើមលាមកប្រឡាក់, **ឱត្តប្បៈ** ដូចខ្លាចដែកក្តៅ ធម៌ទាំង ២ នេះអាចរក្សាបុគ្គលអ្នករក្សាសីលមិនឲ្យធ្លុះ, ពព្រុស, ពពាលទៅបាន ទើបឈ្មោះថាលោកបាលធម៌ ។

**ស**. ដូចម្តេចសីលដាច់ ? សីលធ្លុះ ? សីលពពាល ? សីលពព្រុស ? ផ្សេងគ្នាដូចម្តេច ? ចូរអធិប្បាយ !

**ច**. សេចក្តីផ្សេងគ្នាដូច្នេះគឺ ៖

- **សីលដាច់** នោះដូចសិក្ខាបទទាំង ៥ ដាច់ខាងដើមនិងខាងចុង ។
- **សីលធ្លុះ** គឺសីលទាំង ៥ ដាច់សីលកាមេ ចំកណ្តាល ឈ្មោះថា សីលធ្លុះ ។
- **សីលពពាល** គឺដាច់បន្ទាប់ៗគ្នា ដូចដាច់អទិន្នាទាននិងកាមេឆ្លកៗ ឈ្មោះថា សីលពពាល ។
- **សីលពព្រុស** គឺដាច់អទិន្នាទាន និងមុសាជាចន្លោះៗ ដូចធ្មេញរនាស់ ឈ្មោះថា សីលពព្រុស ។

**ស**. សីលមានចែកតទៅទៀតដែរឬទេ ? គឺអ្វីខ្លះ ? ចូររាប់និងអធិប្បាយ !

**ច**. សីលមានចែកទៅទៀត ៣ យ៉ាងគឺ ៖ ហីនសីល ១, មជ្ឈិមសីល ១, បណីតសីល ១ ។

- **ហីនសីល** រក្សាដោយមាន **ឆន្ទៈ វីរិយៈ ចិត្តៈវិមំសា** អធិបតីធម៌ទាំង ៤ នេះថោកថយ សីលក៏ថោកថយដែរ ឬប្រកបដោយសេចក្តីអំនួតគ្របសង្កត់ ត្មះតិះដៀលបង្អាប់អ្នកដទៃថាសីលមិនស្មើនឹងសីលខ្លួនប្រកបដោយតណ្ហា និងទិដ្ឋិ និងមានះ ដូច្នេះឈ្មោះថា **ហីនសីល** ។
- **មជ្ឈិមសីល** អ្នករក្សាសីលមានអធិបតីធម៌ទាំង ៤ យ៉ាង

កណ្តាលមិនមាន តណ្ហា ទិដ្ឋិ មានះ តែប្រកបដោយញាណ - សម្បយុត្តសង្ខារិក ឈ្មោះថា **មជ្ឈិមសីល** ។

• **បណីតសីល** អ្នករក្សាសីលប្រកបដោយអធិបតីធម៌ទាំង ៤ ជាឧក្រិដ្ឋមិនមាន តណ្ហា, ទិដ្ឋិ, មានះ ចូលទៅជិតលុក-លុយ ប្រកបដោយកុសលចិត្តជាញាណសម្បយុត្តអសង្ខារិកឈ្មោះថា **បណីតសីល** ។

សីលទាំង ៣ មានអានិសង្សខុសផ្សេងពីគ្នា តាមអធិបតីធម៌ទាប, កណ្តាល, ខ្ពង់ខ្ពស់ ។

**ស**. សិក្ខាបទទាំង ៨ មានចែកតទៅទៀតដែរឬទេ ?

**ឆ**. សិក្ខាបទទាំង ៨ មានចែកចេញជាពីរយ៉ាងទៀតគឺ ៖ សិក្ខាបទ ៥ ខាងដើមជា **លោកវជ្ជៈ** មានទោសសម្រាប់លោកទោះបីសមាទានក្តីមិនសមាទានក្តីបើប្រព្រឹត្តកន្លងហើយមានទោសនេះចំពោះនិច្ចសីល លើកអព្រហ្មចរិយចេញ សិក្ខាបទណាដែលមានក្នុងថ្ងៃឧបោសថ សិក្ខាបទនោះឈ្មោះ **បណ្ណត្តិវជ្ជៈ** មានទោសព្រោះកន្លងបញ្ញត្តិ មិនបានទៅកាន់អបាយភូមិទេ គ្រាន់តែខាតអានិសង្សឧបោសថប៉ុណ្ណោះ ។

**ស**. ហេតុដូចម្តេចបានជាសិក្ខាបទជាបណ្ណត្តិវជ្ជៈ មិនធ្លាក់អបាយបើខ្លួនទៅសមាទានបានសន្មតិឧបោសថសីលឥឡូវត្រឡប់ទៅជាប្រព្រឹត្តកន្លងទៅវិញ មិនមុសាវាទទៅហើយឬ ?

**ឆ**. មិន **មុសាវាទ** ទេ ឯមុសាវាទនោះចំពោះឲ្យគេខូចប្រយោជន៍ហើយមានបុគ្គលជាទីតាំង គេស្តាប់បាននូវពាក្យកុហក

នោះឈ្មោះថា **មុសាវាទ** រឿងនេះមានតាំងចិត្តឲ្យអ្នកណាខូចប្រយោជន៍ សិក្ខាបទខាងចុងនេះមានតែក្នុងថ្ងៃឧបោសថ ក្រៅពីថ្ងៃឧបោសថមិនមានទេ ដូច **វិកាល** បរិភោគបាយរបស់ខ្លួនឯងមានលួចរបស់អ្នកណានឹងមានទោស មិនដែលឮគម្ពីរណានិយាយអំពីអ្នកស៊ីបាយមានពៀរវេរាធ្លាក់ទៅអបាយនោះកាលណា, ដាច់សីលខាងចុងនោះ គ្រាន់តែខូចឧបោសថប៉ុណ្ណោះ សមាទានទៀតមិនឡើងជាឧបោសថ ។

**ស**. វេរាទាំង ៥ ដល់ស្លាប់ទៅអបាយ តើទៅតាមវេរាណាមុន, ឬទៅរៀងគ្នា តាំងពីបាណាជាលំដាប់ទៅ ?

**ឆ**. ធ្លាក់ទៅអបាយមិនមានកំណត់ទេ, ស្រេចតែវេរាណាមានទោសធ្ងន់ជាង ធ្លាក់ទៅមុនគេ ។

**ស**. និច្ចសីលព្រះអង្គបញ្ញត្ត ចំពោះបុគ្គលណា ?

**ឆ**. និច្ចសីលនេះ ព្រះអង្គមិនបានបញ្ញត្តចំពោះបុគ្គលណាទេ ព្រោះនិច្ចសីលមានតាំងពីព្រះអង្គមិនទាន់បានត្រាស់ម្លេះ ។

**ស**. ឧបោសថសីល ព្រះអង្គប្រារព្ធនឹងបុគ្គលណា ?

**ឆ**. ឧបោសថសីល ព្រះអង្គទ្រង់ប្រារព្ធនឹងសក្យមហានាម ។

**ស**. ដាច់សីល តើដាច់សរណគមន៍ឬទេ ?

**ឆ**. ដាច់សីលនោះបើដាច់ដោយស្លាប់ សរណគមន៍ក៏ដាច់, បើដាច់ដោយប្រព្រឹត្តកន្លងសិក្ខាបទ សរណគមន៍ដាច់ខ្លះមិនដាច់ខ្លះ ដាច់សីលដោយយល់ថា បញ្ចវេរាទាំង ៥ នេះមិនមានទោសទេ សីលក៏ដាច់ សរណគមន៍ក៏ដាច់ ព្រោះប្រកបដោយ

ទិដ្ឋិ, ឯដាច់សីលសរណគមន៍មិនដាច់នោះ គឺប្រព្រឹត្តកន្លងសិក្ខាបទមែន តែនៅមានសទ្ធាជឿកម្មផលនៅឡើយ ដាច់សីលសរណគមន៍នៅដដែល ។

**ស**. ហេតុដូចម្តេច បានជាសរណគមន៍មិនដាច់ ? បើសីលដាច់ហើយ ?

**ច**. បានជាមិនដាច់សរណគមន៍នោះ ព្រោះសរណគមន៍កើតដោយសទ្ធាចេតសិក ចំណែកសីលកើតដោយវិរតិចេតសិក ដាច់សីលនេះគ្រាន់តែខូចវិរតិចេតសិកប៉ុណ្ណោះ ។

**ស**. បើសរណគមន៍នៅ សីលដាច់ មានអានិសង្សដែរឬទេ ?

**ច**. សរណគមន៍នៅ សីលដាច់ មិនសូវមានអានិសង្សទេ ប្រៀបឧបមាដូចដើមឈើ បាក់មែកអស់ទៅហើយ មិនសូវមានផ្លែផ្កាប៉ុន្មានទេ សរណគមន៍ទុកដូចជាដើម សីលទុកដូចជាមែក។

**ស**. បើដាច់សរណគមន៍ តើដាច់សីលឬទេ ?

**ច**. ដាច់សរណគមន៍ សីលក៏ដាច់ព្រោះសរណគមន៍ជាឫសគល់ ។

**ស**. កាមេសុមិច្ឆាចារៈ និងអព្រហ្មចរិយៈ ផ្សេងគ្នាឬដូចគ្នា ?

**ច**. កាមេសុមិច្ឆាចារៈ និង អព្រហ្មចរិយៈ ផ្សេងគ្នាដូច្នេះ ៖

- **កាមេសុមិច្ឆាចារៈ** វៀរចំពោះស្ត្រី ២០ ចំពូក លើកលែងតែស្វាមី និងភរិយារបស់ខ្លួន
- **អព្រហ្មចរិយៈ** វៀរចំពោះទ្វារមគ្គទាំង ៣០ ទ្វារណាមួយអស់យប់មួយ និងថ្ងៃមួយ ។

**ស**. សីលកើតពីអ្នកឲ្យ ឬកើតពីអ្នកសូម ?

**ច**. សីលនោះ កើតពីអ្នកសូម បើអ្នកសូមវៀរចាកទោសគ្រប់សិក្ខាបទទាំងអស់ សីលក៏ពេញបរិបូណ៌ ព្រោះសីលកើតដោយចេតនា ហៅថា **ចេតនាកម្ម** ។

**ស**. បើសីលកើតពីអ្នកសូម ហេតុអ្វីក៏ចាំទៅសូមពីលោកធ្វើអ្វីទៀត ?

**ច**. បានជាទៅសូមពីលោកនោះ ដើម្បីនឹងឲ្យកើតសេចក្ដីគោរពដល់ព្រះរតនត្រ័យទាំង ៣ ផង និងឲ្យកើតបុញ្ញកិរិយាវត្ថុផ្សេងៗផង និងបានស្ដាប់ឱវាទអំពីលោកផង បានជាថាសូមពីលោកទើបគួរ ។

**ស**. ឧបោសថកម្ម, ឧបោសថសីល, ឧបោសថកាល ផ្សេងគ្នាដូចម្ដេច ?

**ច**. ផ្សេងគ្នាដូច្នេះ ឧបោសថកម្មនោះ គឺអំពើដែលត្រូវធ្វើក្នុងថ្ងៃឧបោសថ មានទទួលព្រះត្រៃសរណគមន៍ជាដើម ឈ្មោះថា **ឧបោសថកម្ម** ។

ឧបោសថសីលនោះ គឺសីល ៨ ឈ្មោះថា **ឧបោសថសីល**។

ឧបោសថកាលនោះ កំណត់ថ្ងៃដែលត្រូវរក្សានូវឧបោសថមានថ្ងៃ ៥ កើតជាដើម ក្នុង ១ ខែមាន ៨ ថ្ងៃ ដូច្នេះឈ្មោះថា **ឧបោសថកាល** ។

**ស**. ឧបោសថមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? ចូរអធិប្បាយ !

**ច**. ឧបោសថមានពីរយ៉ាងគឺ ៖ បកតិឧបោសថ ១, បដិជាគរ -

ឧបោសថ ១ ។ អធិប្បាយថា ៖

- **បកតិឧបោសថ** នោះ ១ ខែមាន ៨ ថ្ងៃ គឺថ្ងៃបញ្ចមី, អដ្ឋមី, ចាតុទ្ទសី, បណ្ណរសី, ខាងខ្នើត ៤ ខាងរនោច ៤ ត្រូវជា ៨ ។
- **បដិជាគរឧបោសថ** នោះ គឺថ្ងៃអមថ្ងៃបកតិ ហៅថា បដិជាគរឧបោសថ ។

**ស**. ឧបោសថនោះមានតែប៉ុណ្ណឹងទេ ឬមានតទៅទៀត ?

**ឆ**. ឧបោសថមាន ៣ ទៀត ។

**ស**. ៣ ទៀតនោះគឺអ្វីខ្លះ ? ចូររាប់ និងអធិប្បាយ !

**ឆ**. ៣ ទៀតនោះគឺ ៖ គោបាលឧបោសថ ១, និគ្គណ្ឋ-ឧបោសថ ១, អរិយុបោសថ ១ ។ អធិប្បាយថា ៖

- **គោបាលឧបោសថ** នោះដូចជានាយគង្វាលគោស៊ីឈ្នួលឃ្វាលគោឲ្យគេ គៀងគោទៅកាន់ទីដែលមានទឹកនិងមានស្មៅ នាយគង្វាលគោនោះតែងទន្ទឹងឲ្យតែដល់ពេលល្ងាច នឹងគៀងគោមកឲ្យម្ចាស់គេវិញរួចទារយកតែថ្លៃឈ្នួលប៉ុណ្ណោះ ត្រង់បញ្ហាគោរស ឥតបានដឹងរសជាតិយ៉ាងណាសោះ, ចំណែកអ្នករក្សានូវឧបោសថទន្ទឹងឲ្យតែអស់កាលឧបោសថ នឹងប្រព្រឹត្តធ្វើកិច្ចផ្សេងៗ តាមសេចក្ដីប្រាថ្នារបស់ខ្លួន មានផលតិច អានិសង្សតិច ដូចជានាយគង្វាលគោ ដូច្នេះឈ្មោះថា គោបាលឧបោសថ។
- **និគ្គណ្ឋឧបោសថ** អ្នករក្សាឧបោសថដូចនិគ្រន្ថតិរ្ថិយ ពួកនិគ្រន្ថរក្សាឧបោសថ កំណត់ទី ឬកំណត់សត្វ ។ កំណត់ទីដូចសត្វនៅទិសខាងកើតសម្លាប់មិនបាន សត្វនៅទិសខាងលិច

សម្លាប់បាន, កំណាត់សត្វនោះដូចសម្លាប់មាន់បាន សម្លាប់ទាមិនបានដូច្នេះជាដើម អ្នករក្សាឧបោសថកាន់របៀបនិគ្រន្ថដូច្នេះ ឈ្មោះថា និគ្គណ្ឋឧបោសថ ។

- **អរិយុបោសថ** ឧបោសថរបស់អរិយបុគ្គលដែលលះកិលេសណាមួយហើយ កិលេសនោះមិនត្រឡប់កើតឡើងវិញបាន លោករក្សាឧបោសថដើម្បីកំចាត់បង់នូវកិលេសដែលសេសសល់ទាំងប៉ុន្មាន នោះឲ្យស្អាតចេញពីសន្តានលោកអ្នករក្សាឧបោសថកាន់របៀបអរិយបុគ្គលដើម្បីកំចាត់បង់នូវកិលេសដូច្នេះ ឈ្មោះថា អរិយុបោសថ ។

**ស**. អរិយុបោសថ មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? ចូររាប់និងអធិប្បាយ !

**ឆ**. អរិយុបោសថមាន ៦ យ៉ាងគឺ ៖ ព្រហ្មុបោសថ ១, ធម្មុបោសថ ១, សង្ឃុបោសថ ១, សីលុបោសថ ១, ទេវតូបោសថ ១, អរហន្តុបោសថ ១ ។ អធិប្បាយថា ៖

- **ព្រហ្មុបោសថ** អ្នករក្សាឧបោសថ មានពុទ្ធគុណជាអារម្មណ៍ទាំង ១០ ព្រះនាមមានអរហំជាដើម បរិកម្មគ្រប់ឥរិយាបថទាំង ៤ មិនឲ្យដាច់ដើម្បីសង្កត់សង្កិននូវពួកកិលេសដូច្នេះឈ្មោះថា ព្រហ្មុបោសថក៏បាន ព្រហ្មនិងពុទ្ធនេះជាពាក្យវេវចនៈផ្លាស់ប្តូរគ្នាហៅថា ព្រហ្មុបោសថក៏បាន ពុទ្ធុបោសថក៏បាន ។

- **ធម្មុបោសថ** អ្នករក្សាឧបោសថ មានធម្មគុណជាអារម្មណ៍មានស្វាក្ខាតោជាដើម ។

• **សង្ឃុបោសថ** អ្នករក្សាឧបោសថ មានសង្ឃគុណជាអារម្មណ៍មានសុប្បដិបន្នោជាដើម ។

• **សីលុបោសថ** អ្នករក្សាឧបោសថ រឭកនឹកគុណដល់សីលដែលខ្លួនបានរក្សាហើយដោយបរិសុទ្ធ មិនសៅហ្មង ចិត្តក៏ជ្រះថ្លាឡើង ។

• **ទេវតូបោសថ** អ្នករក្សាឧបោសថ រឭកនឹកគុណដល់ធម៌ដែលនាំសត្វឲ្យទៅកើតក្នុងស្ថានសួគ៌ ៦ ជាន់ តើទៅដោយគុណធម៌អ្វីហ្ន៎ ! នឹកឃើញថានៅជាមនុស្សនៅឡើយប្រកបដោយគុណធម៌ ៥[១] យ៉ាងទើបបានទៅកើតជាទេវតាបាន ។ **អរហន្តុ-បោសថ** អរិយសាវក លោករក្សាឧបោសថលះបង់នូវបញ្ចវេរាទាំង ៥ អស់មួយជីវិត អ្នករក្សាឧបោសថសព្វថ្ងៃនេះតាំងចិត្តដូចអរិយសាវក បានឈ្មោះថា អរហន្តុបោសថ ។

អរហន្តុបោសថនេះ មានផលានិសង្សច្រើនជាអនេកប្រៀបឧបមាដូចពន្លឺព្រះច័ន្ទ្រ, ឯគោបាលបោសថ ដូចពន្លឺអំពិលអំពែក ។

**ស**. ឧបោសថដាច់ដោយហេតុប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? ចូររាប់ និងអធិប្បាយ !

**ឆ**. ឧបោសថដាច់ដោយហេតុ ២ យ៉ាងគឺ ៖ សាវជ្ជោ ១ និងអនាវជ្ជោ ១ ។ អធិប្បាយថា ៖

• **សាវជ្ជោ** ដាច់ប្រកបដោយទោស គឺប្រព្រឹត្តកន្លងនូវ

---

(១) គុណធម៌ ៥ យ៉ាងនោះគឺ សទ្ធា១, សីល១, ចាគៈ១ (ការលះឲ្យ), សុតៈ១ (ការឮ, ការស្តាប់), បញ្ញា១ ។

សិក្ខាបទដែលជាលោកវជ្ជសិក្ខាបទដែលជាបណ្ណត្តិវជ្ជ គ្រាន់តែខាតខានបានផលានិសង្សឧបោសថប៉ុណ្ណោះ ។

- **អនាចរោ** ដាច់មិនមានទោស គឺស្លាប់ ។

**ស**. អ្នករក្សាឧបោសថ មានកិច្ចប៉ុន្មានយ៉ាងដែលត្រូវធ្វើក្នុងថ្ងៃឧបោសថនោះ ?

**ច**. កិច្ចដែលត្រូវធ្វើក្នុងថ្ងៃឧបោសថនោះមាន ៣ យ៉ាង ។

**ស**. មាន ៣ យ៉ាងនោះគឺអ្វីខ្លះ ? ចូររាប់ និងអធិប្បាយ !

**ច**. មាន ៣ យ៉ាងនោះគឺ ៖ កាលេនធម្មស្សវនៈ ១, កាលេនធម្មសាកច្ឆា ១, កាលេនសមថោ ១ ។ អធិប្បាយថា ៖

- **កាលេនធម្មស្សវនៈ** អ្នករក្សាឧបោសថ ត្រូវស្តាប់ធម៌តាមកាលដ៏គួរដើម្បីនឹងរម្ងាប់បង់នូវតណ្ហា ។
- **កាលេនធម្មសាកច្ឆា** ត្រូវសាកសួរនូវធម៌វិន័យតាមកាលគួរ ដើម្បីនឹងកំចាត់បង់នូវសេចក្តីសង្ស័យ ។
- **កាលេនសមថោ** អ្នករក្សាឧបោសថ ត្រូវចំរើននូវកម្មដ្ឋានទាំង ៦ ណាមួយ តាមការគួរដើម្បីនឹងសង្កត់សង្កិននូវនីវរណធម៌ទាំង ៥ ក្នុងថ្ងៃឧបាសថនោះ អ្នករក្សាឧបោសថត្រូវប្រកបកិច្ចការណាមួយកុំខានឡើយ បើមិនប្រកបកិច្ចទាំង ៣ នេះទេនឹងក្លាយទៅជាគោបាលឧបោសថ ។

( **ចប់កិច្ចឧបោសថតែប៉ុណ្ណោះ** )

# វគ្គទី ៥ វិនយឧបាសកបញ្ហា



**សំណួរ**. វិន័យឧបាសក ឧបាសិកានោះមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ចម្លើយ**. វិន័យឧបាសក ឧបាសិកានោះមាន ១០ យ៉ាងគឺ ៖ កាយកម្ម ៣, វចីកម្ម ៤, មនោកម្ម ៣ ។

**ស**. កាយកម្ម ៣ នោះគឺអ្វីខ្លះ ? ចូររាប់ ?

**ច**. **កាយកម្ម ៣** នោះគឺ ៖

**១**. **បាណាតិបាតា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ;

**២**. **អទិន្នាទានា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយ ឬ ដោយវាចា ;

**៣**. **កាមេសុមិច្ឆាចារា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**ស**. វចីកម្ម ៤ នោះគឺអ្វីខ្លះ ? ចូររាប់ ?

**ច**. **វចីកម្ម ៤** នោះគឺ ៖

**១**. **មុសាវាទា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា

ពោលនូវពាក្យកុហក ;

**២. បិសុណាយ វាចាយ វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ ;

**៣. ផរុសាយ វាចាយ វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យត្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម ;

**៤. សម្ផប្បលាបា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

**ស**. មនោកម្ម ៣ នោះគឺអ្វីខ្លះ ? ចូររាប់ ?

**ឆ. មនោកម្ម ៣** នោះគឺ ៖

**១. អនភិជ្ឈា** មិនមានចិត្តគិតសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ ;

**២. អព្យាបាទោ** មិនគិតចងគំនុំគុំកួនគិតប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្ដីវិនាសឡើយ ;

**៣. សម្មាទិដ្ឋិ** គំនិតយល់ឃើញត្រូវពិត ហើយប្រកាន់ឡើងថាជាត្រូវមែន ។

ទាំង ១០ នេះហៅថា «**វិន័យ**» ក៏បានហៅថា «**កុសលកម្មបថ**» ១០ ក៏បាន ។

**ស**. អកុសលកម្មបថមានប៉ុន្មាន ? ចូររាប់ ?

**ឆ**. អកុសលកម្មបថមាន ១០ ចែកជា ៖ កាយកម្ម , វចីកម្ម , មនោកម្ម ។ តែក្នុងទីនេះមិនបានចែកដូចកុសលកម្មបថទេ គ្រាន់

តែមួយ «**ប្រព្រឹត្តកន្លង**» មួយ «**វៀរ**» ប៉ុណ្ណោះ ។

លំដាប់ពីនេះទៅនឹង បុច្ឆា វិស្សជ្ជនា អំពីអង្គនិច្ចសីល អង្គឧបោសថសីល អង្គកុសលកម្មបថ និងអង្គអកុសលកម្មបថ ។

## អង្គនៃនិច្ចសីល

**ស.** បាណាតិបាត មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច. បាណាតិបាត** មានអង្គ ៥ គឺ ៖

**១. បាណោ** សត្វមានជីវិត ;

**២. បាណសញ្ញិតា** សេចក្តីដឹងថាសត្វមានជីវិត ;

**៣. វធកចិត្តំ** គិតនឹងសម្លាប់ ;

**៤. ឧបក្កមោ** ព្យាយាមនឹងសម្លាប់ ;

**៥. តេន មរណំ** សត្វស្លាប់ដោយព្យាយាមនោះ ។

**ស.** អទិន្នាទាន មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច. អទិន្នាទាន** មានអង្គ ៥ គឺ ៖

**១. បរបរិគ្គហិតំ** ទ្រព្យដែលគេហួងហែងថែរក្សា ;

**២. បរបរិគ្គហិតសញ្ញិតា** សេចក្តីដឹងថា ទ្រព្យមានម្ចាស់របស់គេហួងហែងថែរក្សា ;

**៣. ថេយ្យចិត្តំ** គិតនឹងលួច ;

**៤. ឧបក្កមោ** ព្យាយាមនឹងលួច ;

**៥. តេន ហរណំ** លួចបានមកដោយព្យាយាមនោះ ។

**ស.** កាមេសុមិច្ឆាចារ មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច. កាមេសុមិច្ឆាចារ** មានអង្គ ៤ គឺ ៖

**១. អគមនីយដ្ឋានំ** ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា ;

**២. តស្មឹ សេវនចិត្តំ** គិតនឹងសេពមេថុនធម្មនឹងស្ត្រីនោះ ;

**៣. ឧបក្កមោ** ព្យាយាមនឹងសេពមេថុនធម្ម ;

**៤. មគ្គេន មគ្គប្បដិបាទនំ** ញ៉ាំងមគ្គ និងមគ្គឲ្យដល់គ្នា ។

**ស.** មុសាវាទ មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច. មុសាវាទ** មានអង្គ ៤ គឺ ៖

**១. អតថំវត្ថុ** វត្ថុមិនពិត ;

**២. វិសំវាទនចិត្តំ** គិតនឹងពោលឲ្យខុស ;

**៣. តជ្ជោ វាយាមោ** ព្យាយាមនឹងពោលឲ្យខុស ;

**៤. បរស្ស តទត្ថវិជាននំ** ញ៉ាំងអ្នកដទៃ ឲ្យដឹងច្បាស់នូវសេចក្តីនោះ ។

**ស.** សុរាមេរយ មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច. សុរាមេរយ** មានអង្គ ៤ គឺ ៖

**១. មជ្ជនីយវត្ថុ** វត្ថុជាទីតាំងនៃសេចក្តីស្រវឹង ;

**២. បាតុកម្យតាចិត្តំ** គិតបំរុងនឹងផឹក ;

**៣. តជ្ជោ វាយាមោ** ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ ;

**៤. តស្ស បាណំ** បានផឹកនូវទឹកស្រវឹងនោះ ឲ្យកន្លងបំពង់កចូលទៅ ។

( **ចប់អង្គនៃនិច្ចសីល** )

# អង្គនៃឧបោសថសីល

អង្គនៃ **បាណាតិបាត** និង **អទិន្នាទាន** ដូចនិច្ចសីលខាងដើម ។

**ស.** អព្រហ្មចរិយៈ មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច. អព្រហ្មចរិយៈ** មានអង្គ ៤ គឺ ៖

**១. តេធនវត្ថុ** វត្ថុជាទីទំលាយនូវសីល គឺទ្វារទាំង ៣០ ចំពោះត្រង់ទ្វារណាមួយ ;

**២. សេវនចិត្តំ** គិតនឹងសេព ;

**៣. តជ្ជោ វាយាមោ** ព្យាយាមនឹងសេពមេថុនធម្មនោះ ;

**៤. មគ្គេន មគ្គប្បដិបាទនំ** ញ៉ាំងមគ្គនិងមគ្គឲ្យដល់គ្នា ។

អង្គនៃ **មុសាវាទ** និង **សុរាមេរយ** ដូចនិច្ចសីលខាងដើម ។

**ស.** វិកាលភោជនៈ មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច. វិកាលភោជនៈ** មានអង្គ ៣ គឺ ៖

**១. វិកាលោ** កាលខុសគឺព្រះអាទិត្យជ្រេទៅហើយដរាបទល់នឹងអរុណរះ ;

**២. យាវកាលិកំ** របស់ដែលគួរបរិភោគបានក្នុងកាល គឺតាំងពីអរុណរះឡើង ដរាបដល់ថ្ងៃត្រង់ ;

**៣. អជ្ឈោហរណំ** បានលេបចូលទៅក្នុងបំពង់ក ។

**ស.** នច្ចគីតៈ ព្រមទាំង មាលា រួមជាសិក្ខាបទមួយ មានអង្គប៉ុន្មាន ? ចូររាប់ !

**ច. នច្ចគីតៈ** ព្រមទាំង **មាលា** រួមជាសិក្ខាបទមួយមានអង្គ ៦

គឺ ៖

**១. នច្ចគីតាទិ** ការល្បែងមានរាំ និងច្រៀងជាដើម ;

**២. ភត្តុកម្យតាចិត្តំ** គិតបម្រុងនឹងធ្វើ ;

**៣. សុតទស្សនត្ថាយ គមនំ** ទៅដើម្បីនឹងស្តាប់ឬមើល ហើយបានស្តាប់ឬមើល ;

**៤. មាលាទិ** វត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើម ;

**៥. ធារណច្ឆន្ទតា** សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង ;

**៦. តស្ស ធារណំ** បានប្រដាប់តាក់តែងនូវវត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើមនោះ ។

**ស.** ឧច្ចាសយនៈ មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច. ឧច្ចាសយនៈ** មានអង្គ ៣ គឺ ៖

**១. ឧច្ចាសយនមហាសយនំ** ទីដេកទីអង្គុយដ៏ខ្ពស់ដ៏ប្រសើរហួសប្រមាណ ;

**២. បរិភោគចិត្តំ** គិតនឹងដេកឬអង្គុយ ;

**៣. បរិភោគករណំ** បានដេកឬអង្គុយ ។

កាលបើឧបាសក ឧបាសិកាប្រព្រឹត្តឲ្យកន្លងនូវសិក្ខាបទណាៗ លុះតែព្រមដោយអង្គនៃសិក្ខាបទនោះៗ ទើបបានឈ្មោះថាកន្លង បើមិនទាន់ព្រមដោយអង្គនោះៗទេ, ក៏មិនបានឈ្មោះថាកន្លងនូវសិក្ខាបទនោះៗឡើយ ។

( **ចប់អង្គនៃនិច្ចសីល និង ឧបោសថសីលតែប៉ុណ្ណោះ** )

# អង្គនៃអកុសលកម្មបថ ១០

អង្គនៃ **បាណាតិបាត**, **អទិន្នាទាន**, **កាមេសុមិច្ឆាចារ** និង **មុសាវាទ** ដូចបានពោលមក ក្នុងអង្គសីលខាងដើមរួចហើយ ។

**ស**. បិសុណាវាចា មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច**. **បិសុណាវាចា** មានអង្គ ៤ គឺ ៖

**១**. **ភិន្ទិតព្វោ បរោ** អ្នកដទៃដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែកបាន ;

**២**. **ភេទនបុរេក្ខារតា** គិតនឹងញុះញង់បំបែកអ្នកដទៃ ;

**៣**. **តជ្ជោ វាយាមោ** ព្យាយាមនឹងញុះញង់បំបែកអ្នកដទៃនោះ ;

**៤**. **តស្ស តទត្ថវិជាននំ** ញុំាំងអ្នកដទៃឲ្យដឹងច្បាស់នូវដំណើរដែលខ្លួនញុះញង់បំបែកនោះ ។

**ស**. ផរុសវាចា មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច**. **ផរុសវាចា** មានអង្គ ៣ គឺ ៖

**១**. **អក្កោសិតព្វោ បរោ** អ្នកដទៃដែលមានរូប គឺខ្លួនគប្បីជេរប្រទេច ;

**២**. **កុបិតចិត្តំ** ចិត្តខឹងរន្ធត់ ;

**៣**. **អក្កោសនា** បានជេរប្រទេច ។

**ស**. សម្ផប្បលាបៈ មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច**. **សម្ផប្បលាបៈ** មានអង្គ ២ គឺ ៖

**១. ភារតយុទ្ធសិតាហរណាទិនិរត្ថកថា** ពាក្យឥតប្រយោជន៍មានរឿងចម្បាំងនៃមហាភារត និងរឿងរាពណ៍លួចនាំនាងសិតាយកទៅជាដើម ;

**២. តថារូបី កថាកថនំ** បានពោលនូវពាក្យឥតប្រយោជន៍មានសភាពដូច្នោះ ។

**ស.** អភិជ្ឈា មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច. អភិជ្ឈា** មានអង្គ ២ គឺ ៖

**១. បរភណ្ឌំ** ទ្រព្យរបស់អ្នកដទៃ ;

**២. អត្តនោ បរិណាមនំ** គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះឲ្យបានមកជាទ្រព្យរបស់ខ្លួនដោយកលឧបាយផ្សេងៗ ។

**ស.** ព្យាបាទ មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច. ព្យាបាទ** មានអង្គ ២ គឺ ៖

**១. បរសត្តោ** អ្នកដទៃក្រៅពីខ្លួន ;

**២. តស្ស ត់ តំ វិនាសចិន្តា** គិតគុំកួនប្រុងនឹងឲ្យអ្នកនោះដល់នូវសេចក្តីវិនាសដោយហេតុនោះៗ ។

**ស.** មិច្ឆាទិដ្ឋិ មានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់ !

**ច. មិច្ឆាទិដ្ឋិ** មានអង្គ ២ គឺ ៖

**១. វត្ថុនោ ច គហិតាការវិបរិតា** ចិត្តប្រែប្រួលដោយអាការខុសអំពីព្រះរតនត្រ័យជាដើម ;

**២. យថា ច នំ គណ្ហាតិ តថាភាវេន តថាស្សុបនំ** គំនិតដែលយល់ខុសនោះឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្តី

ខុសនោះថាជាត្រូវវិញ ។

អកុសលកម្មបថទាំង ១០ ប្រការដូចបានពោលមកហើយនេះ ទោះត្រង់បទណាក្តី លុះតែព្រមដោយអង្គនោះៗ ទើបត្រូវទោសដល់អ្នកដែលប្រព្រឹត្តខុស អ្នកនោះនឹងបាននូវសេចក្តីទុក្ខ សេចក្តីវិនាសក្នុងលោកនេះ និងបរលោកនាយ បើទុកជាមិនទាន់ឲ្យផលឃើញច្បាស់ក្នុងលោកនេះ លុះទៅក្នុងលោកខាងមុខ ក៏គង់នឹងឲ្យផលដល់អ្នកនោះពុំខានឡើយ បើមិនទាន់ព្រមដោយអង្គនោះ គឺថាបើខ្វះអង្គណាមួយនោះ ក៏គង់មិនទាន់បានឈ្មោះថាមានទោសក្នុងអកុសលកម្មបថដល់អ្នកប្រព្រឹត្តខុសនោះឡើយទេ ។

( **ចប់អកុសលកម្មបថ ១០ព្រមទាំងអង្គតែប៉ុណ្ណោះ** )

**ស**. កាយកម្ម និងកាយទុច្ចរិត និងកាយទ្វារផ្សេងគ្នាដូចម្តេច ? ចូរអធិប្បាយ !

**ច**. កាយទាំង ៣ ផ្សេងគ្នាដូច្នេះ ៖

• **កាយកម្ម** គឺអំពើដែលសម្រេចដោយកាយ បើសម្លាប់លុះតែព្រមដោយអង្គ តាមសិក្ខាបទនោះៗ ដែលចាត់ជាកាយកម្មដូច្នេះឈ្មោះថាជា **កាយទ្វារ** ។

• ឯ **កាយទុច្ចរិត** នោះ គឺប្រព្រឹត្តអាក្រក់ដោយកាយមានចាប់ដំបងព្រនង់ជាដើម ដេញវាយសត្វនោះៗ ស្លាប់ក្តីមិនស្លាប់ក្តី ឈ្មោះថា **កាយទុច្ចរិត** ។

• **កាយទ្វារ** នោះលើកអវយវៈមានដៃជាដើម ឲ្យកំរើកឡើងឈ្មោះថា **កាយទ្វារ** ។

សេចក្តីផ្សេងៗគ្នាដូចវិស្សជ្ជនាមកខាងលើនេះ ។

**ស**. កាយកម្មប្រព្រឹត្តទៅបានទ្វារប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់និងអធិប្បាយ !

**ច**. កាយកម្មប្រព្រឹត្តទៅបានទ្វារ ២ គឺ ៖ កាយទ្វារ ១, វចីទ្វារ ១ ។ អធិប្បាយថា ៖

• កាយទ្វារនោះ គឺសម្លាប់សត្វ ឬលួចទ្រព្យគេប្រព្រឹត្តកាមេដោយខ្លួនឯង ឈ្មោះថា **កាយកម្ម** ជា **កាយទ្វារ** ។

• វចីទ្វារនោះ គឺប្រើគេឲ្យសម្លាប់សត្វ ឲ្យលួចទ្រព្យគេជាដើមឈ្មោះថា **កាយកម្ម** ជា **វចីទ្វារ** ។

**ស**. វចីកម្មប្រព្រឹត្តទៅបានទ្វារប៉ុន្មាន ? គឺអ្វីខ្លះ ? ចូររាប់និងអធិប្បាយ !

**ច**. វចីកម្មប្រព្រឹត្តទៅបានទ្វារ ២ គឺ ៖ កាយទ្វារ ១, វចីទ្វារ ១។

អធិប្បាយថា ៖

• កាយទ្វារនោះ គឺមានសរសេរសំបុត្រពាក្យកុហកជាដើមឲ្យគេជឿ ឬងារដៃឡើង ឬក៏ងក់ក្បាលចុះដូច្នេះឈ្មោះថា **វចីកម្ម** ជា **កាយទ្វារ** ។

• វចីទ្វារនោះពោលនូវពាក្យកុហកជាដើម ដោយទ្វារមាត់ឯងឈ្មោះថា **វចីកម្ម** ជា **វចីទ្វារ** ។

**ស**. មនោកម្មប្រព្រឹត្តទៅបានដោយទ្វារប៉ុន្មាន ? គឺអ្វីខ្លះ ?

ចូររាប់និងអធិប្បាយ !

**ច. មនោកម្ម** ប្រព្រឹត្តទៅបានដោយទ្វារ ៣ គឺ ៖ កាយទ្វារ ១, វចីទ្វារ ១, មនោទ្វារ ១ ។ អធិប្បាយថា ៖

- **កាយទ្វារ** អភិជ្ឈាប្រព្រឹត្តទៅក្នុងកាយទ្វារ មានសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃ ហើយញ៉ាំងកាយឲ្យកម្រើក ចាប់របស់ផ្អៀងផ្អងមើលដើម្បីឲ្យគេឲ្យខ្លួន ។

«**ព្យាបាទ**» ប្រព្រឹត្តទៅក្នុងកាយទ្វារ មានកាន់ព្រនង់ដំបងជាដើមបម្រុងនឹងឲ្យសត្វស្លាប់ ។

«**មិច្ឆាទិដ្ឋិកោ**» បុគ្គលដែលយល់ខុសនោះ មានធ្វើនូវកិរិយាថ្វាយបង្គំ និងធ្វើអញ្ជលីកម្មដល់ជនទាំងឡាយមាន គន្ធកុមារជាដើម ថាប្រសើរជាងព្រះរតនត្រ័យ ដូច្នេះឈ្មោះថា មនោកម្មប្រព្រឹត្តទៅក្នុង កាយទ្វារ ។

- **វចីទ្វារ** អភិជ្ឈាសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃ ហើយពោលថា ៖ របស់នេះបើបានមកខ្ញុំទើបសម អ្នកឯងមិនសមប្រើប្រាស់របស់នេះទេ ។

«**ព្យាបាទ**» ប្រព្រឹត្តទៅក្នុងវចីទ្វារនោះដូច្នេះ មានពោលពាក្យផ្តន្ទាថា ៖ សត្វទាំងឡាយចូរវិនាសហិនហោចទៅ ចូរសាបសូន្យទៅ ។

«**មិច្ឆាទិដ្ឋិ**» នោះពោលនូវទិដ្ឋិ ១០ យ៉ាង មានពោលថា **នត្ថិ ទិន្នំ** ជាដើមទាំង ៣ នេះ ឈ្មោះថា **មនោកម្ម** ជា **វចីទ្វារ** ។

- **មនោកម្ម** ជា **មនោទ្វារ** នោះមិនបានញ៉ាំងកាយនិង

វាចាឲ្យកម្រើកទេ គ្រាន់តែចូលទៅអង្គុយក្នុងទីស្ងាត់ ហើយញុំាងចិត្តឲ្យកម្រើកឡើងដោយអភិជ្ឈា, ព្យាបាទ និងមិច្ឆាទិដ្ឋិដូច្នេះ ឈ្មោះថា **មនោកម្ម** ជា **មនោទ្វារ** ។

វិស្សជ្ជនាមកក្នុងមនោទ្វារទាំង ៣ ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៣ សង្ខេបតែប៉ុណ្ណេះ ។

**ស**. ចំណែកកុសលកម្មបថ ចែកដូចអកុសលកម្មដែរឬទេ ?

**ឆ**. ចំណែកកុសលកម្មបថ ផ្សេងគ្នាខ្លះដូចគ្នាខ្លះ ។

**ស**. ផ្សេងគ្នាដូចម្ដេច ? ដូចគ្នាដូចម្ដេចខ្លះ ?

**ឆ**. ផ្សេងគ្នានោះគឺ កាយកម្មនិងវចីកម្មប្រព្រឹត្តទៅបានទ្វារ ៣ ចំណែកមនោកម្ម ប្រព្រឹត្តទៅបានទ្វារ ៣ ដូចអកុសលដែរ ។

**ស**. កាយកម្មនិងវចីកម្មប្រព្រឹត្តទៅបានទ្វារ ៣ ដូចម្ដេច ? ចូរអធិប្បាយ !

**ឆ**. អធិប្បាយថា ៖ **កាយកម្ម** ជា **កាយទ្វារ** គឺវៀរបាណាតិបាតដោយកាយខ្លួនឯងឈ្មោះថា **កាយកម្ម** ជា **កាយទ្វារ** ។ មិនប្រើគេឲ្យសម្លាប់ដោយវាចារបស់ខ្លួនឈ្មោះថា **កាយកម្ម** ជា **វចីទ្វារ** ។ **មនោកម្ម** ជា **មនោទ្វារ** នោះ ផ្សាយមេត្តាចិត្តទៅរកសត្វ ចំពោះសត្វនិងទ្រព្យអ្នកដទៃដូច្នេះ ឈ្មោះថា **មនោកម្ម** ជា **មនោទ្វារ** ។ ត្រង់នេះខុសគ្នានឹងអកុសល ចំណែកអកុសល លុះត្រាតែព្រមដោយកាយ ទើបធ្លាយកម្មបថ ចំណែកកុសល គ្រាន់តែផ្សាយមេត្តាចិត្តទៅក៏កើតជាកុសលចិត្តបានដែរ ។ វចីកម្មមានន័យដូចគ្នានឹងកាយកម្ម ។ មនោកម្ម

មានន័យដូចគ្នានឹងមនោកម្មប៉ែកអកុសល ។ សេចក្ដីផ្សេងគ្នាដូចវិសជ្ជនាមកនេះ ។

**ស**. អកុសលទាំង ១០ ណាមួយមានទោសធ្ងន់ជាងគេ ?

**ច**. អកុសលទាំង ១០ **មិច្ឆាទិដ្ឋិ** មានទោសធ្ងន់ជាងគេ ។

**ស**. ហេតុអ្វីក៏ **មិច្ឆាទិដ្ឋិ** មានទោសធ្ងន់ជាងគេ ?

**ច**. **មិច្ឆាទិដ្ឋិ** មានទោសធ្ងន់ជាងគេ, ព្រោះមានសេចក្ដីយល់ខុស កាលណាបើយល់ខុសហើយកាយនិងវាចា ក៏ប្រព្រឹត្តធ្វើនូវអំពើអកុសលទៅតាមទិដ្ឋិដែលយល់ខុសនោះ ព្រោះកាយនិងវាចានៅក្រោមអំណាចចិត្តទាំងអស់, ចំណែកអកុសលកម្មបថដទៃ បើជ្រុលទៅហើយអាចនឹងធ្វើកុសលបាន ព្រោះមិនប្រកបដោយមិច្ឆាទិដ្ឋិ ។

**ស**. មិច្ឆាទិដ្ឋិ ចែកជាប៉ុន្មានពួក ? ចូរអធិប្បាយ !

**ច**. **មិច្ឆាទិដ្ឋិ** ចែកជា ៣ ពួកគឺ ៖ និយតមិច្ឆាទិដ្ឋិ ១, អន្តគាហិកទិដ្ឋិ ១, សក្កាយទិដ្ឋិ ១ ។ អធិប្បាយថា ៖

- **និយតមិច្ឆាទិដ្ឋិ** នេះ បើបុគ្គលយល់ខុសហើយទៀងតែធ្លាក់ទៅលោកន្តរនរក ។ និយតមិច្ឆាទិដ្ឋិ ចែកចេញជា ៣ ពួកទៀតគឺ ៖ អកិរិយទិដ្ឋិ ១, អហេតុកទិដ្ឋិ ១, នត្ថិកទិដ្ឋិ ១ ។

**១. អកិរិយទិដ្ឋិ** នោះយល់ថា សម្លាប់សត្វក្ដី លួចទ្រព្យគេក្ដី ប្រព្រឹត្តកាមេសុមិច្ឆាចារក្ដី ឬពោលពាក្យកុហកក្ដី ឈ្មោះថាមិនធ្វើនូវអំពើបាប បានជាថាមិនធ្វើនូវអំពើបាបនោះព្រោះធាតុនិងធាតុធ្វើគ្នាទេតើ សត្វក៏ធាតុ អ្នកសម្លាប់ក៏ធាតុដូចគ្នា ដែលទៅ

កើតទៀតគឺវិញ្ញាណ ឯសម្លាប់នេះមានត្រូវវិញ្ញាណសត្វកាលណា ! ពោលដូច្នេះឈ្មោះថា អកិរិយទិដ្ឋិ ។

**២. អហេតុកទិដ្ឋិ** នោះយល់ឃើញថា សត្វទាំងអស់កើតមកគ្មានហេតុ គ្មានបច្ច័យ សៅហ្មងក៏សៅហ្មងឯង ស្អាតក៏ស្អាតឯង ដូចជាដើមឈើឥតមានបាបបុណ្យអ្វីតាក់តែងវា ឲ្យវៀចឲ្យត្រង់នោះទេ ដូច្នេះឈ្មោះថា អហេតុកទិដ្ឋិ ។

**៣. នត្ថិកទិដ្ឋិ** នោះយល់ឃើញថា កុសលមានទានជាដើមមិនមាន ស្ថានសួគ៌ក៏មិនមាន ស្ថានព្រហ្មក៏មិនមាន សត្វស្លាប់ទៅសូន្យមិនកើតទៀតដូច្នេះឈ្មោះថា នត្ថិកទិដ្ឋិ ។

ទិដ្ឋិទាំង ៣ នេះឃាត់នូវស្ថានសួគ៌ផង ឃាត់នូវព្រះនិព្វានផង ។

- **អន្តគាហិកទិដ្ឋិ** នោះឃាត់តែព្រះនិព្វាន ស្ថានសួគ៌មិនឃាត់ទេ ចែកទៅមាន ១០ យ៉ាងគឺៈ

**១. សស្សតោ លោកោ** លោកទៀង ;

**២. អសស្សតោ លោកោ** លោកមិនទៀង ;

**៣. អន្តវា លោកោ** លោកមានទីបំផុត ;

**៤. អអន្តវា លោកោ** លោកមិនមានទីបំផុត ;

**៥. តំ ជីវិតំ សរីរំ** ជីវៈក៏នោះ សរីរៈក៏នោះ ;

**៦. អញ្ញំ ជីវំ អញ្ញំ សរីរំ** ជីវៈក៏ដទៃ សរីរៈក៏ដទៃ ;

**៧. ហោតិ តថាគតោ បរម្មរណា** សត្វខាងមុខអំពីស្លាប់ហើយរមែងមាន គឺកើតទៀត ;

**៨. ន ហោតិ តថាគតោ បរម្មរណា** សត្វខាងមុខអំពីស្លាប់ហើយ រមែងមិនមាន គឺមិនមានកើតទៀត ;

**៩. ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា** សត្វខាងមុខអំពីស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន ;

**១០. នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា** សត្វខាងមុខអំពីស្លាប់ហើយកើតទៀតក៏ទេ មិនកើតទៀតក៏ទេ[១] ។

- ចំណែក **សក្កាយទិដ្ឋិ** ស្ថានសួគ៌ក៏មិនឃាត់ ព្រះនិព្វានក៏មិនឃាត់ ។

**ស**. អ្នកធ្វើអំពើដោយកាយមានបាណាតិបាតជាដើម ធ្វើដោយវាចាមានមុសាវាទជាដើម អំពើទាំង ២ នេះមានចាត់ទៅជាមនោកម្មបានខ្លះដែរឬទេ ? ចូរបរិយាយ !

**ឆ**. បើចាត់ទៅជាមនោកម្មបានខ្លះដែរ ដូចយ៉ាងសម្លាប់សត្វក្តី លួចទ្រព្យគេក្តី ប្រព្រឹត្តកាមេសុមិច្ឆាចារក្តី និយាយកុហកក្តី យល់ឃើញថាគ្មានបាបដូច្នោះឈ្មោះថា មនោកម្មពេញទី, ពិតមែនតែធ្វើដោយកាយ ធ្វើដោយវាចា ប៉ុន្តែមិច្ឆាទិដ្ឋិជាមូលដ្ឋាន មិច្ឆា-ទិដ្ឋិនេះជាតួមនោកម្មសុទ្ធ ។

**ស**. ចុះមនោកម្ម ចាត់ទៅជាកាយកម្ម វចីកម្ម បានខ្លះដែរឬទេ ?

**ឆ**. បើមនោកម្មពេញទីចាត់ទៅជាកាយកម្ម និងវចីកម្ម មិនបានទេ ។

---

(១) **សារត្ថទីបនី ដីកា បរិវារវណ្ណនា**

**ស**. ហេតុដូចម្តេចបានជាចាត់មិនបាន កាយកម្ម និង វចីកម្ម ក៏គង់មានចិត្តផងដែរ បើគ្មានចិត្តធ្វើម្តេចនឹងសម្រេចកិច្ចទៅបាន ?

**ឆ**. ពិតមែនតែមានចិត្ត តែក្នុងទីនេះមិនទាន់ចាត់ទៅជា អភិជ្ឈាព្យាបាទ មិច្ឆាទិដ្ឋិនៅឡើយទេ, គ្រាន់តែកើតជាមួយនឹង កាយ វាចាប៉ុណ្ណោះ ព្រោះកាយនិងវាចាធំជាង, បើចិត្តទៅនៅនឹង កាយ ចាត់ជា កាយកម្ម ទៅជាមួយនឹងវាចា ចាត់ជាវចីកម្ម អំពើ ទាំងនេះសម្រេចទៅបាន ដោយកាយនិងវាចា មិនមែនសម្រេច ទៅបានដោយចិត្តទេ គ្រាន់តែចិត្តគិត មិនបានធ្លាយកម្មបថឡើយ នេះចំណែកកាយកម្ម និងវចីកម្ម ។

បើមនោកម្មវិញ លើកចិត្តជាធំ កាយនិងវាចានៅក្រោម បង្គាប់ចិត្ត ដូចអភិជ្ឈាព្យាបាទនិងមិច្ឆាទិដ្ឋិ កើតឡើងទោះបីធ្វើ ដោយកាយក្តី ដោយវាចាក្តី ក៏ឈ្មោះថាមនោកម្មទាំងអស់ ។

សេចក្តីប្រៀបធៀបថា ធាតុទាំង ៤ គឺធាតុដី, ទឹក, ភ្លើង, ខ្យល់ ធាតុដីគង់មានទឹក, មានភ្លើងនៅជាមួយដែរ គេហៅធាតុដី តែម្យ៉ាងព្រោះដីច្រើនជាង ។

ធាតុទឹកមានដី ភ្លើង ខ្យល់ នៅជាមួយផងដែរហៅថា ធាតុ ទឹកតែម្យ៉ាង ព្រោះទឹកច្រើនជាងធាតុទាំង ៤ នេះដូចគ្នាទាំងអស់ យ៉ាងណា កម្មទាំង ៣ ក៏យ៉ាងនោះដែរ ។

**ស**. ទោសរបស់អកុសលកម្មបថ មានប៉ុន្មាន ? គឺអ្វីខ្លះ ?

**ឆ**. ទោសរបស់ **អកុសលកម្មបថ** មាន ៥ យ៉ាងគឺ ៖

**១. អត្តាបិ អត្តានំ ឧបវទតិ** ខ្លួនឯងតិះដៀលខ្លួនឯងបាន

គឺឃើញទោសដែលខ្លួនប្រព្រឹត្តខុសពីដើមមក កើតវិប្បដិសារីក្ដៅក្រហាយស្ដាយក្រោយ ;

**២. អនុវិច្ច វិញ្ញូ គរហន្តិ** អ្នកប្រាជ្ញតែងតិះដៀលបាន គឺទៅកាន់ទីប្រជុំណាៗ មានមុខសំយុងចុះ គ្មានសេចក្ដីរីករាយ ;

**៣. បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** អ្នកប្រព្រឹត្តអកុសលកម្មបថមានកិត្តិសព្ទមិនពីរោះ ទៅកាន់ទីផ្សេងៗ គេថាមនុស្សអាក្រក់ ;

**៤. សម្មូឡ្ហោ កាលំ ករោតិ** ពេលជិតស្លាប់វង្វេងស្មារតី ព្រោះកម្មអកុសលនោះមកបណ្ដាលឲ្យឃើញ ;

**៥. កាយស្ស ភេទា បរម្មរណា ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ** លុះទំលាយកាយទៅកាលណានឹងទៅកាន់អបាយ ទុគ្គតិ វិនិបាត នរកព្រោះមានអារម្មណ៍គឺអំពើអាក្រក់ដែលខ្លួនធ្វើទុកពីខាងដើមមក និម្មិតឲ្យឃើញក្នុងពេលទៀបស្លាប់នោះនៅចាំព័ទ្ធពីមុខ ។

**ស.** ចុះកុសលកម្មបថ មានអានិសង្សប៉ុន្មាន ? ចូររាប់ !

**ច. កុសលកម្មបថ** មានអានិសង្ស ៥ យ៉ាងគឺ ៖

**១. អត្តាបិ អត្តានំ ន ឧបវទតិ** ខ្លួនឯងមិនបានតិះដៀលខ្លួនឯង ;

**២. អនុវិច្ច វិញ្ញូ បសំសន្តិ** អ្នកប្រាជ្ញតែងសរសើរ ;

**៣. កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** នឹងមានកិត្តិសព្ទរន្ទឺខ្ចរខ្ចាយទៅ ;

**៤. អសម្មូឡ្ហោ កាលំ ករោតិ** ពេលជិតស្លាប់មិនវង្វេងស្មារតី ;

**៥. កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ** លុះបែកធ្លាយកាយនឹងមានសុគតិ ប្រព្រឹត្តទៅខាងមុខគឺថានឹងទៅកាន់ស្ថានសួគ៌ ។

**ស**. អកុសលកម្មបថ ១០ មានតែប៉ុណ្ណឹង ឬមានតទៅទៀត ?

**ច**. អកុសលកម្មបថ ១០ មានចែកទៅជា ៤០ ទៀត ។

**ស**. មាន ៤០ នោះគឺអ្វីខ្លះ ? ចូរាប់ !

**ច**. មាន ៤០ នោះគឺក្នុងកម្មបថ ១០ កម្មបថនីមួយៗ ចែកចេញជា ៤ ៗ ដូចរាប់ខាងក្រោមនេះ ៖

## ១. បាណាតិបាតចែកជា ៤ គឺ ៖

**ក). អត្តនា ច បាណាតិបាតី ហោតិ** ជាអ្នកសម្លាប់សត្វដោយខ្លួនឯង ;

**ខ). បរញ្ច បាណាតិបាតេ សមាទបេតិ** បបួល ឬប្រើអ្នកដទៃ ឲ្យសម្លាប់សត្វ ;

**គ). បាណាតិបាតេ សមនុញ្ញោ ហោតិ** ត្រេកអរនឹងគេសម្លាប់សត្វ ;

**ឃ). បាណាតិបាតស្ស ច វណ្ណំ ភាសតិ** ពោលសរសើរនូវកិរិយាសម្លាប់សត្វ ។

## ២. អទិន្នាទានចែកជា ៤ គឺ ៖

**ក). អត្តនា ច អទិន្នាទាយី ហោតិ** ជាអ្នកកាន់យកនូវទ្រព្យដែលគេមិនបានឲ្យដោយខ្លួនឯង ;

**ខ). បរញ្ច អទិន្នាទានេ សមាទបេតិ** បបួលឬប្រើគេឲ្យកាន់យកនូវទ្រព្យដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ;

**គ). អទិន្នាទានេ ច សមនុញ្ញោ ហោតិ** ត្រេកអរនឹងគេលួចបានមក ;

**ឃ). អទិន្នាទានស្ស ច វណ្ណំ ភាសតិ** ពោលសរសើរក្នុងការលួច ។

## ៣. កាមេសុមិច្ឆាចារចែកជា ៤ គឺ ៖

**ក). អត្តនា ច កាមេសុមិច្ឆាចារី ហោតិ** ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយដោយខ្លួនឯង ;

**ខ). បរញ្ច កាមេសុមិច្ឆាចារេ សមាទបេតិ** បបួលអ្នកដទៃឲ្យប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ;

**គ). កាមេសុមិច្ឆាចារេ ច សមនុញ្ញោ ហោតិ** ត្រេកអរក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ;

**ឃ). កាមេសុមិច្ឆាចារស្ស ច វណ្ណំ ភាសតិ** ពោលសរសើរក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

## ៤. មុសាវាទចែកជា ៤ គឺ ៖

**ក). អត្តនា ច មុសាវាទី ហោតិ** ជាអ្នកពោលកុហកដោយខ្លួនឯង ;

**ខ). បរញ្ច មុសាវាទេ សមាទបេតិ** បបួលអ្នកដទៃឲ្យពោលកុហក ;

**គ). មុសាវាទេ ច សមនុញ្ញោ ហោតិ** ត្រេកអរនឹងគេពោលកុហក ;

**ឃ). មុសាវាទស្ស ច វណ្ណំ ភាសតិ** ពោលសរសើរនូវពាក្យកុហក ។

## ៥. បិសុណាវាចាចែកជា ៤ គឺ ៖

**ក). អត្តនា ច បិសុណាវាចា ហោតិ** ជាអ្នកពោលពាក្យញុះញង់អុជអាលដោយខ្លួនឯង ;

**ខ). បរញ្ច បិសុណាវាចាយ សមាទបេតិ** បបួលគេ ឬប្រើគេឲ្យញុះញង់អុជអាល ;

**គ). បិសុណាវាចាយ ច សមនុញ្ញោ ហោតិ** ត្រេកអរនឹងពាក្យញុះញង់អុជអាល ;

**ឃ). បិសុណាវាចាយ ច វណ្ណំ ភាសតិ** ពោលសរសើរនូវពាក្យញុះញង់អុជអាល ។

## ៦. ផរុសវាចាចែកជា ៤ គឺ ៖

**ក**). **អត្តនា ច ផរុសវាចា ហោតិ** ជាអ្នកពោលពាក្យជេរប្រទេចដោយខ្លួនឯង ;

**ខ**). **បរញ្ច ផរុសវាចាយ សមាទបេតិ** បបួលគេ ឬប្រើគេឲ្យជេរប្រទេចផ្ដាសារ ;

**គ**). **ផរុសវាចាយ ច សមនុញ្ញោ ហោតិ** ត្រេកអរនឹងគេជេរប្រទេចផ្ដាសារ ;

**ឃ**). **ផរុសវាចាយ ច វណ្ណំ ភាសតិ** ពោលសរសើរនូវពាក្យជេរប្រទេចផ្ដាសារ ។

## ៧. សម្ផប្បលាបចែកជា ៤ គឺ ៖

**ក**). **អត្តនា ច សម្ផប្បលាបោ ហោតិ** ជាអ្នកពោលពាក្យរោយរាយឥតប្រយោជន៍ដោយខ្លួនឯង ;

**ខ**). **បរញ្ច សម្ផប្បលាបេ សមាទបេតិ** បបួលគេ ឬប្រើគេឲ្យនិយាយនូវពាក្យរោយរាយឥតប្រយោជន៍ ;

**គ**). **សម្ផប្បលាបេ ច សមនុញ្ញោ ហោតិ** ត្រេកអរនឹងគេនិយាយការ ឬរឿងរ៉ាវឥតប្រយោជន៍ ;

**ឃ**). **សម្ផប្បលាបស្ស ច វណ្ណំ ភាសតិ** ពោលសរសើរនូវពាក្យរោយរាយឥតប្រយោជន៍ ។

## ៨. អភិជ្ឈាចែកជា ៤ គឺ ៖

**ក). អត្តនា ច អភិជ្ឈាលុ ហោតិ** ជាអ្នកសំឡឹងរំពៃចំពោះទ្រព្យអ្នកដទៃមកដើម្បីខ្លួនដោយខ្លួនឯង ;

**ខ). បរញ្ច អភិជ្ឈាយ សមាទបេតិ** បបួលគេ ឬប្រើគេឲ្យសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ;

**គ). អភិជ្ឈាយ ច សមនុញ្ញោ ហោតិ** ត្រេកអរនឹងគេសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ;

**ឃ). អភិជ្ឈាយ ច វណ្ណំ ភាសតិ** ពោលសរសើរនូវកិរិយាសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ។

## ៩. ព្យាបាទចែកជា ៤ គឺ ៖

**ក). អត្តនា ច ព្យាបាទី ហោតិ** ជាអ្នកគុំកួនគេខ្លួនឯង ;

**ខ). បរញ្ច ព្យាបាទេ សមាទបេតិ** បបួលគេ ឬ ប្រើអ្នកដទៃឲ្យគុំកួនគេ ;

**គ). ព្យាបាទេ ច សមនុញ្ញោ ហោតិ** ត្រេកអរនឹងគេគុំកួនដល់អ្នកដទៃ ;

**ឃ). ព្យាបាទស្ស ច វណ្ណំ ភាសតិ** ពោលសរសើរនូវពាក្យគុំកួន ។

## ១០. មិច្ឆាទិដ្ឋិចែកជា ៤ គឺ ៖

**ក). អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ** ជាអ្នកមានទិដ្ឋិយល់ខុសដោយខ្លួនឯង ;

**ខ). បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ** បបួលគេឬពន្យល់អ្នកដទៃឲ្យយល់ខុសតាមខ្លួន ;

**គ). មិច្ឆាទិដ្ឋិយា ច សមនុញ្ញោ ហោតិ** ត្រេកអរនឹងការយល់ខុស ;

**ឃ). មិច្ឆាទិដ្ឋិយា ច វណ្ណំ ភាសតិ** ពោលសរសើរនូវមិច្ឆាទិដ្ឋិ ។

ចំណែកអកុសលកម្មបថមាន ៤០ ដូចគ្នាដែរ តែក្នុងទីនេះមិនបានចែកទេ ប្លែកគ្នាតែត្រង់ «**អកុសលប្រព្រឹត្តកន្លង**» «**កុសលវៀរ**» អ្នកសិក្សាគប្បីពិនិត្យតាមន័យនេះចុះ ។

( **ចប់អកុសលកម្មបថ ៤០ តែប៉ុណ្ណោះ** )

## មូលកម្មបថ[១]

**សំណួរ.** អកុសលកម្មបថទាំង ១០ នេះកម្មបថណារាប់ចូល

(១) មូល សំ. បា. ( ន. ) ឫស; គល់, ឫសគល់; មើម, ដើមកំណើត, ដើមចម, ដើមទង, ទីតាំង; ទីជិត; ទ្រព្យដើម; តម្លៃ... ។

កម្មបថ (កាំម៉ៈបត់) ន. (បា.) ផ្លូវ ឬ គន្លងនៃកម្ម គឺដំណើររបស់អំពើអាក្រក់ ឬ ល្អដែលសត្វលោកធ្វើដោយ កាយ វាចា ចិត្ត ។

ក្នុង " **មូល** " ណា ?

**ចម្លើយ**. អកុសលកម្មបថ ទាំង ១០ នេះរាប់ចូលក្នុងមូល ទាំង ៣ ដូច្នេះគឺ ៖

- **បាណាតិបាត** មានមូល ២ គឺទោសមូល ១, មោហមូល១ ;
- **អទិន្នាទាន** មានមូល ៣ គឺលោភមូល ១, ទោសមូល ១, មោហមូល ១ ;
- **កាមេសុមិច្ឆាចារ** មានមូល ២ គឺលោភមូល ១, មោហមូល ១ ;
- **មុសាវាទ** មានមូល ៣ គឺលោភមូល ១, ទោសមូល ១, មោហមូល ១ ;
- **បិសុណាវាចា** និង **សម្ផប្បលាបៈ**(១) ទាំងពីរនេះមានមូលដូច **មុសាវាទ** ;
- **ផរុសវាចា** មានមូល ២ គឺទោសមូល ១, មោហមូល ១
- **អភិជ្ឈា** មានមូល ១ គឺទោសមូល ;
- **ព្យាបាទ** មានមូល ១ គឺទោសមូល ;
- **មិច្ឆាទិដ្ឋិ** មានមូល ២ គឺលោភមូល ១, មោហមូល ១ ។

អកុសលកម្មបថ មានមូលផ្សេងៗគ្នា ដូចវិស្សជ្ជនាមកនេះ។

---

(១) សម្ផប្បលាប ស័ម-ផ័ប-ប៉ៈ ល៉ាប៉ៈ បា. ( ន. ) (សម្ផប្បលាប < សម្ផ "បង្ខូចប្រយោជន៍; ឥតប្រយោជន៍;..." + ប- លាប "ការពោល, និយាយ") សម្ដីបង្ខូចប្រយោជន៍, សម្ដីឥតប្រយោជន៍, ពាក្យរោយរាយ, សម្ដីឥតសព្វឥតសារ (រាប់ចូលក្នុងវចីទុច្ចរិត) ។

**ស.** **បាណាតិបាត** ហេតុដូចម្ដេចក៏ចាត់ចូលក្នុងមូលពីរ, លោភមូល ម្ដេចក៏មិនចាត់ចូលផង ?

**ច.** លោភមូល បានជាមិនរាប់ចូលក្នុងបាណាតិបាតនោះ ព្រោះបាណាតិបាត មានកិរិយាផ្ដាច់បង់នូវជីវិតសត្វ គឺប្រទូស្តនឹងអារម្មណ៍មូលទាំងពីរនេះកើតក្នុងទីជាមួយគ្នាមិនបាន ទោសៈនិងមោហៈ កើតក្នុងទីជាមួយគ្នាបាន បានជាថាបាណាតិបាត មានមូលពីរដូច្នេះ ។

**ស.** **អទិន្នាទាន** ដែលចាត់ចូលក្នុងមូលទាំង ៣ នោះ, អធិប្បាយដូចម្ដេច ?

**ច.** អទិន្នាទាន ប្រកបដោយ លោភៈ និងមោហៈ លួចទ្រព្យរបស់គេយកមកដើម្បីនឹងប្រើប្រាស់ចាយវាយ លោភៈកើតឡើង មោហៈនាំវង្វេង បានជាកើតលួច ទោសៈនិងមោហៈកើតសេចក្ដីព្យាបាទលួចដុតផ្ទះឬបំផ្លាញរបស់អ្វីៗចោល ដោយទោសចិត្ត មូលទាំង ៣ នេះមិនដែលកើតជាមួយគ្នាទាំង ៣ អង្គទេ កើតឡើងផ្លាស់ប្តូរគ្នាដូចវិស្សជ្ជនាមកស្រាប់ ។

**ស.** **កាមេសុមិច្ឆាចារ** ហេតុដូចម្ដេចបានជាចាត់ចូលក្នុង «**លោភមូល**» ?

**ច.** កាមេសុមិច្ឆាចារ បានជាចាត់ចូលក្នុង «**លោភមូល**» ព្រោះលោភៈ ប្រែថាចិត្តជំពាក់នឹងអារម្មណ៍ គឺផស្សារម្មណ៍[១]ប៉ះ

---

(១) ផស្ស ផ័ស-សៈ បា.; សំ. (ន.) (ផស្ប; ស្បត៌) សម្ផស្ស, ផ្សព្វ គឺអារម្មណ៍ដែលមកប៉ះត្រូវអាយតនៈ មានភ្នែកជាដើម, ការប៉ះពាល់ត្រូវ ។

ពាល់ត្រូវគ្នា ។

កម្មបថណាដែលមានកម្មបថ ៣ ៗ អធិប្បាយដូចអទិន្នាទាន ប្លែកគ្នាត្រង់សេចក្ដី ដំណើរលោភៈ ទោសៈ មោហៈដូចគ្នា ។

**ស. អភិជ្ឈា**[១] និង **ព្យាបាទ** ក្នុងទីនេះហេតុអ្វីក៏ចាត់ជាមូល ១, កម្មបថដទៃៗ ខ្លះមូល ២, ខ្លះមូល ៣ ?

**ឆ** . អភិជ្ឈា និង ព្យាបាទ បានជាចាត់ចូលក្នុងមូល ១ នោះព្រោះ អភិជ្ឈាកើតឡើងគ្រាន់តែសំឡឹងរំពៃទ្រព្យប៉ុណ្ណោះ, ព្យាបាទគ្រាន់តែគំនុំគុំកួនគេ ចង់ឲ្យគេវិនាសប៉ុណ្ណោះ កម្មបថ ២ នេះ មនោកម្ម មនោទ្វារ បានជាចាត់ចូលក្នុងមូលមួយៗ ។

**ស. មិច្ឆាទិដ្ឋិ** ហេតុដូចម្ដេចបានជាមិនចាត់ជាតួ «**មោហៈ**» ផង ?

**ឆ.** មិច្ឆាទិដ្ឋិ នេះមិនមែនជាតួ «**មោហៈ**» ទេ មានសេចក្ដីផ្សេងគ្នាមោហៈចេញទៅជា **ឧទ្ធច្ច** និង **វិចិកិច្ឆា**, **មិច្ឆាទិដ្ឋិ** គឺ **និយតមិច្ឆាទិដ្ឋិ** នេះឯង ។

**ស.** កុសលកម្មបថ ១០ បណ្ឌិតគប្បីវិនិច្ឆ័យដោយអាការៈប៉ុន្មានយ៉ាង ?

**ឆ.** កុសលកម្មបថ ១០ បណ្ឌិតគប្បីវិនិច្ឆ័យដោយអាការៈ ៥ យ៉ាង ។

---

(១) អភិជ្ឈា អៈភិច-ឈា បា.; សំ. ( ន. ) (អភិធ្យា) គំនិតសម្លឹងរំពៃរកទំនងឲ្យបានទ្រព្យអ្នកដទៃមកជារបស់ខ្លួន; ការចង់បានហួសហេតុហួសទំនង; តណ្ហា; អភិលាស : អភិជ្ឈាជាទុច្ចរិតមួយខាងផ្លូវចិត្ត រាប់ចូលជាមនោទុច្ចរិត មួយក្នុងមនោទុច្ចរិត ៣ យ៉ាង ។

**ស**. អាការៈ ៥ យ៉ាងនោះគឺអ្វីខ្លះ, ចូររាប់និងអធិប្បាយ !

**ច**. អាការៈ ៥ យ៉ាងនោះគឺ ៖ **ធម្មៈ ១, កោដ្ឋាសៈ ១, អារម្មណ៍ ១, វេទនា ១, មូល ១** ។

អធិប្បាយថា កម្មបថ ១០ ចែកជា ២, កម្មបថ ៧ ខាងដើម ចាត់ជាចេតនាធម៌ ព្រោះមានវិរតិ សម្រាប់វៀរដោយកាយនិងវាចា, កម្មបថ ៣ ខាងចុង ចាត់ជាចេតនាសុទ្ធ ដូច្នេះឈ្មោះថា **ធម្មៈ** ។ កម្មបថ ៧ ខាងដើម ចាត់ជាកម្មបថសុទ្ធ មិនបានចាត់ជាមូលទេ, កម្មបថ ៣ ខាងចុង ចាត់ជាកម្មបថផង ជាមូលផង ដូច្នេះឈ្មោះថា **កោដ្ឋាសៈ** ។

ដូច បាណាតិបាត មានជីវិតិន្ទ្រិយារម្មណ៍ជាដើម ឧបមាដូចជាព្រះអរិយមគ្គមានព្រះនិព្វានជាអារម្មណ៍ ហើយលះបង់នូវកិលេសនោះយ៉ាងណា កុសលកម្មបថ មានជីវិតិន្ទ្រិយ[១]ជាអារម្មណ៍ដើម្បីនឹងលះបង់នូវភាវៈទ្រុស្តសីលក៏យ៉ាងនោះដែរដូច្នេះ ឈ្មោះថា **អារម្មណ៍** ។

វេទនា[២]នោះដូច្នេះ កុសលកម្មបថទាំង ១០ នោះមានវេទនាពីរគឺ ៖ សុខវេទនា ១, មជ្ឈត្តវេទា ១[៣] ឯទុក្ខវេទនាមិនមានឡើយ

(១) ជីវិតិន្ទ្រិយ --តិន ទ្រី បា.; សំ. ( ន. ) (ជីវិតិន្ទ្រិយ; ជីវិតេន្ទ្រិយ) ឥន្ទ្រិយគឺជីវិត, អំណាចនៃជីវិត, កម្លាំងជីវិត ។

(២) វេទនា --ទៈ-- សំ. បា. ( ន. ) ការទទួលអារម្មណ៍, ការសោយឬការរងអារម្មណ៍, ការដឹងអារម្មណ៍ជាសុខឬជាទុក្ខ... ។ ច្រើនសំដៅចំពោះការទទួលអារម្មណ៍ជាទុក្ខ : គួរឲ្យមានវេទនាណាស់ ! ។

(៣) មជ្ឈត្តវេទនា វេទនាជាកណ្ដាល ។

ដូច្នេះឈ្មោះថា **វេទនា** ។

មូលនោះដូច្នេះ កម្មបថ ៧ ខាងដើមបើវៀរដោយញាណសម្បយុត្ត[១]ចាត់ជាមូល ៣ គឺ ៖ អលោភៈ, អទោសៈ, អមោហៈ បើវៀរដោយញាណវិប្បយុត្ត ចាត់ជាមូលពីរគឺ អលោភៈ និង អទោសៈ ។

អភិជ្ឈា បើវៀរដោយញាណសម្បយុត្តចាត់ជាមូល ២ គឺ អទោសៈ និង អមោហៈ បើវៀរដោយ ញាណវិប្បយុត្ត ចាត់ជាមូល ១ គឺ អទោសៈ ។ អព្យាបាទ ដូចអភិជ្ឈាដែរ ។ សម្មាទិដ្ឋិមានមូល ២ គឺ អលោភៈ និង អទោសៈ ដូច្នេះឈ្មោះថា **មូល** ។

**ស.** សម្មាទិដ្ឋិ ហេតុអ្វីក៏មិនចាត់ជាញាណវិប្បយុត្តផង ?

**ឆ.** បានជាមិនចាត់ជាញាណវិប្បយុត្ត ព្រោះសម្មាទិដ្ឋិនេះជាតួប្រាជ្ញាសុទ្ធ ចាំបាច់ជាញាណវិប្បយុត្តធ្វើអ្វីទៀត ។

កម្មបថ ១០ បើចាត់ជាសីលគឺ កម្មបថ ៧ ខាងដើមចាត់ជាចេតនាសីល កម្មបថ ៣ ខាងចុង ចាត់ជាចេតសិកសីល ។

**ស.** ហេតុដូចម្ដេចក៏កម្មបថ ៧ ខាងដើម ចាត់ជាចេតនាសីល ?

**ឆ.** កម្មបថ ៧ ខាងដើម បានចាត់ជាចេតនាសីលព្រោះមានវិរតិវៀរដោយកាយនិងវាចា បានជាចាត់ជា **ចេតនាសីល** ។

---

(១) សម្បយុត្ត ស័ម-ប៉ៈយុត បា.; សំ. ( កិ. ឬ គុ. ) (សំប្រយុក្ត ឬ សម្ប្រ--) ប្រកប, ផ្សំ; ដែលប្រកប, ដែលផ្សំហើយ, ដែលលាយច្រឡំ, ដែលរួមចូលគ្នា : ចិត្តសម្បយុត្តដោយអំណរ ។ ញាណសម្បយុត្ត ចិត្តដែលសម្បយុត្តដោយការដឹង, ដោយប្រាជ្ញា ។

**ស**. កម្មបថ ៣ ខាងចុង ហេតុដូចម្ដេចបានជាចាត់ជាចេតសិកសីល ?

**ច**. បានជាចាត់ជាចេតសិកសីល ព្រោះរៀរតែផ្លូវចិត្តម្យ៉ាង ក៏គង់កើតជាសីលបាន ទើបហៅថា **ចេតសិកសីល** ។

( **ចប់មូលកម្មបថតែប៉ុណ្ណោះ** )

# អារម្មណ៍កម្មបថ

**ស. បាណាតិបាត** មានអ្វីជាអារម្មណ៍ ?

**ច**. បាណាតិបាត មានជីវិតិន្ទ្រិយជាអារម្មណ៍ គឺអ្នកសម្លាប់សត្វណា មានជីវិតរបស់សត្វនោះ ជាអារម្មណ៍ ។

**ស. អទិន្នាទាន** មានអ្វីជាអារម្មណ៍ ?

**ច**. អទិន្នាទាន មានសត្វនិងសង្ខារជាអារម្មណ៍ ។ បានជាចាត់ថាមានសត្វនិងសង្ខារជាអារម្មណ៍នោះ សត្វគឺម្ចាស់ សង្ខារគឺទ្រព្យ អ្នកលួចនោះតែងនឹកក្រែងម្ចាស់ទ្រព្យគេទាន់ ត្រង់នេះចាត់ថាមានសត្វជាអារម្មណ៍ នឹករកទ្រព្យនៅត្រង់នេះនៅត្រង់នោះចាត់ថាមានសង្ខារជាអារម្មណ៍ ។

**ស. កាមេសុមិច្ឆាចារ** មានអ្វីជាអារម្មណ៍ ?

**ច**. កាមេសុមិច្ឆាចារ មានសង្ខារជាអារម្មណ៍ ។ បានជាចាត់ថា មានសង្ខារជាអារម្មណ៍នោះ សង្ខារគឺសម្ផស្សដែលប៉ះពាល់ត្រូវ អ្នកប្រព្រឹត្តកាមេរមែងនឹករកតែសម្ផស្សម្យ៉ាងជាអារម្មណ៍បាន

ជាចាត់ថាមានសង្ខារជាអារម្មណ៍ ។

**ស. មុសាវាទ** មានអ្វីជាអារម្មណ៍ ?

**ឆ.** មុសាវាទ មានសត្វនិងសង្ខារជាអារម្មណ៍ ។ បានជាចាត់ថា មានសត្វជាអារម្មណ៍នោះ ព្រោះអ្នកពោលនូវមុសាវាទចំពោះបុគ្គលណា ប្រារព្ធនូវបុគ្គលនោះទើបប្រព្រឹត្តទៅបាន ។ សង្ខារនោះ គឺបម្រុងនឹងចង់បានរបស់គេដោយពាក្យកុហក ។

- **បិសុណាវាចា** ដូច **មុសាវាទ** ។
- **ផរុសវាចា** មានសត្វជាអារម្មណ៍ ។
- **សម្ផប្បលាប:** មានសត្វនិងសង្ខារជាអារម្មណ៍ ។
- **អភិជ្ឈា** ក៏ដូចជា **សម្ផប្បលាប:** ដែរ ។
- **ព្យាបាទ** មានសត្វជាអារម្មណ៍តែម្យ៉ាង ។
- **មិច្ឆាទិដ្ឋិ** កាលបើយល់ថា សត្វស្លាប់ហើយមិនកើតទៀតដូច្នេះជាដើម មានតេភូមិកធម៌ គឺធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ជាអារម្មណ៍ ឬនឹងថាមានសង្ខារជាអារម្មណ៍ ដូច្នេះវិញក៏បាន ។

**ស.** ដូចម្តេច **សត្វ** ? ដូចម្តេច **សង្ខារ** ? ចូរឆ្លើយមកមើល !

**ឆ.** សត្វនោះ បានដល់កូនប្រពន្ធនិងរបស់ដែលមានវិញ្ញាណ, សង្ខារបានដល់ទ្រព្យដែលឥតវិញ្ញាណ ។

( **ចប់អារម្មណ៍កម្មបថ ១០ ដោយសង្ខេប** )

**ស**. កិច្ចប្រតិបត្តិរបស់គ្រហស្ថមានតែត្រឹមប៉ុណ្ណឹង ឬមានតទៅទៀតដែរ ?

**ឆ**. កិច្ចប្រព្រឹត្តិរបស់គ្រហស្ថមានច្រើនតទៅទៀត ។

**ស**. កិច្ចក្រោយដែលមានតទៅទៀតនោះគឺអ្វីខ្លះ ?

**ឆ**. កិច្ចក្រោយដែលមានតទៅទៀតនោះដូច្នេះគឺ ៖ វៀរចាកអបាយមុខ ៦ យ៉ាង, ប្រតិបត្តិមាតាបិតា, ប្រតិបត្តិដល់កូន, ប្រតិបត្តិដល់ស្វាមីភរិយា, ប្រតិបត្តិដល់ពលី ៥ យ៉ាង, ប្រតិបត្តិដល់គ្រូឧបជ្ឈាយ៍ និងប្រតិបត្តិដល់សមណៈ និងធ្វើប្រយោជន៍ទាំងពីរឲ្យកើតឡើង ។

**ស**. អបាយមុខ ៦ យ៉ាងនោះគឺអ្វីខ្លះ ? គ្រហស្ថត្រូវវៀរចាកដូចម្ដេច ?

**ឆ**. **អបាយមុខ ៦** យ៉ាងនោះគឺ ៖

**១. សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគោ** កិរិយាប្រកបរឿយៗ ក្នុងកិរិយាផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទ ;

**២. វិកាលវិសិខាចរិយានុយោគោ** កិរិយាប្រកបរឿយៗ ក្នុងការដើរលេងតាមច្រកល្ហក ក្នុងវេលាយប់ខុសកាល ;

**៣. សមជ្ជាភិចរណំ** កិរិយាដើរមើលល្បែងមហោស្រព ;

**៤. ជូតប្បមាទដ្ឋានានុយោគោ** កិរិយាប្រកបរឿយៗ ក្នុងការលេងល្បែងភ្នាល់ ដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទ ;

**៥. បាបមិត្តានុយោគោ** កិរិយាប្រកបរឿយៗដោយបាបមិត្ត;

**៦. អលសានុយោគោ** កិរិយាប្រកបរឿយៗ ដោយសេចក្ដីខ្ជិលច្រអូស ។

អបាយមុខ ៦ យ៉ាងនេះឧបាសក, ឧបាសិកាមិនត្រូវប្រព្រឹត្តឡើយ ។

**ស**. កូនត្រូវប្រតិបត្តិមាតាបិតា ដោយស្ថានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ឆ**. កូនត្រូវប្រតិបត្តិមាតាបិតា ដោយស្ថាន ៥ យ៉ាងគឺ ៖

**១. ភតោ នេសំ ភរិស្សាមិ** កូនត្រូវតាំងចិត្តថា អញគឺមាតាបិតាអញបានចិញ្ចឹមរក្សាមកហើយ អញត្រូវចិញ្ចឹមមាតាបិតាវិញ ;

**២. កិច្ចំនេសំ ករិស្សាមិ** កូនត្រូវតាំងចិត្តថា កាលបើមាតាបិតាមានកិច្ចរវល់ អញត្រូវបញ្ឈប់ការងាររបស់ខ្លួនទុកសិន ហើយជួយធ្វើកិច្ចការរវល់របស់មាតាបិតា ;

**៣. កុលវំសំ ឋបេស្សាមិ** កូនត្រូវតាំងចិត្តថា អញត្រូវតម្កល់វង្សត្រកូលមាតាបិតាទុកឲ្យល្អមិនឲ្យវិនាស គឺថានឹងមិនញ៉ាំងឲ្យទ្រព្យសម្បត្តិរបស់មាតាបិតាវិនាសដោយការឥតប្រយោជន៍ និងសង្គ្រោះឲ្យផុតអំពីវង្សដែលមិនប្រកបដោយធម៌ ហើយឲ្យតាំងនៅក្នុងវង្សដែលប្រកបដោយធម៌ និងមិនផ្ដាច់បង់នូវការកុសលទាំងឡាយមានសលាកភត្តជាដើមដែលមាតាបិតា បានប្រព្រឹត្តធ្វើតាមគន្លងត្រូវល្អមកហើយ ;

**៤. ទាយជ្ជំ បដិបជ្ជាមិ** កូនត្រូវតាំងចិត្តថា អញនឹងតាំងចិត្តគំនិតមារយាទឲ្យល្អ ឲ្យជាទីពេញចិត្តនៃមាតាបិតា ឲ្យជា

មនុស្សគួរមាតាបិតានឹងប្រគល់ទ្រព្យសម្បត្តិកេរដំណែលឲ្យ ;

**៥. ទក្ខិណំ អនុប្បទស្សាមិ** កូនត្រូវតាំងចិត្តថា កាលបើមាតាបិតាធ្វើកាលកិរិយាហើយអញត្រូវធ្វើទក្ខិណានុប្បទានឧទ្ទិសចំណែកផលបុណ្យជូនដល់មាតាបិតាជារឿយៗ ចាប់តាំងពីថ្ងៃគំរប់ ៣ អំពីថ្ងៃដែលមាតាបិតាដល់នូវមរណកាលនោះតរៀងទៅ ។

**ស**. មាតាបិតាត្រូវប្រតិបត្តិកូននោះដូចម្ដេច ? ហេតុដូចម្ដេចបានជាមាតាបិតាត្រូវប្រតិបត្តិកូន ? គួរតែកូនប្រតិបត្តិមាតាបិតាវិញទើបគួរ ?

**ឆ**. មាតាបិតាត្រូវប្រតិបត្តិកូននោះ មិនមែនទៅគោរពលំអុតលំឱនដល់កូននោះទេ កិច្ចប្រតិបត្តិក្នុងទីនេះ សំដៅយកការសង្គ្រោះដល់កូនទេតើ ! ។

**ស**. កិច្ចដែលត្រូវសង្គ្រោះដល់កូននោះ តើមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ឆ**. កិច្ចដែលត្រូវសង្គ្រោះដល់កូននោះមាន ៥ យ៉ាងគឺ ៖

**១. បាបានិ វារេន្តិ** ហាមឃាត់កូនមិនឲ្យធ្វើកម្មអាក្រក់មានឃាត់មិនឲ្យសម្លាប់សត្វ និងមិនឲ្យលួចទ្រព្យគេជាដើម ;

**២. កល្យាណេ និវេសេន្តិ** តាំងនៅក្នុងកម្មជាកុសល មានទាននិងសីលជាដើម ;

**៣. សិប្បំ សិក្ខាបេន្តិ** ឲ្យកូនសិក្សារៀនសិល្បសាស្ត្រចំណេះវិជ្ជាដែលគួររៀនមានអក្សរនិងលេខជាដើម ;

**៤. បតិរូបេន ទារេន សំយោជេន្តិ** រៀបចំឲ្យកូនមាន

ភរិយាឬស្វាមី តាមសមគួរដល់ជាតិ និងត្រកូល និងទ្រព្យសម្បត្តិ ;

**៥. សមយេ ទាយជ្ជំ និយ្យាទេន្តិ** ឲ្យទ្រព្យសម្បត្តិដល់កូនក្នុងសម័យ ២ យ៉ាងគឺ ៖ និច្ចសម័យ ១, កាលសម័យ ១ ។

- **និច្ចសម័យ** នោះគឺឲ្យទ្រព្យសម្បត្តិរឿយៗ ដើម្បីឲ្យកូនចាយវាយតាមកាលគួរ ឬឲ្យដើម្បីឲ្យធ្វើកុសលណាមួយ ។

- **កាលសម័យ** នោះគឺ ឲ្យទ្រព្យសម្បត្តិក្នុងកាលដែលបានរៀបចំឲ្យកូនមានភរិយា-ស្វាមីហើយ ឬឲ្យក្នុងកាលដែលខ្លួនជិតនឹងដល់នូវមរណភាព ។

**ស**. កិច្ចដែលស្វាមី ត្រូវប្រតិបត្តិដល់ភរិយានោះមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ឆ**. កិច្ចដែលស្វាមី ត្រូវប្រតិបត្តិដល់ភរិយានោះមាន ៥ យ៉ាងគឺ ៖

**១. សម្មាននាយៈ** ដោយសេចក្ដីរាប់អានដោយសំដីទន់ផ្អែមទៅរកភរិយា ;

**២. អវិមាននាយៈ** ដោយកិរិយាមិនបៀតបៀន គឺមិនមើលងាយភរិយាដូចជាទាសកម្មករ ;

**៣. អនតិចរិយាយៈ** ដោយកិរិយាមិនប្រព្រឹត្តកន្លងចិត្តភរិយា ;

**៤. ឥស្សរិយវោស្សគ្គេន** ដោយកិរិយាប្រគល់នូវគ្រឿងឥស្សរិយយស គឺភារៈជាធំក្នុងការចាត់ចែងនូវខាទនីយៈ និងភោជនីយាហារឲ្យដាច់មុខទៅភរិយា ;

**៥. អលង្ការានុប្បទានេន** ដោយកិរិយាទំនុកបំរុងគ្រឿងប្រដាប់ដល់ភរិយាតាមសមគួរដល់សម្បត្តិរបស់ខ្លួន ។

**ស.** កិច្ចដែលភរិយា ត្រូវប្រតិបត្តិដល់ស្វាមីដោយស្ថានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ឆ.** កិច្ចដែលភរិយា ត្រូវប្រតិបត្តិដល់ស្វាមីដោយស្ថាន ៥ យ៉ាងនោះគឺ ៖

**១. សុសំវិហិតកម្មន្តា** ចាត់ចែងការងារ មានការចំអិននូវអាហារគឺបបរនិងបាយជាដើម ដោយផ្ចិតផ្ចង់ឲ្យត្រូវតាមពេលកំណត់ ;

**២. សុសង្គហិតបរិជនា** សង្គ្រោះដល់ជនជាញាតិរបស់ស្វាមីនិងញាតិរបស់ខ្លួនដោយស្មោះស្មើ ;

**៣. សម្ភតញ្ច អនុរក្ខតិ** ថេះថែទាំនូវទ្រព្យសម្បត្តិដែលស្វាមីរកបានមកហើយ ;

**៤. អនតិចារិនី** មិនប្រព្រឹត្តកន្លងចិត្តស្វាមី ;

**៥. ទក្ខា ច ហោតិ អនលសា សព្វកិច្ចេសុ** ជាស្ត្រីឈ្លាសវៃប្រសប់ក្នុងកិច្ចការទាំងឡាយ មានការចាត់ចែងនូវបបរនិងបាយជាដើមឥតខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង ហើយអាចញ៉ាំងកិច្ចការទាំងនោះឲ្យសម្រេចបាន ។

**ស.** កិច្ចដែលឧបាសក ឧបាសិកា ត្រូវប្រតិបត្តិ, ផ្គត់ផ្គង់ដល់សមណៈនោះមានប៉ុន្មានយ៉ាង ?

**ឆ.** កិច្ចដែលឧបាសក ឧបាសិកា ត្រូវប្រតិបត្តិ, ផ្គត់ផ្គង់ដល់

សមណៈនោះមាន ៥ យ៉ាងគឺ ៖

**១. មេត្តេន កាយកម្មេនៈ** ដោយកាយកម្មប្រកបដោយមេត្តា គឺថាធ្វើនូវកិច្ចដោយកាយ មានទៅនិមន្តលោកដល់វត្ត និងទទួលយកនូវធម្មក្រក[១] ទៅត្រងទឹកប្រគេនលោក និងគក់ច្របាច់ជាដើម ដោយសេចក្ដីរាប់អានដ៏ស្មោះត្រង់អស់ពីដួងចិត្ត ;

**២. មេត្តេន វចីកម្មេនៈ** ដោយវចីកម្មប្រកបដោយមេត្តា គឺថាធ្វើនូវកិច្ចដោយវាចា មានពោលពាក្យដាស់តឿនអ្នកឯទៀតឲ្យធ្វើទានដល់សមណព្រាហ្មណ៍ និងបន្លឺនូវសព្ទសាធុការ ក្នុងកាលដែលស្ដាប់ធម៌ទេសនាចប់និងធ្វើបដិសណ្ឋារៈ ដោយសំដីរាក់ទាក់ជាដើមដោយសេចក្ដីរាប់អានដ៏ស្មោះត្រង់អស់ពីដួងចិត្ត ;

**៣. មេត្តេន មនោកម្មេនៈ** ដោយមនោកម្មប្រកបដោយមេត្តា គឺថាធ្វើនូវកិច្ចដោយចិត្តមានគិតថា ព្រះថេរៈទាំងឡាយដែលលោកតែងនិមន្តមកកាន់ត្រកូលរបស់យើង សូមឲ្យលោកបានប្រកបដោយសេចក្ដីសុខសប្បាយជាដើម ដោយសេចក្ដីរាប់អានដ៏ស្មោះត្រង់អស់ពីដួងចិត្ត ;

**៤. អនាវដទ្វារតាយៈ** ដោយភាវៈជាអ្នកមានទ្វារផ្ទះមិនបិទ គឺថាជាអ្នកឧស្សាហ៍ធ្វើទានដល់សមណព្រាហ្មណ៍ កាលបើឃើញសមណព្រាហ្មណ៍មកដល់ហើយ ក៏ឲ្យទានដោយមិនបានត្អូញត្អែរចំពោះរបស់ដែលមាននោះ ថាជាគ្មានទៅវិញឡើយ ;

---

(១) តម្រងសំរាប់ត្រង ឬច្រោះទឹក ការពារសត្វល្អិត ។

**៥. អាមិសានុប្បទានេន** ដោយកិរិយាឲ្យនូវអាមិស គឺឲ្យនូវខាទនីយៈ និងភោជនីយាហារដល់សមណព្រាហ្មណ៍ ។

**ស.** កិច្ចដែលឧបាសក ឧបាសិកា ត្រូវប្រតិបត្តិដល់សមណៈដូចបានរៀបរាប់មកខាងលើរួចហើយ ចុះសមណៈវិញតើមានកិច្ចសង្គ្រោះដល់ឧបាសក ឧបាសិកាវិញដែរឬទេ ?

**ច.** សមណៈត្រូវមានកិច្ចសង្គ្រោះដល់ឧបាសក ឧបាសិកាវិញដែរ មានធម៌ ៦ យ៉ាងគឺ ៖

**១. បាបា និវារេន្តិ** ហាមឃាត់ឧបាសក ឧបាសិកាមិនឲ្យធ្វើកម្មអាក្រក់ មានឃាត់មិនឲ្យសម្លាប់សត្វ និងមិនឲ្យលួចទ្រព្យគេជាដើម ;

**២. កល្យាណេ និវេសេន្តិ** ឲ្យឧបាសក ឧបាសិកាតម្កល់នៅក្នុងកុសលធម៌ មានទាននិងសីលជាដើម ;

**៣. កល្យាណេន មនសា អនុកម្បន្តិ** អនុគ្រោះឧបាសក ឧបាសិកាដោយកល្យាណចិត្ត គឺតាំងចិត្តផ្សាយមេត្តាធម៌ដល់ឧបាសក ឧបាសិកាទាំងឡាយឲ្យបានសេចក្តីសុខ កុំបីមានទុក្ខសោករោគភ័យអ្វីឡើយ ;

**៤. អស្សុតំ សាវេន្តិ** ឲ្យឧបាសក ឧបាសិកាបានស្តាប់ធម៌ដែលមិនធ្លាប់បានស្តាប់ ;

**៥. សុតំ បរិយោទបេន្តិ** ញុំាំងធម៌ដែលឧបាសក ឧបាសិកាធ្លាប់បានស្តាប់ហើយឲ្យផូរផង់ល្អ គឺថាប្រាប់ពន្យល់សេចក្តីនៃធម៌នោះៗ ឲ្យច្បាស់លាស់ប្រាកដឡើង ត្រាតែឧបាសក ឧបាសិកា

នោះលែងមានសេចក្ដីសង្ស័យ ;

**៦. សគ្គស្ស មគ្គំ អាចិក្ខន្តិ** ប្រាប់ផ្លូវសួគ៌ដល់ឧបាសក ឧបាសិកា មានប្រាប់ឲ្យដឹងដូច្នេះថា បុគ្គលដែលបានទៅកើតក្នុងស្ថានសួគ៌នោះព្រោះអំណាចនៃកុសលមានសីល ៥ និងកុសលកម្មបថ ១០ ជាដើម ។

**ស.** ពាក្យថា **ពលី** នោះប្រែថាដូចម្ដេច ? **ពលី** នោះតើមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ឆ.** ពាក្យថា **ពលី** នោះប្រែថា **បូជា** ។ ពលីនោះមាន ៥ យ៉ាងគឺ ៖ ញាតិពលី ១, អតិថិពលី ១, បុព្វបេ្បតពលី ១, រដ្ឋពលី ១, ទេវតាពលី ១ ។

**ស. ញាតិពលី** បូជាញាតិនោះដូចម្ដេច ?

**ឆ.** បូជាញាតិនោះ គឺសង្គ្រោះញាតិដោយវត្ថុផ្សេងៗ ដែលគួរនឹងសង្គ្រោះបាន ។

**ស. អតិថិពលី** បានសេចក្ដីដូចម្ដេច ?

**ឆ.** អតិថិពលីនោះ គឺបូជាភ្ញៀវដែលទើបមកដល់ថ្មីដោយវត្ថុផ្សេងៗ ដែលគួរនឹងទទួល ។

**ស. បុព្វបេ្បតពលី** បានសេចក្ដីដូចម្ដេច ?

**ឆ.** បុព្វបេ្បតពលីនោះ គឺធ្វើបុណ្យឧទ្ទិសផលបញ្ជូនទៅដល់ពួកញាតិដែលទៅកើតក្នុងលោកខាងមុខទៀត ។

**ស. រដ្ឋពលី** បានសេចក្ដីដូចម្ដេច ?

**ឆ.** រដ្ឋពលីនោះ គឺបូជាដល់រដ្ឋដោយបង់សួយសាអាករដល់

រដ្ឋការដោយចិត្តស្មោះត្រង់ ( បង់ពន្ធជូនរដ្ឋការដោយជ្រះថ្លា ) ។

**ស. ទេវតាពលី** នោះបូជាដូចម្ដេច ?

**ច.** ទេវតាពលីនោះ គឺបូជាដល់ទេវតាធ្វើបុណ្យឧទ្ទិសផល បញ្ជូនទៅដល់ទេវតា នឹកដល់ទេវតាដែលបានទៅកើតជាទេវតា ព្រោះប្រកបដោយគុណធម៌ទាំង ៥ យ៉ាងមានសទ្ធាជាដើម ។

ពលីទាំង ៥ នេះ គ្រហស្ថគប្បីប្រតិបត្តិ ដើម្បីសេចក្ដីសុខក្នុងលោកនេះ និងលោកខាងមុខ ។

**ស.** ចុះគ្រហស្ថដែលត្រូវប្រតិបត្តិប្រយោជន៍ទាំងពីរនោះ តើប្រយោជន៍ដូចម្ដេចខ្លះ ?

**ច.** ប្រយោជន៍ទាំងពីរនោះគឺ ៖

**១. ទិដ្ឋធម្មិកត្ថ** ប្រយោជន៍ក្នុងបច្ចុប្បន្ន ;

**២. សម្បរាយិកត្ថ** ប្រយោជន៍ក្នុងបរលោក ។

**ស.** ប្រយោជន៍ក្នុងបច្ចុប្បន្នមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ច.** ប្រយោជន៍ក្នុងបច្ចុប្បន្នមាន ៤ យ៉ាងគឺ ៖

**១. ឧដ្ឋានសម្បទា** ដល់ព្រមដោយការខ្នះខ្នែងប្រឹងប្រែងចាត់ចែងការងារដែលខ្លួនត្រូវប្រកបនោះៗ ដែលជាការប្រាសចាកទោស មានកសិកម្មជាដើម ;

**២. អារក្ខសម្បទា** ដល់ព្រមដោយការថែទាំរក្សាទ្រព្យដែលរកបានមកមិនឲ្យវិនាសទៅដោយហេតុផ្សេងៗ មានភ្លើងឆេះ ចោរលួច និងលេងល្បែងភ្នាល់ជាដើម ;

**៣. កល្យាណមិត្តតា** សេពគប់មិត្រល្អ គឺមិត្រដែលមាន

ចិត្តល្អ ដែលនាំឲ្យរកប្រយោជន៍ក្នុងបច្ចុប្បន្ន គឺជាមនុស្សត្រង់ មិនចេះបោកប្រាស់ក្នុងកិច្ចណាមួយ ឬរកស៊ីអ្វីៗ ជាហេតុឲ្យកើតប្រយោជន៍ ;

**៤. សមជីវិតា** ចិញ្ចឹមជីវិតដ៏ស្មើ គឺរកទ្រព្យបានមកហើយចាយវាយតាមកម្លាំងខ្លួនដែលរកបានមក មិនឲ្យខ្វះខ្វាយហួសប្រមាណលៃឲ្យស្មើដូចគេថ្លឹងនឹងជញ្ជីង ។

**ស**. ប្រយោជន៍ក្នុងបរលោកមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ឆ**. ប្រយោជន៍ក្នុងបរលោកមាន ៤ យ៉ាងគឺ ៖

**១. សទ្ធាសម្បទា** ដល់ព្រមដោយសេចក្តីជឿគុណព្រះរតនត្រ័យ ជឿកម្ម ជឿផល ;

**២. សីលសម្បទា** ដល់ព្រមដោយសីល មានសីល ៥ ជាដើម ;

**៣. ចាគសម្បទា** ដល់ព្រមដោយការលះបង់បច្ច័យ ៤ មានចីវរប្បច្ច័យជាដើមដល់សមណៈនិងព្រាហ្មណ៍ ;

**៤. បញ្ញាសម្បទា** ដល់ព្រមដោយបញ្ញា គឺការចេះដឹង ។

ប្រយោជន៍ទាំង ៤ យ៉ាងនេះ បើបុគ្គលណាបានធ្វើហើយឈ្មោះថាបានតម្រង់ផ្លូវទៅកាន់លោកខាងមុខជានិច្ច លុះរំលាងខន្ធពីនេះទៅនឹងបានទៅសុគតិដោយស្រួលមិនលំបាក ឧបមាដូចជាមនុស្សដែលដើរតាមថ្នល់ដ៏ស្អាតរមែងមិនលំបាកឡើយ ។

ប្រយោជន៍ទាំងពីរយ៉ាងនេះ បើបុគ្គលណាមិនមានទេ បុគ្គលនោះឈ្មោះថា **អន្ធបុគ្គល** គឺ **បុគ្គលគ្មានភ្នែក**, បើបុគ្គលណា

មានតែប្រយោជន៍ក្នុងបច្ចុប្បន្ន បុគ្គលនោះឈ្មោះថា **ឯកចក្ខុ-បុគ្គល** គឺបុគ្គលមានភ្នែកតែម្ខាង, បើមានប្រយោជន៍ទាំងពីរគឺ **ទិដ្ឋធម្មិកត្ថ** ប្រយោជន៍ក្នុងបច្ចុប្បន្ន និង **សម្បរាយិកត្ថ** ប្រយោជន៍ក្នុងបរលោក ឈ្មោះថា **ទិព្វចក្ខុបុគ្គល** បុគ្គលមាន**ភ្នែកពីរ** មើលឆ្វេងស្តាំឃើញបានទាំងអស់ បុគ្គលណាកាន់យកនូវប្រយោជន៍ទាំងពីរនេះបានបុគ្គលនោះឈ្មោះថា **បណ្ឌិត** សមនឹងពុទ្ធភាសិតដែល ព្រះបរមគ្រូទ្រង់សំដែងថា ៖

**ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ ។**

» ប្រយោជន៍ឯណាដែលជាប្រយោជន៍ ក្នុងបច្ចុប្បន្នក្តី, ប្រយោជន៍ឯណាដែលជាប្រយោជន៍ ក្នុងបរលោកក្តី, បុគ្គលដែលលោកហៅថាបណ្ឌិត មានប្រាជ្ញាខ្ជាប់ខ្ជួនព្រោះបាននូវប្រយោជន៍ ( ទាំងពីរនោះឯង ) ។

**( ចប់វិន័យឧបាសក )**



# វគ្គទី ៦ ភាវេតព្វកិច្ចប្បញ្ហា



ឧបាសក ឧបាសិកាបានទទួលសមាទានឧបោសថសីល ក្នុងថ្ងៃឧបោសថកាលនោះរួចហើយ បើចង់ឲ្យមានផលានិសង្ស ច្រើនក្នុងថ្ងៃនោះយប់នោះ ត្រូវសង្រួមកាយវាចាឲ្យបានសមគួរ រៀបរយតាមពុទ្ធានុញ្ញាតទុកមក ។

ឯការដែលសង្រួមកាយឲ្យបានសមគួរនោះ គឺត្រូវលះបង់ នូវការងារទាំងឡាយមានភ្ជួរស្រែ កាប់ចំការជាដើម ដែលជាការ សៅហ្មងដល់ព្រហ្មចរិយសីលដែលខ្លួនបានទទួលសមាទានហើយ ក្នុងថ្ងៃនោះ យប់នោះ, សង្រួមវាចាឲ្យបានសមគួរនោះគឺត្រូវលះ បង់នូវតិរច្ឆានកថាទាំង ៣២ យ៉ាង មាននិយាយអំពីបាយឬ ស្រូវ អង្ករថាអាក្រក់ ល្អ អំពីទឹកឬអំពីដីថាក្នុងទីនេះ ទីនោះមានទឹកថ្លា ទឹកល្អក់ ដីល្អ ដីអាក្រក់ អំពីគ្រឿងស្លៀកពាក់ថាល្អ ថាអាក្រក់ អំពីញាតិរបស់ខ្លួនថាល្អ ថាចំរើនដោយសេចក្ដីសុខ អំពីរូបស្ត្រី ប្រុសថាអាក្រក់ ថាល្អជាដើម ហើយគួរប្រកបដោយពាក្យពោល ជាទីសប្បាយ ១០ ប្រការ មានពោល អំពីសីល ៥ សីល ៨ និង អានិសង្សសីល ៥ សីល ៨ អំពីសមាធិកម្មដ្ឋានទាំង ៤០ អំពី

វិបស្សនាបញ្ញា ជាដើម ។

បើបានសង្រួមកាយវាចាសមគួរហើយ ក្នុងថ្ងៃនោះយប់នោះ ត្រូវស្ដាប់ធម៌ទេសនា ឬធ្វើនូវធម្មសាកច្ឆា គឺសាកសួរអំពីធម៌ បើមិនបានស្ដាប់ធម៌នោះទេ ត្រូវសង្រួមចិត្តតាំងចំរើននូវកម្មដ្ឋាន ក្នុងសមថកម្មដ្ឋាន ៤០ ប្រការត្រង់កម្មដ្ឋានណាមួយក៏បាន ។ ឯកម្មដ្ឋានទាំង ៤០ នោះមានសេចក្ដីពិស្ដារនៅក្នុងគម្ពីរវិសុទ្ធិមគ្គបាលី ឬសំរាយត្រង់សមាធិនិទ្ទេសជានិទ្ទេសទី ២, ក្នុងទីនេះមិនបានសំដែងអំពីកម្មដ្ឋានទាំងនោះដោយសព្វគ្រប់ទេ គ្រាន់តែប្រាប់របៀបនិងធម៌ដែលត្រូវចំរើននោះខ្លះប៉ុណ្ណោះ ។ ព្រោះពុទ្ធភាសិតសំដែងថា ៖ អ្នកដែលចំរើននូវកម្មដ្ឋានទាំង ៤០ ប្រការត្រង់កម្មដ្ឋានណាមួយក្ដីនោះ ត្រូវចំរើនមូលកម្មដ្ឋាន គឺពុទ្ធានុស្សតិ-កម្មដ្ឋានជាមុនសិន ហើយទើបឲ្យចំរើនកម្មដ្ឋានឯទៀតៗ តទៅតាមគួរដល់អធ្យាស្រ័យ ។

**សំណួរ**. កម្មដ្ឋានទាំង ៤០ ប្រការនេះ តើកម្មដ្ឋានណាមួយជាកំពូលលើកម្មដ្ឋានទាំងអស់ ទោះចំរើនទៅហើយកើតឧគ្គហនិមិត្ត[១]ក្ដី មិនកើតក្ដី តែមានប្រយោជន៍ច្រើន មានអានិសង្សជាងកម្មដ្ឋានដទៃ តើកម្មដ្ឋានណា ?

---

(១) ឧគ្គហនិមិត្ត អ៊ុក-គៈ-ហាៈ និមិត បា.; សំ. ( ន. ) (ឧទ្គ្រហ + និមិត្ត) គ្រឿងសម្គាល់ដែលអ្នកចម្រើនកសិណកម្មដ្ឋានសង្កេតយកបាន គឺរូបកសិណដែលជាក់ច្បាស់ដល់ដួងចិត្តយោគីទោះធ្មេចភ្នែកទៅក៏នៅតែឃើញជាក់ច្បាស់ដូចកាលដែលបើកភ្នែកសម្លឹង : កើតឧគ្គហនិមិត្ត (ព. ពុ.) ។

**ចំលើយ**. ត្រូវចំរើន **កាយគតាសតិកម្មដ្ឋាន** ទើបមានអានិសង្សច្រើន ។

**ស**. តើវិធីចំរើនកាយគតាសតិកម្មដ្ឋាននោះដូចម្តេច ?

**ច**. កាលបើព្រះយោគីប្រាថ្នាដើម្បីចំរើន កាយគតាសតិ[១] កម្មដ្ឋាននេះ, គប្បីរៀនយកនូវឧគ្គហកោសល្លវិធី គឺវិធីឈ្លាសក្នុងឧគ្គហៈ ៧ យ៉ាងនិងមនសិការកោសល្លវិធី គឺវិធីឈ្លាសក្នុងមនសិការៈ ១០ យ៉ាងក្នុងសំណាក់នៃអាចារ្យដែលជាកល្យាណមិត្តជាមុនសិន ។

## ឧគ្គហកោសល្លវិធី ៧ យ៉ាងនោះគឺ ៖

**១. វចសា** ឈ្លាសដោយវាចាស្វាធ្យាយក្នុងអាការៈ ៣២;

**២. មនសា** ឈ្លាសដោយចិត្តកំណត់តាមការស្វាធ្យាយន៍ក្នុងអាការៈ ៣២ ;

**៣. វណ្ណតោ** ឈ្លាសដោយការកំណត់ពណ៌របស់អាការៈនោះៗ ;

**៤. សណ្ឋានតោ** ឈ្លាសដោយការកំណត់សណ្ឋានរបស់អាការៈនោះ ;

**៥. ទិសតោ** ឈ្លាសដោយការកំណត់ទិសដែលអាការៈនោះតម្កល់នូវ ;

**៦. ឱកាសតោ** ឈ្លាសដោយការកំណត់ឱកាសដែល

---

(១) **កាយគតាសតិ** ស្មារតីដែលតាំងនៅក្នុងកាយ, សេចក្តីពិចារណាក្នុងរូបកាយ ។

អាការៈនោះៗ តម្កល់នូវ ;

**៧. បរិច្ឆេទតោ** ឈ្លាសដោយការកំណត់ព្រំជុំវិញរបស់អាការៈនោះៗ និងភាពដែលអាការៈនោះមិនច្រឡំគ្នា ;

អធិប្បាយទី ១ ត្រូវហាត់ស្វាធ្យាយដោយវាចាឲ្យស្ទាត់ជំនាញក្នុងអាការៈទាំង ៣២, ឯអាការៈទាំង ៣២ នោះ លោកចាត់ទុកជា ៦ ពួកគឺ ៖

## ពួកទី ១ ឈ្មោះតចបញ្ចកៈមានអាការៈ ៥ គឺ ៖

**១. កេសា** សក់ទាំងឡាយមាន ៩ លានសរសៃ មានពណ៌ខ្មៅមានឫសចាក់ទៅក្នុងស្បែកក្បាល ប្រវែងមួយចុងស្រូវ, សក់នេះដុះតែក្នុងមួយរន្ធមួយសរសៃ មិនដែលមានពីរសរសៃឡើយ, សក់នេះអ្នកប្រាជ្ញទាំងឡាយ លោកកំណត់ពិចារណាដោយបដិកូលកម្មដ្ឋានថាជាទីគួរខ្ពើមរអើម ៥ ប្រការ : បដិកូលដោយសម្បុរ ១, បដិកូលដោយឋាន ១, បដិកូលដោយក្លិន ១, បដិកូលដោយទីកើត ១, បដិកូលដោយទីលំនៅ ១ ត្រូវជា ៥ ប្រការ ឲ្យពិចារណាដូចបុគ្គលបរិភោគភោជនាហារ កាលបើបានឃើញសក់ធ្លាក់ចុះមកលើភោជនាហារ ក៏ខ្ពើមរអើមចាក់ចោលចេញពុំបានបរិភោគឡើយ, សក់នេះជាទីស្រឡាញ់ពេញចិត្តតែកាលតាំងនៅលើក្បាល វេលាដែលជ្រុះចុះមកកាលណាហើយក៏មានសេចក្ដីខ្ពើមពន់ពេកណាស់, សក់នេះដុះនៅលើក្បាលត្រាំនៅក្នុងខ្ទុះ, ឈាមនិងទឹកស្លេស្មជាដើម ឧបមាដូចជាបន្លែ ឬស្មៅ

ដុះនៅជិតកុដិឬបង្គន់ ជារបស់ស្មោកគ្រោកលាមកអាក្រក់គួរខ្ពើមរអើមពេកណាស់ ។

**២. លោមា** រោមទាំងឡាយមានប្រមាណ ៩ ហ្មឺនរណ្តៅ សម្បុរសក៏មាន លឿងក៏មាន ខ្មៅក៏មាន ឧបមាដូចឫសត្នោត, ឯរោមនោះកើតពីសាច់ស្បែកដែលរុំកាយ វៀរលែងតែទីដែលសក់ដុះនិងបាតដៃ, ដុះតែក្នុងមួយរន្ធមួយសរសៃៗ មិនដែលដុះមួយរន្ធៗ ពីរបីសរសៃឡើយ រោមនេះជាបដិកូលកម្មដ្ឋាន ៥ ប្រការដូចគ្នានឹងសក់ដែរ ។

**៣. នខា** ក្រចកទាំងឡាយមាន ២០ ពណ៌សដូចស្រកាត្រីដុះនៅចុងម្រាមទាំង ២០ គឺម្រាមដៃ ១០ ម្រាមជើង ១០ ក្រចកនេះជាបដិកូលកម្មដ្ឋាន ៥ ប្រការដូចគ្នា ។

**៤. ទន្តា** ធ្មេញទាំងឡាយមាន ៣២ ចំពោះអ្នកមានវាសនា បើអ្នកដែលឥតមានវាសនាមាន ២៨ ខ្លះ ២១ ខ្លះ ធ្មេញនេះមានសម្បុរស មានសណ្ឋានទីទៃ ៗ ពីគ្នា គឺចុងធ្មេញ ៤ នោះបីដូចគ្រាប់ឃ្លោកដុះរៀងគ្នា ឯចង្កូមទាំង ៤ មានសណ្ឋានដូចផ្កាម្លិះក្រពុំមានចុងស្រួចឡើង មានឫសដុះចុះទៅ ចង្កូម ១ បន្ទាប់ចេញមកម្ខាងៗ ៤ សណ្ឋានដូចកង់រទេះ ឯចុងចាក់ឫសទៅនោះមានចំពាម ៣ ខាងលើមានចំពាម ២, ធ្មេញនេះបង្កើតពីឆ្អឹងលើឆ្អឹងក្រោម ជាទីស្មោកគ្រោកជាប់ស្លេស្មខ្លះ ជាប់ឈាមខ្លះ ជាប់ទឹកមាត់ខ្លះ ឈាមអាក្រក់ខ្លះ បើមិនបានជំរះតែមួយវេលា ក៏មានក្លិនស្អុយឆ្អាប ជាទីគួរខ្ពើមរអើមដល់បុគ្គលទាំងពួង ធ្មេញនេះតែកើត

មកហើយតែងបាក់បែករង្គោះរង្គើចេញទៅវិញជាធម្មតាឥតខ្លឹមសារទេ, ធ្មេញនេះក៏ជាបដិកូលដោយកម្មដ្ឋាន ៥ ប្រការដែរ ។

**៥. តចោ** ស្បែក ស្បែកនេះបើបកយកតែសម្បកក្រៅចេញពីខ្លួនមកប្រមូលឲ្យមូលមានប្រមាណ ប៉ុនផ្លែពុទ្រាមានសម្បុរទីទៃៗពីគ្នា ខ្លះស, ខ្លះខ្មៅ, ខ្លះលឿង, ខ្លះក្រហម ស្បែករុំសាច់ឧបមាដូចជាសម្បុរដង្កូវនាង ស្បែកជើងដូចជាគេពាក់ទ្រនាប់ជើង ស្បែកកំភួនជើងដូចជាគេយកស្លឹកត្នោតមករុំ, ស្បែករលោងដូចជាថង់ដែលបុគ្គលច្រកអង្ករពេញ, ស្បែកត្រគាកដូចជាដំរងទឹក, ស្បែកខ្នងដូចជាស្បែកដែលគេរុំផែនក្ដារ, ស្បែកពោះដូចជាស្បែករុំជើង, ស្បែកដើមទ្រូងមានសណ្ឋាន ៤ ជ្រុង, ស្បែកដៃទាំងពីរដូចជាស្បែកគេរុំបំពង់ធ្នូ, ស្បែកម្រាមដៃដូចស្រោមកាំបិតកោរ, ស្បែករុំកាយដូចថង់ដាក់កូនសោ, ស្បែកកដូចគេយកបន្ទះឫស្សីមកត្បាញជាបំពង់តៗ គ្នា, ស្បែកមាត់មានរន្ធព្រោកដូចជាសម្បុកកណ្ដុប, ស្បែកក្បាលដូចជាស្លោកបាត្រ ស្បែកនេះក៏ជាបដិកូលដោយកម្មដ្ឋាន ៥ ប្រការដូចគ្នាដែរ ។

## ពួកទី ២ ឈ្មោះវក្កបញ្ចកៈមានអាការៈ ៥ គឺ ៖

**១. មំសំ** សាច់នោះមានប្រមាណ ៩០០ដុំ មានសម្បុរក្រហមដូចផ្កាចារមានសណ្ឋានទីទៃៗ ពីគ្នា សាច់កំភួនជើងនោះដូចជាស្លឹកត្នោតដែលគេវេចប្រមូលហើយតម្កល់ទុក, សាច់ភ្លៅដូចអង្រែថ្ម, សាច់ចុងត្រគាកនោះដូចដុំថ្មចង្ក្រាន, សាច់ស្មងនោះដូចផែន

នៃស្ករ, សាច់ឆ្អឹងជំនីនោះដូចជាដីស្អិតដែលលាបជញ្ជាំង, សាច់ដោះទាំងពីរនោះ ដូចដីគេយកទៅចងព្យួរទុក, សាច់ ៩០០ ដុំនេះដូចជាគេរុំជាប់នឹងឆ្អឹង ៣០០ កំណាត់, សាច់ក្រោមជាប់នឹងឆ្អឹង, សាច់លើជាប់ស្មើនឹងស្បែក, សាច់ទាំងនេះពុំមានខ្លឹមសារទេជាអសុភស្មោកគ្រោកគួរខ្ពើមរអើមក្រៃពេក ។

**២. ន្ហារូ** សរសៃទាំងឡាយ, សរសៃនេះមានប្រមាណ ៩០០ សរសៃ មានសម្បុរសសុទ្ធចងព័ទ្ធ រឹតរួតឆ្អឹងទាំង ៣០០ កំណាត់ ដូចរូបយន្តដែលគេដោតក្រងខ្សែយន្ត សរសៃធំទាក់ទៅតាមឆ្អឹងជំនីខាង ឆ្វេង ៥ សរសៃ, ខាងស្ដាំ ៥ សរសៃ, សរសៃធំចាក់ចុះទៅតាមឆ្អឹងខ្នងខាងឆ្វេង ៥ សរសៃ, ខាងស្ដាំ ៥ សរសៃ, សរសៃធំៗ មកជួបប្រជុំគ្នានូវកទាំងអស់, សរសៃធំសួរទៅតាមដៃស្ដាំ ដៃឆ្វេងម្ខាងៗ ១០ គឺសរសៃខ្នងដៃ ៥ បាតដៃ ៥ ត្រូវជា ១០, សរសៃធំដែលសួរទៅតាមជើងម្ខាងៗ ដប់ៗ និងពួរជើងម្ខាងៗ ប្រាំៗ សរសៃ, រួមត្រូវជាសរសៃធំៗ ៦០ ដែលរឹតរួតនូវឆ្អឹង ៣០០ កំណាត់ដែលមាននៅក្នុងកាយ ។

**៣. អដ្ឋិ** ឆ្អឹងទាំងឡាយ ឆ្អឹងនេះមានប្រមាណ ៣០០ កំណាត់ លើកលែងតែធ្មេញ ៣២ ចេញ គឺឆ្អឹងដៃ ៦៤, ឆ្អឹងជើង ៦៤, ឆ្អឹងខ្ចីដែលអាស្រ័យនូវសាច់នោះ ៦៤, ឆ្អឹងកែង ២ ជើងមួយៗ មានឆ្អឹងភ្នែកគោពីរៗ, ឆ្អឹងជង្គង់ ២, ឆ្អឹងភ្លៅ ២, ឆ្អឹងចង្កេះ ២, ឆ្អឹងទ្រនុងខ្នង ១៨, ឆ្អឹងជំនី ២៤, ឆ្អឹងដើមទ្រូង ១៤, ឆ្អឹងចុងដង្ហើម ១, ឆ្អឹងដងកាំបិត ២, ឆ្អឹងច្បាក់ ២, ឆ្អឹងស្មា ២,

ឆ្អឹងចង្កួយស្មា ២, ឆ្អឹងដើមដៃ ២, កំភួនដៃមួយៗ មានឆ្អឹងពីរៗ, ឆ្អឹងក ៧, ឆ្អឹងចង្កា ២, ឆ្អឹងច្រមុះ ១, ឆ្អឹងភ្នែក ២, ឆ្អឹងត្រចៀក ២, ឆ្អឹងថ្ងាស ១, ឆ្អឹងបង្ហើយ ១, ឆ្អឹងលលាដ៍ក្បាល ៩ រួមត្រូវជាឆ្អឹង ៣០០ កំណាត់ ។

ឯឆ្អឹងទាំងនេះ មានសម្បុរសសុទ្ធមានសណ្ឋានទ្រង់ទ្រាយផ្សេងៗ ពីគ្នា គឺឆ្អឹងចុងម្រាមជើងដូចផ្លែកែស ឆ្អឹងម្រាមដៃដូចគ្រាប់ខ្នុរណាំង, ឆ្អឹងម្រាមជើងខាងគល់ដូចដើមបបុស, ឆ្អឹងនោះបីដូចគំនរផ្កា, ឆ្អឹងកែងជើងដូចកំពីងត្នោត, ឆ្អឹងភ្នែកគោដូចផ្លែអង្គញ់, ឆ្អឹងកជើងដូចបណ្តូលចេក, ឆ្អឹងស្មងជើងតូចដូចដងធ្នូ ឆ្អឹងស្មងជើងធំដូចឆ្អឹងពស់ស្ងិត, ឆ្អឹងក្បាលជង្គង់ដូចពពុះទឹក, ឆ្អឹងដែលជាប់ទៅនឹងឆ្អឹងភ្លៅដូចផ្លែក្រូចទុំ ដែលគេកាត់ចុងចេញ, ឆ្អឹងចង្កេះទាំងពីរជាប់គ្នាតែមួយដូចចង្ក្រានស្នូនឆ្នាំង, បើញែកឲ្យផ្សេងគ្នាដូចដង្កាប់ជាងទង, ឆ្អឹងត្រគាកដែលនៅក្នុងឆ្អឹងចង្កេះដូចពស់ផ្កាប់មុខបើកពពារ មានប្រហោងតូចៗ ចំនួន ៧ ឬ ៨ ឆ្អឹងខ្នងទាំងអស់ខាងក្នុង ដូចជារង្វង់សំណដែលគេដំកល់ទុកលើៗ គ្នាខាងក្រៅដូចរបៀបកូនផ្គាំ, ឆ្អឹងទ្រនុងខ្នង ២-៣ តាមចន្លោះឆ្អឹងខ្នងទាំងនោះដូចធ្មេញរណារ, ឆ្អឹងជំនីទាំង ២៤ បើមិនពេញបរិបូណ៌ទេដូចកណ្តៀវដែលមានធ្មេញមិនពេញបរិបូណ៌ បើពេញបរិបូណ៌ដូចកណ្តៀវដែលពេញបរិបូណ៌ រូបរួមទាំងអស់ដូចស្លាបមាន់សដែលគេលាតសន្ធឹង, ឆ្អឹងបេះដូងដូចរលាវែក, ឆ្អឹងទ្រូងទាំង ១៤ ដូចស្លាបគ្រុឌចាស់, ឆ្អឹងភ្នែកដូចដងកាំបិត ស្តាន់ តូច,

ឆ្អឹងបង្គួយស្មា ដូចផ្លែចបរបស់ជនក្នុងប្រទេសឈ្មោះ សីហឡៈ ដែលរិចរិលអស់, ឆ្អឹងដើមដៃដូចក្របកញ្ចក់, ឆ្អឹងដើមដៃខាងចុង ដូចគ្រាប់ត្នោតមួយគូ, ឆ្អឹងភ្នែកដៃដូចផែនសំណដែលគេរំលាយ ជាមួយតម្កល់ទុក, ឆ្អឹងខ្នងដៃដូចគំនរឫសរុនដែលគេយកមក តម្រៀប, ឆ្អឹងម្រាមដៃខាងគល់ដូចខ្លុយ, ឆ្អឹងកណ្ដាលដូចគ្រាប់ ខ្នុរមិនពេញ, ឆ្អឹងខាងចុងដូចគ្រាប់ល្មៀង, ឆ្អឹងទាំង ៧ ដូចថ្នាំង ឫស្សីដែលគេដោតនឹងឈើតាមលំដាប់គ្នា, ឆ្អឹងចង្កាខាងក្រោម ដូចខ្សែដង្កាប់ដែករបស់ជាងទង, ខាងលើដូចផ្លែកាំបិតសកអំពៅ, ឆ្អឹងថ្ងាសដូចស្នូកស័ង្ខដែលគេដាក់ផ្កាប់, ឆ្អឹងរណ្ដៅភ្នែកនិងរណ្ដៅ ច្រមុះដូចគ្រាប់ត្នោតខ្ចីដែលគេយកសាច់ក្នុងចេញ, ឆ្អឹងគុម្ពត្រចៀក ដូចស្រោមកាំបិតកោររបស់ខ្មាន់ព្រះកេស, ឆ្អឹងថ្ងាស ឆ្អឹងគុម្ព ត្រចៀកដែលជាប់គ្នាជាថ្នាំងៗ ខាងលើដូចក្អមដាក់ខ្លាញ់ពេញ, ឆ្អឹងបង្ហើយដូចត្រឡោកដូងកោងដែលគេកាត់មាត់ចេញ, ឆ្អឹងក្បាល ដូចរលាឃ្លោកសាយដៀវចាស់គេស្រែះទុក ។

បណ្ដាឆ្អឹងទាំងឡាយឆ្អឹងក្បាលនៅលើឆ្អឹងក ឆ្អឹងកនៅលើ ឆ្អឹងខ្នង ឆ្អឹងខ្នងនៅលើឆ្អឹងចង្កេះ ឆ្អឹងចង្កេះនៅលើឆ្អឹងភ្លៅឆ្អឹង ភ្លៅនៅលើឆ្អឹងជង្គង់ ឆ្អឹងជង្គង់នៅលើឆ្អឹងស្មង ឆ្អឹងស្មងនៅលើ ឆ្អឹងភ្នែកគោ ឆ្អឹងភ្នែកគោនៅលើឆ្អឹងជើង មានសភាពគួរខ្ពើម រអើមក្រៃពេក ។

**៤. អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង មានសម្បុរសតាំងនៅក្នុងឆ្អឹង ៣០០ កំណាត់បើឆ្អឹងធំខួរក៏ច្រើន បើឆ្អឹងតូចខួរក៏តិច ឧបមាដូច

ផ្តៅដែលបុគ្គលរោលភ្លើងឲ្យឆ្អិនហើយយកសំបកចេញ ហើយដាក់ក្នុងបំពង់ឫស្សី ។

**៥. វក្កំ**[១] ទាច មានសម្បុរក្រហមដូចផ្លែឧទុម្ពរស្រគាលជាប់នៅជាមួយនិងថ្លើម សួត បេះដូងទាំងពួង ។

## ពួកទី ៣ ឈ្មោះបច្ឆាសបញ្ចកមានអាការៈ ៥ គឺ ៖

**១. ហទយំ** បេះដូងឬចិត្ត នៅចំពាក់កណ្តាលដើមទ្រូង មានសម្បុរក្រហមដូចផ្លែបទុមជាតិ, ឯខាងក្នុងបេះដូងនោះប្រៀបដូចផ្លែននោងទុំ រន្ធប៉ុនផ្លែក្រូចឆ្មារ មានសណ្ឋានដូចឈូកក្រពុំ, បើបុគ្គលណាមានប្រាជ្ញាឈ្លាសវាងវៃ បេះដូងនោះដូចផ្កាឈូកស្រពោនខាងក្នុងមានទឹករក្សា ទឹកចំនួន ១ ទូកដៃ, បើបុគ្គលជារាគចរិតទឹករក្សាចិត្តក្រហម, ទោសចរិតទឹករក្សាចិត្តខ្មៅ, មោហចរិតទឹករក្សាចិត្តក្រហមដូចទឹកលាងសាច់, វិតក្កចរិត[២]ទឹករក្សាចិត្តពណ៌ដូចកាកផ្លែពពាយជ្រុំង, សទ្ធាចរិតទឹករក្សាចិត្តពណ៌ដូចផ្កាកណ្ណិកា, បញ្ញាទឹករក្សាចិត្តថ្លាមិនល្អក់កករឡើយដូចកែវមណី ។

**២. យកនំ** ថ្លើម មានសម្បុរក្រហមដូចផ្កាឈូកក្រហមតម្កល់នៅខាងចន្លោះខាងស្តាំ រាងដូចស្លឹករលួសផ្អុងបើអ្នកមាន

(១) វក្កំ ក្នុងសៀវភៅប្រជុំកងធម៌ថ្នាក់ត្រីប្រែថា តម្រងបស្សាវៈបើតម្រងបស្សាវៈទេហេតុ អ្វីក៏នៅជាមួយសួត បេះដូងទៅវិញ ?

(២) វិតក្កចរិត (--ត័ក-កៈចៈរ៉ិត) ដែលមានសេចក្តីត្រិះរិះច្រើនជាចរិត : មនុស្សវិតក្កចរិត (មនុស្សមានគំនិតសាញ) ។

ប្រាជ្ញាចុងថ្លើមឆែក, បើអ្នកអ័ប្បឥតប្រាជ្ញាចុងថ្លើមនោះមិនឆែកឡើយ, បើខ្លួនធំម្ដេចម្ដាតែមានប្រាជ្ញា ថ្លើមនោះតូច, បើមនុស្សនោះតូចតែជាអ្នកឆោតល្ងង់ ថ្លើមនោះក៏ធំពុំមានចុងឆែកឡើយ ។

**៣. កិលោមកំ** វាវឬក្រដាស់ មាន ២ យ៉ាងគឺ ៖ វាវដែលរុំថ្លើម សួត បេះដូង ១, វាវដែលរុំឆ្អឹង ៣០០ កំណាត់ ១, មានពណ៌ដូចសំពត់ទុកូលពស្ត្រចាស់ ។

**៤. មិហកំ** ក្រពះ មានសម្បុរដូចផ្កាកន្ទឹស ដូចអណ្ដាតកូនគោខ្មៅក៏មាន បើគេប្រហារដោយគ្រឿងសស្ត្រាវុធ ឲ្យតែក្រពះនោះលៀនចេញមកខាងក្រៅទៀងតែពីស្លាប់ ។

**៥. បប្ផាសំ** សួត សួតនេះមានប្រភេទជាដុំសាច់ ៣៣ ដុំជាប់គ្នាមានសម្បុរក្រហមព្រឿងៗ ដូចផ្លែឧទម្ពរស្រគាល បើបុគ្គលនោះអត់អាហារពុំបានបរិភោគ ភ្លើងក៏ឆេះឆ្លូលដល់សួតៗក៏ក្រៀម បើបានបរិភោគអាហារឆ្អែតបរិបូណ៌ហើយភ្លើងធាតុនោះក៏ឆេះអស់អាហារដែលបរិភោគចូលទៅ សួតនោះក៏ស្រស់ឡើងដូចពីដើម ឯសួតនោះស្ថិតនៅត្រង់ចន្លោះដោះទាំងពីរសំយុងចុះមកគ្របថ្លើមនិងសាច់សួត ។

## ពួកទី ៤ ឈ្មោះមត្ថលុង្គបញ្ចក មានអាការៈ ៥ គឺ ៖

**១. អន្តំ** ពោះវៀនធំ បើពោះវៀនមនុស្សប្រុសប្រវែង ៣២ ហត្ថ, បើពោះវៀនមនុស្សស្រីប្រវែង ២៨ ហត្ថ, វៀនជាផ្នត់ ២៨ ផ្នត់, ទៅលើទល់ដើមកចុះទៅក្រោមទល់ទ្វារធំ, ពោះវៀននេះមាន

សម្បុរស ខាងក្នុងពោះវៀននោះដូចសម្បុរខ្នុរណាំង ក្រៅពីនោះ រមួលៗក្នុងពោះវៀននោះសឹងច្រឡំដោយហ្វូងដង្កូវ ៣២ ត្រកូល ដង្កូវនេះវារទៅវារមកក្នុងពោះវៀនធំ បើខានបរិភោគអាហារចូល ទៅដង្កូវទាំងនោះវាងើបក្បាលឡើងច្រូង ហើយវាក៏ជញ្ជក់ថ្លើម, បេះដូង, សួត បើបុគ្គលបានបរិភោគអាហារចូលទៅបាន ១ ម៉ាត់ ឬ ២ ម៉ាត់ ដង្កូវទាំងនោះក៏នាំគ្នាមកប្រជែងដណ្ដើមស៊ីអាហារ ដែលចូលទៅនោះ ដង្កូវទាំងនោះតែងកើតតែងស្លាប់នៅក្នុងពោះ វៀនធំនោះឯង ។ ពោះវៀនធំនោះជាលំនៅ, ជាទីកើត, ជាទីស្លាប់ នៃដង្កូវទាំងឡាយ ឧបមាដូចបុគ្គលកាត់ក្បាលពស់ ហើយបំពេន ក្នុងទីណាមួយ ។

**២. អន្តគុណំ** ពោះវៀនតូច ពោះវៀនតូចនេះចងទាក់ នឹងពោះវៀនធំ មានសម្បុរសដូចជានីលុប្បល ( ផ្កាឧប្បលខៀវ ) បើបុគ្គលធ្វើការជាទម្ងន់ពោះវៀនតូចធូ បើពោះវៀនតូចនោះធូ ហើយពោះវៀនធំក៏ធូតាម បើនៅស្ងៀមដូចប្រក្រតីពោះវៀនតូច នោះក៏រិតរួតពោះវៀនធំគង់នៅដូចដើម ។

**៣. ឧទរិយំ** អាហារថ្មីដែលបុគ្គលបរិភោគចូលទៅនោះល្អិត ដោយធ្មេញក្រោម និងធ្មេញលើដូចត្បាល់បុក អណ្ដាតនោះ ដូចបុគ្គលយកដៃត្រឡប់បង្វិល កាលបើអាហារចូលទៅក្នុង អណ្ដាតជ្រួតជ្រាប ច្រឡំនឹងទឹកមាត់រាវ លុះដល់ដើមអណ្ដាត ជ្រួតជ្រាបច្រឡំនឹងទឹកមាត់ខាប់ក្លិនរសពិសាក៏បាត់ទៅ ។ លុះ ដល់ក្នុងពោះហើយ មុខគួរឲ្យខ្ពើមរអើមក្រៃពេកឧបមាដូចកំអួត

ឆ្អែតពុំនោះសោតដូចបាយគេត្រាំសិតអំបោះ កាលបើអាហារនោះធ្លាក់ចុះទៅក្នុងពោះហើយ ក៏ប្រឡាក់ដោយទឹកលាមកអាក្រក់ បើបុគ្គលនោះមានស្លេស្មច្រើនអាហារនោះខៀវ បើមានខ្ទុះច្រើនអាហារនោះច្រឡុំទៅដោយទឹកស្អុយ បើមានឈាមច្រើនអាហារនោះក្រហមភ្លើងធាតុដុតអាហារនោះបក់ឡើងឲ្យហ្វូងដង្កូវដណ្ដើមគ្នា អាហារដែលបុគ្គលលេបចូលទៅនោះ ចែកចេញជា ៥ ចំណែក គឺបានទៅដង្កូវស៊ី ១ ចំណែក, ភ្លើងធាតុដុតក្នុងឧទរ ១ ចំណែក, បានជាទឹកមូត្រ ១ ចំណែក, បានជាលាមក ១ ចំណែក, បានជាសាច់ស្បែកឈាម ១ ចំណែករួមជា ៥ ចំណែក ។

**៤. ករីសំ** អាហារចាស់ ដែលភ្លើងធាតុដុតឲ្យស្អាតដូចគេបុកនឹងត្បាល់ថ្មល្អិតហើយ ក៏ហូរចូលទៅតាមចន្លោះពោះវៀនធំចូលទៅខាប់ជាដុំហើយក៏តាំងនៅក្រោមពោះវៀនធំ ក្នុងពោះវៀនយើងនេះឧបមាដូចផ្ទាំងឫស្សីប្រវែង ១ អង្គុលី ដ៏ពេញដោយដីដូចម្ដេចវិញ, ឯអាហារចាស់នោះសោតក៏ដូចដីដែល បុគ្គលដាក់ក្នុងបំពង់ឫស្សីនោះឯង ។ អាហារដែលជ្រួតជ្រាបសព្វសព៌ាង្គកាយឲ្យចំរើនសាច់សម្បុរឈាម គឺអាហារដែលបុគ្គលបរិភោគទៅនោះទោះតិចក្ដីច្រើនក្ដីក៏បែកចេញជា ៥ ជំពូកដូចពណ៌នាមកនោះឯង អាហារដែលភ្លើងធាតុឆេះពុះផុលឡើង ឧបមាដូចឆ្នាំងបាយពុះធម្មតាបាយពុះកន្ទក់លំអងរមែងអណ្ដែតតាមពពុះឡើងមកជាប់នឹងមាត់ឆ្នាំងដូចម្ដេចមិញ, អាហារដែលយើងបរិភោគចូលទៅភ្លើងធាតុរមែងឆេះផុលឡើងមកជាប់នៅត្រចៀក, ភ្នែក, ច្រមុះដូច្នោះ

ដែរ ។ ពពុះអាហារដែលភ្លើងធាតុបក់ឡើងមកជាប់នៅ ក្នុងរន្ធត្រចៀក, ភ្នែក, ច្រមុះ សន្មតថា អាចម៍ត្រចៀក, ភ្នែក, ច្រមុះ បើមកជាប់នៅធ្មេញ សន្មតថាសំអេកធ្មេញ បើមកជាប់អណ្ដាត សន្មតថាអុលអណ្ដាត ភ្លើងធាតុដុតឲ្យល្អិតឡើងបែកជាលាមក ( អាចម៍ ) បែកចេញឲ្យចំរើនសាច់ស្បែកទាំងពួង ។

**៥. មត្ថកេមត្ថលុង្គំ** ខួរក្នុងក្បាល មូលបីដូចជានំខួរក្នុងក្បាលនេះឧបមាដូចម្សៅ ដែលបុគ្គលលុញឲ្យមូលជាដុំមានសម្បុរសដូចដំឡូងខ្ទី ៣ ដុំប្រជុំគ្នានៅក្នុងឆ្អឹងក្បាល មុខគួរឲ្យខ្ពើមរអើមក្រៃពេក ។ លោកអ្នកប្រាជ្ញគប្បីពិចារណាភ្លើងឆេះខួរអសុភដូចម្ដេចមិញ ខួរក្នុងក្បាលយើងទាំងពួងក៏ដូចគ្នាពុំមានប្លែកឡើយ ។

## ពួកទី ៥ ឈ្មោះមេទឆក្កៈ មានអាការៈ ៦ គឺ ៖

**១. បិត្តំ** ទឹកប្រមាត់ ឯទឹកប្រមាត់នោះមាន ២ យ៉ាងគឺ ៖ ពទ្ធបិត្ត ១, អពទ្ធបិត្ត ១ ។ ពទ្ធបិត្តនោះមានសណ្ឋានដូចផ្លែននោងនៅក្នុងទីជាចន្លោះបេះដូងថ្លើម, ទឹកប្រមាត់នោះថាបើកំរើកហើយសត្វផងទាំងពួង ទៅជាឆ្កួតល្ងីល្ងើពុំដឹងអ្វីឡើយ, អពទ្ធបិត្តនោះមានសម្បុរសដូចផ្កាថ្កុលស្វិត ប្រមាត់នេះជ្រាបសព្វសព៌ាង្គកាយចៀសតែសក់រោមក្រចកចេញ ក្រៅពីនោះទាំងប៉ុន្មានជ្រាបទៅសព្វទាំងអស់ឥតមានសេសសល់ឡើយ, ប្រមាត់នេះតែកម្រើកហើយតែងធ្វើឲ្យភ្នែកក្រហម, ឲ្យវិល, ធ្វើខ្លួនឲ្យកម្រើកញាប់ញ័ររួម

ត្រូវប្រមាត់ ២ ប្រការ ។

**២. សេម្ហំ** ស្លេស្ម៍ ស្លេស្ម៍ក្នុងរាងកាយនៃអ្នកទាំងពួងនេះ ប្រមាណ ១ បាត្រ សម្បុរដូចទឹកស្លឹកខ្លុងតម្កល់នៅក្នុងពោះ បរិភោគអាហារចំណីអ្វីៗ ទៅក្នុងបំពង់កហើយ អាហារនោះក៏វែកសេម្ហៈចែកជាចន្លោះ ហើយក៏លេបចុះទៅក្នុងខាងក្រោមពោះ កាលអាហារលេបចុះទៅក្រោម ស្លេស្ម៍នោះក៏ប្រមូលគ្នាដូចដែលវិញមានគណនាដោយស្រះដ៏ពេញទៅដោយចកសារាយទាំងពួង ហើយបុគ្គលយកដុំដីមួយចោលទៅក្នុងស្រះ ចក សារាយ នោះក៏មកជិតវិញ មានឧបមាយ៉ាងណាមិញ អាហារដែលបរិភោគចូលទៅហើយក៏ជិតមកវិញដូចដើម មានឧបមេយ្យដូច្នោះដែរ ។

សេម្ហៈនេះ ប្រមូលបិទបាំងនៅលើក្លិនអសោច៏ក្នុងពោះមិនឲ្យហុយមកលើបាន បើពុំមានសេម្ហៈបិទបាំងទេ សំអុយអសោច៏ក្នុងពោះក៏ហុយឡើង ស្លេស្ម៍នេះមានឧបមាដូចផែនក្តារបិទបង្គន់មិនឲ្យក្លិនអសោច៏ហុយឡើងលើយ៉ាងណា, ស្លេស្ម៍បិទបាំងក្លិនអសោច៏ក្នុងកាយមិនឲ្យហុយ ឬចំហាយឡើងយ៉ាងនោះដែរ ។

**៣. បុព្វោ** ខ្ទុះ មានពណ៌ក្រហម ស លឿងទីទៃៗ ពីគ្នា បើត្រូវមុតនឹងអ្វីៗ ខ្លាំង ឈាមក៏មកគុំទៅជាខ្ទុះត្រង់កន្លែងដែលមុតនោះ ។

**៤. លោហិតំ** ឈាម មានពីរប្រការគឺ សំសរណលោហិត ១, សន្និចិតលោហិត ១ ។ សន្និចិតលោហិត មានសម្បុរដូចជាទឹកស្បៀងខាប់នៅក្នុងពោះឡើងទៅដល់សួត ថ្លើម បេះដូង

បើឈាមនោះពុំបានលិចដល់សួត ថ្លើម បេះដូងកាលណា ក៏បណ្ដាលទៅជាផ្សាឆ្លួលក្ដៅក្នុងដើមទ្រូងកាលណោះ ។ ថាបើឈាមនោះតាំងនៅដោយធម្មតាប្រក្រតី ក៏ត្រជាក់ដើមទ្រូងត្រជាក់ចិត្ត មានសិរីសួស្ដី មានសម្បុរដូចទឹកល័ក្ខក្រហមថ្លា ។

**៥. សេទោ** ញើស ញើសនេះជាទីតាំងនៅក្នុងរោមទាំងពួងមានសម្បុរដូចប្រេងល្ងថ្លា ថាបើត្រូវក្ដៅកាលណាក៏ហូរចេញពីរន្ធរោមទាំងពួងកាលណោះ ។

**៦. មេទោ** ខ្លាញ់ខាប់ មានសម្បុរដូចរមៀត មានសណ្ឋានដូចសំពត់ទុកូលពស្រ្តចាស់នៅចន្លោះស្បែក និងសាច់ បើបុគ្គលនោះស្គមខ្លាញ់ខាប់ក៏តិច បើធាត់ខ្លាញ់ក៏ច្រើន ។

## ពួកទី ៦ ឈ្មោះមុត្តឆក្កៈមានអាការៈ ៦ គឺ ៖

**១. អស្សុ** ទឹកភ្នែក ទឹកភ្នែកបីដូចប្រេងថ្លា នៅក្នុងរង្វង់ភ្នែកទាំងពីរ ថាបើមានកើតទុក្ខទោមនស្ស កាលណាហើយទឹកភ្នែកនោះក៏ហូរចេញមកឬសើចខ្លាំងពេកឬអត់ងងុយណាស់ទៅក៏បណ្ដាលឲ្យទឹកភ្នែកហូរចេញមកដែរ ហើយក៏ស្រក់មកពីរង្វង់ភ្នែក ។

**២. វសា** ខ្លាញ់រាវ សម្បុរដូចប្រេងដូង ដែលតាំងនៅក្នុងស្បែកពោះ ច្រមុះ ថ្ងាស និងចុងស្មា ថាបើបុគ្គលត្រូវកំដៅភ្លើងក្ដីកំដៅព្រះអាទិត្យក្ដី ឬធ្វើការសារពើអ្វីជាទម្ងន់ ខ្លាញ់រាវនោះក៏ហូរចេញមកជ្រាបអស់ទាំងខ្លួន ។

**៣. ខេឡោ** ទឹកមាត់ មានសម្បុរស តាំងនៅក្នុងថ្ពាល់ បើឃើញវត្ថុអ្វីៗ ដែលគួរខ្ពើមរអើម ទឹក មាត់នោះក៏ហូរចេញមក ឬឃើញគេបរិភោគអ្វីៗ ដែលមានរសជាតិដ៏ឆ្ងាញ់ ក៏កើតសេចក្ដីស្រេកឃ្លានឡើង ទឹកមាត់នោះក៏ហូរចេញមក ពុំនោះសោត បរិភោគរបស់មានរសជូរ ប្រៃ ហឹរជាដើមក៏បណ្ដាលឲ្យហូរមកដែរ ឬមិនបាច់បរិភោគអ្វីៗ សោះទេស្រាប់តែហូរមកឯងៗ ក៏មាន, បើទឹកមាត់គ្មានទេ បំពង់កក៏ខះស្ងួតពុំបានសេចក្ដីសុខស្រួលឡើយ ។ ទឹកមាត់រាវនៅចុងអណ្ដាត ទឹកមាត់ខាប់នៅដើមអណ្ដាត ទឹកមាត់តែងហូរជ្រាបមកជានិច្ច ឧបមាដូចអណ្ដូងខ្សាច់ដែលបុគ្គលជីកមិនដែលរីងទឹកដូចម្ដេចមិញ, ទឹកមាត់យើងនេះក៏ជ្រាបសើមចេញមកពីក្នុងមាត់មិនដែលដាច់ ដូចអណ្ដូងខ្សាច់នោះឯង ។

**៤. សិង្ឃាណិកា** ទឹកសម្បោរ មានសម្បុរដូចជាទឹកនៅក្នុងគ្រាប់ត្នោតខ្ចី បើបុគ្គលនោះមានជម្ងឺឈឺផ្ដាសាយ ក្អក ទឹកសម្បោរក៏ហូរចេញមកតាមរន្ធច្រមុះ មានសភាពគួរខ្ពើមរអើមក្រៃពេក ។

**៥. លសិកា** ទឹករំអិល នៅក្នុងសន្លាក់ឆ្អឹងទាំងពួង បើបុគ្គលនោះមានទឹករំអិលនៅក្នុងសន្លាក់ឆ្អឹងតិច នឹងដេក, ដើរ, ឈរ អង្គុយមិនសូវរហ័សរហួន ហើយច្រើនលាន់ឮប្រសៗ បើសន្លាក់ឆ្អឹងនោះមានទឹករំអិលច្រើន មិនលាន់ឮឡើយហើយជាអ្នករហ័សរាងវៃផង ។

**៦. មុត្តំ** ទឹកមូត្រ មានសម្បុរដូចទឹកជ្រក់សណ្តែករាជមាស កើតនៅក្នុងខាងក្រោមស្ថិតនៅក្នុងក្រពះនោម ផ្លូវដែលទឹកមូត្រចូលទៅមិនបានប្រាកដ ប្រាកដតែទឹកមូត្រហូរចេញ បើក្រពះនោះមានទឹកមូត្រពេញហើយ សត្វទាំងឡាយតែងខ្វល់ខ្វាយថា «អញនឹងបន្ទោបង់នូវបស្សាវៈ» ដូច្នេះទឹកមូត្រដែលហូរចេញមកនោះ គួរខ្ពើមរអើមក្រៃពេក ។

ត្រូវស្វាធ្យាយពួកទី ១ ជាអនុលោមប្បដិលោមឲ្យបានស្ទាត់ជាមុន រួចហើយស្វាធ្យាយចូលទៅក្នុងពួកទី ២, លុះបានស្ទាត់ក្នុងពួកទី ២ ហើយ ត្រូវស្វាធ្យាយសាភ្ជាប់មកនឹងពួកទី ១ ខាងដើមវិញ ជាអនុលោមប្បដិលោមដូចគ្នាត្រាបានស្ទាត់ហើយ សឹមស្វាធ្យាយឆ្លងចូលទៅក្នុងពួកខាងចុងៗ ទៀតជាលំដាប់តទៅ ។

ព្រះយោគាវចរ ស្វាធ្យាយនូវកាយគតាសតិកម្មដ្ឋាននេះ ឧបមាដូចសត្វស្វាដែលទីពឹងអាស្រ័យ នូវដើមត្នោត ៣២ ដើម ដែលជាទីលំនៅរបស់សត្វស្វានោះ ថ្ងៃមួយមានព្រានព្រៃម្នាក់បណ្តើរឆ្កែមួយហ្វូងទៅជួបប្រទះឃើញសត្វស្វានោះ ។ ព្រានព្រៃក៏ពន្យុះឆ្កែឲ្យដេញស្វានោះ ស្វាភ័យនឹងឆ្កែដេញខាំក៏បោលទៅឡើងដើមត្នោតទី ១ ដែលជាលំនៅរបស់ខ្លួន ។ លុះស្វានោះឡើងដល់ចុងត្នោតហើយក៏គិតថា «អញអស់នរណា បៀតបៀនបានហើយ» ។ ព្រានព្រៃនោះ បានឃើញស្វាឡើងដើមត្នោតដូច្នោះក៏បានឫស្សីមួយដើមក៏ដេញចាក់ស្វានោះៗ ក៏លោតពីដើម

ទី ១ ទៅដើមទី ២ ស្វាក៏នៅមិនទាន់ភ័យដោយអាងថាដើមត្នោតច្រើន ។ ព្រានព្រៃមិនឈប់ដេញ ចេះតែយកដើមឫស្សីទៅចាក់សត្វស្វាឲ្យលោតពីដើម ១ ទៅដើម ១ ចេះតែលោតតៗ ទៅដរាបដល់ដើមទីបំផុត ស្វានោះទល់គំនិតដោយមើលទៅខាងមុខឃើញសុទ្ធតែវាលស្រឡះនឹងលោតទៅទៀតពុំបាន ព្រោះរកដើមឈើខ្ពស់ទីពឹងគ្មាន ។ ស្វានោះភ័យណាស់ពុំ ដឹងទៅណាទៀត ក៏លោតទៅឱបកំពូលត្នោតសម្ងំនៅស្ងៀម ។ ព្រានព្រៃបានឃើញដូច្នោះហើយក៏លបឡើងទៅចាប់ស្វានោះបានមកទាំងរស់ ហើយយកស្វានោះទៅបង្ហាត់បង្រៀន ដរាបដល់ប្រើការបាន យ៉ាងណាចំណែកសតិទុកដូចជាព្រានព្រៃ, ចិត្តទុកដូចជាស្វា, អាការៈទាំង ៣២ ទុកដូចដើមត្នោត, ព្រះយោគាវចរដែលស្វាធ្យាយនូវអាការៈ ៣២ ដូចព្រានព្រៃដេញស្វាដែលនៅលើកំពូលត្នោតនោះៗ ដូចជាចិត្តដែលពឹងអាការៈ ៣២ ព្រោះឃើញសុទ្ធតែជាបដិកូលគួរខ្ពើមរអើមក្រៃពេកលែងជាប់ចិត្តក្នុងអាការៈនោះៗ ក៏យ៉ាងនេះឯង ។

ម្យ៉ាងទៀតឧបាសក ឧបាសិកា ដល់ថ្ងៃឧបោសថសីលបើសមាទានរួចហើយ គប្បីចម្រើននូវកម្មដ្ឋានណាមួយដើម្បីពង្រាត់ចិត្តឲ្យចេញចាកពីកាមគុណ ៥ ឧបមាដូចគេពង្រាត់កូនគោដែលកំពុងបៅដោះនៅឡើយ ។ កូនគោនោះនូវអាល័យដោះខ្លាំងណាស់ព្រោះជាសត្វនៅតូច តែគេអាចចាប់កូនគោនោះបង្ខាំងទុកហើយគេយកមេវាទៅ ។ លុះគេយកទៅបាត់ចំនួនរំលងស្រែមួយ ឬស្រែពីរទើបគេលែងកូនគោនោះឲ្យទៅបៅដោះមេ ។ ថ្ងៃ

ក្រោយមកទៀតគេចងកូនគោនោះទុកចំនួន ១ ថ្ងៃ កូនគោនោះក៏ទ្រាំនៅបាន ។ គេចេះតែធ្វើដូច្នេះរាល់ៗថ្ងៃដើម្បីឲ្យកូនគោដាច់អាល័យអំពីដោះបន្តិចម្តងៗ ។ យ៉ាងណា, ឧបាសក ឧបាសិកា ដែលស្វាធ្យាយកម្មដ្ឋានក្នុងថ្ងៃឧបោសថរឿយៗ ទៅទាល់តែចិត្តឃ្លាតចេញពីកាមគុណទាំង ៥ បន្តិចម្តងៗ ដើម្បីឲ្យចិត្តឃ្លាតទៅរកវិបស្សនាញាណ ក៏យ៉ាងនោះដែរ ។

**ស.** វិបស្សនាញាណ មានប៉ុន្មាន ?

**ឆ.** វិបស្សនាញាណមាន ៩ យ៉ាង ។

**ស.** មាន ៩ យ៉ាងនោះតើមានអ្វីខ្លះ ? ចូររាប់ និង អធិប្បាយមកមើល !

**ឆ.** មាន ៩ យ៉ាងនោះដូច្នេះគឺ ៖

**១. ឧទយព្វយានុបស្សនាញាណ** ប្រាជ្ញារំពឹងឃើញទាំងសេចក្តីកើតទាំងសេចក្តីរលត់ ;

**២. ភង្គានុបស្សនាញាណ** ប្រាជ្ញារំពឹងឃើញសេចក្តីរលត់ ;

**៣. ភយតុបដ្ឋានញ្ញាណ** ប្រាជ្ញារំពឹងសង្ខារឃើញប្រាកដជារបស់គួរខ្លាច ;

**៤. អាទីនវានុបស្សនាញាណ** ប្រាជ្ញារំពឹងឃើញទោសសង្ខារ ;

**៥. និព្វិទានុបស្សនាញាណ** ប្រាជ្ញារំពឹងដោយសេចក្តីនឿយណាយ ;

**៦. មុញ្ចិតុកម្យតាញាណ** ប្រាជ្ញារំពឹងដោយចង់ចេញផុត

ទៅ ;

**៧. បដិសង្ខារុបស្សនាញ្ញាណ** ប្រាជ្ញារំពឹងដោយពិចារណារកផ្លូវ ;

**៨. សង្ខារុបេក្ខាញ្ញាណ** ប្រាជ្ញារំពឹងដោយសេចក្ដីព្រងើយកន្តើយចំពោះសង្ខារ ;

**៩. សច្ចានុលោមិកញ្ញាណ** ប្រាជ្ញាប្រព្រឹត្តទៅដោយសមគួរដល់សេចក្ដីកំណត់ដឹងនូវអរិយសច្ច ។

## អធិប្បាយថា ៖

- **ញាណទី ១** ពិចារណាឃើញនូវសភាវៈកើតឡើងរលត់សូន្យទៅនៃសង្ខារ ដូចជាពពុះទឹកដែលប៉ោងឡើងហើយបែកធ្លាយទៅវិញ ។
- **ញាណទី ២** ពិចារណាឃើញនូវកិរិយាបែកធ្លាយនៃសង្ខារ គឺឃើញថា **ឧប្បាទៈ**, **ឋិតិ**, **ភង្គៈ**, **ឧប្បាទៈ** ជាជាតិទុក្ខ, **ឋិតិ** ជាជរាទុក្ខ, **ភង្គៈ** ជាមរណទុក្ខ ។ ដូចជាទឹកសន្សើមដែលជាប់នៅលើចុងស្មៅ ព្រះអាទិត្យរះឡើងក៏ស្ងួតហែងហួតអស់ទៅមួយរំពេច យ៉ាងណាមិញ, ចំណែកសង្ខារដែលកើតឡើងហើយសូន្យទៅវិញយ៉ាងនោះដែរ ។
- **ញាណទី ៣** ពិចារណាឃើញថាសង្ខារជាធម្មជាតិគួរខ្លាច ដូចគេខ្លាចសត្វសាហាវមានសីហៈជាដើម ព្រោះឃើញថាសង្ខារណាដែលកន្លងហួសទៅហើយ សង្ខារនោះក៏រលត់ទៅ,

សង្ខារណាដែលកំពុងមាននៅក្នុងបច្ចុប្បន្ន, សង្ខារនោះក៏រលត់ទៅក្នុងបច្ចុប្បន្ន, សង្ខារណាដែលមិនទាន់មានមក ក៏សង្ឃឹមទុកជាមុនថា មុខជានឹងបែកធ្លាយទៅ, ឧបមាដូចជាស្ត្រីមានកូន ៣ នាក់មានទោសកំហុសនឹងព្រះរាជអាជ្ញា ព្រះរាជាមានព្រះរាជឱង្ការឲ្យពេជ្ឈឃាតនាំយកទៅសម្លាប់ ។ មាតាក៏ដើរតាមកូនដែលពេជ្ឈឃាតនាំយកទៅសម្លាប់ ។ លុះដល់កន្លែងសម្រាប់សម្លាប់ហើយ ពេជ្ឈឃាតក៏កាត់ក្បាលកូនច្បងជាដំបូង ។ លុះស្លាប់កូនច្បងនោះហើយ ទើបប្រារព្ធនឹងសម្លាប់កូនកណ្ដាលនោះទៀត ស្ត្រីនោះ កាលបើឃើញនាយពេជ្ឈឃាតកាត់ក្បាលកូនច្បងហើយប្រារព្ធនឹងកាត់ក្បាលកូនបន្ទាប់ទៀត ក៏អស់អាល័យនឹងកូនពៅដោយគិតថាមុខតែគេសម្លាប់កូនពៅទៀតជាមិនខានឡើយ ។ ព្រះយោគីពិចារណាឃើញសង្ខារជាអតីតរលត់ទៅនោះ ដូចជាស្ត្រីឃើញពេជ្ឈឃាតកាត់ក្បាលកូនច្បង ដែលឃើញនូវសង្ខារជាបច្ចុប្បន្នរលត់ទៅនោះ ដូចជាស្ត្រីឃើញពេជ្ឈឃាតកាត់ក្បាលកូនបន្ទាប់ ដែលឃើញនូវសង្ខារជាអនាគតមុខជានឹងបែកធ្លាយទៅដូចជាស្ត្រីអស់អាឡោះអាល័យនឹងកូនពៅ ។

- **ញាណទី ៤** ពិចារណាឃើញទោសរបស់សង្ខារមិនគួរស្ម័គ្រចិត្ត ដូចជាផ្ទះដែលភ្លើងឆេះហើយភៀសខ្លួនចេញពីផ្ទះនោះទៅ ពុំនោះដូចជាឃើញទោសក្នុងភពទាំង ៣ ដ៏វិចិត្ររចនាទៅដោយរងើកភ្លើង **ចត្តារោ មហាភូតា ឃោរវិសាសិវិសាវិយ** មហាភូតរូប ៤ ដូចជាពស់មានពិសដ៏ពន្លឹក, **បញ្ចក្ខន្ធា**

**ឧក្ខិត្តាសិកវធកា វិយ** បញ្ចក្ខន្ធដូចជាខ្មាំង ៥ នាក់ លើកដាវឡើងបំរុងនឹងប្រហារ អ្នកដំណើរដែលដើរទៅតាមផ្លូវ, **ឆ អជ្ឈត្តិកាយតនានិ សុញ្ញគាមោ វិយ** អាយតនៈខាងក្នុង ៦ ដូចជាស្រុកដីស្ងាត់ ជាទីរហោឋាន, **ឆ ពាហិរាយតនានិ គាមឃាតកចោរា វិយ** អាយតនៈខាងក្រៅ ៦ ដូចជាចោរសម្លាប់អ្នកស្រុក, **សត្តវិញ្ញាណដ្ឋិតិយោ នវសត្តាវាសោ ឯកាទសហិ អគ្គីហិ អាទិត្តា សម្បជ្ជលិតា សញ្ជោតិភូតា វិយ ច វិញ្ញាណដ្ឋិតិ ៧** និងសត្តាវាស ៩ ដូចជាគប់ភ្លើងទាំង ១១ សន្ធោសន្ធៅទៅលើពពួកសត្វដែលដេកលក់ក្នុងផ្ទះ គឺសង្សារវដ្ដ, **សព្វេ សង្ខារា រោគា វិយ** សង្ខារទាំងឡាយដូចជាដំបៅនិងរោគាពាធគ្រប់យ៉ាង ។ ព្រះយោគីដែលពិចារណាឃើញទោសរបស់សង្ខារជាក់ច្បាស់កើតឡើងប្រាកដ ដូចជាបុរសមានភ័យប្រាថ្នាចង់បានសេចក្ដីសុខ រត់ទៅរកព្រៃជ្រកបែរទៅឯព្រៃនោះសុទ្ធតែបន្លាជិតស្និទ្ធចូលមិនរួច ចុះទឹកមានអារក្ស ទឹកឬក្រពើជាដើម ។ ដើរតាមផ្លូវប្រទះនឹងចោរ នៅក្នុងភូមិ សុទ្ធតែសេនាទាហាន បុរសនោះឃ្លានបាយណាស់ងាកទៅមើលភោជនសុទ្ធតែថ្នាំពិស ហើយក៏ភិតភ័យតក់ស្លុតមហិមា យ៉ាងណាមិញ, ព្រះយោគាវចរឃើញទោសរបស់សង្ខារ ហើយភិតភ័យខ្លាចក៏យ៉ាងនោះដែរ ។

- **ញាណទី ៥** ពិចារណាឃើញទោសក្នុងសង្ខារធុញទ្រាន់នឿយណាយរអារចិត្ត ដូចសត្វរាជហង្សមាសនៅលើកំពូលភ្នំ

ចិត្តកូដ មិនត្រេកអរនឹងរណ្ដៅដែលប្រឡាក់ដោយវត្ថុមិនស្អាត ត្រេកអរតែនឹងស្រះធំ ៧ ប្រការ យ៉ាងណាមិញ, ព្រះយោគី មិនពេញចិត្តនឹងសង្ខារដែលប្រកបដោយទោសផ្សេងៗ ពេញចិត្ត តែក្នុងអនុបស្សនា ៧ ប្រការយ៉ាងនោះដែរ ។ ពុំនោះសោត, ដូច ជាសត្វសីហៈដែលគេដាក់ក្នុងទ្រុងមាស រមែងមិនត្រេកអរឡើយ តែងត្រេកអរក្នុងព្រៃហេមពាន្តតែម្យ៉ាង យ៉ាងណាមិញ, ព្រះយោគី មិនត្រេកអរក្នុងសុគតិភព ៣ ត្រេកអរតែក្នុង អនុបស្សនាញាណ ៣ ក៏យ៉ាងនោះដែរ ។

- **ញាណទី ៦** ពិចារណាឃើញទោសរបស់សង្ខារប្រាថ្នាចង់ ដោះខ្លួនឲ្យរួចពីខន្ធ ៥ ប្រៀបដូចត្រីចង់រួចពីសំណាញ់ ឬក៏ពី ទីគោក ឬក៏ដូចមនុស្សមានទោសចង់រួចពីទីគុកច្រវាក់ខ្នោះឃ្នាង ពុំនោះដូចសត្វលលកចង់រួចចេញពីទ្រុង ពុំនោះសោតដូចជាសត្វ ពស់ចង់រួចពីកណ្ដាប់ដៃនៃហ្មពស់ សេចក្ដីចង់រួចដូចប្រៀបមកនេះ ហៅថា **មុញ្ចិតុកម្យតាញាណ** ។
- **ញាណទី ៧** ពិចារណាឃើញទោសរបស់សង្ខារហើយ រកឧបាយដែលនឹងដោះខ្លួនឲ្យរួចពីបញ្ចក្ខន្ធ[១] ប្រៀបដូចបុរស ចាប់ពស់ស្មានថាជាត្រី លុះដឹងថាពស់ទើបរកឧបាយនឹងវាយ ពស់នោះឲ្យអន់ហើយទើបលែងទៅ ។
- **ញាណទី ៨** ពិចារណាឃើញទោសរបស់សង្ខារដូច្នោះ

(១) ខន្ធ ៥ គឺរូបក្ខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, វិញ្ញាណក្ខន្ធ ។ ទម្លាយខន្ធ ឬ រំលាង ខន្ធ គឺស្លាប់ ។ រំលត់ខន្ធ គឺចូលនិព្វាន ។

ហើយ ក៏តាំងចិត្តជាឧបេក្ខា[១] គឺតោះតើយមិនសោមនស្សមិនថ្នាំងថ្នាក់នឹងសង្ខារធម៌នោះៗ ឡើយ ដូចបុរសដែលព្រងើយកន្តើយនឹងប្រពន្ធដែលលែងលះស្រឡះហើយ ។ វិបស្សនា ញាណទាំង ៨ នោះប្រៀបឧបមាដូចជាសត្វប្រចៀវ សេចក្ដីថា ប្រចៀវទំនៅលើមែកស្រគំទាំង ៥ ថាមុខជានឹងបានផ្លែផ្កាពីមែកស្រគំទាំង ៥ នេះមិនខានឡើយ ហើយហើរទៅទំលើមែកទីមួយ មិនឃើញមានផ្កាផ្លែនៅត្រង់មែកនោះសោះ ទើបហើរទៅទំលើ មែកទី ២, ទី ៣, ទី ៤, ទី ៥ ទៀតក៏មិនឃើញមានផ្លែទៀត វាក៏គិតថាឈើនេះគ្មានផ្លែបន្តិចបន្តួចសោះ ទើបហើរចេញពីដើមឈើនោះទៅ ហើយហើរទៅទំដើមឯទៀតដែលមានផ្លែវិញមានឧបមាយ៉ាងណាមិញ, ព្រះយោគីពិចារណារូបក្ខន្ធ មិនឃើញមានរបស់អ្វីបន្តិចបន្តួចក្នុងរូបក្ខន្ធសោះ ហើយពិចារណានូវខន្ធដ៏វិសេសដូចជាប្រចៀវទំនៅលើមែកមួយៗ ហើយមិនឃើញនូវរបស់អ្វីបន្តិចបន្តួចសោះ ដូចប្រចៀវស្ទាបអង្អែលនូវមែកដ៏វិសេសដែលធុញទ្រាន់នឿយណាយប្រាថ្នានឹងចេញពីដើមឈើ ដូចប្រចៀវសំគាល់ថាឈើគ្មានផ្លែហើយហើរចេញទៅ ។ ឯអនុលោម ជវនរបស់ព្រះយោគីដូច

---

(១) ឧបេក្ខា ឬ ឧបេក្សា នេះជាប័ក្ខពួកនៃព្រហ្មវិហារធម៌បួន, រាប់រួមគឺ មេត្តា ការរាប់អានជិតដិតស្និទ្ធស្នាលនឹងគ្នា, ករុណា ការអាណិតអាសូរគ្នាទៅវិញទៅមក, មុទិតា ការរីករាយជានិច្ចចំពោះសេចក្ដីសុខ-ចម្រើននៃអ្នកដទៃ, ឧបេក្ខា ការតាំងចិត្តជាកណ្ដាលៗស្មើៗ ។ ព្រហ្មវិហារធម៌ទាំងបួននេះជាប្រភពនៃសន្តិភាពនិងវឌ្ឍនភាពក្នុងលោក... (ព. ពុ.) ។ ព. កា. ថា : មេត្តា-ករុណា-មុទិតា ឧបេក្ខាទាំងបួននេះសោភា ប្រសិនបើជនទាំងអស់គ្នា អាចកាន់រក្សាឲ្យជិតដល់ ។

ប្រចៀវឡើងទៅលើមែកឈើ ត្រង់គោត្រភូញាណដូចប្រចៀវអើតក្បាលចេញ ហើយក្រឡេកមើលទៅខាងលើមគ្គញាណដូចប្រចៀវហើរទៅឰដ៏អាកាស ផលញាណដូចជាប្រចៀវទំនៅលើដើមឈើឯទៀតដែលមានផ្លែ មានឧបមេយ្យដូច្នោះឯង ។

- **ញាណទី ៩** បញ្ញាដែលអនុលោមតាមវិបស្សនាញាណទាំង ៨ ខាងដើម សច្ចានុលោមញ្ញាណ នេះបានដល់ជវនទាំង ៣ គឺ **បរិកម្មជវន** លះកិលេសគ្រោតគ្រាត ១, **ឧបចារជវន** លះកិលេសយ៉ាងកណ្តាល ១, **អនុលោមជវន** លះកិលេសយ៉ាងល្អិត ១ ។ វិបស្សនាញាណខាងដើមមានព្រះត្រៃលក្ខណ៍ជាអារម្មណ៍ អនុលោមញ្ញាណមានពោធិបក្ខិយធម៌ជាអារម្មណ៍ ឧបមាដូចស្តេចប្រកបដោយរាជធម៌ គង់នៅក្នុងសាលាសម្រាប់វិនិច្ឆ័យក្តី ហើយចាំស្តាប់ពាក្យមហាមាត្យទាំង ៨ នាក់ដែលជាអ្នកវិនិច្ឆ័យទ្រង់ពេញព្រះរាជហឫទ័យចំពោះពាក្យមហាមាត្យទាំងនោះព្រះអង្គក៏ទ្រង់អនុលោម ទៅតាមពាក្យមហាមាត្យដែល វិនិច្ឆ័យត្រឹមត្រូវនោះ យ៉ាងណាមិញ, អនុលោមញ្ញាណ ដូចជាស្តេច, វិបស្សនាទាំង ៨ ទុកដូចជាមហាមាត្យ, ពោធិបក្ខិយធម៌ ៣៧ ទុកដូចជាស្តេចប្រកបដោយរាជធម៌ដែលមានមកពីដើម ក៏យ៉ាងនោះដែរ ។

**វិបស្សនាញាណទាំង ៩** ដូចជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងមើលសង្ខារធម៌ទាំងអស់ ។

( **ចប់ភាវេតព្វកិច្ចតែប៉ុណ្ណោះ** )

# សច្ចកិរិយាគាថា[១]

## គាថានៃដំណើរបួងសួង ៖



**ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា**
**អាចរិយូបការា ច មាតា បិតា បិយា មមំ**

*ប្រែថា* ព្រះឧបជ្ឈាយ៍ទាំងឡាយផងដែលមានគុណយ៉ាងលើសលុប, ព្រះអាចារ្យទាំងឡាយផងដែលមានឧបការគុណ, មាតាបិតាផងដែលជាទីស្រឡាញ់របស់ខ្ញុំ ( សូមឲ្យជាបុគ្គលមានសេចក្ដីសុខ ) ដោយសារបុញ្ញកម្ម[២]នេះ ;

---

(១) ធម៌គមិនានេះ ព្រះមហាវិរិយបណ្ឌិត **សទ្ធាវិន្ទ ( ពាខ សុខ )** អតីតក្រុមជំនុំព្រះត្រៃបិដកបានប្រែនិងកែបាលីយ៉ាងត្រឹមត្រូវឥតខ្ចោះ ព្រោះលោកឮកែខាងបាលីលេខ ១ ។
(២) បុញ្ញ បុញ-ញ៉ៈ បា.; សំ. ( ន. ) (បុណ្យ) គុណជាតជាគ្រឿងជម្រះសន្តានចិត្តឬដែលកើតពីចិត្តជ្រះថ្លា គឺបុណ្យ, កុសល, អំពើល្អ (ម. ព. បុណ្យ) ។ ពាក្យ បុញ្ញ នេះសម្រាប់តែប្រើខាងដើមពាក្យឯទៀតៗ ដូចជា បុញ្ញកម្ម (បុញ-ញ៉ៈក័ម) ន. (បា.; សំ. បុណ្យ + កម៌ន៑) អំពើដែលជាបុណ្យ (ម. ព. បុណ្យ ផង) ។ ព. ផ្ទ. បាបកម្ម ។

**សុរិយោ ចន្ទិមា រាជា គុណវន្តា នរាបិ ច ព្រហ្មា**
**មារា ច ឥន្ទ្រា ច លោកបាលា ច ទេវតា**

*ប្រែថា* ព្រះអាទិត្យផង ព្រះចន្ទផង ព្រះរាជាផង ទាំងមនុស្សទាំងឡាយដែលមានគុណផង ព្រះព្រហ្មនិងទេវបុត្តមារទាំងឡាយផង ព្រះឥន្ទ្រទាំងឡាយផង ទេវតាទាំងឡាយដែលថែរក្សានូវសត្វផង (សូមឲ្យជាបុគ្គលមានសេចក្ដីសុខ) ដោយសារបុញ្ញកម្មនេះ ;

**យមោ មិត្តា មនុស្សា ច មជ្ឈត្តា វេរិកាបិ ច**
**សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ បកតានិ មេ**
**សុខញ្ច តិវិធំ ទេន្តុ ខិប្បំ បាបេថ វោមតំ ។**

*ប្រែថា* ព្រះយមរាជផង មនុស្សទាំងឡាយផង ដែលជាទីស្រឡាញ់ខ្លះ ដែលមានចិត្តយ៉ាងកណ្ដាលខ្លះ ដែលមានពៀរខ្លះ សត្វទាំងឡាយទាំងអស់ផង សូមឲ្យជាបុគ្គលមានសេចក្ដីសុខ ( ដោយសារបុញ្ញកម្មនេះ ) សូមឲ្យបុណ្យទាំងឡាយដែលខ្ញុំបានសាងហើយ ឲ្យនូវសេចក្ដីសុខដែលមាន ៣ យ៉ាងដល់ខ្ញុំផង សូមឲ្យអ្នកទាំងឡាយ ( ញុំាងខ្លួន ) ឲ្យដល់នូវព្រះនិព្វានយ៉ាងឆាប់ផង ;

**ឥមិនា បុញ្ញកម្មេន ឥមិនា ឧទ្ទិសេន ច**
**ខិប្បាហំ សុលភេ ចេវ តណ្ហុបាទានឆេទនំ**

*ប្រែថា* សូមឲ្យខ្ញុំបានងាយនូវកិរិយាកាត់នូវតណ្ហា និង ឧបាទានយ៉ាងឆាប់ផងកុំឲ្យខាន ដោយសារបុញ្ញកម្មនេះ និង ដោយសារកិរិយាផ្សាយនូវផលនៃបុញ្ញកម្មនេះ ;

**យេ សន្តានេ ហីនា ធម្មា យាវ និព្វានតោ មមំ**
**នស្សន្តុ សព្វទាយេវ យត្ថ ជា តោ ( តា ) ភវា ភវេ**

*ប្រែថា* ធម៌គឺចិត្តចេតសិកទាំងឡាយណាដែលថោកថយ ( មាន ) ក្នុងសន្តានរបស់ខ្ញុំ ខ្ញុំកើតក្នុងភពណា ក្នុងភពណា សូមឲ្យ ( ធម៌គឺចិត្តនិងចេតសិកទាំងឡាយនោះ ) បាត់ ( ក្នុងភព នោះភពនោះ ) ផងកុំឲ្យខាន គ្រប់កាលទាំងពួង រហូតអំពី ព្រះនិព្វាន ( ដោយសារបុញ្ញកម្មនេះ និងដោយសារកិរិយាផ្សាយ នូវផលនៃបុញ្ញកម្មនេះ ) ;

**ឧជុចិត្តំ សតិប្បញ្ញោ សល្លេខោ វិរីយោម្ហិ នា**
**មារា លភន្តុ នោកាសំ កាតុញ្ច វិរីយេសុ មេ**

*ប្រែថា* ចិត្តត្រង់ផងមែនពិត សតិនិងបញ្ញាទាំងឡាយ ផងមែនពិត សេចក្តីហ្មត់ហ្មងផងមែនពិត សេចក្តីព្យាយាមផង មែនពិត ( សូមឲ្យមានដល់ខ្ញុំផងកុំខាន ), សូមកុំឲ្យមារទាំងឡាយ បានសោះនូវឱកាសដើម្បីធ្វើនូវ ( អន្តរាយ ) ក្នុងសេចក្តីព្យាយាម ទាំងឡាយរបស់ខ្ញុំផង ( ដោយសារបុញ្ញកម្មនេះ និងដោយសារ បុញ្ញកម្មនេះ និងដោយសារកិរិយាផ្សាយនូវផលនៃបុញ្ញកម្មនេះ ) ;

**ពុទ្ធោ ទីបវរោ នាថោ ធម្មោ នាថោ វរុត្តមោ**
**នាថោ បច្ចេកពុទ្ធោ ច សង្ឃោ នាថោត្តរោ មមំ**
**តេ សោត្តមានុភាវេន មារោកាសំ លភន្តុ មា ។**

*ប្រែថា* ព្រះពុទ្ធដូចប្រទីបដ៏ប្រសើរជាទីពឹងរបស់ខ្ញុំផង ព្រះធម៌ដ៏ប្រសើរជាទីពឹងរបស់ខ្ញុំផង ព្រះបច្ចេកពុទ្ធដ៏ខ្ពង់ខ្ពស់ជាទីពឹងរបស់ខ្ញុំផង ព្រះសង្ឃដ៏លើសលប់ជាទីពឹងរបស់ខ្ញុំផង សូមកុំឲ្យមារទាំងឡាយបាននូវឱកាស ( ដើម្បីធ្វើនូវអន្តរាយនៃបុញ្ញកម្មរបស់ខ្ញុំ ) ដោយសារអានុភាពដ៏ខ្ពង់ខ្ពស់របស់ព្រះពុទ្ធ និងព្រះធម៌ និងព្រះបច្ចេកពុទ្ធ និងព្រះសង្ឃទាំងឡាយនោះ ។

( **ចប់ឥមិនា** )

# សុខមូលកគាថា

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា[១]**
**សុខា សង្ឃស្សសាមគ្គី សមគ្គានំ តបោ សុខោ ។**

*ប្រែថា* ការកើតឡើងនៃព្រះពុទ្ធទាំងឡាយនាំមកនូវសេចក្ដីសុខ, ការសំដែងព្រះសទ្ធម្មនាំមកនូវសេចក្ដីសុខ ការព្រមព្រៀងគ្នានៃពួកនាំមកនូវសេចក្ដីសុខ, តបធម៌របស់ជនអ្នកព្រម

(១) សុខោនេះ មហាពុទ្ធបរិស័ទតែងសូត្រក្នុងធម្មសភាវត្តលង្កាក្រុងភ្នំពេញ ដែលជាកន្លែងប្រជុំសមាទានសីលធំបំផុតក្នុងប្រទេសកម្ពុជា, សូត្រពេលព្រះសង្ឃឲ្យពរហើយ បន្ទាប់ពីសូត្រសុខោនេះទៅ សូត្រអាកាសដ្ឋា ទើបសូត្រយំកិញ្ចិចុងបំផុត ។

ព្រមព្រៀងគ្នាទាំងឡាយនាំមកនូវសេចក្តីសុខ ។

**ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា**
**សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ**
**អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេជសា ។**

*ប្រែថា* ព្រះអាទិត្យរុងរឿងតែពេលថ្ងៃ, ព្រះចន្ទរុងរឿងតែពេលយប់, ក្សត្រទ្រង់គ្រឿងក្រោះទើបរុងរឿង, ព្រាហ្មណ៍មានឈានទើបរុងរឿង, ឯព្រះពុទ្ធទ្រង់រុងរឿងដោយតេជៈទាំងថ្ងៃទាំងយប់ ។

**ឯតេន សច្ចវជ្ជេន សុវត្ថិ (មេ / នោ) ហោតុ សព្វទា ។**

*ប្រែថា* ដោយសច្ចវាចានេះសូមសួស្តីមានដល់ ( ខ្ញុំ / យើងទាំងឡាយ ) គ្រប់កាលទាំងពួង ។

**ហិរិឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា**
**សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ ។**

*ប្រែថា* ពួកសប្បុរសមានសន្តានស្ងប់ បរិបូណ៌ដោយហិរិនិងឱត្តប្បៈ មានស្មារតីតម្កល់មាំក្នុងធម៌ស បណ្ឌិតទាំងឡាយហៅថាទេវធម៌ក្នុងលោក ។

( **ចប់សុខោ** )

# នមស្ការបូជនីយវត្ថុជាទីគោរព

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ**
**សារីរិកធាតុ មហាពោធឹ ពុទ្ធរូបំ សកលំ សទា ។**

*ប្រែថា* ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះចេតិយទាំងអស់ ដែលប្រតិស្ឋានល្អហើយក្នុងទីទាំងពួង នូវព្រះមហាពោធិព្រឹក្ស និងព្រះសារីរិកធាតុផង នូវព្រះពុទ្ធរូបទាំងអស់ ផងក្នុងកាលទាំងពួង ។

## ប្រែមួយបែបទៀត

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលស្ថិតនៅគ្រប់ទី ស្ថាននានានោះទាំងអស់ ។
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ ។
សូមឲ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឲ្យក្លាយមកជាមិត្ត ។
សូមទាន់ព្រះអរិ- យមេត្រីថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ៕

# រតនត្តយវន្ទនគាថា
# នមស្ការព្រះរតនត្រ័យ - យោកប្បកោដីហិបិ

( ប្រែជាពាក្យកាព្យ )

**យោ កប្បកោដីហិបិ អប្បមេយ្យំ កាលំ ករោន្តោ**
**អតិទុក្ករានិ ខេទំ គតោ លោកហិតាយ នាថោ**
**នមោ មហាការុណិកស្ស តស្ស ។**

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន ។
ធ្វើកម្មជាកម្រ មនុស្សនិករគ្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

**អសម្ពុធំ ពុទ្ធនិសេវិតំ យំ ភវាភវំ គច្ឆតិ**
**ជីវលោកោ នមោ អវិជ្ជាទិកិលេសជាលំ**
**វិទ្ធំសិនោ ធម្មវរស្ស តស្ស ។**

សត្វតែងកើតស្លាប់បង់ ព្រោះចំណង់កម្មជាគោល
ឲ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ។

ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម
គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្ការ ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្តាញកិលេសហើយ ។

**គុណេហិ យោ សីលសមាធិបញ្ញា**
**វិមុត្តិញាណប្បភុតីហិ យុត្តោ**
**ខេត្តញ្ជនានំ កុសលត្ថិកានំ**
**តមរិយសង្ឃំ សិរសា នមាមិ ។**

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។

**ឥច្ចេវមច្ចន្ត នមស្សនេយ្យំ**
**នមស្សមានោ រតនត្តយំ យំ**
**បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ**
**តស្សានុភាវេន ហតន្តរាយោ ។**

ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។

| | |
|---|---|
| សូមបុណ្យកងកុសល | ឲ្យបានដល់យើងខ្ញុំណា |
| ពេញពោរស្មើធារា | ដូចជលសាធំទូលាយ ។ |
| សូមឲ្យកំចាត់បង់ | អពមង្គលទាំងឡាយ |
| ឲ្យចៀសចេញចាកឆ្ងាយ | ក្តីអន្តរាយកុំបីមាន ។ |
| ដោយកម្លាំងអានុភាព | បុញ្ញលាភជាប្រធាន |
| កងបុណ្យរាសីមាន | សូមបានក្សាន្តកុំមានមោះ ។ |
| ដោយគុណនមស្ការ | ត្រៃរតនាប្រសើរខ្ពស់ |
| សូមអានិសង្សនោះ | ដាក់ដល់ឋាននិព្វានហោង ៕ |

## សូមរង់ចាំអាន! សូមរង់ចាំអាន!

**១. ក្រមងកំណាព្យ ភាគទី ២**

រៀបរៀងដោយ ឧបាសក **ហ៊ុម ឆាន់**

(បោះពុម្ពផ្សាយនៅចូលឆ្នាំសកល ២០១៥)

**២. ចំណងដៃឆ្នាំថ្មី**

រៀបរៀងដោយ ឧបាសក **ម៉ិញ សាវ៉ាន**

(បោះពុម្ពផ្សាយនៅចូលឆ្នាំខ្មែរ ២០១៥)

# អនុមោទនារក្ខាយាចនគាថា

( គាថានៃកិរិយាសូមនូវកិរិយាអនុមោទនា និងកិរិយារក្សា )

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ** (**មេ**[១] / **នោ**[២]) **អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។**

*ប្រែថា* ទេវតាទាំងឡាយ ដែលស្ថិតនៅឰដ៏អាកាសផង ដែលស្ថិតលើផែនដីផង នាគទាំងឡាយដែលមានឫទ្ធិច្រើនផង សូមឲ្យអនុមោទនានូវបុណ្យរបស់ (ខ្ញុំ[១] / យើងទាំងឡាយ[២]) សូមឲ្យរក្សានូវព្រះពុទ្ធសាសនា (ឲ្យស្ថិតស្ថេររុងរឿង) យូរយារ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ** (**មេ**[១] / **នោ**[២]) **អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ។**

*ប្រែថា* ទេវតាទាំងឡាយ ដែលស្ថិតនៅឰដ៏អាកាសផង ដែលស្ថិតលើផែនដីផង នាគទាំងឡាយដែលមានឫទ្ធិច្រើនផង សូមឲ្យអនុមោទនានូវបុណ្យរបស់ (ខ្ញុំ[១] / យើងទាំងឡាយ[២]) សូមឲ្យរក្សានូវព្រះរាជាទាំងឡាយ (ឲ្យស្ថិតក្នុងជោគជ័យ) យូរយារ ។

---

(១) **មេ** : ខ្ញុំ ( ម្នាក់ឯង )

(២) **នោ** : យើងទាំងឡាយ ( គ្នាច្រើន )

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ (មេ[១] / នោ[២]) អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ ។**

*ប្រែថា* ទេវតាទាំងឡាយ ដែលស្ថិតនៅឰដ៏អាកាសផង ដែលស្ថិតលើផែនដីផង នាគទាំងឡាយដែលមានឫទ្ធិច្រើនផង សូមឲ្យអនុមោទនានូវបុណ្យរបស់ (ខ្ញុំ[១] / យើងទាំងឡាយ[២]) សូមរក្សានូវញាតិទាំងឡាយ (ឲ្យបានចម្រុងចម្រើន និងសុខសាន្ត) យូរយារ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ (មេ[១] / នោ[២]) អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ។**

*ប្រែថា* ទេវតាទាំងឡាយ ដែលស្ថិតនៅឰដ៏អាកាសផង ដែលស្ថិតលើផែនដីផង នាគទាំងឡាយដែលមានឫទ្ធិច្រើនផង សូមឲ្យអនុមោទនានូវបុណ្យរបស់ (ខ្ញុំ[១] / យើងទាំងឡាយ[២]) សូមរក្សានូវសត្វទាំងឡាយ (ឲ្យចម្រុងចម្រើន និងសុខសាន្ត) យូរយារ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ (មេ[១] / នោ[២]) អនុមោទន្តុ ចិរំ រក្ខន្តុ (មេ[១] / នោ[២]) សទា ។**

---

(១) **មេ** : ខ្ញុំ ( ម្នាក់ឯង )

(២) **នោ** : យើងទាំងឡាយ ( គ្នាច្រើន )

*ប្រែថា* ទេវតាទាំងឡាយ ដែលស្ថិតនៅឰដ៏អាកាសផង ដែលស្ថិតលើផែនដីផង នាគទាំងឡាយដែលមានឫទ្ធិច្រើនផង សូមឲ្យអនុមោទនានូវបុណ្យរបស់ (ខ្ញុំ[១]យើងទាំងឡាយ[២]) សូមរក្សានូវយើងទាំងឡាយ (ឲ្យបានចម្រុងចម្រើន និងសុខសាន្ត) យូរយារគ្រប់កាលទាំងពួង ។

( **ចប់អាភាសង្ឃា** )

(១) **មេ** : ខ្ញុំ ( ម្នាក់ឯង )

(២) **នោ** : យើងទាំងឡាយ ( គ្នាច្រើន )

# បត្តិទានគាថា

ពុទ្ធសាសនិកជន ដែលបានធ្វើកុសលណាមួយរួចហើយ បើមានប្រាថ្នា និងឲ្យចំរើនផលានិសង្សដល់ខ្លួនដោយច្រើនឡើងទៀតនោះ គប្បីឧទ្ទិសផ្សាយផលនៃកុសលនោះដល់សត្វទាំង-ឡាយ ដោយកុសលចិត្តជាបុញ្ញកិរិយាវត្ថុ ១ យ៉ាងដែលហៅថា **បត្តិទាន** គឺកិរិយាឲ្យនូវចំណែកបុណ្យដល់អ្នកដទៃ ដោយបត្តិទានគាថានេះដូចនេះ ៖

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម**
**កាយេន វាចាមនសា តិទសេ សុគតំ កតំ**
**យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ**
**កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុតេ**
**យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា**
**យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ**
**សព្វេ លោកម្ហិយេ សត្តា ជីវន្តាហារហេតុកា**
**មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។**

*ប្រែថា* **យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម** អំពើជាកុសលឯណាមួយដែលខ្ញុំគប្បីធ្វើ **កាយេន វាចា មនសា** ដោយទ្វារទាំង ៣ គឺកាយ វាចា ចិត្ត **តិទសេ សុគតំ កតំ** អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយជា

កុសលអាចនឹងនាំឲ្យទៅកើតក្នុងឋានត្រៃត្រិង្សសួគ៌បាន **យេ សត្តា សញ្ញិនោ អត្ថិ** សត្វទាំងឡាយឯណា គឺជាមនុស្សឬទេវតា ឬព្រហ្មដែលជាសត្វមានសញ្ញាក្តី **យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយឯណា ជាអសញ្ញីសត្វ គឺសត្វដែលឥតសញ្ញាក្តី **កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ** សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយបានឧទ្ទិសផ្សាយឲ្យទៅនេះចុះ **យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណាបានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឲ្យបានសោយនូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសឲ្យទៅនោះចុះ **យេ ច តត្ថ ន ជានន្តិ** ម្យ៉ាងទៀត បណ្តាសត្វទាំងអស់នោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ **ទេវា គន្ត្វា និវេទយុំ** សូមទេវតាទាំងឡាយអញ្ជើញទៅឲ្យដំណឹងដល់សត្វទាំងឡាយនោះ ឲ្យបានដឹងផងថាជនឯនោះគេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ **សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ដែលអាស្រ័យនូវអាហារហើយរស់នៅ **មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ** សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវភោជន

ជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិតាមចិត្តខ្ញុំដែលឧទ្ទិសផ្សាយទៅឲ្យនេះចុះ ។

# បត្តិទានគាថា (ប្រែជាពាក្យកាព្យ)

កម្មជាកុសលឯណា ដែលជាការឥតសៅហ្មង
យើងខ្ញុំបានកសាង ដោយទ្វារកាយវាចាចិត្ត ។
កុសលទាំងអស់នោះ អាចជួយដោះជួយបង្ខិត
នាំសត្វឲ្យជាប់ចិត្ត ស្ថិតនៅនាស្ថានឧត្តម ។
សត្វណាមានសញ្ញា មនុស្សទេព្តាឬឥន្ទព្រហ្ម
ដែលមានស័ក្តិតូចធំ ព្រមទាំងសត្វឥតសញ្ញា ។
សូមបានចំណែកបុណ្យ ដែលជាគុណល្អថ្លៃថ្លា
យើងខ្ញុំបានរចនា ចាត់ចែងការកុសលហ្នឹង ។
ម្យ៉ាងទៀតសត្វឯណា ឆ្ងាយអស្ចារ្យពុំបានដឹង
សូមទេព្តាទៅប្តឹង ឲ្យដំណឹងយ៉ាងនេះថា ។
នរជននៅឯនុ៎ះ ស្រីឬប្រុសបានជ្រះថ្លា
កសាងបុញ្ញកិរិយា វត្តជាផ្លូវឆើតឆាយ ។
ហើយគេឧទ្ទិសផល ឲ្យបានដល់អ្នកទាំងឡាយ
ចូរមានចិត្តស្រស់ស្រាយ បន្ទន់កាយទទួលយក ។
សត្វលោកទាំងអស់នោះ ដែលបានរស់តរៀងមក
ដោយបានបរិភោគ នូវអាហារទើបរស់បាន ។

សត្វទាំងអស់នោះណា បានសុខាសព្វគ្រប់ប្រាណ
អាហារយ៉ាងចំណាន សូមឲ្យបានកុំខានឡើយ ៕

**ស**. សត្វដែលឥតសញ្ញានោះ បានដល់សត្វពួកណា ? ស្ថិតនៅទីណា ?

**ឆ**. សត្វដែលឥតសញ្ញានោះ បានដល់អសញ្ញីសត្វ ស្ថិតនៅក្នុងអសញ្ញីភព ។

**ន**. អសញ្ញីសត្វនោះ ហេតុអ្វីក៏ទទួលកុសលដែលគេឧទ្ទិសឲ្យនោះបាន ? បើគ្មានសញ្ញាសោះ ?

**ឆ**. ទោះបីទទួលបានក្តី មិនបានក្តី ត្រូវឧទ្ទិសផលឲ្យទៅអ្នកធ្វើកុសលត្រូវឧទ្ទិសផលឲ្យ ព្រោះប្រកបដោយមេត្តាចិត្ត ។

**ស**. អ្នកឧទ្ទិសផលឲ្យទៅនោះ សុទ្ធតែបានដល់ឬមានមិនដល់ដែរ ?

**ឆ**. អ្នកឧទ្ទិសផលឲ្យទៅនោះ សុទ្ធតែបានដល់ទាំងអស់ ។

**ស**. បើសុទ្ធតែដល់ទាំងអស់ ចុះក្នុងសោណិជានិសូត្រ ថាបានដល់តែប្រេត ៣ ពួក មានប្រេតបរទត្តូបជិវីជាដើមទេ ចុះហេតុអ្វីក្នុងបត្តិទានគាថានេះថាបានដល់ពួកសត្វទាំងអស់ ?

**ឆ**. ឧទ្ទិសផលនោះមានពីរចំណែក, ១ ចំណែកឧទ្ទិសចំពោះឲ្យកើតអាហារ ឬសំពត់សម្រាប់ស្លៀកពាក់ នោះបានចំពោះតែប្រេត ៣ ពួកទេ, ឯមនុស្សទេវតាជាដើមមិនបានទេ ឧទ្ទិសឲ្យទៅបាននោះ គឺឧទ្ទិសកុសលឲ្យទៅមិនកំណត់ដូចបុណ្យធ្វើជា

សាធារណ៍ ទោះបីទៅកើតក្នុងទីណាក៏គង់ដល់ ។

**ស**. ឧទ្ទិសដល់ ប្រកបដោយអង្គប៉ុន្មាន ?

**ច**. ឧទ្ទិសដល់ ប្រកបដោយអង្គ ៣ ។

**ស**. អង្គ ៣ នោះគឺអ្វីខ្លះ ? ចូររាប់និងអធិប្បាយ !

**ច**. អង្គ ៣ ដូច្នេះគឺ ៖

**១. ឧទ្ទិសេន** អ្នកឧទ្ទិសឲ្យទៅ ;

**២. សង្ឃម្ហិ សុប្បតិដ្ឋិតំ** តម្កល់នៅចំពោះសង្ឃ ;

**៣. អនុមោទនេន** ពួកសត្វទាំងអស់នោះបានទទួលអនុមោទនា ។ អធិប្បាយថា ៖

- **ឧទ្ទិសេន** អ្នកឧទ្ទិសឲ្យទៅនោះគឺ កូនចៅសាច់សាលោហិតញាតិមិត្រ ធ្វើកុសលណាមួយហើយឧទ្ទិសឲ្យទៅដោយមេត្តាចិត្ត ឬដោយកតញ្ញូកតវេទី ។

- **សង្ឃម្ហិ សុប្បតិដ្ឋិតំ** ដែលតម្កល់នៅចំពោះសង្ឃនោះគឺឲ្យដល់សង្ឃ ឬដែលគណៈសង្ឃឧទ្ទិសឲ្យទៅ ឈ្មោះថាសង្ឃទាំងអស់ ។

- **អនុមោទនេន** សត្វដែលកំពុងរងទុក្ខ ដែលគេឧទ្ទិសផលឲ្យទៅបើសត្វមានកម្មស្រាលទទួលផលបាន បើសត្វនោះមានកម្មធ្ងន់ផលទៅដល់ទទួលយកមិនបានទេ ។ បើប្រកបដោយអង្គទាំង ៣ នេះទើបទទួលបាន ។

# បត្តិទានគាថា

យា ទេវតា សន្តិ វិហារវាសិនី
ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ
តា ធម្មទានេន ភវន្តុ បូជិតា
សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ
ថេរា ច មជ្ឈា នវកា ច ភិក្ខវោ
សារាមិកា ទានបតី ឧបាសកា
គាមា ច ទេសា និគមា ច ឥស្សរា
សប្បាណភូតា សុខិតា ភវន្តុ តេ
ជលាពុជា យេបិ ច អណ្ឌសម្ភវា
សំសេទជាតា អថ វោបបាតិកា
និយ្យានិកំ ធម្មវរំ បដិច្ច តេ
សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ ។
ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា
សង្ឃោ ហោតុ សមគ្គោ វ អត្ថាយ ច ហិតាយ
ច អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ
វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ ។

*ប្រែថា* **យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ** ទេវតាទាំងឡាយឯណាមានប្រក្រតីនៅក្នុងទីវត្តជាទីនៅនៃសង្ឃ ឰដ៏ខឿនព្រះសថូប ឰដ៏ខឿនព្រះពោធិព្រឹក្សក្នុងទីនោះៗ **តា ធម្មទានេន ភវន្តុ បូជិតា**

ទេវតាទាំងឡាយនោះជាបុគ្គល គឺយើងទាំងឡាយបូជាហើយដោយធម្មទាន **សោត្ថឹ ករោន្តុ ឲ វិហារមណ្ឌលេ** ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវត្តជាទីនៅនៃសង្ឃនេះ **ថេរា ច មជ្ឈា នវកា ច ភិក្ខវោ** ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី **សារាមិកា ទានបតី ឧបាសកា** ឧបាសក និងឧបាសិកាទាំងឡាយដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជន គឺញោមវត្តក្តី **គាមា ច ទេសា និគមា ច ឥស្សរា** ជនទាំងឡាយដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈជាធំក្តី **សប្បាណភូតា សុខិតា ភវន្តុ តេ** សត្វទាំងឡាយនោះ ៗ ចូរឲ្យបានដល់នូវសេចក្តីសុខ **ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថវោបបាតិកា** មួយវិញទៀតសត្វទាំងឡាយឯណាដែលជាជលាពុជៈ[១]កំណើតក្តី ដែលជាអណ្ឌជៈ[២] កំណើតក្តី ដែលជាសំសេទជៈ[៣]កំណើតក្តី ដែលជាឧបបាតិកៈ[៤] កំណើតក្តី **និយ្យានិកំ ធម្មវរំ បដិច្ច តេ**

---

(១) ជលាពុជៈ សត្វដែលកើតឡើងអំពីសុក ។

(២) អណ្ឌៈ អន់-ឌៈ បា.; សំ. (ន.) (អណ្ឌ; អាណ្ឌ ឬជា អណ្ឌ ក៏មាន) ស៊ុត (ពងសត្វមានពងមាន់, ពងទា ជាដើម) : អណ្ឌជៈ សត្វដែលកើតអំពីស៊ុត (ហៅ អណ្ឌជសត្ត ឬ--សត្វ ក៏បាន) ។ អណ្ឌជៈកំណើត កំណើតអំពីស៊ុត (ហៅ ទ្វិជសត្វ ក៏បាន) ។

(៣) សំសេទជ ស័ង-សេទៈ ជៈ បា. សំ. (គុ.) (--ជ; សំស្វេទជ) ដែលកើតពីញើសក្អែល ។ សំសេទជសត្ត ឬ សំស្វេទជសត្វ សត្វដែលកើតពីញើសក្អែលឬពីទីដែលស្មោកគ្រោកអាប់អួ : ចៃ, សង្កើច,... ជាសំសេទជសត្ត (ម. ព. សេទជ ផង) ។

(៤) ឧបបាតិក អ៊ុប៉ៈប៉ាតិកៈ បា. (ន.) ដែលកើតឯង; សត្វដែលចាប់កំណើតឯងៗ ។

**សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ** សត្វទាំងឡាយទាំងអស់នោះកាលបើបានអាស្រ័យនូវធម៌ដ៏ប្រសើរជានិយ្យានិកធម៌[១] ហើយចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ **ឋាតុ ចិរំ សតំ ធម្មោ** សូមឲ្យធម៌របស់សប្បុរសទាំងឡាយស្ថិតនៅអស់កាលយូរអង្វែងទៅ **ធម្មធរា ច បុគ្គលា** បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរស្ថិតនៅអស់កាលយូរអង្វែងទៅ) **សង្ឃោ ហោតុ សមគ្គោវ** សូមព្រះសង្ឃព្រមព្រៀងគ្នា **អត្ថាយ ច ហិតាយ ច** ដើម្បីសេចក្ដីចំរើនផង ដើម្បីសេចក្ដីសម្រេចផលប្រយោជន៍ផង **អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ** សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង **វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ** សូមឲ្យយើងទាំងឡាយបានដល់នូវ សេចក្ដីចំរើនក្នុងធម៌ដែលព្រះអរិយៈទាំងឡាយលោកសំដែងហើយ ។

( **ចប់យាវទេវតា** )

---

(១) និយ្យានិកធម៌ និយ-យា និក:ធ័រ បា.; សំ. ( ន. ) (--ធម្ម) ធម៌សម្រាប់ដឹកនាំ ឬ យឹតយោងស្រោចស្រង់សត្វឲ្យរួចចាកទុក្ខ : ពុទ្ធសាសនា ជានិយ្យានិកធម៌ ។

# សុខាភិយាចនគាថា

**បសន្នា ហោន្តុ សព្វេបិ បាណិនោ ពុទ្ធសាសនេ**
**សម្មា ធារំ បវេច្ឆន្តោ កាលេ ទេវោ បវស្សតុ**
**វុឌ្ឍិភាវាយ សត្តានំ សមិទ្ធំ នេតុ មេទនឹ**
**មាតា បិតា ច អត្រជំ និច្ចំ រក្ខន្តិ បុត្តកំ**
**ឯវំ ធម្មេន រាជានោ បជំ រក្ខន្តុ សព្វទា ។**

*ប្រែថា* **បសន្នា ហោន្តុ សព្វេបិ បាណិនោ ពុទ្ធសាសនេ** សត្វទាំងឡាយទាំងពួងចូរជ្រះថ្លាក្នុងព្រះពុទ្ធសាសនា **សម្មា ធារំ បវេច្ឆន្តោ កាលេ ទេវោ បវស្សតុ វុឌ្ឍិភាវាយ សត្តានំ សមិទ្ធំ នេតុ មេទនឹ** សូមឲ្យភ្លៀងបង្អូរនូវធារទឹកដោយប្រពៃ ចូរបង្អុរចុះក្នុងកាលដ៏គួរ ចូរបណ្ដាលឲ្យផែនដីសំរិទ្ធិ គឺថាឲ្យមានជីវជាតិល្អឡើងដើម្បីឲ្យកើតសេចក្ដីចំរើនដល់សត្វទាំងឡាយ **មាតា បិតា ច អត្រជំ និច្ចំ រក្ខន្តិ បុត្តកំ** មាតាក្ដី បិតាក្ដី បីបាច់រក្សាជានិច្ចនូវកូនតូចជាកូនបង្កើត យ៉ាងណាមិញ **ឯវំ ធម្មេន រាជានោ បជំ រក្ខន្តុ សព្វទា** សូមព្រះបរមក្សត្រទាំងឡាយរក្សានូវប្រជាជនតាមគន្លងធម៌ ដូចជាមាតាបិតាបីបាច់រក្សាកូនដូច្នោះឲ្យបានសព្វកាលទៅហោង ។

( ធម៌នេះសម្រាប់សូត្រក្នុងកាលចប់ទេសនា ឬចប់ព្រះបរិត្ត )

# បរិត្តភាសនាយាចនគាថា

( ពាក្យអារាធនាព្រះភិក្ខុសង្ឃសូមឲ្យចម្រើនព្រះបរិត្ត )

**វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា**
**សព្វទុក្ខវិនាសាយ បរិត្តំព្រូថមង្គលំ ។**
**វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា**
**សព្វភយវិនាសាយ បរិត្តំព្រូថមង្គលំ ។**
**វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា**
**សព្វរោគវិនាសាយ បរិត្តំព្រូថមង្គលំ ។**

*ប្រែថា* សូមព្រះករុណាទាំងឡាយចម្រើននូវព្រះបរិត្តជាជយមង្គល ដើម្បីនឹងការពារបញ្ចៀសនូវវិបត្តិ គឺសេចក្តីអន្តរាយទាំងពួង ដើម្បីនឹងឲ្យបានសម្រេចនូវសម្បត្តិគ្រប់យ៉ាង ដើម្បីនឹងញុំាង **ទុក្ខ** ទាំងអស់ឲ្យវិនាសបាត់ទៅ ។

*ប្រែថា* សូមព្រះករុណាទាំងឡាយចម្រើននូវព្រះបរិត្តជាជយមង្គល ដើម្បីនឹងការពារបញ្ចៀសនូវវិបត្តិ គឺសេចក្តីអន្តរាយទាំងពួង ដើម្បីនឹងឲ្យបានសម្រេចនូវសម្បត្តិគ្រប់យ៉ាង ដើម្បីនឹងញុំាង **ភ័យ** ទាំងអស់ឲ្យវិនាសបាត់ទៅ ។

*ប្រែថា* សូមព្រះករុណាទាំងឡាយចម្រើននូវព្រះបរិត្តជាជយមង្គល ដើម្បីនឹងការពារបញ្ចៀសនូវវិបត្តិ គឺសេចក្តីអន្តរាយទាំងពួង ដើម្បីនឹងឲ្យបានសម្រេចនូវសម្បត្តិគ្រប់យ៉ាង ដើម្បីនឹងញុំាង **រោគ** ទាំងអស់ឲ្យវិនាសបាត់ទៅ ។

លុះលោកអាចារ្យអារាធនាដូច្នេះហើយ លោកសង្ឃចំរើនព្រះបរិត្តនោះ ត្រូវសូត្រធម៌ **សគ្គេ កាមេ ។ល។ អយម្ភទន្តា** ប្រកាសអញ្ជើញពួកទេវតារួចហើយ ទើបចំរើនព្រះបរិត្តជាពុទ្ធមន្តតាមគួរដល់ពុទ្ធានុញ្ញាតក្នុងខុទ្ទកវត្ថុក្ខន្ធកៈក្នុងព្រះវិន័យ ។

# ទេវតាបកាសនគាថា

## ( ពាក្យប្រកាសអញ្ជើញពួកទេវតា )

**សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ**
**វិមានេ ទីបេ រដ្ឋេ ច គាមេ តរុវនគហនេ**
**គេហវត្ថុម្ហិ ខេត្តេ ភុម្មា ចាយន្តុ ទេវា**
**ជលថលវិសមេ យក្ខគន្ធព្វនាគា តិដ្ឋន្តា សន្តិកេ**
**យំ មុនិវរវចនំ សាធវោ មេ សុណន្តុ**

*ប្រែថា* ទេវតាទាំងឡាយដែលស្ថិតនៅក្នុងស្ថានសួគ៌ដែលជាកាមភពនិងរូបភពក្តី ភុម្មទេវតាទាំងឡាយដែលស្ថិតនៅក្នុងទិព្វវិមានគឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី ឰដ៏អាកាសក្តី នៅនាកោះនិងដែន និងស្រុកក្តី នៅនាដើមព្រឹក្សានិងព្រៃញាតស្បាត ឬទីស្រែចម្ការក្តី យក្ខនិងគន្ធព្វ និងនាគទាំងឡាយ ដែលស្ថិតនៅទីទឹកទីគោក ឬទីមិនរាបស្មើ ដែលនៅក្នុងទីជិតនេះ សូមអញ្ជើញមកប្រជុំគ្នា ( ក្នុងទីនេះ ) ពាក្យឯណាដែលជាពាក្យព្រះសក្យមុនីដ៏ប្រសើរ ( ដែលយើងនឹងសូត្រឥឡូវនេះ ) លោកអ្នក

សប្បុរសទាំងឡាយចូរស្តាប់នូវពាក្យនោះ ( ដោយគោរព ) ។

**ធម្មស្សវនកាលោ អយម្ភទន្តា**
**ធម្មស្សវនកាលោ អយម្ភទន្តា**
**ធម្មស្សវនកាលោ អយម្ភទន្តា**

***ប្រែថា*** បពិត្រលោកអ្នកដ៏ចំរើនទាំងឡាយ ពេលនេះជាពេលគួរនឹងស្តាប់នូវព្រះធម៌ ។ ( ត្រូវសូត្រ ៣ ដង )

**ស**. ទេវតាមានភ្នែកទិព្វ ត្រចៀកទិព្វ ហេតុអ្វីកាលបើមានកិច្ចទាំងឡាយ មានស្តាប់ធម៌ជាដើម ចាំបាច់ឲ្យគេអញ្ជើញធ្វើអ្វី បើមានភ្នែកទិព្វ ត្រចៀកទិព្វហើយ ?

**ច**. ទេវតាមានភ្នែកទិព្វ ត្រចៀកទិព្វពិតមែនតែកិច្ចបុណ្យរបស់គេទុកណាជាដឹងក៏មិនត្រូវមក លុះតែគេប្រាប់ គេអញ្ជើញទើបគួរមក ដូចជាមនុស្សយើងបើមានគេធ្វើបុណ្យជិតខាងបើទុកជាដឹងក៏មិនហ៊ានទៅ លុះតែគេប្រាប់ គេអញ្ជើញទើបហ៊ានទៅយ៉ាងណាទេវតាក៏យ៉ាងនោះដែរ ។

# ពាក្យប្រកាសមុនអារាធនាព្រះធម៌ទេសនា

អហំរីខ្ញុំម្ចាស់ សូមឱកាសក្រាបប្រណិប័តន៍
ដល់អស់ពួកបរិស័ទ ដែលលះកាត់ក្ដីកង្វល់ ។
ហើយមកប្រជុំគ្នា ព្រោះប្រាថ្នាយកកុសល
ហេតុនេះសូមតម្កល់ តាំងចិត្តស្ដាប់ធម៌ទេសនា ។
ដើម្បីជាការបុណ្យ និងជាគុណច្រើនណាស់ណា
អំណាចស្ដាប់ទេសនា ដោយជ្រះថ្លាក្នុងសន្ដាន ។
សូមតាំងចិត្តឲ្យស្អាត ខ្ញុំអារាធនាថ្កាន
និមន្តលោកនិទាន ទេសន៍ទូន្មានយើងគ្រប់គ្នា ។
ពេលនេះសូមបរិស័ទ ដែលប្រណិប័តន៍គាល់ត្រៀបត្រា
កុំពោលកុំចចារ និយាយគ្នាបែរមុខក្រោយ ។
សូមផ្ចង់នូវសញ្ញា ផ្ទៀងសោតាស្ដាប់កុំធ្លោយ
ទើបនឹងបានផលសោយ អានិសង្ស ៥ ប្រការ ៕

## ធម្មទេសនាយាចនគាថា

( ពាក្យសូមអារាធនាលោកអ្នកសំដែងធម៌ទេសនា )

**ព្រហ្មា ច លោកាធិបតី សហម្បតី**
**កតញ្ជលី អន្ធិវរំ អយាចថ ។**

**សន្តីធ សត្តាបរជក្ខជាតិកា**
**ទេសេតុ ធម្មំ អនុកម្បិមំ បជំ ។**
**សទ្ធម្មតេរី វិនយញ្ច ភាយំ**
**សុត្តញ្ច ពន្ធំ អភិធម្មចម្មំ ។**
**អាកោដយន្តោ ចតុសច្ចទណ្ឌំ**
**បព្វោធ នេយ្យេ បរិសាយ មជ្ឈេ ។**
**ឯវំ សហម្បតី ព្រហ្មា ភគវន្តំ អយាចថ**
**តុណ្ហីភាវេន តំ ពុទ្ធោ ភារុញ្ញេនាធិវាសយ**
**តម្ហា ឋុដ្ឋាន បាទេន មិគទាយំ តតោ គតោ**
**បញ្ចវគ្យានយោ នេយ្យ អមតំ បាយេសិ ធម្មតោ**
**តតោ បត្វូតិ សម្ពុទ្ធោ អន្វូនា ធម្មទេសនំ**
**មាយវស្សានិ ទេសេសិ សត្តានំ អត្ថសិទ្ធកំ**
**តេន សាធុ អយ្យោ ភន្តេ ទេសេតុ ធម្មទេសនំ**
**សព្វាយិធ បរិសាយ អនុកម្បម្បិ ភាតវេ ។**

គ្រានោះសហម្បតី ព្រហ្មជាឥស្សរលោកា
ចូលគាល់ព្រះសាស្តា លើកហត្ថាសិរោរាប ។
ហើយពោលពាក្យទូលថា សូមករុណាស្តេចទ្រង់ជ្រាប
ដ្បិតសត្វអន់ទន់ទាប ទុព្វលភាពបាបក្រៃក្រាស់ ។
ទន្ទឹងព្រះធម៌ថ្លៃ ជានិស្ស័យបច្ច័យច្បាស់
ឥឡូវទ្រង់បានត្រាស់ ត្រេកអរណាស់ពុំកន្តើយ ។
សត្វខ្លះក្រាស់ដោយកាម មិនយល់តាមត្រៃលក្ខណ៍ឡើយ
ឥឡូវយល់ខ្លះហើយ ដោយអំណាចព្រះមានបុណ្យ។

បើបានស្ដាប់ទេសនា បញ្ញាក្លាខ្លាំងលើសមុន
សូមព្រះដ៏មានបុណ្យ ទ្រង់និមន្តត្រាស់ទេសនា ។
ប្រោសសត្វបំបាត់សោក ទាំងរាគរោគរូបតណ្ហា
ងងឹតប្រែជ្រះថ្លា កើតបញ្ញាភិយ្យោយល់ ។
ត្រៃលោកគោកត្រៃលក្ខណ៍ សង្សារចក្រវិលមិនដល់
អវិជ្ជាកប្ញសគល់ ជាបច្ច័យនៃសង្ខារ ។
នាំសត្វឲ្យសោកសៅ លិចលង់នៅក្នុងសង្សារ
បញ្ចមារមោហន្ធការ រិតរុំហ៊ុមជុំជាប់នៅ ។
ហេតុនេះសូមព្រះអង្គ ប្រោសស្រោចស្រង់ដាក់សំពៅ
ចំឡងសត្វឆ្ពោះទៅ កាន់ត្រើយត្រាណនិព្វាននាយ ។
ដូចកលប្រទីបធំ សាយត្រសុំភ្លឺព្រោងព្រាយ
បំភ្លឺសត្វទាំងឡាយ ឲ្យសប្បាយក្សាន្តភិរម្យ ។
ព្រះសទ្ធម្មជាស្គរជ័យ ព្រះវិន័យជារាងធំ
ព្រះសូត្រជាខ្សែរុំ ព្រះអភិធម្មជាស្បែកដាស់ ។
អរិយសច្ចជាអន្លង សម្រាប់ទូងឲ្យឮច្បាស់
សត្វលោកងោកងុយណាស់ ឮស្គរដាស់ក្រោកឡើងបាន ។
បរិស័ទ ៤ ចំពូក ដូចផ្កាឈូកក្នុងជលដ្ឋាន
ខ្លះផុសចាំសូរ្យឆាន រះនិងរីកដោយរស្មី ។
ព្រះធម៌ជាសូរ្យសែង រះឡើងចែងចាំងរង្សី
បំភ្លឺលោកទាំងបី ឲ្យយល់ផ្លូវឋានសុខា ។
សហម្បតីព្រហ្ម ឱនបង្គំអារាធនា

សម្ដេចព្រះភគវា ដោយគាថាយ៉ាងនេះឯង ។
ព្រះពុទ្ធទ្រង់អនុកូល ព្រមទទួលនឹងសំដែង
ដោយតុណ្ហីភាពថ្លែង តាមភាវៈគុណករុណា ។
ទើបក្រោកចាកទីនោះ ភក្ត្រាឆ្ពោះព្រៃមិគទា
យាងចេញចរលីលា ពីទីនោះដោយព្រះបាទ ។
ញ៉ាំងសត្វចូលពុទ្ធចក្រ មានបញ្ចវគ្គីយ៍ជាអាទ៍
ឲ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា ។
ចាប់ដើមពីនោះឯង ទ្រង់សម្ដែងធមិទេសនា
ធ្វើពុទ្ធក្រឹត្យា អស់វស្សាសែសិបប្រាំ ។
ពុំថយពុំបន្ធូរ ប្រយោជន៍យូរអង្វែងឆ្នាំ
សំរេចបុញ្ញកម្ម ដល់សព្វសត្វទាំងភពត្រៃ ។
ហេតុនោះឥឡូវនេះ យើងខ្ញុំនេះសាទរក្រៃ
បពិត្រព្រះគុណថ្លៃ សូមនិមន្តប្រោសទេសនា ។
អនុគ្រោះពួកបរិស័ទ ដែលជាប់ខាត់ដោយមោហា
ឲ្យកើតមានបញ្ញា ប្រាកដនាទីនេះហោង ។ល។

**ស.** ដូចម្ដេចពាក្យថា «**ត្រៃលោកគោកត្រៃលក្ខណ៍**» ?

**ឆ.** ត្រៃលោកនោះបានដល់លោកទាំង ៣ គឺ**កាមលោក ១**, **រូបលោក ១**, **អរូបលោក ១** ។ សត្វដែលត្រេកអរក្នុងសម្បត្តិក្នុងលោកទាំង ៣ នេះ មិនឃើញនូវព្រះត្រៃលក្ខណ៍ទាំង ៣ ដូច្នេះឈ្មោះថា **ត្រៃលោកគោកត្រៃលក្ខណ៍** ។

**ឆ**. ព្រះពុទ្ធទ្រង់បំពេញបារមីចំនួន ៤ អសង្ខេយ្យកម្រៃ មួយសែនកប្ប ដើម្បីនឹងបានត្រាស់សព្វញ្ញុតញ្ញាណ និងសម្ដែងធម៌ប្រោសសត្វ ឥឡូវបានត្រាស់ហើយហេតុម្ដេចក៏មិនសម្ដែងទៅ ? ចាំបាច់ឲ្យព្រហ្មមកអារាធនាធ្វើអ្វីទៀត ?

**ច**. ព្រះអង្គបានជាទ្រង់មិនទាន់សម្ដែងធម៌ទេសនា ក្នុងពេលនោះព្រោះពួកទេវតានិងមនុស្សទាំងឡាយនៅរាប់អានមហាព្រហ្មថាជាសាស្ដាធំជាងគេ, បានជាព្រះអង្គរង់ចាំឲ្យព្រហ្មមកអារាធនាដើម្បីនឹងងាយសម្ដែងធម៌ដល់ពួកទេវតា និងមនុស្សបានជារង់ចាំឲ្យព្រហ្មមកអារាធនា ។

# ភត្ត ១៨ យ៉ាងគឺ ៖

**១. សង្ឃភត្តំ** វេរន្ទវភត្តាហារដែលទាយកទាយិកាទាំង-ឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាត ចំពោះព្រះភិក្ខុសង្ឃដែលនិមន្តមកអំពីទិសទាំង ៤ ទទួលចង្ហាន់បិណ្ឌបាតឥតកំណត់ ;

**២. ឧទ្ទេសភត្តំ** វេរន្ទវភត្តដល់ភិក្ខុ ១ អង្គឬ ៣ អង្គជាដើមតាមពាក្យដែលសង្ឃសំដែងឲ្យ ;

**៣. និមន្តនភត្តំ** វេរន្ទវភត្តដល់ភិក្ខុដែលខ្លួននិមន្តមក ហើយប្រគេន ចំណែកខាងភិក្ខុសង្ឃបានដឹងហើយក៏ចេញទៅទទួលចង្ហាន់បិណ្ឌបាត សំគាល់តាមបាត្ររបស់ខ្លួន ;

**៤. សលាកភត្តំ** វេរន្ទវភត្តដល់ភិក្ខុទាំងឡាយ ដែលខ្លួន

សរសេរឈ្មោះក្នុងស្លាក ហើយចូលទៅកាន់អារាម វាយរគាំងប្រជុំលោកឲ្យចាប់ស្លាក លុះព្រឹកឡើងលោកក៏និមន្តទៅទទួលចង្ហាន់តាមស្លាករបស់ខ្លួន ;

**៥. បក្ខិកភត្តំ** វេរន្សវភត្តដល់ភិក្ខុសង្ឃ ក្នុងសុក្កបក្ខ ( ចំណែកខាងខ្នើត ) ឬកាឡបក្ខ ( គឺចំណែកខាងរនោច ) តែក្នុងមួយបក្ខប្រគេនតែមួយថ្ងៃមិនមានកំណត់ថ្ងៃណា ;

**៦. ឧបោសថិកភត្តំ** វេរន្សវភត្តដល់ភិក្ខុសង្ឃក្នុងថ្ងៃឧបោសថកាល គឺក្នុងមួយខែៗ អស់វារៈ ២ ដង ឬ ៤ ដង ឬក៏ ៨ ដង តាមថ្ងៃឧបោសថដ៏សមគួរដល់សទ្ធា ;

**៧. បាដិបទិកភត្តំ** វេរន្សវភត្តដល់ភិក្ខុសង្ឃក្នុងថ្ងៃ ១ កើត ឬ ១ រោចដែលជាភត្ត គឺព្រះពុទ្ធទ្រង់សរសើរថាជាភត្តមានផលានិសង្សច្រើន ;

**៨. អាគន្តុកភត្តំ** វេរន្សវភត្តដល់ភិក្ខុសង្ឃជាអាគន្តុក ( ដែលទើបនិមន្តមកថ្មីៗ ) ;

**៩. គមិកភត្តំ** វេរន្សវភត្តដល់ភិក្ខុសង្ឃដែលបានធ្វើដំណើរទៅកាន់ទីណាមួយ ;

**១០. គិលានភត្តំ** វេរន្សវភត្តដល់ភិក្ខុសង្ឃដែលមានជម្ងឺតែម្យ៉ាង ;

**១១. គិលានុបដ្ឋាកភត្តំ** វេរន្សវភត្តដល់ភិក្ខុសង្ឃជាអ្នករក្សាជម្ងឺភិក្ខុសាមណេរផងគ្នា ;

**១២. និច្ចភត្តំ** វេរន្សវភត្តដែលប្រគេនជានិច្ចដល់ភិក្ខុសង្ឃ ;

**១៣. កុដិភត្តំ** វេរនូវភត្តដល់ភិក្ខុសង្ឃដែលបានបវារណា នៅទីលំនៅមានកុដិជាដើម ដែលខ្លួនបានកសាងទុកក្នុងព្រះពុទ្ធសាសនា ( ភត្តនេះហៅទៅតាមឈ្មោះទីកន្លែងដែលសង្ឃនៅ ) ;

**១៤. វារភត្តំ** វេរនូវភត្តដល់ភិក្ខុសង្ឃដោយបានចាត់ចែងដាក់វេនផ្លាស់ប្ដូរគ្នា ម្ដងត្រូវផ្ទះអ្នកឯណេះម្ដងត្រូវផ្ទះអ្នកឯណោះ ចំពោះភិក្ខុសង្ឃ សមណេរ ដែលនៅវត្តមួយៗ ;

**១៥. វិហារភត្តំ** វេរនូវភត្តាហារដល់ភិក្ខុសង្ឃ សាមណេរ ដែលនៅក្នុងវត្តមួយៗ បានឆាន់គ្រប់គ្រាន់បរិបូណ៌ទាំងអស់ ;

**១៦. ចតុក្កភត្តំ** វេរនូវភត្តាហារចំពោះភិក្ខុសង្ឃបួនអង្គៗ ដែលខ្លួនបានសូមមកអំពីគណៈសង្ឃៗ បានចាត់មកទទួលចង្ហាន់បិណ្ឌបាតនៅផ្ទះខ្លួនរាល់ៗ ថ្ងៃពុំដែលដាច់ ;

**១៧. អដ្ឋកភត្តំ** វេរនូវភត្តាហារចំពោះភិក្ខុសង្ឃ ៨ អង្គ ដែលខ្លួនបានសូមមកអំពីគណៈសង្ឃៗ បានចាត់មកទទួលចង្ហាន់បិណ្ឌបាតនៅផ្ទះខ្លួនរាល់ៗ ថ្ងៃពុំដែលដាច់ ;

**១៨. គុឡភត្តំ** វេរនូវភត្តាហារ ដែលលាយដោយស្ករអំពៅមានបាយដំណើប បបរស្ករ នំលតជាដើម ចំពោះភិក្ខុសង្ឃ សាមណេរ ដែលនៅក្នុងវត្តមួយៗ តាមសទ្ធា ។

**ភត្ត** ទាំង ១៨ ប្រការនេះ បើទាយក ទាយិកាប្រាថ្នានឹងវេរនូវភត្តណាមួយ ត្រូវដាក់ឈ្មោះភត្តនោះត្រង់បាលីដែលវង់ក្រចក (.........) ទុកនោះចុះ ។

**ស**. សង្ឃភត្ត និងសង្ឃទាន ផ្សេងគ្នាឬដូចគ្នា ?

**ឆ**. សង្ឃភត្ត និងសង្ឃទានមិនដូចគ្នាទេ ។ **សង្ឃភត្ត** បានចំពោះតែបិណ្ឌបាតបច្ច័យ ១ , ចំណែក **សង្ឃទាន** បានចំពោះបច្ច័យទាំង ៤ សេចក្តីផ្សេងគ្នាដូច្នេះឯង ។



# បាលីវេរ «ភត្ត»

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**
**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**
**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

**អយំ នោ ភន្តេ (បិណ្ឌបាតោ(*) / ភត្តាហារោ ) ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (ឥត្ថន្នាមំ) សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម តេ គុណវន្តាទយោ (ឥត្ថន្នាមំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ**

**សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។**
**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ រីចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះលោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើម ហើយយើងខ្ញុំទាំងឡាយសូមវេរ (នូវ.......) នេះ ព្រមទាំងបរិក្ខារ ប្រគេនដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមនោះសំគាល់ (នូវ ......) នេះ ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឲ្យរួចរំដោះចាកទុក្ខទាំងពួង ឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ ៣ ប្រការ គឺ សម្បត្តិមនុស្ស ១, សម្បត្តិទេវតា ១, សម្បត្តិព្រះនិព្វាន ១ ដោយសមគួរ តាមសេចក្ដីប្រាថ្នារបស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហូរជូនមកមិនដាច់នេះហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

(*) ត្រង់បទថា **ឥត្ថន្នាមំ** នោះ បើវេរចេញឈ្មោះថា **បណ្ឌិបាតោ** ត្រូវដាក់ថា **បិណ្ឌបាតំ** បើវេរចេញឈ្មោះ **ភត្តាហារោ** ត្រូវបញ្ចូលថា **ភត្តាហារំ** ដាក់ឈ្មោះតាមប្រាថ្នា យ៉ាងដូចជា **សង្ឃភត្ត** ត្រូវបញ្ចូល **សង្ឃភត្តំ** ដូច្នេះជាដើម ។

# បើវេរ «ចតុប្បច្ច័យ» ជាសង្ឃទានថាដូច្នេះ

**មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយ បាននាំនូវបច្ច័យទាំងឡាយ ៤ នេះមកតម្កល់ទុកក្នុងទីនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវបច្ច័យទាំងឡាយ ៤ នេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

# បើវេរ «ចតុប្បច្ច័យ» ដល់ភិក្ខុមួយអង្គថាដូច្នេះ

**មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា អាយស្មតោ ទេម សាធុ ភន្តេ អាយស្មា ឥមេ បច្ចយេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះករុណាដ៏ចម្រើន យើងខ្ញុំទាំងឡាយ បាននាំនូវបច្ច័យទាំងឡាយ ៤ នេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរដល់ព្រះករុណាដ៏មានអាយុ បពិត្រព្រះករុណាដ៏ចំរើន សូមព្រះករុណាទទួលយកនូវបច្ច័យទាំងឡាយនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

## បើវេរ «កឋិនទាន» ដល់ព្រះសង្ឃថាដូច្នេះ

**ឥមំ ទុស្សំ កឋិនចីវរំ សង្ឃស្ស ទេម ។**
**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើនអើយ ! យើងខ្ញុំទាំងឡាយសូមវេរនូវសំពត់នេះជាសំពត់ដើម្បីកឋិនចីវរ ប្រគេនដល់ព្រះសង្ឃ ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

ឬនឹងវេរថា ៖ **ឥមំ វត្ថំ កឋិនចីវរំ សង្ឃស្ស ទេម** ដូច្នេះក៏បាន សេចក្តីប្រែដូចគ្នា ។

## វេរ «គ្រឿងបរិក្ខារ» ជាបរិវារកឋិនទាន

ថាដូច្នេះ ៖

**យេនម្ហាកំ[១] កឋិនំ កឋិនានិសំសានិ តស្សេវ ទេម ។**
**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ ! វីកឋិន នៃយើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អង្គណាបានទទួលកាន់យក ហើយ យើងខ្ញុំទាំងឡាយសូមវេរនូវគ្រឿងបរិក្ខារ ជាបរិវារនៃ កឋិនទាំងឡាយប្រគេនដល់លោកម្ចាស់អង្គនោះ ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

## បាលីថេរ «កឋិនទាន» មួយបែបទៀត

**ឥមំ ភន្តេ កឋិនចីវរំ សានិសង្សំ សង្ឃស្ស ទេម ។**
**ឥមំ ភន្តេ កឋិនចីវរំ សានិសង្សំ សង្ឃស្ស ទេម ។**
**ឥមំ ភន្តេ កឋិនចីវរំ សានិសង្សំ សង្ឃស្ស ទេម ។**
**សាធុ នោ ភន្តេ សង្ឃោ ឥមំ កឋិនចីវរំ សានិសង្សំ បដិគ្គណ្ហាតុ កឋិនំ អត្ថរិតុំ មាតាបិតុអាទិនញ្ច គុណវន្តានំ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ**

*ប្រែថា* បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយ សូមវេរប្រគេននូវកឋិនចីវរនេះ ព្រមទាំងអានិសង្សលាភដល់

[១] ពាក្យថា **យេនម្ហាកំ** នេះសំដៅយកត្រៃទាំងបី បើក្រាលសំពត់ណាមួយហើយ សំពត់ទាំងពីរដែលសល់នោះ ទុកជាគ្រឿងបរិវារ របស់កឋិន ។

ព្រះសង្ឃ ។ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃមេត្តាទទួលយក នូវកឋិនចីវររបស់យើងខ្ញុំទាំងឡាយនេះ ព្រមទាំងអានិសង្សលាភដើម្បីក្រាលកឋិន, សូមឲ្យបានសម្រេចប្រយោជន៍, សូមឲ្យបានសម្រេចសេចក្ដីសុខ, ដល់អ្នកដ៏មានគុណទាំងឡាយមានមាតានិងបិតាជាដើមផង, ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាយូរអង្វែងទៅហោង ។

សំពត់ ៧ ប្រការដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតទុកឲ្យជាសំពត់សមណប្បរិក្ខារនោះគឺ សំពត់ត្រៃចីវរ ១, សំពត់សម្រាប់ងូតទឹកភ្លៀង ១, សំពត់សម្រាប់ទ្រាប់អង្គុយ ១, សំពត់សម្រាប់ក្រាលជាកម្រាល ១, សំពត់តូចឬធំជាងប្រមាណ ហៅថាសំពត់បរិក្ខារចោឡ ១, បញ្ចូលសំពត់សម្រាប់ត្រងទឹក ១, សំពត់ចំណាំវស្សា ១ និងសំពត់អច្ចេកចីវរ ១ ថែមទៀតត្រូវជា ១០ ។

សំពត់ទាំង ១០ ប្រការនេះ បើទាយក ទាយិកាមានប្រាថ្នានឹងវេរសំពត់ណាមួយដល់ព្រះសង្ឃ តែសំពត់នោះមានតែ ១ ត្រៃ ឬ ១ ផ្ទត់ ត្រូវឲ្យដាក់ឈ្មោះសំពត់នោះជាបាលីឯកវចនៈ ដូចបែបខាងមុខនេះទាំង ១០ ប្រការគឺ ៖

**១. ឥមំ តិចីវរំ** នូវត្រៃចីវរនេះ ;
**២. ឥមំ វស្សិកសាដិកំ** នូវសំពត់សម្រាប់ងូតទឹកភ្លៀងនេះ ;
**៣. ឥមំ និសីទនំ** នូវសំពត់សម្រាប់ទ្រាប់អង្គុយនេះ ;
**៤. ឥមំ បច្ចត្ថរណំ** នូវសំពត់សម្រាប់ក្រាលនេះ ;

**៥. ឥមំ គណ្ឋុប្បដិច្ឆាទឹ** នូវសំពត់សម្រាប់គ្របបូស ឬគ្របដំបៅនេះ ;

**៦. ឥមំ មុខបុញ្ឆនចោឡំ** នូវសំពត់សម្រាប់ជូតមុខ គឺកន្សែងជាបរិក្ខារនេះ ;

**៧. ឥមំ បរិក្ខារចោឡំ** នូវសំពត់តូចឬធំជាងប្រមាណជាបរិក្ខារនេះ ;

**៨. ឥមំ បរិសាវនំ** នូវសំពត់សម្រាប់ត្រងទឹកនេះ ;

**៩. ឥមំ វស្សាវាសិកំ** នូវសំពត់ចំណាំវស្សានេះ ;

**១០. ឥមំ អច្ចេកចីវរំ** នូវសំពត់អច្ចេកចីវរនេះ ។

សំពត់ទាំង ១០ ប្រការនេះ បើត្រូវការនឹងវេរសំពត់ណាមួយ ឲ្យយកឈ្មោះសំពត់ដែលបានសំណៅជាបែបទុកនេះ មកដាក់ជាបាលីសម្រាប់សូត្រវេរ ត្រង់កន្លែងដែលមានវង់ក្រចកទុកស្រាប់ហើយនោះ ។

## វេរ «ត្រៃចីវរ» ថា ៖

**មយំ ភន្តេ ឥមំ (តិចីវរំ) ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមំ (តិចីវរំ)បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះករុណាដ៏ចម្រើនអើយ ! យើងខ្ញុំទាំងឡាយ បាននាំនូវ ( ត្រៃចីវរ ) នេះមកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេន ដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួល យកនូវ ( ត្រៃចីវរ ) នេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅ ហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

សំពត់ទាំង ១០ ប្រការនេះបើប្រាថ្នានឹងវេរសំពត់ណាមួយ ដល់ព្រះសង្ឃ តែសំពត់នោះមានច្រើនត្រៃឬច្រើនផ្ទត់ ត្រូវឲ្យ យកឈ្មោះសំពត់នោះជាបាលីពហុវចនៈ មកដាក់បញ្ចូលវេរដូច មានសំណៅជាបែបទុកខាងក្រោមនេះស្រាប់ ៖

**១. ឥមានិ តិចីវរានិ** នូវត្រៃចីវរទាំងឡាយនេះ ;

**២. ឥមានិ វស្សិកសាដិកាយោ** នូវសំពត់សម្រាប់ងូត ទឹកភ្លៀងទាំងឡាយនេះ ;

**៣. ឥមានិ និសីទនានិ** នូវសំពត់សម្រាប់ទ្រាប់អង្គុយ ទាំងឡាយនេះ ;

**៤. ឥមានិ បច្ចត្ថរណានិ** នូវសំពត់សម្រាប់ក្រាល ទាំងឡាយនេះ ;

**៥. ឥមានិ កណ្ឌុប្បដិច្ឆាទីនិ** នូវសំពត់សម្រាប់គ្របបូស ឬគ្របដំបៅទាំងឡាយនេះ ;

**៦. ឥមានិ មុខបុញ្ឆនចោឡានិ** នូវសំពត់សម្រាប់ជូតមុខគឺ

កន្សែងជាបរិក្ខារទាំងឡាយនេះ ;

**៧. ឥមានិ បរិក្ខារចោឡានិ** នូវសំពត់បរិក្ខារចោឡ ទាំងឡាយនេះ ;

**៨. ឥមានិ បរិសាវនានិ** នូវសំពត់សម្រាប់ត្រងទឹក ទាំងឡាយនេះ ;

**៩. ឥមានិ វស្សាវាសិកាយោ** នូវសំពត់ចំណាំវស្សា ទាំងឡាយនេះ ;

**១០. ឥមានិ អច្ចេកចីវរានិ** នូវសំពត់អច្ចេកចីវរ ទាំងឡាយនេះ ។

សំពត់ទាំង ១០ ប្រការនេះ បើត្រូវការនឹងវេរសំពត់ណាមួយ ឲ្យយកឈ្មោះសំពត់ដែលបានសំណៅជាបែបទុកនេះមកដាក់ជា បាលីសម្រាប់សូត្រវេរ ត្រង់កន្លែងដែលមានវង់ក្រចកទុកស្រាប់ ហើយនោះ ។

## វេរ «សំពត់ងូតទឹកភ្លៀង» ថាដូច្នេះ ៖

**មយំ ភន្តេ ឥមានិ (វស្សិកសាដិកាយោ) ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមា (វស្សិកសាដិកាយោ) បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះករុណាដ៏ចម្រើនអើយ ! យើងខ្ញុំទាំងឡាយ បាននាំនូវ (សំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយ) នេះមកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកនូវ (សំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយ) នេះដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

## បើវេរ «សង្ឃទាន» ថាដូច្នេះ ៖

**ឥមានិ ខាទនីយភោជនីយានីនិ សជ្ជេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ ខាទនីយភោជនីយានីនិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើនអើយ ! យើងខ្ញុំទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយមានខាទនីយភោជនីយាហារ គឺបង្អែមនិងចំអាបជាដើមនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវវត្ថុទាំងឡាយ មានបង្អែមនិងចំអាបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំ

ទាំងឡាយអស់កាលជាអង្វែងទៅហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

## បើវេរ «គណទាន» ថាដូច្នេះ ៖

**មយំ ភន្តេ ឥមានិ ខាទនីយភោជនីយាទីនិ សង្ឃេត្វា សីលវន្តានំ ទេម សាធុ ភន្តេ សីលវន្តោ ឥមានិ ខាទនីយភោជនីយាទីនិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើនអើយ ! យើងខ្ញុំទាំងឡាយបានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនី - យាហារ គឺបង្អែមនិងចំអាបជាដើមនេះ ហើយវេរប្រគេនដល់លោកម្ចាស់អ្នកមានសីលទាំងឡាយ បពិត្រព្រះករុណាទាំង-ឡាយដ៏ចម្រើន សូមលោកម្ចាស់អ្នកមានសីលទាំងឡាយទទួលយកនូវវត្ថុទាំងឡាយ មានបង្អែមនិងចំអាបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

## បើវេរ «បាដិបុគ្គលិកទាន» ថាដូច្នេះ៖

**មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សង្ឃេ្ហត្វា សីលវតោ ទេម សាធុ ភន្តេ សីលវា ឥមានិ ខាទនីយភោជនីយានិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះករុណាដ៏ចម្រើនអើយ ! យើងខ្ញុំទាំងឡាយបានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនី - យាហារ គឺបង្អែមនិងចំអាបជាដើមនេះ ហើយវេរប្រគេនដល់ព្រះករុណា បពិត្រព្រះករុណាដ៏ចម្រើន សូមលោកអ្នកមានសីលទទួលយកនូវវត្ថុទាំងឡាយ មានបង្អែមនិងចំអាបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

## បើវេរ «អង្ករ» ដល់ព្រះសង្ឃថាដូច្នេះ៖

**មយំ ភន្តេ ឥមានិ តណ្ឌុលានិ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ**

**ឥមានិ តណ្ឌុលានិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**
**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ! យើងខ្ញុំទាំងឡាយបាននាំនូវអង្ករទាំងឡាយនេះ មកតម្កល់ទុកក្នុងទីនេះ ហើយសូមប្រគេនដល់ព្រះសង្ឃ បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវអង្ករទាំងឡាយនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

## បើវេរ «ផ្លែឈើផ្សេងៗ» ថាដូច្នេះ ៖

**មយំ ភន្តេ ឥមានិ នានាផលានិ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ នានាផលានិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**
**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ ! យើងខ្ញុំទាំងឡាយបាននាំនូវផ្លែឈើផ្សេង ៗ ទាំងឡាយនេះ មកតម្កល់ទុកក្នុងទីនេះ ហើយសូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះ

គម្តែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវផ្លែឈើផ្សេង ៗ ទាំងឡាយនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយអស់ កាលជាអង្វែងទៅហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

## បេរ «គ្រឿងសេនាសនៈ» តទៅថាដូច្នេះ ៖

- **បើ «រោងឧបោសថ វិហារ» ថា ៖**

**មយំ ភន្តេ ឥមំ (ឧបោសថាគារំ) ភារទ្វា ឧបោសថបវារណា ទិសង្ឃកម្មករណត្ថាយ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ (ឧបោសថាគារំ) បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើនអើយ! យើងខ្ញុំទាំងឡាយបានចាត់ចែងធ្វើនូវ ( រោងសម្រាប់ធ្វើឧបោសថ ) នេះ ហើយសូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៤ ដើម្បីប្រយោជន៍ដល់កិរិយាធ្វើនូវសង្ឃកម្ម មានឧបោសថកម្ម និងបវារណាកម្មជាដើម បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃទទួលយកនូវ ( រោងសម្រាប់ធ្វើឧបោសថ ) នេះ

ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

- **បើវេរ «សាលា» ថាដូច្នេះ ៖**

**ឥមំ សាលំ** នូវ សាលានេះ ។

- **វេរ «កប្បិយកុដិ» ថាដូច្នេះ ៖**

**ឥមំ កប្បិយកុដឹ** នូវ កប្បិយកុដិនេះ ។

- **វេរ «កុដិតូចឬតូប» ថាដូច្នេះ ៖**

**ឥមំ កុដឹ** នូវ កុដិតូចឬតូបនេះ ។

- **វេរ «កុដិធំ» ថាដូច្នេះ ៖**

**ឥមំ វិហារំ** នូវ កុដិធំនេះ ។

- **វេរ «បង្គន់» ថាដូច្នេះ ៖**

**ឥមំ វច្ចកុដឹ** នូវ បង្គន់នេះ ។

បើប្រាថ្នានឹងវេរសាលាក្តី កប្បិយកុដិក្តី កុដិតូចក្តី ឬតូបក្តី កុដិធំក្តី បង្គន់ក្តី ទាំង ៤ យ៉ាងនេះ នឹងវេររបស់ណា មួយឲ្យយករបស់នោះទាំងបាលី ទាំងសម្រាយមកដាក់ត្រង់វង់ក្រចកនោះ ហើយសូត្រវេរចុះ ។

## បើវេរ «គរុភណ្ឌ» ថាដូច្នេះ ៖

**មយំ ភន្តេ ឥមំ គរុភណ្ឌំ ឥធានេត្វា ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ គរុភណ្ឌំ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនអើយ ! យើងខ្ញុំទាំងឡាយបាននាំនូវគរុភណ្ឌនេះ មកតម្កល់ទុកក្នុងទីនេះសូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃទទួលយកនូវគរុភណ្ឌនេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

## វិធីវេរ «គ្រឿងភេសជ្ជៈ» ថាដូច្នេះ ៖

- **វេរ «ទឹកឃ្មុំ» ថាដូច្នេះ ៖**

**មយំ ភន្តេ ឥមំ (មធុំ) ឥធានេត្វា ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ (មធុំ)**

**បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ... ។ តតិយម្បិ... ។**

*ប្រែថា* បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើនអើយ ! យើងខ្ញុំទាំងឡាយបាននាំនូវ ( **ទឹកឃ្មុំ** ) នេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃទទួលយកនូវ ( **ទឹកឃ្មុំ** ) នេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

អស់វារៈ ២ ដងផង ... ។ អស់វារៈ ៣ ដងផង ... ។

- **បើវេរ «ប្រេង» ថាដូច្នេះ ៖**

**ឥមំ តេលំ** នូវ ប្រេងនេះ ។

- **បើវេរ «ទឹកអំពៅ» ថាដូច្នេះ ៖**

**ឥមំ ផាណិតំ** នូវ ទឹកអំពៅនេះ ។

- **បើវេរ «ថ្នាំរម្ងាប់រោគ» ថាដូច្នេះ ៖**

**ឥមំ គិលានភេសជ្ជំ** នូវ ថ្នាំសម្រាប់មនុស្សឈឺនេះ ។

បើប្រាថ្នានឹងវេរប្រេងក្តី ទឹកអំពៅក្តី ទឹកត្នោតក្តី ថ្នាំរក្សាជម្ងឺក្តី ទាំង ៤ យ៉ាងនេះ នឹងវេររបស់ណាមួយ ឲ្យយកឈ្មោះ

របស់នោះ ទាំងបាលី ទាំងសម្រាយមកដាក់ត្រង់កន្លែងដែលវង់ក្រចកនោះ ហើយសូត្រវេរចុះ ។

## វិធីវេរចតុប្បច្ច័យទាំង ៤ ប្រការចប់ ដោយសង្ខេបតែប៉ុណ្ណោះ ។

# ( ប្រស្នាគិហិប្រតិបត្តិពិស្ដារចប់តែប៉ុណ្ណោះ )

*បើសាធុជនពុទ្ធបរិស័ទ និងលោក-អ្នកអានជាទីមេត្រីទាំងឡាយបានទទួលសេចក្តីយល់ចូលចិត្ត ក្នុងគោលធម៌របស់ព្រះបរមសាស្ដាចារ្យ ដែលជាប្រទីបនៃសកលសត្វក្នុងសកលលោកអំពីការចម្លងរបស់ខ្ញុំ ខ្ញុំក៏ឈ្មោះថាបានធ្វើបុណ្យកុសលហើយ ខ្ញុំក៏សូមឧទ្ទិសចំណែកកុសលទាំងអស់នោះចំពោះលោកអ្នកដ៏មានគុណទាំងឡាយមាន ៖ មាតាបិតាខ្ញុំ, ជីដូនជីតាខ្ញុំ , គ្រូបាធ្យាយន៍របស់ខ្ញុំ ទោះបីលោកឋិតនៅក្នុងភពណាៗ ក៏ដោយ សូមលោកទទួលជ្រាបគោលបំណងល្អរបស់ខ្ញុំ ហើយសូមអនុមោទនានឹងបានសោយសុខតាមសមគួរដល់សុគតិភពនោះចុះ ។*

*ចម្លងចប់នៅក្រុងម៉ុងរេអាល - កេបិក - កាណាដា ,*

*វ៉ាត ភិរក្ស*

# ពាក្យកាព្យឧទ្ទិស

រីទានខ្ញុំធ្វើហើយ ព្រះគុណល្ហើយខ្ញុំសទ្ធា
ឧទ្ទិសផលនេះណា ជូនមាតាបិតាខ្ញុំ ។
ជីដូននិងជីតា គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្តគ្រប់និគម មកជួបជុំទទួលផល ។
ដែលកូនចៅបានធ្វើ នូវអំពើជាកុសល
សូមទានឲ្យបានដល់ ទោះមណ្ឌលឆ្ងាយយ៉ាងណា។
កុសលទាំងអស់ហ្នឹង សូមទីពឹងលើទេវតា
សូមមានចិត្តមេត្តា នាំផល្លាទាំងអស់នេះ ។
ទៅជូនឲ្យខ្ញុំផង ដូចបំណងកុំបីធ្វេស
ថាកូនចៅឯណេះ មិនប្រហែសបញ្ជូនមក ។
សូមមានចិត្តរីករាយ ដោយសប្បាយទទួលយក
កូនចៅបានលៃលក បញ្ជូនមកលោកគ្រប់គ្នា ។
ដើម្បីសោយកម្សាន្ត សូមឲ្យបាននូវសុខជា
កូនចៅទាំងអស់គ្នា បានបូជាជូនទៅហោង ៕

---

* ដកស្រង់ចេញពីសៀវភៅ "**ពិធីច្រូចទឹក**" របស់ព្រះវន្ន័រត **សរ មៀង**
វត្តឧណ្ណាលោម រាជធានីភ្នំពេញ បោះពុម្ព
នៅ ព.ស ២៥៤១ - គ.ស ១៩៩៧

# ព្រះត្រៃលក្ខណ៍

**ទុក្ខំ** ទុក្ខអើយទុក្ខខ្លាំង ខ្លាំងពន់ប្រមាណ
ពីតូចទាល់ធំ ទុក្ខទំក្នុងប្រាណ ទុក្ខឥតស្រាកស្រាន្ត
ទុក្ខដល់ខ្លួនក្ស័យ ។

**អនិច្ចំ** ពុំឋិត ពុំថេរនៅនិត្យ យើនយូរឡើយនៃ
ស្លាប់ទៅជាខ្មោច អសោចពេកក្រៃ ឆ្អឹងសាច់សរសៃ
ជាព្រះធរណី ។

**អនត្តា** សូន្យសោះ សូន្យរូបសូន្យឈ្មោះ សូន្យសព្វសញ្ញី
សូន្យយសសក្កា ធិការសោភី សូន្យសព្វឥន្ទ្រិយ៍
មាសប្រាក់អន្តរាយ ។

ដូច្នេះគួរគិត គួររក្សាចិត្ត ខឹងឆាប់រសាយ
ចិត្តស្លូនទន់ទោន ដូចកូននិងម្ដាយ ខឹងឆាប់រសាយ
បាត់ខឹងទៅហោង ។

គួរកុំបីខ្ជិល កសាងទានសីល និងភាវនាផង
រៀនធម៌វិន័យ ប្រពៃកន្លង ពីក្មេងទៅហោង
កុំចាំដល់ចាស់ ។

ដល់ពេលជិតស្លាប់ ទើបបានប្រញាប់ ប្រវ៉ាខ្វេសខ្វាស់
រកធម៌ឲ្យជួយ ព្រោះព្រួយខ្លាំងណាស់ នោះមិនបានច្បាស់
ដូចនៅក្មេងឡើយ ។

គួរហាត់លះចិត្ត អកុសលទុច្ចរិត បង្ការឲ្យហើយ

ដល់ពេលទៀបស្លាប់ ឈោងចាប់កោះត្រើយ ទីពឹងនោះហើយ
បានដូចប្រាថ្នា ។
ផលការហាត់ចិត្ត រឿយៗល្អពិត នឹងជួយអាត្មា
ឲ្យបានសម្បត្តិ ល្អក្ដាត់ណាស់ណា ជាមនុស្សទេពតា
នៅលោកិយបាន ។
ហើយនិងបានដល់ លោកុត្តរផល សម្រេចនិព្វាន
ក្នុងជាតិបំផុត ចំហុតមែនមាន ដោយបារមីញាណ
សាងទុកនោះហោង ។៚



# ព្រះត្រៃលក្ខណ៍សង្ខេប

**( បទពាក្យប្រាំពីរ )**

អនិច្ចាសង្ខាររូបយើងអើយ គិតគ្រប់ទៅហើយមិនទៀងទេ
កើតមកជាមនុស្សទោះយើងគេ មិនដែលទំនេរសឹងកើតទុក្ខ ។
អនត្តាសង្ខារសោះសូន្យផង សូន្យអស់រលីងបាត់គ្រប់មុខ
ទាំងយសទាំងស័ក្តិម្តាយអាពុក ពុំមានសល់ទុកទេលោកអើយ ។
ជីដូនជីតាម្តាយមីងមា ទាំងបុត្រភរិយាគ្មានសល់ឡើយ
ទាំងរូបរាងកាយសូន្យអស់ហើយ លោកអើយស្តាប់ពាក្យនេះឲ្យបាន។
គេយកទៅចោលក្នុងព្រៃជ្រៅ ដែលគ្មានមនុស្សនៅលែងរាប់អាន
ជាទីព្រៃស្ងាត់រហោស្ថាន មានតែតិរច្ឆាននៅកំដរ ។
ទ្រព្យធនដែលមានទាំងប៉ុន្មាន យកទៅមិនបានពេញហៅក្រ
ដេកដោយទីស្ថានឥតមានល្អ រូបកាយនេះក៏សូន្យទទេ ។
វេរាកម្មកាលខ្លួនស្លាប់ទៅ ប្រពន្ធកូនចៅញាតិផៅគេ
ជូនដល់ព្រៃឆ្ងាយវិលវិញទេ តែឯងឥតគេក្នុងស្ថានស្ងាត់ ។
ចោលឆ្អឹងនិងសាច់លើផែនដី គ្រប់រូបប្រុសស្រីឬរូបសត្វ
រលត់សូន្យសោះបោះបង់បាត់ ទាំងនាមក៏ខ្ចាត់ខ្ចាយសូន្យឈឹង ។
គិតទៅគួរឲ្យកើតស្លុតចិត្ត គួរតែរិះគិតរកទីពឹង
គួរខំស្តាប់ធម៌ហើយគិតប្រឹង ឲ្យទានហើយនិងរក្សាសីល ។
ភាវនាកម្មដ្ឋានឲ្យបានខ្ជាប់ ធម៌នេះគួរគាប់កុំបីខ្ជិល
ធ្វើចិត្តឲ្យល្អជ្រះមន្ទិល កុំបីខ្ជិលធ្វើទុច្ចរិត ។
ត្រូវខំសន្សំសុចរិតធម៌ ឲ្យច្រើនកុះករក្នុងកាយចិត្ត
និងពោលវាចាឲ្យសុចរិត តាមពុទ្ធភាសិតប្រាកដហោង ។ល។

ដកស្រង់ចេញពីសៀវភៅ **គិរីមានន្ទសូត្រ**
រៀបរៀងដោយលោកគ្រូ **ឯក ញឹម** អាចារ្យបង្រៀនសាលាបាលី
និង លោកគ្រូអាចារ្យ **ចាប ពិន** ក្រុមពុទ្ធសាសនបណ្ឌិត្យ

# ធម្មសង្វេគ

## ( បទព្រហ្មគីតិ )

ឱះឱគួរសង្វេគ អាសូរពេករូបរាងកាយ
ប្រុសស្រីផងទាំងឡាយ តែងបែកធ្លាយជាធម្មតា ។
ក្មេងចាស់មិនកំណត់ តាមដោយបទបាលីថា
អនិច្ចំនិងទុក្ខា អនត្តាបីនេះមិញ ។
អនិច្ចំថាមិនទៀង កើតហើយល្មៀងស្លាប់ទៅវិញ
ទុក្ខំទុក្ខពោរពេញ ឥតស្រាកស្រាន្តគ្មានទំនេរ ។
អនត្តាមិនមែនខ្លួន មិនខ្ជាប់ខ្ជួនឥតខ្លឹមទេ
សូន្យសោះទាំងយើងគេ ព្រាត់ប្រាស់ចោលទ្រព្យសម្បត្តិ ។
មាតានិងបិតា បុត្រភរិយាសឹងខ្វាយខ្វាត់
នេះឯងហៅវិបត្តិ គ្រប់រូបសត្វក្នុងត្រៃលោក ។
ដូច្នេះគួរនឿយណាយ នឹងរូបកាយគ្រឿងស្មោកគ្រោក
នាំចិត្តឲ្យជាប់ជោក នៅក្នុងលោកកើតសោកា ។
បើទ្រព្យសម្បត្តិមាន ត្រូវធ្វើទានកុំរួញរា
ព្រមទាំងសីលភាវនា ទាន់ខ្លួនជានៅធ្វើបាន ។
កុំធ្វេសកុំព្រងើយ កុំកន្តើយមិនដឹងប្រាណ
ទាល់តែទៀបចែកស្ថាន នោះទើបបាននឹកស្តាយក្រោយ ។
ស្លាប់ទៅតែម្នាក់ឯង កូនចៅតែងរៀបចំឲ្យ
ប្រវែងដីបណ្តោយ តែបួនហត្ថសម្រាប់កប់ ។
ប្រសិនជាដុតវិញ ឆ្អឹងនោះមិញមួយកញ្ចប់
កូនចៅគេខ្ពើមស្អប់ មិនហ៊ានខ្ចប់ទុកលើផ្ទះ ។

ច្នេះគួរកុំប្រមាទ គួរសង្វាតរករៀនលះ
ចិត្តបាបឲ្យស្រឡះ កម្មអាក្រក់ទាំងប៉ុន្មាន ។
បុណ្យបាបរបស់ខ្លួន លាក់បំពួនទុកមិនបាន
ស្លាប់ទៅៗតាមប្រាណ ល្អអាក្រក់ចាត់ដោយឡែក ។
មនុស្សណាមានទានសីល មិនមានខ្ជិលប្រឹងសង្វាត
ឧស្សាហ៍ខំឱហាត[១] តាមដោយខ្ជាតព្រះចមត្រៃ ។
មនុស្សនោះដោះខ្លួនបាន រួចចាកស្ថានទុក្ខចង្រៃ
បានសួគ៌ប្រសើរថ្លៃ ហើយនឹងបានព្រះនិព្វាន ។
ជាស្ថានបំផុតលោក ទុក្ខភ័យរោគទាំងប៉ុន្មាន
ឥតមកប៉ះពាល់បាន សុខក្សេមក្សាន្តប្រសើរហោង ៚

ដកស្រង់ចេញពីសៀវភៅ **គិរីមានន្ទសូត្រ**
រៀបរៀងដោយលោកគ្រូ **ឯក ញឹម** អាចារ្យបង្រៀនសាលាបាលី
និង លោកគ្រូអាចារ្យ **ចាប ពិន** ក្រុមពុទ្ធសាសនបណ្ឌិត្យ
នៅ ព.ស. ២៤៧៧ គ.ស. ១៩៣៣

---

(១) ឱហាត ( កិ. ) សង្វាតជានិច្ច, សម្ដី : ឱហាតរៀន, ឱហាតធ្វើការ ។

# បារាជសូត្រ

រៀបរៀងដោយ

ព្រះសាសនមុនី កឹម ឆូរ ចន្ទមង្គលោ

ក្រោមការពិនិត្យកែសម្រួល

នៃ

សម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ

## ជ. ណ. ជោតញ្ញាណោ

## ប.អ.ស - អ.ម.រ [១]

(១) អានថា បណ្ឌិតអក្សរសាស្ត្រ - អភិធជមហារដ្ឋគុរុ (អៈភិធៈជៈ មៈហារ័ត-ឋៈគុរុ) ។

**ឯវមេ្ម សុតំ** សូត្រនេះឈ្មោះ «**បរាភវសូត្រ**» គឺខ្ញុំឈ្មោះ **អានន្ទ** បានស្តាប់មកហើយយ៉ាងនេះថា ៖

**ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ **អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ** លំដាប់នោះឯង ទេវតាមួយអង្គ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏រុងរឿង បានញុំាងវត្តជេតពនជុំវិញទាំងអស់ឲ្យភ្លឺស្វាង ហើយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះព្រះមានព្រះភាគ ហើយឈរនៅក្នុងទីដ៏សមគួរ, **ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ** កាលទេវតានោះឈរនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគដោយពាក្យជាគាថាយ៉ាងនេះថា ៖

( ទេវតាទូលសួរព្រះសាស្តាថា )

# បរាភវសូត្រ

## ( បទ បថ្យាវត្ត )

**បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ**
**ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយមកសូមទូលសួរ
នូវហេតុដែលគួរចំរើនវិនាស
ប្រុសស្រីក្នុងលោកសន្និវាស
ដែលនឹងវិនាសសាបសូន្យចាកគុណ ។
ឆ្ពោះព្រះគោតមព្រះអង្គមានបុណ្យ
មេត្តានិមន្តសម្តែងឲ្យទាន
ធម្មជាតិដូចម្តេចដែលជាប្រធាន
នាំសត្វឲ្យមានសេចក្តីវិនាស ។

**សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ**
**ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ ។**

អ្នកដែលចំរើនតថាគតស្គាល់ងាយ
អ្នកដែលអន្តរាយតថាគតស្គាល់ពិត
អ្នកប្រាថ្នាធម៌ល្អិតល្អក្នុងចិត្ត
ហើយខំប្រព្រឹត្តនឹងបានចំរើន ។
អ្នកដែលទ្រុស្តធម៌ស្អប់ធម៌ឥតកើន

ផតកើតចំរើនវិនាសទៅមុខ ។

**ឥតិ ហេតំ វិជានាម បឋមោ សោ បរាភវោ**
**ទុតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង
វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឈ្មោះទី ១ ទាន់ហាន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត
សូមទ្រង់និមន្តសម្តែងឲ្យទាន
វិនាសទី ២ អ្វីជាប្រធាន
នាំសត្វឲ្យមានសេចក្តីវិនាស ។

**អសន្តស្ស បិយា ហោន្តិ សន្តេន កុរុតេ បិយំ**
**អសតំ ធម្ម រោចេតិ តំ បរាភវតោ មុខំ ។**

អ្នកដែលស្រឡាញ់ពេញចិត្តស្នេហា
តែនឹងមនុស្សណាអសប្បុរស
តែងមិនស្រឡាញ់ពេញចិត្តទាំងអស់
នឹងអ្នកសប្បុរសមកធ្វើជាមិត្រ ។
សេចក្តីស្រឡាញ់ពេញចិត្តគំនិត
ហើយទៅគប់មិត្រអសប្បុរស
គាប់ចិត្តក្នុងធម៌ឬមួយរបស់

ហេតុនោះទាំងអស់នាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ**
**តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង
វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឈ្មោះទី ២ ទាន់ហាន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត
សូមទ្រង់និមន្តសម្តែងឲ្យទាន
វិនាសទី ៣ អ្វីជាប្រធាន
នាំសត្វឲ្យមានសេចក្តីវិនាស ។

**និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ**
**អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ។**

អ្នកដេកច្រើនមួយនិយាយច្រើនមួយ
នឹងអ្នកឥតព្រួយឥតគិតប្រឹងប្រែង
អ្នកខ្ជិលច្រអូសមិនមានខ្នះខ្នែង
ខឹងច្រើនសំដែងឲ្យគេឃើញបាន ។
ហេតុធម៌ទាំងនោះមិនជាកល្យាណ
នាំឲ្យខកខានខាតខូចប្រយោជន៍
មានជាប្រធានតិចច្រើនដោយហោច

នាំបង់ប្រយោជន៍ហើយឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម តតិយោ សោ បរាភវោ**
**ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្ដែង
វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្ដីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឈ្មោះទី ៣ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត
សូមទ្រង់និមន្តសម្ដែងឲ្យទាន
វិនាសទី ៤ អ្វីជាប្រធាន
នាំសត្វឲ្យមានសេចក្ដីវិនាស ។

**យោ មាតរំ បិតរំ វា ជិណ្ណកំ គតយោព្វនំ**
**បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ ។**

នរជនណាមានទ្រព្យធនធាន
ហើយខ្លួនមិនបានចិញ្ចឹមរក្សា
មាតាបិតាដែលចាស់ជរា
ហេតុនោះទៅជានាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម ចតុត្ថោ សោ បរាភវោ**
**បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង
វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឈ្មោះទី ៤ ទាន់ហាន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត
សូមទ្រង់និមន្តសម្តែងឲ្យទាន
វិនាសទី ៥ អ្វីជាប្រធាន
នាំសត្វឲ្យមានសេចក្តីវិនាស ។

**យោ ព្រាហ្មណំ សមណំ វា អញ្ញំ វាបិ វនិព្វកំ**
**មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។**

ជនបញ្ឆោតព្រាហ្មណ៍ឬពួកសមណៈ
ពួកស្មូមឬអ្នកដទៃ ៗ
ដោយមុសាវាទឃ្លោតពាក្យប្រពៃ
នោះប្រធាននៃសេចក្តីវិនាស ។

**ឥតិ ហេតំ វិជានាម បញ្ចមោ សោ បរាភវោ**
**ឆដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង
វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឈ្មោះទី ៥ ទាន់ហាន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត
សូមទ្រង់និមន្តសម្ដែងឲ្យទាន
វិនាសទី ៦ អ្វីជាប្រធាន
នាំសត្វឲ្យមានសេចក្ដីវិនាស ។

**បហុតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ**
**ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ ។**

បុរសអ្នកមានទ្រព្យធនធានច្រើន
មាសប្រាក់ចំរើននិងគ្រឿងអាហារ
លបលាក់របស់ដែលឆ្ងាញ់ពិសា
ស៊ីម្នាក់ឯងជាប្រធានវិនាស ។

**ឥតិ ហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ**
**សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្ដែង
វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្ដីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឈ្មោះទី ៦ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត
សូមទ្រង់និមន្តសម្ដែងឲ្យទាន
វិនាសទី ៧ អ្វីជាប្រធាន
នាំសត្វឲ្យមានសេចក្ដីវិនាស ។

**ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ**
**សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។**

អ្នកដែលប្រកាន់ជាតិទ្រព្យត្រកូល
ហើយមិនប្រមូលសាច់ញាតិសន្តាន
មើលងាយញាតិខ្លួនដោយអាងខ្លួនមាន
នោះជាប្រធានសេចក្តីវិនាស ។

**ឥតិ ហេតំ វិជានាម សត្តមោ សោ បរាភវោ**
**អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង
វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឈ្មោះទី៧ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត
សូមទ្រង់និមន្តសម្តែងឲ្យទាន
វិនាសទី ៨ អ្វីជាប្រធាន
នាំសត្វឲ្យមានសេចក្តីវិនាស ។

**ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ**
**លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។**

ជនអ្នកប្រព្រឹត្តល្បែង ៣ ប្រការ
ល្បែងស្រីល្បែងស្រាល្បែងភ្នាល់ទាំងឡាយ

ធ្វើទ្រព្យខ្លួនមានឲ្យអន្តរាយ
ការល្បែងទាំងឡាយនោះនាំវិនាស ។

**ឥតិ ហេតំ វិជានាម អដ្ឋមោ សោ បរាភវោ**
**នវមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្ដែង
វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្ដីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឈ្មោះទី ៨ ទាន់ហាន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត
សូមទ្រង់និមន្តសម្ដែងឲ្យទាន
វិនាសទី ៩ អ្វីជាប្រធាន
នាំសត្វឲ្យមានសេចក្ដីវិនាស ។

**សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ**
**ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។**

ប្រុសមិនត្រេកអរនឹងប្រពន្ធខ្លួន
ហើយទៅជាប់ជួននឹងស្រីពេស្យា
ទ្រុស្តនឹងប្រពន្ធកូនជននានា
ហេតុនោះទៅជានាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម នវមោ សោ បរាភវោ**
**ទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង
វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឈ្មោះទី ៩ ទាន់ហាន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត
សូមទ្រង់និមន្តសម្តែងឲ្យទាន
វិនាសទី ១០ អ្វីជាប្រធាន
នាំសត្វឲ្យមានសេចក្តីវិនាស ។

**អតីតយោព្វនោ បោសោ អានេតិ តិម្ពរុត្ថនឹ**
**តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។**

បុរសមានវ័យដែលចាស់ហួសពេក
ហើយមានតម្រេកដោយក្តីតណ្ហា
នាំយកស្រីក្មេងមកធ្វើភរិយា
ហេតុនោះទៅជានាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម ទសមោ សោ បរាភវោ**
**ឯកាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង
វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ

វិនាសនោះឈ្មោះទី ១០ ទាន់ហាន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត
សូមទ្រង់និមន្តសម្តែងឲ្យទាន
វិនាសទី ១១ អ្វីជាប្រធាន
នាំសត្វឲ្យមានសេចក្តីវិនាស ។

**ឥត្ថី សោណ្ឌឹ វិកិរណឹ បុរិសំ វាបិ តាទិសំ**
**ឥស្សរិយស្មឹ ឋបេតិ តំ បរាភវតោ មុខំ ។**

បុរសតាំងស្រីអ្នកលេងខ្ជះខ្ជាយ
ឬស្រីទាំងឡាយតាំងបុរសនោះ
ដែលជាអ្នកលេងខ្ជះខ្ជាយដូច្នោះ
អំពើទាំងនោះនាំឲ្យវិនាស ។

**ឥតិ ហេតំ វិជានាម ឯកាទសមោ សោ បរាភវោ**
**ទ្វាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង
វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឈ្មោះទី ១១ ទាន់ហាន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត
សូមទ្រង់និមន្តសម្តែងឲ្យទាន

វិនាសទី ១២ អ្វីជាប្រធាន
នាំសត្វឲ្យមានសេចក្តីវិនាស ។

**អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ**
**សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ ។**

ជនណាកើតក្នុងត្រកូលជាក្សត្រ
អ្នកខ្សត់សម្បត្តិហើយប្រាថ្នាធំ
ចង់បានជាស្តេចសោយរាជ្យស្តុកស្តម្ភ
ហេតុនោះនឹងនាំឲ្យដល់វិនាស ។

**ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ**
**អរិយោទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ ។**

ជនជាបណ្ឌិតគំនិតប្រសើរ
បានឃើញដំណើរនៃហេតុវិនាស
ដល់សត្វក្នុងលោកសន្និវាស
គេចពីវិនាសគប់រកចម្រើន ។ល។

( **បរាភវសុត្តំ និដ្ឋិតំ** )

# សមាសភាពចូលរួម

១. ព្រះភិក្ខុ ធឹង ធីម (ចន្ទត្ថេរ)

២. ព្រះភិក្ខុ សុំ ប៊ុនធៀម (សុវណ្ណត្ថេរោ)

៣. ឧបាសក ម៉ិញ សាវ៉ាន

៤. ឧបាសក ហ៊ិម ឆាន់

៥. លោក វ៉ាត សុគន្ធ

៥. លោក វ៉ាត តារា (ធីធី)

៦. លោក វ៉ាត ម៉ូលីវណ្ណា

៧. កញ្ញា វ៉ាត វារីយ៉ា



# នាមពុទ្ធបរិស័ទ

## មានសទ្ធាជ្រះថ្លាបានបរិច្ចាគបច្ច័យ ដើម្បីបោះពុម្ព

## សៀវភៅ «ប្រស្នាគិហិពិស្តារ» ជាធម្មទាន ៖

. បច្ច័យនៅសល់ពីសៀវភៅ មង្គលសូត្រនិងនមស្ការ ............................... **៩១០ ដុល្លារ**

. ព្រះភិក្ខុ **វិនយធរោ ( មហា យិន ឡឿន )** ប្រធានពុទ្ធិកសមាគមខ្មែរ ទីក្រុង សាន់តាអាណា សហរដ្ឋអាមេរិក ............................... ១០០ ដុល្លារ

. ព្រះភិក្ខុ **ធឹម ធីម ( ចន្ទត្ថេរ )** ចៅអធិការវត្ត **ធម្មិការាម** ..... ១០០ ដុល្លារ

. ព្រះភិក្ខុ **ហ៊ិន ឃួយ** វត្ត **ធម្មិការាម** ................................. ១០០ ដុល្លារ

. ព្រះភិក្ខុ **សុំ ម៉ុនធៀម ( សុវណ្ណត្ថេរោ )** វត្ត **ពុទ្ធសុទ្ធារាម** ... ៥០ ដុល្លារ

. ព្រះភិក្ខុ **ប៉ាវ សែន** វត្ត **ខេមរារាម** ....................................... ៤០ ដុល្លារ

. ព្រះភិក្ខុ **គុម៉ា គុម៉ាលី** ........................................................... ១០ ដុល្លារ

. មហាឧបាសក **យិត ឆេង** និងមហាឧបាសិកា **ប្រាក់ ចាន់ថន** ......... ៥០ ដុល្លារ

. ឧបាសក **ឱក គិមអាន** និងគ្រួសារ ....................................... ២០ ដុល្លារ

. ឧបាសក **ប៉ែន សារឿន** និងឧបាសិកា **ឈួម ឡាំ** ...................... ៤០ ដុល្លារ

. ឧបាសក **លិម ហ៊ុយគាង** និងឧបាសិកា **លិម ឡៀង**(ONT) ..... ១៣០ ដុល្លារ

. ឧបាសិកា **អ៊ិម ឃួច** .......................................................... ១០០ ដុល្លារ

. លោក **នូ ស៊ីយឿន** និងអ្នកស្រី **លី សុភី** ...................... ១០០ ដុល្លារ

. អ្នកស្រី **តាន់ ចាន់ថា** ........................................................ ៦៥ ដុល្លារ

. ឧបាសក **ម៉ិញ សាវ៉ាន** និងឧបាសិកា **សិម ចាន់ធូរ៉ា** ............ ៦០ ដុល្លារ

. អ្នកស្រី **សិម ចាន់ទេវី** ..................................................... ៦០ ដុល្លារ

. អ្នកស្រី **សិម ចាន់នី** .......................................................... ៥០ ដុល្លារ

. លោក **ផាន ប៊ិត** និងអ្នកស្រី **លឹម ហួច** ............................ ៥០ ដុល្លារ

. លោក **គិម សាក់ភ្វាន** និងអ្នកស្រី **ត្រាំ ធីខេម** និងបុត្រ .......... ៥០ ដុល្លារ

. ឧបាសក **ខាយ ម៉ុនគីម** និងឧបាសិកា **ស សុខឆេង** ............. ៥០ ដុល្លារ

. លោក **ប្រាង សន** និងអ្នកស្រី **ទួន សុធីណា** ...................... ៥០ ដុល្លារ

. ឧបាសិកា **ឡុត យឿម** .......................................................... ៥០ ដុល្លារ

. លោក **ឱប ច័ន្ថា** និងអ្នកស្រី **លៀម សុភាព** ...................... ៥០ ដុល្លារ
. ឧបាសិកា **តាន់ គឹមហ៊ាវ** ................................................ ៤០ ដុល្លារ
. ឧបាសិកា **លី ហៃស៊ីម** .................................................. ៤០ ដុល្លារ
. លោក **នុន ស្បៃ** និងអ្នកស្រី **នុន ណាន់ថា** ...................... ៤០ ដុល្លារ
. ឧបាសក **អ៊ឹម កុសល** និងឧបាសិកា **តែ ធឹងលាត** ................ ៣៥ ដុល្លារ
. ឧបាសិកា **ទី ភាយ៉ាន** .................................................. ៣០ ដុល្លារ
. លោក **យ៉ង់ ម៉ិច** និងអ្នកស្រី **ហែម សាឡន** ...................... ៣០ ដុល្លារ
. ឧបាសក **ទេង ឈាំ** និងឧបាសិកា **សក់ សាននី** ..................... ៣០ ដុល្លារ
. ឧបាសក **ហ៊ិម ឆាន់** និងឧបាសិកា **សាមិត សុភ័ណ** ................ ៣០ ដុល្លារ
. អ្នកស្រី **ហ៊ុន ម៉ារ៉ានី** .................................................. ៣០ ដុល្លារ
. លោក **ថ៉ាត តិរត្ន** និងអ្នកស្រី **មៀច វណ្ណា** ...................... ៣០ ដុល្លារ
. លោក **យន់ សាវុធ** និងអ្នកស្រី **ណាម នី** ........................ ៣០ ដុល្លារ
. ឧបាសិកា **សេង ស៊ីត** ..................................................... ៣០ ដុល្លារ
. ឧបាសិកា **ហង្ស វណ្ណារី** ................................................ ៣០ ដុល្លារ
. អ្នកស្រី **អ៊ុន ភាន់យ៉ា** ................................................ ២០ ដុល្លារ
. ឧបាសិកា **ម៉ៅ ទេង** ..................................................... ២០ ដុល្លារ
. ឧបាសិកា **ប៊ុង ផល្លា** (**ហៅគីម**) ..................................... ២០ ដុល្លារ
. ឧបាសក **ឈឿក ឈុំ** ..................................................... ២០ ដុល្លារ
. ឧបាសក **ហ៊ុន ហេង** និងឧបាសិកា **ឆាង រ៉ែម** ..................... ២០ ដុល្លារ
. ឧបាសក **រស់ សុផុន** និងឧបាសិកា **ហ៊ុន ហឿប** .................. ២០ ដុល្លារ
. ឧបាសក **ហេង លីស៊ីវ** និងឧបាសិកា **ជួន ថុល** ..................... ២០ ដុល្លារ
. ឧបាសក **ឡាវ លាងថេង** និងឧបាសិកា **ពឹង ឈីវអ៊ាន** ......... ២០ ដុល្លារ
. ឧបាសិកា **សោ ហ៊ី** និងឧបាសិកា **ប៊ិត ម៉ាន់** ............................ ២០ ដុល្លារ
. ឧបាសក **តាន់ គិមយ៉ុក** និងឧបាសិកា **សោ ហ៊ុន** ................... ២០ ដុល្លារ
. ឧបាសក **សោ ជា** ......................................................... ២០ ដុល្លារ
. ឧបាសិកា **ពុំ យឿប** ..................................................... ២០ ដុល្លារ
. លោក **តាន់ វុឌ្ឍី** និងអ្នកស្រី **សេក ណាវី** ........................ ២០ ដុល្លារ
. លោក **ម៉ម ជីវ័ត្ថ** និងអ្នកស្រី **រស់ វុទ្ធី** ............................ ២០ ដុល្លារ
. ឧបាសិកា **តែ ធឹងអ៊ី** ..................................................... ២០ ដុល្លារ

. លោកយាយ **នូ លឹម** ........ ២០ ដុល្លារ

. ឧបាសិកា **នី ហៀងឡាញ់** ........ ២០ ដុល្លារ

. អ្នកស្រី **ស៊ុន គិមហៀង** ........ ២០ ដុល្លារ

. អ្នកស្រី **ផូ សុធី** ........ ២០ ដុល្លារ

. ឧបាសក **អ៊ួង ហ៊ាង** និងឧបាសិកា **ម៉ែន ឃិម** ........ ២០ ដុល្លារ

. ឧបាសក **ស សុន** និងឧបាសិកា **ឱ វ៉ាន** ........ ២០ ដុល្លារ

. ឧបាសក **ហែម សំអៀច** ........ ២០ ដុល្លារ

. លោក **គី គីឡាំ** និងអ្នកស្រី **តាន់ វ៉ាន់នី** ........ ២០ ដុល្លារ

. លោក **តាន់ បូណាំ** ........ ២០ ដុល្លារ

. ឧបាសក **ផូ យ៉ុត** និងគ្រួសារ ........ ២០ ដុល្លារ

. អ្នកស្រី **ណាវ វ៉ាន់នី** ........ ២០ ដុល្លារ

. ឧបាសិកា **ដាង គេម** និងគ្រួសារ (St. Pete, Florida) ........ ២០ ដុល្លារ

. ឧបាសិកា **ជា នាង** ........ ២០ ដុល្លារ

. ឧបាសិកា **លឹម ឆេង** ........ ២០ ដុល្លារ

. លោក **ពេជ្រ សារឿម** និងអ្នកស្រី **សិម ចាន់ដារ៉ា** ........ ២០ ដុល្លារ

. លោក **លាវ សោភឿន** និងអ្នកស្រី **ត្អួង រតនា** ........ ២០ ដុល្លារ

. លោក **ម៉ី រុណា** និងអ្នកស្រី **ឈឿប ឡាពីន** ........ ២០ ដុល្លារ

. លោក **អ៊ឹង ហុកខេង** និងអ្នកស្រី **តែ អូន** ........ ២០ ដុល្លារ

. ឧបាសក **អ៊ិប គិមអ៊ុន** ........ ២០ ដុល្លារ

. ឧបាសិកា **នាង ខេង** ព្រមទាំងបុត្រ ........ ២០ ដុល្លារ

. កុមារី **ថេប មីយ៉ា** ........ ១៥ ដុល្លារ

. ឧបាសិកា **ឈិត ឈាង** និងគ្រួសារ ........ ១០ ដុល្លារ

. លោក **ស្រី ស្ដេហ្វាន់** ........ ១០ ដុល្លារ

. លោក **ខូវ ថែង** និងភរិយា ........ ១០ ដុល្លារ

. លោក **យ៉ុន យី** និងភរិយា ........ ១០ ដុល្លារ

. ឧបាសិកា **ជា ស្រីយុទ្ធថូ** ........ ១០ ដុល្លារ

. ឧបាសក **អ៊ឹម សាម៉ៃ** និងឧបាសិកា **ភូវ នឿន** ........ ១០ ដុល្លារ

. ឧបាសិកា **ឱក ស៊ីម** ........ ១០ ដុល្លារ

. ឧបាសក **សំ ខន** និងឧបាសិកា **សុខ សុខុម** ........................ ១០ ដុល្លារ
. ឧបាសក **ឈុន លី** និងឧបាសិកា **ជួន ថុល** .............................. ១០ ដុល្លារ
. ឧបាសក **ជឿន** និងឧបាសិកា **គិម ជូ** ...................................... ១០ ដុល្លារ
. អ្នកស្រី **គិម ណាង** ............................................................. ១០ ដុល្លារ
. ឧបាសិកា **តែ គុយឡាង** .................................................... ១០ ដុល្លារ
. ឧបាសិកា **គីម មួយហៀង** .................................................. ១០ ដុល្លារ
. លោក **អៀម ឆៃឡៃរិទ្ធ** និងអ្នកស្រី ...................................... ១០ ដុល្លារ
. លោក **ឱក សូវៀត** និងអ្នកស្រី **ទេព វណ្ណា** ...................... ១០ ដុល្លារ
. លោក **អ៊ុង អេង** និងអ្នកស្រី **សក់ ស៊ីណុច** ........................ ១០ ដុល្លារ
. លោក **វេង ណារ៉ា** និងអ្នកស្រី **សក់ សាលី** ....................... ១០ ដុល្លារ
. ឧបាសិកា **ប្លែក អ៊ាម** ........................................................... ១០ ដុល្លារ
. ឧបាសក **ខាំផាន់ ម៉ាលីថៃ** និងឧបាសិកា **ម៉ា ថងអន** ........... ៥ ដុល្លារ
. លោក **អុង ងួនវិសាល** ....................................................... ៥ ដុល្លារ
. លោក **អុង ងួនវិចត័រ** ....................................................... ៥ ដុល្លារ
. កុមារី **ស៊ាប លីសា** .............................................................. ៥ ដុល្លារ
. កុមារី **ស៊ាប ភានិកា** ........................................................... ៥ ដុល្លារ

*សូមពុទ្ធបរិស័ទដែលបានចូលរួមបោះពុម្ពសៀវភៅ

ជាធម្មទាន បានសម្រេចនូវសម្មាទិដ្ឋិគ្រប់ៗជាតិ

និងបានឧបនិស្ស័យរួចផុតចាកទុក្ខទាំងពួង

កុំបីឃ្លៀងឃ្លាតឡើយ !

**សូមអនុមោទនាធម្មទាន** !!!



# សៀវភៅ និង ថាស ដែលផ្សព្វផ្សាយដោយគេហដ្ឋាន

## អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ

ក្រុងម៉ុងរេអាល - កេបិក - កាណាដា

❖ សៀវភៅ ៖

១. ស្នាព្រះហស្តក្រោយបង្អស់នៃសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត**
២. ធម៌នមស្ការព្រះរតនត្រ័យ ពិស្តារ - សង្ខេប
៣. ប្រស្នា គិហិប្រតិបត្តិពិស្តារ ( ឈឹម ទូច, សុង ស៊ីវ )
៤. ប្រជុំនានាធម៌សង្វេគ ( ជ័យ ម៉ៃ )
៥. អានាបាណស្សតិកម្មដ្ឋាន វិបស្សនាបញ្ញាធម្មបរិយាយ ( គង់ ឌឹប )
៦. ធម្មនិយាម ៣០ និងកំណាព្យផ្សេង ៗ ( ប៊ុត សាវង្ស, ភិក្ខុ សាន សុជា )
៧. ជីវិតកថា ( ម៉ិញ សារ៉ាន ) ថ្មី
៨. ធម្មប្រទីប ( ប្រជុំកងធម៌ យិន វន់ )
៩. រឿង ព្រះភិក្ខុពនេចរ ( ឱម ណាគ្រី )
១០. រឿង នគរកាយ ( ចាប ពិន )
១១. ច្បាប់គោរពមាតាបិតា ( អ៊ូ ចុង )
១២. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម អ៊ុម ស៊ុម )
១៣. ត្រៃកូដធម៌ ( សុង ស៊ីវ )
១៤. ឱវាទបាតិមោក្ខ ( ចាប ពិន )
១៥. កម្រងកំណាព្យ ( ហ៊ិម ឆាន់ ) ថ្មី
១៦. ឧបនីយតិសូត្រ ( ព្រះមហាវីរិយបណ្ឌិតោ ប៉ាង ខាត់ )
១៧. ធម្មទេស ៤ យ៉ាង ( ម៉ិញ សារ៉ាន ) ថ្មី
១៨. ធម៌នមស្ការសង្ខេបសម្រាប់យុវវ័យ Khmère-Français ( វ៉ាត ភិរក្ស ) ថ្មី
១៩. ធម៌នមស្ការសង្ខេបសម្រាប់យុវវ័យ Khmère-Anglais ( វ៉ាត ភិរក្ស ) ថ្មី
២០. លោកនីតិបករណ៍ ( អ៊ុក ជា )
២១. មង្គលសូត្រ ៣៨ ប្រការ ( ព្រះវិន័យធរអនុគណ ឯក ញឹម ធម្មិស្សរោ )

❖ **ផ្សាយ** CD, MP3 ៖

១. ព្រះត្រៃបិដក ភាគទី ១ ដល់ភាគទី ១១០ ( PDF )
២. ព្រះវិន័យបិដក ភាគទី ១ ដល់ភាគទី ១៣ ( MP3 )
៣. ព្រះសុត្តន្តបិដក ភាគទី ១៤ ដល់ភាគទី ៣៧ ( MP3 )
៤. ព្រះសុត្តន្តបិដក ភាគទី ៣៨ ដល់ភាគទី ៦២ ( MP3 )
៥. ព្រះគុណម៉ែ ( MP3 )
៦. ព្រះភិក្ខុពនេចរ ( MP3 )
៧. វិធីសាស្រ្តចំរើនអានាបាណស្សតិកម្មដ្ឋាន ( MP3 )
៨. ព្រះពុទ្ធដីកា ( MP3 )
៩. ព្រះសុត្តន្តបិដក ភាគទី ៦៣ ដល់ភាគទី ៧៧ ( MP3 )
១០. អាមិសទាន និង ធម្មទាន ( MP3 )
១១. ៤៨ ធម្មទស្សន៍ ព្រះពុទ្ធសាសនា (ខ្លឹមសារគួរយល់ដឹង) ( MP3 )
១២. ព្រះអភិធម្ម ភាគទី ៧៨ ដល់ភាគទី ១១០ ( MP3 )
១៣. ប្រវត្តិមហាឧបាសិកា **វិសាខា** ( DVD )
១៤. ព្រះវេស្សន្តជាតក ( DVD )
១៥. ទុក្ខសច្ចៈ( DVD ) ៖ ភិក្ខុ **នៅ សាខន**
១៦. សមថវិបស្សនា (MP3) វគ្គទី ១ និងវគ្គទី ២ : មហាវិមលធម្ម **ពិន សែម**
១៧. ភាពយន្តឯកសារ ( DVD ) Angkor Land Of The Gods

សូមប្រគេន និងជំរាប ដល់ព្រះតេជព្រះគុណព្រមទាំងបងប្អូនពុទ្ធបរិស័ទជាសទ្ធាសម្បន្ន និងសទ្ធាសម្បន្នាទាំងអស់ដែលចង់ស្តាប់ ឬចង់អាននូវព្រះធម៌ណាមួយ ឬក៏មានសទ្ធាជ្រះថ្លាចូលរួមក្នុងការបោះពុម្ពសៀវភៅ និងធ្វើ CD MP3 សម្រាប់ចែកជាធម្មទាន សូមនិមន្ត និងអញ្ជើញទាក់ទងតាមរយៈគេហដ្ឋាន ៖

# អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ

ក្រុងម៉ុងរេអាល - កេបិក - កាណាដា

---

# អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ

ក្រុងម៉ុងរេអាល - កេបិក - កាណាដា


- ឧបាសក **មុិញ សាវ៉ាន** ៥១៤ - ៧៣៥ - ៥៩៧៥
- ឧបាសក **ហុិម ឆាន់** ៥១៤ - ២៧៧ - ៤១២៩

  ( chhann@live.ca )
- **វ៉ាត ភិរក្ស** ៥១៤ - ៥០៩ - ៥០២៥

  ( phireak.vat@gmail.com )


ម្យ៉ាងទៀតសៀវភៅចាស់ៗ ដែលបានចម្លងថ្មី មានចុះផ្សាយនៅ

ក្នុងគេហទំព័រ «៥០០០ ឆ្នាំ» 5000-years.org ផងដែរ ។

សូមអស់លោកពុទ្ធបរិស័ទអញ្ជើញអានដោយមេត្រី...

សូមអរគុណ

គេហដ្ឋាន **អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ**

---

# សូមរង់ចាំអាន, សូមរង់ចាំអាន ...

## ចំណីចក្ខុថ្មី, ចំណីចក្ខុថ្មី...

# កម្រងកំណាព្យ

# ភាគ ២

រៀបរៀងដោយឧបាសក **ហ៊ិម ឆាន់**

នឹងបោះពុម្ពផ្សាយក្នុងឱកាសចូលឆ្នាំសកល ២០១៨

# បំណងដៃឆ្នាំថ្មី

រៀបរៀងដោយឧបាសក **ម៉ិញ សាវ៉ាន**

នឹងបោះពុម្ពផ្សាយក្នុងឱកាសចូលឆ្នាំខ្មែរ «ឆ្នាំមមី»

**សូមអរគុណ**

គឺជាការសួរ និងឆ្លើយអំពីធម៌របស់ឧបាសក ឧបាសិកា ក្នុងព្រះពុទ្ធសាសនា ដូចជា ៖

- គិហិប្រតិបត្តិវចនប្បញ្ហា ;
- ត្រៃបណាមប្បញ្ហា ;
- សរណគមនវចនប្បញ្ហា ;
- ឧបាសកវចនប្បញ្ហា ;
- វិន័យឧបាសកប្បញ្ហា ជាដើម . . .

រៀបរៀងដោយ ៖

❖ លោក បណ្ឌិត **ឈឹម ទូច ( ឥន្ទប្បញ្ញោ )**

❖ លោក សិទ្ធត្ថបណ្ឌិត **សុខ ស៊ីវ**

បោះពុម្ពលើកទី ៩ ដែលជាលើកចុងក្រោយបង្អស់នៅ ព.ស. ២៥១៦ ត្រូវនឹង គ.ស. ១៩៧២ ។

* ចម្លងតាមច្បាប់ដើមដោយខ្ញុំព្រះករុណា ខ្ញុំបាទ **ទ៉ាត តិរៈវង្ស**



**សម្រាប់ចែកជាធម្មទាន**